ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ បង្រៀនសិស្សអំពីរបបកម្ពុជាប្រជាធិបតេយ្យ គឺជាការផ្សះផ្សាជាតិ

◆ ការឆ្លើយតបទៅនឹងអំពើប្រល័យពូជសាសន៍ : តួនាទីរបស់ស្ថាប័នផ្សេងៗ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១១៥ ខែកក្កដា ឆ្នាំ២០០៩

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


# ស្វែងរកការពិត

លេខ១១៥ ខែកក្កដា ឆ្នាំ២០០៩



◆បង្រៀនសិស្សអំពីរបបកម្ពុជាប្រជាធិបតេយ្យគឺជាការផ្សះផ្សាជាតិ ..........១

**ផ្នែកឯកសារ**

◆ការយល់ដឹងរបស់ដៃ ៖ ថ្នាក់ក្រោមមិនបានធ្វើអ្វីតាមអំពើចិត្តទេ ..............៣

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆អៀង សារី ក្នុងប្រទេសកម្ពុជា និងប្រទេសជិតខាង ............................៥

◆អ្នកប្រវត្តិសាស្ត្រក្នុងតំបន់ ..........................................................៨

◆សែត ឌុន ..........................................................................១០

◆ការបញ្ចាំងខ្សែភាពយន្តនៅបូជនីយដ្ឋានអំពែភ្នំ ................................១២

◆សង្ខេបប្រវត្តិសាស្ត្រប្រទេសកម្ពុជា ............................................១៦

**ផ្នែកច្បាប់**

◆យុត្តិធម៌ដែលមិនបង្ហាញឲ្យឃើញ .............................................២២

◆អ្នករស់រានដែលបានចំណាយពេលរាប់ម៉ោង ...................................២៥

◆សេចក្តីលម្អិតអំពីតួនាទីរបស់ ឌុច នៅមន្ទីរស-២១ .......................២៩

◆ការឆ្លើយតបទៅនឹងអំពើប្រល័យពូជសាសន៍ ...................................៣៣

**វេទិកាពិភាក្សាសាធារណៈ**

◆ព្រះពុទ្ធសាសនានៅក្រោមរបប ប៉ុល ពត ....................................៤២

◆ខ្មែរកម្ពុជាក្រោម ..................................................................៤៥

◆ប្រតិកម្មរបស់ជនរងគ្រោះចំពោះការសូមអត់ឱនទោសរបស់ ឌុច ......៥១

**ធំព័រស្រាវជ្រាវរកគ្រួសារ**

◆ពិភពលោកនៅសែនឆ្ងាយ .......................................................៥៤




អ្នកភូមិកំពុងមើលការបញ្ចាំងខ្សែភាពយន្តស្តីពីសវនាការកាត់ទោស ឌុច




## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ ៖*** *ដេង ពង្សរ៉ាស៊ី, សុខ វណ្ណៈ, ឆាល ជេកសាន់, ម៉ែន ពិចិត្រ, លី សុខឃាង ស៊ីរិ សាវីណា និងអាដាម ខូឌី, ដេវីដ ឆេនល័រ, តូនី ហូលីនេស, ឡូរ៉ា ម៉ាកដូណល, ចច ជីហ្គាស, អៀន ហារីស, ជី ទេវិទ្ធិ, ហេង ខុន* ***អ្នកនិពន្ធនិងស្រាវជ្រាវ ៖*** *គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា, ទេស ម៉ារ៉ែម* ***អ្នកបកប្រែៈ*** *ជា ដល្លា, ទែន សុខស្រីនិត* ***និពន្ធនាយកទូទៅៈ*** *ឆាំង យុ* ***ជំនួយការនិពន្ធនាយកៈ*** *ទេព ម៉េងឃាន, ញាណ សុជាតិ* ***ក្រាហ្វិកកុំព្យូទ័រៈ*** *ស៊ឹម សុភ័ក្រ្ត* ***គ្រប់គ្រងការចែកផ្សាយៈ*** *ម៉ម សុផាត*



Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ៖*

# បង្រៀនសិស្សអំពីរបបកម្ពុជាប្រជាធិបតេយ្យ គឺជាការផ្សះផ្សាជាតិ

ពិធីសម្ពោធលើកដំបូងអំពីវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ ដើម្បីបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យបានត្រូវប្រារព្ធធ្វើឡើងនៅក្នុងទីស្តីការក្រសួងកាលពីវេលាម៉ោងបីរសៀលថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩ ក្រោមអធិបតីដ៏ខ្ពស់ខ្ពស់របស់ឯកឧត្តម អ៊ឹម សិទ្ធី ជារដ្ឋមន្ត្រី និងលោក ជំទាវ ទន់ សាអ៊ឹម ជាអនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ។ ក្នុងឱកាសដ៏មានសារសំខាន់នេះ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានដឹកនាំក្រុមអ្នកជំនាញផ្នែកប្រវត្តិសាស្ត្រ មកពីប្រទេសកម្ពុជានិងអន្តរជាតិ ព្រមទាំងបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលធ្វើការនៅក្នុងគម្រោងស្តីពី «ការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» រួមជាមួយសិក្ខាកាមដែលជាគ្រូបង្គោលថ្នាក់ជាតិចំនួន២៤រូប មកពីនាយកដ្ឋានចំនួន៤ចំណុះឲ្យក្រសួងអប់រំ យុវជន និងកីឡា ចូលជួបសំណេះសំណាលដើម្បីសម្តែងការគួរសម និងសុំអនុសាសន៍ណែនាំពីឯកឧត្តមរដ្ឋមន្ត្រី ក្នុងន័យធ្វើឲ្យកម្មវិធីបើកសម្ពោធវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិប្រព្រឹត្តទៅប្រកបដោយលទ្ធផលល្អ ។

ជាកិច្ចចាប់ផ្តើម សិក្ខាកាម ព្រមទាំងអ្នកជំនាញជាតិ និងអន្តរជាតិទាំងអស់ បានណែនាំខ្លួនជម្រាបដល់អង្គប្រជុំទាំងមូលដើម្បីជាកិច្ចស្វាគមន៍ដល់វត្តមានដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម អ៊ឹម សិទ្ធី និងដើម្បីជាការស្គាល់គ្នាជាលើកដំបូងមុនពេលអង្គសិក្ខាសាលាពេញ



ឯកឧត្តម អ៊ឹម សិទ្ធី ជួបសំណេះសំណាលជាមួយគ្រូបង្គោលថ្នាក់ជាតិ អ្នកជំនាញ និងបុគ្គលិកមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា

អង្គចាប់ផ្តើមនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០០៩ ។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានជម្រាបជូនអង្គប្រជុំពីគោលគំនិតដំបូងនៃការបង្កើតគម្រោងនេះឡើងដោយសង្កត់ធ្ងន់ថា ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យគួរតែត្រូវចងចាំនិងស្វែងយល់ឲ្យកាន់តែច្បាស់សម្រាប់កូនខ្មែរជំនាន់ក្រោយតាមរយៈការដាក់បញ្ចូលកម្មវិធីសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅក្នុងកម្មវិធីសិក្សាដែលមានស្រាប់របស់ក្រសួង ។ លោកនាយកបានមានប្រសាសន៍បន្តថា ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅតាមសាលាមធ្យមសិក្សាគឺជាការផ្សះផ្សាររវាងជនរងគ្រោះនិងជនដៃដល់ថ្នាក់ក្រោមនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយកិច្ចការនេះបានដើរតួនាទីយ៉ាងសំខាន់ជា «គណៈកម្មការស្វែងរកការពិត» នៅកម្ពុជា ។ លើសពីនេះទៀត លោកនាយកក៏បានបង្ហាញផែនការ និងដំណើរការរបស់គម្រោងក្នុងពេលបច្ចុប្បន្ន និងទៅអនាគតដ៏វែងឆ្ងាយថាគ្រូបង្គោលថ្នាក់ជាតិ គ្រូបង្គោលថ្នាក់ខេត្តចំនួន១៨៥រូប ព្រមទាំងលោកគ្រូអ្នកគ្រូបង្រៀនផ្នែកប្រវត្តិវិទ្យា សីលធម៌ពលរដ្ឋ និងអក្សរសាស្ត្រខ្មែរនៅទូទាំងប្រទេសចំនួន៣០០០រូប នឹងទទួលបានការបណ្តុះបណ្តាលវគ្គសិក្សាមួយដូចគ្នាស្តីអំពី «ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» តាមដំណាក់កាលដែលបានកំណត់ដូចតទៅ ÷ ១) វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅថ្នាក់មធ្យមសិក្សានឹងប្រព្រឹត្តទៅនៅថ្ងៃទី២៩ ខែមិថុនា ដល់ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៩ ។ ២) វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ខេត្តនឹងប្រព្រឹត្តទៅនៅចុងខែវិច្ឆិកា និង ៣) វគ្គបណ្តុះបណ្តាលគ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យា សីលធម៌ពលរដ្ឋនិងអក្សរសាស្ត្រនឹងប្រព្រឹត្តទៅនៅខែធ្នូ ឆ្នាំ២០០៩ខាងមុខ ។ ការបង្កើតវគ្គបណ្តុះបណ្តាលនេះឡើងគឺក្នុងគោលបំណងជួយឲ្យលោកគ្រូអ្នកគ្រូនៅទូទាំងប្រទេសទទួលបាននូវចំណេះដឹង និងគរុកោសល្យក្នុងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដល់សិស្សានុសិស្សដែលមិនធ្លាប់ឆ្លងកាត់របបខ្មែរក្រហមឲ្យដឹង និងស្គាល់ពីរឿងហេតុទាំងឡាយដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ក្នុងពេលជាមួយគ្នានេះដែរ អ្នកជំនាញជាតិនិងអន្តរជាតិដែលមានវត្តមាននៅក្នុងអង្គប្រជុំត្រូវបានណែនាំឲ្យដឹងថាជាអ្នកដែលបានខិតខំជួយជ្រោមជ្រែងអស់ពីកម្លាំងកាយចិត្ត ដើម្បីធ្វើយ៉ាងណាឲ្យវគ្គបណ្តុះបណ្តាលនេះក្លាយជាវគ្គបណ្តុះបណ្តាលដែលប្រកបដោយគុណភាពនិងទទួលស្គាល់ជាលក្ខណៈជាតិនិងអន្តរជាតិ ។ លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានសង្កត់ធ្ងន់ផងដែរថា គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ជាគម្រោងមួយដែលមានរយៈពេលវែងក្នុងការត្រួសត្រាយផ្លូវដល់លោកគ្រូអ្នកគ្រូនៅទូទាំងប្រទេសឲ្យស្វែងយល់កាន់តែច្បាស់ពីរបៀបនិងគរុកោសល្យក្នុងការបង្រៀនប្រវត្តិសាស្ត្រខ្លួនឯងដល់កូនខ្មែរជំនាន់ក្រោយដែលពុំធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម ។ នៅចុងបញ្ចប់ លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការសហការរបស់ក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសឯកឧត្តម អ៊ឹម សិទ្ធី ផ្ទាល់ ដែលតែងតែចំណាយពេលវេលាដ៏មានតម្លៃធ្វើការសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាតាំងពីគម្រោងនេះទើបតែត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៤ ។

ស្ថិតក្នុងឱកាសដ៏មានសារសំខាន់នេះ ឯកឧត្តម អ៊ឹម សិទ្ធី បានមានអនុសាសន៍ផ្តាំផ្ញើដល់សិក្ខាកាមទាំងអស់ដែលជាសមាជិករបស់គណៈកម្មការរៀបចំកែលម្អឯកសារ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលបង្កើតឡើងដោយក្រសួងអប់រំ យុវជននិងកីឡា និងជាគ្រូបង្គោលថ្នាក់ជាតិ ឲ្យខិតខំយកចិត្តទុកដាក់ក្នុងការក្រេបជញ្ជក់ចំណេះដឹងដែលបានមកពីការបង្រៀនរបស់អ្នកជំនាញជាតិ និងអន្តរជាតិស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា និងពិភពលោក ។ ក្នុងពេលជាមួយគ្នានេះដែរ ឯកឧត្តមរដ្ឋមន្ត្រីបានសំណេះសំណាលជាមួយសិក្ខាកាមទាំងអស់ ដោយបានលើកឡើងពីជីវប្រវត្តិឈឺចាប់ដែលឯកឧត្តមបានឆ្លងកាត់ផ្ទាល់ក្នុងរបបខ្មែរក្រហម ព្រមទាំងបានលើកឡើងពីទុក្ខលំបាកនានាដែលឯកឧត្តមមិនអាចបំភ្លេចបាន ។

នៅចុងបញ្ចប់នៃកិច្ចប្រជុំ ឯកឧត្តមបានសង្កត់ធ្ងន់ពីការសិក្សាផ្នែកប្រវត្តិសាស្ត្រដោយចាប់ផ្តើមពីការបង្វែរការឈឺចាប់ឲ្យទៅជាការចងចាំ ហើយការចងចាំទាំងនេះគឺជាប្រវត្តិសាស្ត្រដែលមនុស្សជំនាន់ក្រោយគួរតែស្វែងយល់និងសិក្សា ។

**ផេង ពង្សរ៉ាស៊ី**

# ការយល់ឃើញរបស់តា ផៃ : ថ្នាក់ក្រោមមិនបានធ្វើអ្វីតាមអំពើចិត្តទេ

រយៈពេលជាងបីឆ្នាំដែលប្រទេសកម្ពុជាបានឆ្លងកាត់របបវាលពិឃាដខ្មែរក្រហម ប្រជាជនខ្លះមិនចង់រំឭករឿងរ៉ាវដែលបានកើតឡើងនៅជំនាន់នោះទេព្រោះធ្វើឲ្យខ្លួនរបស់គាត់កាន់តែមានភាពឈឺចាប់ខ្លាំងឡើងថែមទៀត ចំណែកខ្លះទៀតចង់និយាយរឿងរ៉ាវផ្ទាល់ខ្លួនប្រាប់ដល់ក្មេងជំនាន់ក្រោយឲ្យបានដឹងផងដែរ ដូចជាលោកតា ផៃ អាយុ៧៧ឆ្នាំ រស់នៅស្រុកជុំគិរី ខេត្តកំពតជាដើម ។ លោកតាជាកម្មាភិបាលខ្មែរក្រហមសកម្មមួយរូបដែលមានចណេះដឹងខ្ពង់ខ្ពស់និងធ្លាប់បួសជាព្រះសង្ឃអស់រយៈពេល១៥វស្សានៅក្នុងវត្តចក ខេត្តកំពត ។

នៅឆ្នាំ១៩៦២ លោកតាបានសឹកមកជួយធ្វើការងារស្រែចម្ការជាមួយឪពុកម្តាយ និងរៀបអាពាហ៍ពិពាហ៍ជាមួយនារីម្នាក់នៅក្នុងភូមិ ។ នៅឆ្នាំ១៩៦៨ ដោយសារតែមានគំនិតចង់ចូលប្រឡូកក្នុងឆាកនយោបាយ លោកតាក៏សុំលាឪពុកម្តាយនិងប្រពន្ធចាកចេញពីផ្ទះទៅតស៊ូក្នុងព្រៃ ។ លោកតាជាសកម្មជនមួយរូបក្នុងចលនាតស៊ូជាមួយក្រុម តាម៉ុក ដែលធ្លាប់ មានទំនាក់ទំនងជាមួយវៀតណាមខាងជើង ហើយធ្លាប់ជួបជាមួយសកម្មជនវៀតណាមឈ្មោះ ទី កាម, បាសឹង និង ថាច់ វ៉ាន់លឿង ទៀតផង ។

ការស្ម័គ្រចិត្តចូលព្រៃដោយមិនខ្លាចនឿយហត់និងមិនគិតពីអាយុជីវិតគឺក្នុងគោលបំណងធ្វើឲ្យប្រទេសរបស់ខ្លួនមានឯករាជ្យពិតប្រាកដនិងមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់បរទេស ។ នៅឆ្នាំ១៩៧០ មានចលនាខ្មែររំដោះកើតឡើងជាច្រើនកន្លែង បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ ចេញពីអំណាច ។ ដោយសារកំហឹងនិងការមិនពេញចិត្តជាមួយរបបគ្រប់គ្រងថ្មី (របបសាធារណរដ្ឋខ្មែរ) អ្នកភូមិជាច្រើននាក់បាននាំគ្នារត់ចូលក្នុងព្រៃម៉ាគីដើម្បីតស៊ូដណ្តើមយករបបរាជានិយមមកវិញ ។ ប្រជាជននៅតាមតំបន់ខ្លះបានប្រមូលផ្តុំគ្នាធ្វើបាតុកម្មប្រឆាំងនឹងរបបថ្មីនេះ ប៉ុន្តែពួកគេបានត្រឹមតែរងរបួសនិងស្លាប់បាត់បង់ជីវិតប៉ុណ្ណោះ ។ បន្ទាប់ពីការប៉ះទង្គិចដ៏ខ្លាំងក្លានេះរួចមក ប្រជាជនបានទៅចូលរួមសហការជាមួយចលនាបដិវត្តន៍ខ្មែរក្រហមនិងកងទ័ពវៀតណាមខាងជើង ។ នៅឆ្នាំ១៩៧៣ ខ្មែរក្រហមបានប្រមូលកម្លាំងកាន់តែច្រើនដើម្បីធ្វើការប្រយុទ្ធប្រឆាំងជាមួយនឹងកងទ័ពលន់ នល់ ប៉ុន្តែក្រោយមក ដោយសារខ្មែរក្រហមមិនចង់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់វៀតណាម ទើបបង្កឲ្យមានជម្លោះប្រដាប់អាវុធនិងចលនាប្រជាជនដេញកងទ័ពវៀតណាមខាងជើងចេញពីប្រទេសកម្ពុជា ។


លោកតា ផៃ

ដោយមើលឃើញពីគោលជំហរការពារជាតិរបស់ចលនាបដិវត្តន៍ខ្មែរក្រហមដែលផ្ទុយពីភាពឃោរឃៅក្នុងការទម្លាក់គ្រាប់បែករបស់ចក្រពត្តិអាមេរិកដែលគាំទ្ររបប លន់ នល់ មកលើភូមិកររបស់ប្រជាជន និងអំពើពុករលួយដែលប្រព្រឹត្តដោយមន្ត្រីក្នុងរបបសាធាររដ្ឋខ្មែររបស់ លន់ នល់ ទើបធ្វើឲ្យប្រជាជនគ្រប់តំបន់កាន់តែច្រើនបានងាកមកគាំទ្របដិវត្តន៍វិញ ។

នៅអំឡុងពេលគ្រប់គ្រងអំណាចរបស់ខ្មែរក្រហម លោកតាជាលេខាសម្ងាត់របស់ភូមិភាគនិរតីដែលមាន តាម៉ុក ជាប្រធាន ជូ ទ្រី ហៅ ជូ ជេត ជាអនុប្រធាន និង កង ចាប ជាសមាជិក ។ លោកតាបានរៀបរាប់ថា គាត់មានការសោកស្តាយចំពោះមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលប្រើគោលនយោបាយកុម្មុយនីស្តផ្តាច់ការហួសហេតុពេក ដោយបានបិទសិទ្ធិសេរីភាព លុបបំបាត់

សាលារៀន សាសនា ដែលប្រជាជនធ្លាប់តែគោរពតាំងពីយូរណាស់មកហើយ ។

ក្នុងរយៈពេលជាងបីឆ្នាំដែលលោកតាបម្រើការងារជាកម្មាភិបាលថ្នាក់ស្រុក គាត់ត្រូវអង្គការហៅមកប្រជុំរៀនសូត្រអំពីគោលនយោបាយបក្សនៅទីក្រុងភ្នំពេញជាញឹកញាប់ ដោយមានកម្មាភិបាលថ្នាក់ស្រុករហូតដល់ប្រធានភូមិភាគទូទាំងប្រទេសមកចូលរួមប្រមាណជា៧០០នាក់ ។ អង្គការក៏បានចេញគោលការណ៍ឲ្យកម្មាភិបាលថ្នាក់ក្រោមធ្វើការបោសសម្អាតខ្មាំងស៊ីរូងផ្ទៃក្នុងជាពិសេសបញ្ញវន្ត មន្ត្រីរដ្ឋការរបប លន់ នល់ និងពួកសក្តិភូមិ-នាយទុន ដែលគេងប្រវ័ញ្ចមកលើវណ្ណៈកសិករ-កម្មករ ។

ក្រោយពីបញ្ចប់វគ្គរៀនសូត្រ អង្គការបានរៀបចំកម្មវិធីទស្សនកិច្ចដើម្បីលើកទឹកចិត្តឲ្យកម្មាភិបាលមកពីគ្រប់ភូមិភាគធ្វើដំណើរកម្សាន្តនៅទីក្រុងកំពង់សោម និងទៅពិនិត្យមើលកោះមួយចំនួនដូចជា កោះតាង កោះសេះ កោះកាពិ កោះរ៉ុង ដែលមានព្រំប្រទល់ជាប់ប្រទេសវៀតណាមនិងប្រទេសថៃ ។ នៅពេលបំពេញភារកិច្ច លោកតាបានស្គាល់កម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់មួយចំនួនដូចជា ប៉ុល ពត, នួន ជា, អៀង សារី, ខៀវ សំផន និងកម្មាភិបាលថ្នាក់ក្រោមមួយចំនួនធំផ្សេងទៀត ។ ទោះបីអង្គការលើកទឹកចិត្តឲ្យមានដំណើរកម្សាន្តក៏ដោយ ក៏លោកតាតែងតែភ័យខ្លាចនិងព្រួយបារម្ភពីសុវត្ថិភាពរបស់ខ្លួនជានិច្ច ព្រោះជាញឹកញាប់ នៅពេលដែលលោកតាបានទទួលសំបុត្រពីនិរសារ គាត់តែងតែសម្គាល់ឃើញថ្នាក់លើមានការសង្ស័យថា កម្មាភិបាលតំបន់នេះក្បត់និងតំបន់នោះក្បត់ជាដរាប ។ លោកតាបានរំឭកនូវពាក្យមួយឃ្លារបស់អង្គការថា «យើងត្រូវតែបោសសម្អាតខ្មាំងឲ្យអស់» ដែលពាក្យនេះធ្វើឲ្យកម្មាភិបាលថ្នាក់ក្រោមមួយចំនួនបានយកទៅអនុវត្តលើប្រជាជនមិនរើសមុខ និងសូម្បីតែកម្មាភិបាលខ្មែរក្រហមដូចគ្នាក៏ត្រូវយកទៅសម្លាប់ដែរ ។ លើសពីនេះទៅទៀត កម្មាភិ-បាលឈ្មោះ កង ចាប និង ជូ ជេត ដែលជាសកម្មជនបម្រើឲ្យចលនាខ្មែរក្រហមដោយមិនខ្លាចនឿយហត់ និងធ្លាប់ធ្វើការជាមួយលោកតាក៏ត្រូវអង្គការចាប់ខ្លួនបញ្ជូនទៅឃុំឃាំងនៅមន្ទីរស-២១ រួចយកទៅសម្លាប់ចោលដែរ ។ ចំណែករបបអាហាររបស់ប្រជាជនត្រូវបានកាត់បន្ថយ ហើយថែមទាំងបង្ខំឲ្យធ្វើពលកម្មធ្ងន់ធ្ងរបណ្តាលឲ្យប្រជាជនស្លាប់ជាបន្តបន្ទាប់ ។ ដូច្នេះដើម្បីបំពេញនូវសេចក្តីស្រេកឃ្លាន ប្រជាជនមួយចំនួនសុខចិត្តប្រព្រឹត្តខុសពីវិន័យរបស់អង្គការ រហូតបណ្តាលឲ្យមានការសម្លាប់កាន់តែច្រើនឡើងថែមទៀត ។


ការដ្ឋានសាងសង់ទំនប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

សព្វថ្ងៃនេះ លោកតាមិនចង់គិតពីរឿងនយោបាយទេ ព្រោះការតស៊ូជាច្រើនជំនាន់របស់គាត់ពុំបានទទួលផលប្រយោជន៍អ្វីសោះ បានត្រឹមតែធ្វើឲ្យគាត់មានវិប្បដិសារីនិងការបាត់បង់ប៉ុណ្ណោះ ។

**សុខ វណ្ណៈ**

# អៀង សារី ក្នុងប្រទេសកម្ពុជានិងប្រទេសជិតខាង

*«ដកស្រង់ចេញពីអ្នកអានអត្ថបទនៃសេចក្តីថ្លែងសុន្ទរកថាទៅកាន់ឯកអគ្គរាជទូតរដ្ឋសភារបស់អង្គការសហប្រជាជាតិ»*

*ចលនាបដិវត្តន៍តស៊ូដ៏ស្វាហាប់ដើម្បីការរំដោះប្រទេសជាតិនិងការពារឯករាជ្យភាព អធិបតេយ្យភាព បូរណភាពដែនដី និងសិទ្ធិក្នុងការធ្វើជាម្ចាស់ជោគវាសនារបស់ខ្លួនដែលទទួលការគាំទ្រពីប្រជាជនទូទាំងពិភពលោក បានជំរុញឲ្យមានកិច្ចខិតខំប្រឹងប្រែងក្នុងពេលបច្ចុប្បន្នរបស់ប្រជាជនកម្ពុជាដែលបានចូលរួមបំពេញកាតព្វកិច្ចការពារនិងកសាងប្រទេសនៅក្នុងសម័យកាលបដិវត្តន៍ថ្មីរបស់ពួកគេ ។ គោលការណ៍ដ៏ពិសិដ្ឋរបស់ប្រជាជនកម្ពុជាយើងគឺថាពួកគេចង់រស់នៅក្នុងសន្តិភាពជាមួយនឹងសេចក្តីថ្លៃថ្នូរ និងកិត្តិយសក្នុងនាមជាអ្នកគ្រប់គ្រងប្រទេសរបស់ខ្លួនដើម្បីកសាងនូវសង្គមមួយដែលគោរពតាមឧត្តមគតិដ៏ភ្លឺស្វាងរបស់ពួកគេ និងដើម្បីដើរនៅលើមាគ៌ាមួយដែលពួកគេជាអ្នកជ្រើសរើសដោយឈរលើស្មារតីឯករាជ្យភាពនិងអធិបតេយ្យភាព ។*

*យ៉ាងណាមិញ កាលពីប៉ុន្មានសតវត្សរ៍កន្លងទៅប្រជាជនយើងត្រូវបានបង្ខំឲ្យរស់នៅក្នុងនាមជាខ្ញុំបម្រើគេ ។ ប្រទេសរបស់យើងធ្លាប់បានគ្រប់គ្រង កេងប្រវ័ញ្ចយកប្រយោជន៍ និងគាបសង្កត់ដោយពួកប្រតិកិរិយាបរទេសដូចជា ពួកសក្តិភូមិ ពួកអាណានិគម និង ពួកចក្រពត្តិនិយម លើសពីនេះយើងបានបាត់បង់នូវទឹកដីមួយផ្នែកធំទៀតផង ។ ខ្សែបន្ទាត់ព្រំដែនដ៏រួមតូចរបស់យើងនៅពេលនេះ គឺជាលទ្ធផលដ៏គួរឲ្យឈឺចាប់ដែលកើតចេញពីសកម្មភាពដ៏ជោគជ័យនៃការឈ្លានពាន វាតទី និង រំលោភរបស់ពួកបរទេស ។ ចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលដែលប្រទេសកម្ពុជាត្រូវបានរំដោះជាស្ថាពរនិងពេញលេញប្រជាជនយើងបានក្លាយជាម្ចាស់លើជោគវាសនានិងប្រទេសខ្លួនឯងយ៉ាងពិតប្រាកដ ។ យើងទាំងអស់គ្នាមានស្មារតីស្នេហាជាតិដ៏ខ្លាំងក្លានិងត្រឹមត្រូវតាមក្រមច្បាប់ ។ ទោះបីជាប្រវត្តិសាស្ត្ររបស់យើងពោរពេញទៅដោយភាពទុក្ខសោក ប៉ុន្តែយើងមិនដែលដឹកកកាយរឿងចាស់ឡើយ ។ យើងសម្លឹងមើលតែបច្ចុប្បន្ននិងឆ្ពោះទៅកាន់អនាគតតែប៉ុណ្ណោះ ។ យើងមិនយកចិត្តទុកដាក់ស្អប់ខ្ពើមលើនរណាម្នាក់ឡើយ ហើយយើងក៏គ្មានបំណងប្រព្រឹត្តការឈ្លានពានលើប្រទេសណាមួយឬពង្រីកទឹកដីដើម្បីបង្កើតនូវភាពមហន្តរាយលើប្រទេសណាមួយឡើយ ។ យើងមិនចង់បានទឹកដីរបស់ប្រទេសដទៃសូម្បីតែមួយម៉ែត្រការ៉េ ។ ប្រទេសរបស់យើងមានទំហំតូច និងប្រជាជនតិចណាស់ ហើយទីតាំងភូមិសាស្ត្រនិងប្រព័ន្ធនយោបាយរបស់ប្រទេសយើងមិនអាចអនុញ្ញាតឲ្យយើងប្រព្រឹត្តការឈ្លានពានលើប្រទេសដទៃបានទេ ។ ប្រទេសដែលទន់ខ្សោយ និងតូចបែបនេះមិនអាចលេបយកទឹកដីធំបានទេ ។*

*កម្ពុជាប្រជាធិបតេយ្យរបស់យើងមិនមានមូលហេតុអ្វីដើម្បីប្រព្រឹត្តនូវសកម្មភាពឈ្លានពានលើនរណាម្នាក់ទេ ។ យើងមានទឹកដីទំហំតែ១៨១.០០០គីឡូម៉ែត្រការ៉េ និងមានដីកសិកម្មចំនួន៦ហិកតានិងប្រជាជនចំនួនតែ៨លាននាក់ប៉ុណ្ណោះ ។ អាស្រ័យលើដីកសិកម្មសម្រាប់ដាំដំណាំនិងបន្លែ គ្រួសារកសិករជាមធ្យមទទួលបានដីសម្រាប់ធ្វើកសិកម្មចំនួន៥ហិកតា ។ ក្នុងទិដ្ឋភាពបែបនេះ វាពិតជាគ្មានតម្រូវការអ្វីឲ្យយើងធ្វើការរំលោភឈ្លានពានលើទឹកដីរបស់នរណាម្នាក់ឡើយ ។ បន្ថែមពីនេះ ប្រទេសយើងទើបតែងើបឡើងពីសង្គ្រាមបំផ្លិចបំផ្លាញ ដូច្នេះយើងទាំងអស់គ្នាត្រូវការពេលវេលានិងកម្លាំងដែលយើងត្រូវតែប្រមូលបង្រួបបង្រួមគ្នាដើម្បីកសាងប្រទេសរបស់យើង និងធ្វើឲ្យកម្រិតជីវភាពរស់នៅរបស់ប្រជាជនយើងមានភាពល្អប្រសើរបានយ៉ាងឆាប់រហ័ស ។*

*យើងមានឆន្ទៈដ៏ស្មោះត្រង់ក្នុងការគោរពឯករាជ្យភាព អធិបតេយ្យភាព និង បូរណភាពដែនដីរបស់យើង ។ យើងតែងតែខិតខំប្រឹងប្រែងចងសម្ព័ន្ធភាពល្អនិងជិតស្និទ្ធជាមួយនឹងប្រទេសជិតឆ្ងាយទូទាំងពិភពលោក ដែលបានបង្ហាញឲ្យឃើញតាមរយៈ*

ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូកម្ពុជាយើងទៅកាន់ប្រទេសជាច្រើននៅក្នុងឆ្នាំ១៩៧៥ ភ្លាមៗបន្ទាប់ពីថ្ងៃរំដោះរបស់ប្រទេសយើង។ ទន្ទឹមនឹងនោះ យើងក៏បានគោរពយ៉ាងស្មោះស្ម័គ្រលើឯករាជ្យភាព អធិបតេយ្យភាព និង បូរណភាពដែនដីរបស់ប្រទេសដទៃទៀតផងដែរ។ ប៉ុន្តែ យើងក៏បានប្តេជ្ញាចិត្តថានឹងការពារឯករាជ្យភាព អធិបតេយ្យភាព និង បូរណភាពដែនដីរបស់ប្រទេសយើងយ៉ាងដាច់ខាត។

ប្រជាជនរបស់យើងក្នុងពេលបច្ចុប្បន្ននេះកំពុងតែក្តាប់យកជោគវាសនាប្រទេសជាតិក្នុងដៃរបស់ពួកគេ។ កាលៈទេសៈនេះអាចកើតឡើងបានដោយសារតែការតស៊ូដ៏ជូរចត់ និងក្លាហានពោរពេញទៅដោយការលះបង់ ដែលជាការតស៊ូធ្វើឲ្យពួកចក្រពត្តិនិយមអាមេរិកនិងពួកប្រតិកិរិយារបស់វាទទួលបរាជ័យនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ដូច្នេះ ប្រជាជនទាំងអស់នេះនឹងមិនអនុញ្ញាតឲ្យនរណាម្នាក់ធ្វើការឈ្លានពាន រំលោភ អន្តរាគមន៍ វិទ្ធង្សនាឬបង្កជម្លោះលើប្រទេសរបស់ពួកគេ ហើយក៏មិនអនុញ្ញាតឲ្យនរណាម្នាក់មករំកិលខ្សែបន្ទាត់ព្រំដែនរបស់ប្រទេសពួកគេឡើយ។ យោងតាមគោលជំហរដ៏ត្រឹមត្រូវនេះ ប្រជាជនយើងទទួលបាននូវការទទួលស្គាល់ពីប្រទេសជាមិត្តទាំងជិតឆ្ងាយក្នុងទ្វីបទាំងប្រាំ ដោយសារតែគោលជំហរនេះប្រកបដោយភាពទៀងត្រង់។ យ៉ាងណាមិញ សត្រូវគ្រប់ប្រភេទទាំងអស់បានព្យាយាមស្វែងរកគ្រប់មធ្យោបាយដើម្បីបំផ្លាញកម្ពុជាប្រជាធិបតេយ្យ។

សំណួរថាតើកម្ពុជាប្រជាធិបតេយ្យអាចទទួលបានជោគជ័យនៅក្នុងការការពារទឹកដីរបស់ខ្លួនបានឬទេ បើយើងពិចារណាលើចំនួនប្រជាជនតិចតួចបែបនេះ យើងអាចឆ្លើយនឹងសំណួរនេះដោយមោទនភាពថា ប្រជាជនយើងក្នុងពេលបច្ចុប្បន្នដែលកំពុងតែទទួលបាននូវអំណាចបដិវត្តន៍នៅក្នុងដៃអាចការពារទឹកដីរបស់ខ្លួនបានយ៉ាងពេញលេញនិងពិតប្រាកដ ដោយមូលហេតុថាប្រជាជនរបស់យើងមានបទពិសោធន៍ក្នុងសង្គ្រាមរំដោះជាតិប្រឆាំងនឹងសង្គ្រាមឈ្លានពានដ៏ឃោរឃៅរបស់ពួកចក្រពត្តិនិយមអាមេរិក និងដោយសារតែប្រជាជនយើងទទួលបានជ័យជម្នះដ៏អស្ចារ្យកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដោយស្មារតីឯករាជ្យភាព និង ស្មារតីខ្លួនទីពឹងខ្លួន និងដោយសារតែមានការគាំទ្រពីប្រជាជនជាមិត្តទាំងជិតឆ្ងាយ។

យើងសូមប្រកាសនៅពេលនេះម្តងទៀតថា កម្ពុជាប្រជាធិបតេយ្យនឹងមិនបង្កជម្លោះជាមួយប្រទេសណាឡើយ ហើយយើងនឹងគោរពយ៉ាងម៉ឺងម៉ាត់តាមគោលការណ៍គោរពឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពដែនដីគ្នាទៅវិញទៅមកដោយស្មើភាព។

សម្រាប់សន្តិសុខផ្ទៃក្នុងរបស់យើងក៏មានស្ថានភាពរឹងមាំ



ល្អដែរ។ ភ្ញៀវទេសចរណ៍អន្តរជាតិអាចធ្វើដំណើរពីថ្ងៃដល់យប់ឬទៅកាន់ទីកន្លែងណាដោយសុវត្ថិភាពក៏បាន។ តាំងពីយូរណាស់មកហើយ ឆន្ទៈការពារជាតិត្រូវបានទទួលជោគជ័យ។ យ៉ាងណាមិញ យើងត្រូវតែរក្សាការយកចិត្តទុកដាក់ដើម្បីត្រៀមខ្លួនដោះស្រាយជាមួយនឹងការប៉ុនប៉ងឈ្លានពាន ឬបង្កវិវាទពីខាំង។ ដូចគ្នានឹងវិស័យនៃការការពារភាពជោគជ័យរបស់បដិវត្តន៍ និងការពារប្រទេស យើងបានបន្តគោរពតាមគោលជំហរឯករាជ្យភាពនិងភាពខ្លួនទីពឹងខ្លួនក្នុងឆន្ទៈស្ថាបនាជាតិយើង។ គោលជំហរនេះត្រូវបានផ្តល់ឲ្យប្រជាជនកម្ពុជាយើងដោយបក្សកុម្មុយនីស្ត

កម្ពុជា និងធ្លាប់បានសាកល្បងនៅក្នុងចលនាបដិវត្តន៍ដ៏ជោគជ័យ និងច្បាស់លាស់ក្នុងផ្លូវបដិវត្តន៍របស់កម្ពុជា ហើយក៏បាននាំមកនូវជ័យជម្នះដ៏ពិសិដ្ឋមួយដល់ប្រជាជនយើងផងដែរ ។

ប្រជាជននិងប្រទេសជាមិត្តជាច្រើនបានអបអរសាទរនឹងលទ្ធផលដ៏អស្ចារ្យដែលកម្ពុជាប្រជាធិបតេយ្យសម្រេចបាន ហើយពួកគេក៏បានបង្ហាញនូវភាពអាណិតអាសូរជាមួយយើង និងបានផ្តល់ឲ្យយើងនូវការគាំទ្រផ្នែកនយោបាយនិងសីលធម៌ ។ លើសពីនេះ ប្រទេសជាមិត្តខ្លះក៏ធ្លាប់បានផ្តល់ជំនួយជាសម្ភារៈដល់


អៀង សារី

យើងផងដែរ ។ យើងសូមស្វាគមន៍នូវជំនួយគ្មានសំណាងដែលផ្តល់ឲ្យដោយមូលដ្ឋានពិតប្រាកដនៃភាពស្មើគ្នា និងការគោរពគ្នាទៅវិញទៅមកដែលនឹងអាចធ្វើឲ្យប្រទេសយើងមានឯករាជ្យបន្ថែមទៀត ។ នេះជាភស្តុតាងនៃសាមគ្គីភាពដ៏ស្មោះស្ម័គ្ររវាងប្រទេសមិនចូលបក្សសម្ព័ន្ធនិងប្រទេសមិនសូវអភិវឌ្ឍ ។ ប៉ុន្តែដោយសារតែប្រទេសរបស់យើងត្រូវបានរំដោះហើយ ប្រជាជនយើងមានសមត្ថភាពការពារនិងកសាងប្រទេសរបស់ខ្លួនដោយផ្អែកលើកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ហើយយើងជឿថាប្រជាជនទាំងអស់នេះដែលកំពុងតែវាយប្រយុទ្ធនិងបានបាត់បង់ឈាមសម្រាប់ការរំដោះជាតិ ក្នុងពេលបច្ចុប្បន្នត្រូវការការគាំទ្រនិងជំនួយដើម្បីធ្វើឲ្យការយល់អំពីគោលការណ៍យុត្តិធម៌របស់ខ្លួនកើតមានឡើង ។ តាមរយៈការនិយាយបែបនេះ មិនមែនមានន័យថាយើងមានសម្ភារៈច្រើនឬគ្រប់គ្រាន់ទេ ប៉ុន្តែយើងត្រូវតែខិតខំប្រឹងប្រែងជម្នះរាល់ឧបសគ្គ ដោះស្រាយបញ្ហាកើតឡើងក្រោយពីសង្គ្រាម និង ការពារ កសាងប្រទេសដោយផ្អែកលើកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនយើងដើម្បីកុំឲ្យមានការរំខានដល់ប្រទេសជាមិត្តរបស់យើង ។ យើងត្រូវតែប្រឹងប្រែងបន្តដើម្បីឲ្យបដិវត្តន៍របស់យើងមានដំណើរការល្អនិងសម្រេចបាននូវជោគជ័យដ៏អស្ចារ្យដើម្បីជួយបន្ថែមដល់ការតស៊ូធ្វើបដិវត្តន៍ ការតស៊ូរំដោះជាតិ និងការពារជាតិដែលឥឡូវនេះកំពុងតែទទួលបានការគាំទ្រពីប្រជាជនទូទាំងពិភពលោក ។

កម្ពុជាប្រជាធិបតេយ្យបានពិចារណាលើសេចក្តីអាណិតអាសូរ ការលើកទឹកចិត្ត និងការស្តែងចេញឲ្យឃើញនូវសាមគ្គីភាពដែលប្រទេសមិនចូលបក្សសម្ព័ន្ធ ប្រទេសមិនសូវអភិវឌ្ឍ និងប្រទេសដែលមានភាពជឿនលឿនពិតប្រាកដបានផ្តល់ការគាំទ្រដ៏មានតម្លៃលើគោលការណ៍ឯករាជ្យភាព សន្តិភាព និងការមិនចូលបក្សសម្ព័ន្ធរបស់ប្រទេសកម្ពុជា ។ យើងតែងតែគោរពតាមគោលនយោបាយនេះជានិច្ច ។ ដោយគ្មានករណីអ្វីទាំងអស់ យើងសូមអនុញ្ញាតឲ្យបរទេសបង្កើតមូលដ្ឋានទ័ពរបស់ខ្លួននៅលើទឹកដីរបស់យើងនិងធ្វើការឈ្លានពានលើទឹកដីរបស់ទឹកដីរបស់ផងដែរ។

ថ្មីៗនេះ យើងបានទទួលលិខិតអញ្ជើញឲ្យយើងចូលរួមជាសមាជិកបក្សសម្ព័ន្ធនិងសមាគមក្នុងតំបន់មួយចំនួន ។ កម្ពុជាប្រជាធិបតេយ្យយើងមិនបានចូលរួមក្នុងបក្សសម្ព័ន្ធឬសមាគមតំបន់ណាមួយឡើយ ។ ប៉ុន្តែ យើងខិតខំប្រឹងប្រែងចងសម្ព័ន្ធមិត្តភាពល្អជាមួយនឹងប្រទេសទាំងអស់ ទាំងជិតនិងឆ្ងាយ ដោយផ្អែកលើមូលដ្ឋានជួយគ្នាទៅវិញទៅមក និងគោលការណ៍ស្មើភាពគ្នា និងការគោរពគ្នាទៅវិញទៅមក ។ គោលជំហរនេះទទួលបាននូវសេចក្តីអាណិតអាសូរ និងការយោគយល់ពីប្រទេសជាច្រើនដែលយើងបានរក្សាចំណងមិត្តភាពល្អជាមួយ ។

**ឯកសារ D២៩៨៤៣**

# អ្នកប្រវត្តិសាស្ត្រក្នុងតំបន់

ពីរបីម៉ោងកន្លងផុតទៅ តាមដងវិថីនៅភ្នំពេញចាប់ផ្តើមពោរពេញទៅដោយធូលី ហើយចរាចរណ៍កកស្ទះក៏បានរំសាយម្តងបន្តិចៗ ដោយឃើញមានតែម៉ូតូមួយចំនួនតូចប៉ុណ្ណោះបើកបរឆ្លងកាត់ផ្លូវ ។ បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជារួមទាំងរូបខ្ញុំបានធ្វើដំណើរទៅកាន់ឃុំទួលខ្ពស់ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ដើម្បីធ្វើការសម្ភាសន៍ជាមួយអ្នកស្រុកដែលធ្លាប់ធ្វើជាកម្មាភិបាលខ្មែរក្រហម ឬជនរងគ្រោះនៃចលនាខ្មែរក្រហម និងដើម្បីបញ្ចាំងភាពយន្តឯកសារចំនួនពីរដែលនិយាយអំពីសម័យខ្មែរក្រហមសម្រាប់ប្រជាជនដែលចង់ចូលរួម ។

នៅពេលមកដល់ឃុំទួលខ្ពស់ ដំបូងយើងបានជួបជាមួយលោក សាក់ សាត ដែលជាប្រធានឃុំ ដើម្បីពន្យល់ប្រាប់គាត់អំពីគោលបំណងរបស់ពួកយើង និងស្នើសុំឲ្យគាត់ជួយប្រកាសប្រាប់ប្រជាជនក្នុងឃុំឲ្យចូលរួមមើលខ្សែភាពយន្តឯកសារទាំងនេះ ។ ដើម្បីជួយដល់ក្រុមរបស់យើង លោកប្រធានឃុំ សាក់ សាត បានចំណាយពេលពីរទៅបីម៉ោងនិយាយជាមួយក្រុមយើងអំពីប្រវត្តិនៃឃុំទួលខ្ពស់ និងក្រុងកំពង់ឆ្នាំងក្នុងសម័យខ្មែរក្រហម ។ គាត់បានអធិប្បាយអស់រយៈពេលយ៉ាងយូរអំពីទីកន្លែងមណ្ឌលរដ្ឋបាលគុកដែលប្រើប្រាស់ដោយកម្មាភិបាលខ្មែរក្រហម វិធីសាស្ត្រធ្វើទារុណកម្មរបស់គុកទាំងនោះ ទីកន្លែងរបស់កម្មាភិបាលខ្មែរក្រហម និងជនរងគ្រោះរស់នៅក្នុងតំបន់នេះ ហើយនិងទំនាក់ទំនងបច្ចុប្បន្នរវាងក្រុមទាំងពីរនេះ ខណៈពេលដែលកំពុងរស់នៅរួមគ្នាក្នុងខេត្តកំពង់ឆ្នាំងសព្វថ្ងៃ ។

នៅថ្ងៃបន្ទាប់ ក្រុមរបស់យើងដែលមានគ្នាបួននាក់បានជួបជាមួយប្រជាជនបីនាក់ផ្សេងទៀត ដែលពីរនាក់គឺជាជនរងគ្រោះពីរបបខ្មែរក្រហម និងម្នាក់ទៀតគឺជាអតីតយោធា ។ ជនរងគ្រោះពីរនាក់ដែលយើងបានជួបបាននិយាយរៀបរាប់អំពីបទពិសោធន៍របស់ខ្លួនដែលបានបែកពីគ្រួសារ និងបង្ខំឲ្យចូលក្នុងក្រុមការងារចល័ត បន្ទាប់មកត្រូវបានបញ្ជូនទៅខេត្តកំពង់ឆ្នាំង ដើម្បីសាងសង់ទំនប់ទឹកនិងស្ពាន និងធ្វើស្រែ ។ មនុស្សទីបីដែលយើងបានជួបគឺជាស្ត្រីម្នាក់ដែលត្រូវបានជ្រើសរើសឲ្យចូលបម្រើកងវរសេនាធំនារីក្នុងជួរកងទ័ពបដិវត្តន៍ខ្មែរក្រហមនៅឆ្នាំ១៩៧៣ ។ គាត់បាននិយាយរៀបរាប់នូវអ្វីដែលខ្មែរក្រហមបង្ខំឲ្យគាត់ចូលទៅមើលព្រលានយន្តហោះភ្នំពេញ ដែលក្នុងអំឡុងពេលនោះមានឈ្មោះថា ពោធិចិនតុង ខណៈពេលដែលព្រលានយន្តហោះនេះត្រូវបានកម្មាភិបាលខ្មែរក្រហមប្រើសម្រាប់ទទួលស្វាគមន៍គណៈប្រតិភូចិនដែលមកទស្សនាប្រទេសកម្ពុជា រួមទាំងបទពិសោធន៍នៃការជិះកង់ទៅកាន់មន្ទីរសន្តិសុខស-២១ នៅពេលដែលគុកនេះបានក្លាយជាទីក្រុងតូចមួយសម្រាប់ទាហាន និងអ្នកទោស រួមទាំងបទពិសោធន៍ឈរនៅតាមដងផ្លូវជាមួយនឹងកងអនុសេនាតូចរបស់គាត់ក្នុងអំឡុងពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ គាត់ក៏បាននិយាយអំពីបទពិសោធន៍ប្រចាំថ្ងៃរបស់គាត់ក្នុងនាមជាយុទ្ធនារីម្នាក់ដែលត្រូវបានដាក់បន្ទុំឲ្យធ្វើការនៅតាមវាលស្រែ ហើយនិងការធ្លាប់ចូលសមរភូមិម្តងប្រយុទ្ធជាមួយទាហានលន់ នល់ នៅពេលយុទ្ធនារីទាំងអស់ត្រូវបានបញ្ជាឲ្យមកប្រមូលសាកសព ។


កម្មាភិបាលខ្មែរក្រហមទទួលគណៈប្រតិ

បន្ទាប់ពីប្រជាជនម្នាក់ៗបានរៀបរាប់អំពីរឿងរ៉ាវផ្ទាល់ខ្លួននិងការយល់ដឹងអំពីប្រវត្តិសាស្ត្រក្នុងអំឡុងទសវត្សរ៍៧០ ខ្ញុំមិននឹកស្មានថាពួកគាត់ម្នាក់ៗទទួលបានសៀវភៅ

ព័ត៌មានដើម្បីចែករំលែកជាមួយនឹងសហគមន៍ក្នុងតំបន់និងសហគមន៍អន្តរជាតិឡើយ ។ ទោះបីជាខ្មែរក្រហមព្យាយាមធ្វើវិមជ្ឈការអំណាចក៏ដោយ ក៏អំពើសាហាវឃោរឃៅជាច្រើនបានកើតឡើងនៅតាមថ្នាក់ស្រុកដែលស្ថិតនៅក្រោមរដ្ឋអំណាចតំបន់ដែរ ។ ជាលទ្ធផលទាំងជនរងគ្រោះនិងអតីតទាហានខ្មែរក្រហមសុទ្ធដែលទទួលបានបទពិសោធន៍ផ្សេងៗគ្នានៅក្នុងរបបនោះ ។ ខណៈពេលដែលមានកិច្ចខិតខំប្រឹងប្រែងដ៏មោះមុតដើម្បីកត់ត្រានូវប្រវត្តិសាស្ត្រដ៏ធំនេះ វាហាក់បីដូចថាមានចំនួនប្រជាជននៅតាមជនបទច្រើនណាស់ ដែលមានបទពិសោធន៍ប្លែកៗផ្សេងគ្នាដែលអាចផ្តល់ជាទស្សនៈប្រវត្តិសាស្ត្រដើម្បីប្រមូលយកព័ត៌មាន ។

ដើម្បីរំឭកអំពីរបបខ្មែរក្រហមដែលប្រជាជននៅតំបន់ដាច់ស្រយាលប្រហែលជាបានបំភ្លេចចោល ដូច្នេះវាមានការលំបាកក្នុងការភ្ជាប់ការសន្ទនាអំពីរបបខ្មែរក្រហម អាស្រ័យហេតុនេះ យើងគួរតែរារាំងប្រវត្តិសាស្ត្រក្នុងតំបន់មិនឲ្យផ្ទេរបន្តពីមនុស្សចាស់ទៅឲ្យក្មេងជំនាន់ក្រោយ ។

ក្នុងយប់នោះ នៅពេលដែលក្រុមរបស់យើងបានបញ្ចាំងភាពយន្តឯកសារទាក់ទងនឹងសម័យខ្មែរក្រហមជូនដល់ក្រុមប្រជាជនដែលមានគ្នាប្រហែល១០០នាក់ ដែលមានគ្រប់វ័យទាំងអស់ ខ្ញុំអាចយល់ពីសារសំខាន់នៃការជួបជុំគ្នាបែបនេះ ។ ដោយសារតែមនុស្សចាស់ជំនាន់ខ្មែរក្រហមមានការលំបាកនៅក្នុងការចែករំលែកពីបទពិសោធន៍របស់ពួកគេទៅកាន់ក្មេងជំនាន់ក្រោយ ខ្សែភាពយន្តនេះក៏បានបង្កើតនូវវេទិកាមួយដើម្បីពិភាក្សាដែលផ្តល់ឱកាសសម្រាប់ប្រជាជននៅក្នុងភូមិធ្វើការស្វែងយល់ពីប្រវត្តិសាស្ត្រក្នុងតំបន់របស់ពួកគេពីអ្នកប្រវត្តិ-សាស្ត្រផ្ទាល់តែម្តង ។

**ឆាល វេជសាន់**



...ភូនៅព្រលានយន្តហោះពោធិចិនតុង

# សែត ឌុន

នៅពេលដែលរំឭកពីរបបកម្ពុជាប្រជាធិបតេយ្យ គេតែងតែនឹកឃើញដល់ភាពសាហាវឃោរឃៅដែលខ្មែរក្រហមបានប្រព្រឹត្តមកលើប្រជាជនខ្មែរ ។ រយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ ដែលខ្មែរក្រហមឡើងកាន់កាប់អំណាច របបនេះបានសម្លាប់ជីវិតប្រជាពលរដ្ឋស្លូតត្រង់អស់ជិតពីរលាននាក់តាមរយៈការបង្ខំឲ្យធ្វើការហួសកម្លាំង ការបង្អត់អាហារ ការធ្វើទារុណកម្ម កង្វះខាតឱសថសម្រាប់ព្យាបាលជំងឺនិងការសម្លាប់ ។ ដូច្នេះ តើខ្មែរក្រហមទាំងអស់សុទ្ធតែជាមនុស្សគួរឲ្យខ្លាចនិងកាចសាហាវមែនឬ? ផ្ទុយទៅវិញ សែត ឌុន ដែលជាប្រធានសហករណ៍ម្នាក់កាលពីរបបកម្ពុជាប្រជាធិបតេយ្យបែរជាត្រូវបានប្រជាជនស្រឡាញ់រាប់អានទៅវិញ ហើយនៅតែនឹកដល់គុណដែលគាត់បានជួយឲ្យរស់មានជីវិត ។



លោកតា សែត ឌុន

ឌុន កើតនៅក្នុងត្រកូលកូនអ្នកកសិករមានបងប្អូនចំនួន៥នាក់ មានស្រុកកំណើតនៅស្រុកឈូក ខេត្តកំពត ។ នៅពេលដែលមានអាយុ៨ឆ្នាំ ឌុន ក៏បានផ្លាស់ទៅរស់នៅជាមួយពូដែលជាប្អូនពៅរបស់ម្តាយគាត់នៅខេត្តបាត់ដំបងវិញ ។ នៅទីនោះ ឌុន រៀនបានតែមួយឆ្នាំប៉ុណ្ណោះ ក៏សម្រេចចិត្តឈប់ពីការសិក្សាមកជួយធ្វើការងារពូរបស់គាត់នៅឯចម្ការ ។ លុះដល់អាយុបាន១៧ឆ្នាំទើប ឌុន ត្រឡប់មករស់នៅភូមិកំណើតជាមួយឪពុកម្តាយ និងបងប្អូនរបស់គាត់ ។ បន្ទាប់មក គាត់ទាំងពីរនាក់ក៏បញ្ជូន ឌុន ទៅបួសនៅវត្តអង្គខ្ជាយ ។ ប៉ុន្តែបួសបានតែបីវស្សាប៉ុណ្ណោះ ឌុន ក៏សឹករួចរៀបការជាមួយនារីម្នាក់ឈ្មោះ មិន អឿង ។ ក្រោយពីរៀបការរួច ឌុន បានផ្លាស់ទៅរស់នៅជាមួយភរិយានៅខាងត្បូងវត្តនារាយណ៍ ស្រុកឈូក ខេត្តកំពត ។

នៅឆ្នាំ១៩៧០ នៅពេលដែលមានរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ ជីវិតឯកជនរបស់ ឌុន ត្រូវបានកែប្រែមកជាសមូហភាពវិញ ព្រោះតំបន់នោះត្រូវបានកាន់កាប់ដោយកងទ័ពខ្មែរក្រហម ។ រហូតដល់ឆ្នាំ១៩៧៧ មេភូមិឈ្មោះ ម៉េន បានជម្លៀសគ្រួសាររបស់ ឌុន ឲ្យទៅរស់នៅខេត្តបាត់ដំបង ។ រថយន្តជាច្រើនគ្រឿងបានដឹកគ្រួសាររបស់គាត់និងគ្រួសារដទៃទៀតទៅសម្រាកនៅខេត្តតាកែវរយៈពេលពីរយប់ ។ នៅទីនោះ ឌុន បានឃើញប្រជាជនជិតបីរយគ្រួសារដែលមកពីតំបន់ផ្សេងៗគ្នាបានចូលប្រជុំរៀនសូត្រអំពីរបៀបការពារខ្លួន ដោយមាន តាម៉ុក ជាគ្រូបង្រៀន ។ ពេលមកដល់ភ្នំពេញ ថ្នាក់លើបានរៀបចំការសម្តែងសៀកដើម្បីឲ្យអ្នកជម្លៀសបានទស្សនា ។ បន្ទាប់ជិះរថភ្លើងរយៈពេលពីរថ្ងៃទៀត គ្រួសាររបស់ ឌុន ក៏មកដល់ស្រុកភ្នំសំពៅ ខេត្តបាត់ដំបងនៅវេលាម៉ោង៨យប់ ។ ក្រោយពីសម្រាកនៅទីនោះបានបីយប់ ទើប ឆេង ដែលជាគណៈស្រុកភ្នំសំពៅធ្វើការបែងចែកប្រជាជនឲ្យធ្វើការទៅតាមសហករណ៍ ។ ពេលនោះ អង្គការស្រាប់តែចាត់តាំង ឌុន ឲ្យធ្វើជាប្រធានភូមិបឹងសង្កែ ឃុំម៉ាល់ ស្រុកភ្នំសំពៅ ខេត្តបាត់ដំបង ។ ដោយសារ ឌុន ទទួលការទុកចិត្តពីអង្គការ គាត់បែងចែកឲ្យប្រជាជនមានការងារធ្វើគ្រប់គ្នា ដូចជាអ្នកខ្លះចិញ្ចឹមសត្វ និងធ្វើស្រែចម្ការជាដើម ។ នៅពេលទទួលបានផលស្រូវ ឌុន យកទៅដាក់ជាសមូហភាព រួចធ្វើការបែងចែកម្នាក់បួនថាំង (១២០គីឡូក្រាម) សម្រាប់ហូបមួយរដូវ ។

ជាទូទៅ ឌុន តែងតែណែនាំប្រជាជននៅក្នុងសហករណ៍

របស់គាត់ឲ្យខំប្រឹងប្រែងធ្វើការសម្រាប់អង្គការថ្នាក់លើ មិនត្រូវខ្ជិលឬធ្វើពុតជាឈឺទេ បើមិនអ៊ីចឹងអង្គការនឹងយកទៅសម្លាប់ ។ ទោះបីជា ឌុន មានឋានៈត្រឹមតែធ្វើជាប្រធានភូមិក៏ដោយ ក៏គាត់តែងតែជួយអ្នកដទៃដែលជួបការលំបាកដែរ ។ នៅចុងឆ្នាំ១៩៧៧ ឌុន បានជួយផ្ដល់អាហារឲ្យគ្រួសារមួយមានគ្នាបីនាក់ដែលបានរត់ពីសហករណ៍របស់ខ្លួន មកសុំបាយហូបនៅសហករណ៍របស់គាត់ ព្រោះទីនោះមិនមានអាហារហូបគ្រប់គ្រាន់ទេដែលបណ្ដាលឲ្យប្ដីរបស់គាត់ស្លាប់ដោយសារតែហូបកន្ទក់ ។ ក្រោយមកទៀត ឌុន បានជួយបុរសម្នាក់ឈ្មោះ ដាវ ឲ្យរត់គេចពីការចាប់ខ្លួនរបស់អង្គការ ។ នៅពេលនោះ គ្រួសាររបស់ ដាវ បានរត់ចេញពីសហករណ៍ដែលខ្លួនធ្លាប់រស់នៅមកធ្វើការនៅក្នុងសហករណ៍របស់គាត់ ។ មួយរយៈក្រោយមក អង្គការថ្នាក់លើចុះមកសហករណ៍របស់គាត់រួចសួររកឈ្មោះ ដាវ ព្រោះឈ្មោះនេះមានជាប់ទិន្នាការនយោបាយខ្លាំង ។ លើសពីនេះទៅទៀត នៅពេលដែលអង្គការប្រាប់ឲ្យមើលដាវ កុំឲ្យលួចរត់ ឌុន មិនត្រឹមតែមិនធ្វើតាមបញ្ជាទេ ថែមទាំងហៅដាវ ឲ្យនាំគ្រួសាររត់ចេញទៀតផង ។ មុនពេលរត់គេចខ្លួន ដាវ បានមកថ្លែងអំណរគុណ ឌុន ដែលមានសន្ដានចិត្តល្អបែបនេះ ។

ឌុន នៅតែបន្តធ្វើនូវទង្វើល្អរបស់គាត់ជានិច្ច ទោះបីជារបបខ្មែរក្រហមដួលរលំហើយក៏ដោយ ។ ឌុន បានរំឭកថា នៅឆ្នាំ១៩៧៩ ពេលដែលកងទ័ពវៀតណាមចូលមករំដោះ ឌុន និងគ្រួសារក៏នាំគ្នារត់ទៅរកកន្លែងដែលមានសុវត្ថិភាព ។ នៅតាមផ្លូវពេលបានឃើញប្រជាជនខ្លះអត់បាយ ខ្លះអត់ទឹក និងខ្លះទៀតឈឺ គាត់ក៏ចែករំលែកស្បៀងអាហារដែលគាត់យកមកតាមខ្លួនទៅឲ្យអ្នកទាំងនោះទៀត ។

សព្វថ្ងៃនេះ ប្រជាជនដែលធ្លាប់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់កាលពីនៅក្នុងរបបនោះនៅតែស្រឡាញ់រាប់អានគាត់និងក្រុមគ្រួសារគាត់គ្រប់ៗគ្នា ទោះបីជារយៈពេលនោះបានកន្លងផុតទៅ៣០ឆ្នាំហើយក៏ដោយ ។ ចុងក្រោយ ឌុន រំឭកថា គាត់អាចរស់រានមានជីវិតរហូតដល់សព្វថ្ងៃនេះគឺដោយសារតែគាត់ធ្វើល្អទើបទទួលផលល្អ ។

**ម៉ែន ពិចិត្រ**



ការសាងសង់ផ្ទះគំរូក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

# ការបញ្ចាំងខ្សែភាពយន្តនៅបូជនីយដ្ឋានអំពែភ្នំ និងប្រតិកម្មរបស់ប្រជាជនចំពោះសវនាការ ឌុច

សវនាការកាត់ទោស កាំង ហ្កេកអ៊ាវ ហៅ ឌុច អតីតប្រធានគុកទួលស្លែងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានដំណើរការអស់រយៈពេលជាច្រើនខែមកហើយ ។ នៅក្នុងសវនាការដំបូង ដំណើរការនីតិវិធីបានទាក់ទាញចំណាប់អារម្មណ៍ជាតិនិងអន្តរជាតិ ។ ខណៈពេលដែលប្រជាជនកម្ពុជាមួយចំនួនមានជំនឿថាមិនមានអ្វីកើតឡើង សវនាការនេះនឹងមិនអាចជួយប្រទេសកម្ពុជាឲ្យមានការផ្សះផ្សាជាតិទេ ប្រជាជនកម្ពុជាភាគច្រើនផ្សេងទៀតបានបង្ហាញពីសេចក្តីសោមនស្សរបស់គេទៅលើដំណើរការនីតិវិធី ហើយមានជំនឿថា យុត្តិធម៌នឹងកើតឡើងក្នុងពេលឆាប់ៗនេះ ។ ដោយមិនគិតទៅលើទស្សនៈចំពោះលទ្ធផលចុងក្រោយ ប្រជាជនបានតាមដានសវនាការយ៉ាងយកចិត្តទុកដាក់ ។ តាមរយៈគម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឬវិទ្យុ និងទូរទស្សន៍ ប្រជាជនកម្ពុជាកំពុងតែតាមដានការវិវឌ្ឍថ្មីៗនៃដំណើរការនីតិវិធីច្បាប់នៅអង្គជំនុំជម្រះ ។

កាលពីព្រឹកថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០០៩ ក្រុមបញ្ចាំងខ្សែភាពយន្តចំនួន៦នាក់ ដែលជាផ្នែកមួយនៃគម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបញ្ចាំងខ្សែភាពយន្តខ្លីៗនៅវត្តអំពែភ្នំសម្រាប់ប្រជាជនមកពីឃុំចំនួនបីនៅក្នុងខេត្តកំពង់ស្ពឺ ។ ក្រុមការងារជ្រើសរើសវត្តនេះមកធ្វើការបញ្ចាំងខ្សែភាពយន្តពីព្រោះតែវត្តនេះធ្លាប់មានប្រវត្តិនៅសម័យ ប៉ុល ពត ។ លោក អ៊ុន ហាក់ អាយុ៨០ឆ្នាំ បានប្រាប់ក្រុមការងារថា នៅក្នុងឆ្នាំ១៩៧៥ វត្តអំពែភ្នំត្រូវបានបោះបង់ចោលនៅពេលដែលខ្មែរក្រហមជម្លៀសប្រជាជនទាំងអស់ទៅតំបន់៥៥នៅក្នុងស្រុកអង្គរបុរី ខេត្តតាកែវ ។ ព្រះសង្ឃដែលរស់នៅក្នុងវត្តនេះត្រូវបានបង្ខំឲ្យសឹកនិងចាកចេញពីវត្តដោយមិនទុកឲ្យនរណាម្នាក់នៅមើលថែវត្តនេះឡើយ ។

នៅក្នុងគំនិតរបស់ ហាក់ អ្វីដែលបានកើតឡើងនៅវត្តនេះគឺជាភស្តុតាងមួយដែលបង្ហាញពីបំណងរបស់ខ្មែរក្រហមក្នុងការលុបបំបាត់សាសនា ។ ទោះបីជាមិនបានដឹងរឿងច្រើនអំពីអ្វីដែលបានកើតឡើងនៅតាមវត្តនៅក្នុងរបបខ្មែរក្រហមក៏ដោយ ហាក់ដែលជាប្រធានភូមិអំពែភ្នំតាំងពីឆ្នាំ១៩៧៩ បានរំឭកថា មានរណ្តៅសាកសពជាច្រើននៅក្នុងបរិវេណវត្ត ។ នៅក្នុងខ្សែភាពយន្តជនរងគ្រោះរាប់រយនាក់ត្រូវបានខ្មែរក្រហមវាយសម្លាប់ហើយកប់នៅក្នុងរណ្តៅសពរួម ។ នៅទសវត្សរ៍៨០ សាកសពជនរងគ្រោះត្រូវបានប្រជាជនគាស់ឡើង ហើយយកទៅតម្កល់នៅក្នុងរោងដែលនៅជិតនោះដើម្បីការពារកុំឲ្យមានការបាត់បង់ ។


កិច្ចពិភាក្សាមុននឹងបញ្ចាំងភាពយន្តឯកសារស្តីអំពីសវនាការ ឌុច

នៅពេលដែលគាត់បានដឹងពីសវនាការនេះ គាត់មានការគាំទ្រយ៉ាងខ្លាំង និងជំរុញឲ្យអ្នកភូមិតាមដានដំណើរការនីតិវិធីនេះ ។ គាត់គាំទ្រការបញ្ចាំងខ្សែភាពយន្តនេះ ហើយចង់ឲ្យអ្នកភូមិមើលខ្សែភាពយន្តខ្លីទាក់ទងនឹងករណី ឌុច នៅក្នុងសវនាការ ។ គោលបំណងនៃការបញ្ចាំងខ្សែភាពយន្តនេះដើម្បីកត់ត្រាពីប្រតិកម្មរបស់អ្នកភូមិនិងប្រើព័ត៌មានដែលប្រមូលបានដើម្បីធ្វើការវាយតម្លៃដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ខាងក្រោមនេះ

គឺជាប្រតិកម្មផ្ទាល់ខ្លួនរបស់អ្នកភូមិបន្ទាប់ពីគេបានទស្សនាខ្សែភាពយន្តខ្លី១ចំនួន៣ អំពីដំណើរការនីតិវិធីលើករណី ឌុច ។

## ប្រតិកម្មរបស់អ្នកភូមិចំពោះសវនាការ ឌុច

លោក វ៉ន វ៉ាង អាយុ៤៨ឆ្នាំ បាននិយាយថា «ខ្ញុំជាជនជាតិកម្ពុជាក្រោម» ។ ខ្ញុំគិតថា ការនាំយកមេដឹកនាំទាំងនោះមកកាត់ទោសគឺជារឿងត្រឹមត្រូវមួយនៅពេលនេះ ។ ឌុច បានធ្វើការសុំទោសជាច្រើនទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅមន្ទីរម-១៣ និងមន្ទីរស-២១ ។ ឌុច និយាយថា គាត់មិនបានធ្វើរឿងនោះដោយចិត្តរបស់គាត់ទេ ហើយគាត់ក៏មិនបានធ្វើទារុណកម្មអ្នកទោសដែរ គាត់គ្រាន់តែបញ្ជាឲ្យកូនចៅរបស់គាត់ធ្វើទារុណកម្មតែប៉ុណ្ណោះ ។ វាគឺជាការពិត ។ ហេតុដូច្នេះវាមានន័យថា គាត់មានសិទ្ធិទុកជីវិតឲ្យនរណាម្នាក់បានប្រសិនបើគាត់ចង់ ។ ប៉ុន្តែគាត់មិនបានធ្វើដូច្នេះទេ ។ ខ្ញុំមានក្តីសង្ឃឹមខ្ពស់លើអង្គជំនុំជម្រះ ពីព្រោះវាជាតុលាការកូនកាត់ដែលមានការចូលរួមទាំងសហគមន៍ជាតិនិងអន្តរជាតិ ។ តាមរយៈខ្សែភាពយន្តនេះ ខ្ញុំគិតថា តុលាការនឹងផ្តល់យុត្តិធម៌ជូនដល់ជនរងគ្រោះនិងជនសង្ស័យ ។ នៅក្នុងខ្សែភាពយន្តនេះ ខ្ញុំសម្គាល់ឃើញថា ចៅក្រមបានសួរ ឌុច ដោយអត់ធ្មត់បំផុតហើយ ឌុច ក៏មិនត្រូវបានគំរាមកំហែងទាំងផ្លូវកាយ ឬផ្លូវចិត្តនៅក្នុងគ្រប់សវនាការដែរ ។ ជាចុងក្រោយ ខ្ញុំសង្ឃឹមថា នឹងមានការបង្កើតកម្មវិធីអប់រំមួយដើម្បីឲ្យក្មេងជំនាន់ក្រោយមានការយល់ដឹងពីរបបនោះដើម្បីការពារកុំឲ្យរបបនោះកើតឡើងម្តងទៀត ។ ខ្ញុំមានក្តីសង្ឃឹមចុងក្រោយមួយថា សហគមន៍អន្តរជាតិនឹងដឹងពីការឈឺចាប់ និងឧក្រិដ្ឋកម្មដែលខ្មែរក្រហមបានធ្វើទៅលើខ្មែរកម្ពុជាក្រោម ។

ឌុច ប៊ុណ្ណារិទ្ធិ អាយុ៤៧ឆ្នាំ បាននិយាយថា «នៅក្នុងរបបខ្មែរក្រហម គ្រួសាររបស់ខ្ញុំនិងខ្ញុំត្រូវបានជម្លៀសទៅខេត្តបាត់ដំបង ។ ឪពុករបស់ខ្ញុំបានស្លាប់ដោយសារអត់អាហារនៅទីនោះ ។ យើងមានអាហារតិចតួចណាស់សម្រាប់ហូប ។ បងប្អូនរបស់ខ្ញុំនិងខ្ញុំស្ទើរតែមិនអាចរស់រានមានជីវិតពីរបបខ្មែរក្រហម ។ បច្ចុប្បន្ននេះតុលាការកាត់ទោសមេដឹកនាំត្រូវបានបង្កើតឡើងហើយ ។ ខ្ញុំសូមអរគុណ ចំពោះមនុស្សទាំងអស់ដែលបានចូលរួមចំណែកបង្កើតតុលាការនេះឡើង ។ ខ្ញុំមិនយល់ដឹងពីនីតិវិធីច្បាប់



អ្នកភូមិបញ្ចេញយោបល់អំពីសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម

អ្វីទេ ដូច្នេះខ្ញុំមិនដឹងថា តើមេដឹកនាំខ្មែរក្រហមទាំងអស់នោះនឹងត្រូវកាត់ទោសដោយរបៀបណាដែរ ។ ខ្ញុំក្លាយទៅជាក្មេងកំព្រាដោយសារតែអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ អ្វីដែលខ្ញុំបាត់បង់នឹងមិនអាចយកមកវិញបានទេ ។ ប៉ុន្តែខ្ញុំសង្ឃឹមថាតុលាការនឹងធ្វើអ្វីមួយសម្រាប់ប្រជាជនកម្ពុជាដើម្បីស្វែងរកយុត្តិធម៌ ។ ជាផ្នែកមួយនៃកេរដំណែលរបស់តុលាការ រាជរដ្ឋាភិបាលប្រហែលជាចង់កសាងសាលា ឬក៏បូជនីយដ្ឋានសម្រាប់ជាសំណងរួម» ។

សេង សាខន អាយុ៤៤ឆ្នាំ បាននិយាយថា «ឌុច មានវិប្បដិសារីចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហម ។ ប៉ុន្តែខ្ញុំមិនគិតថា ឌុច គួរតែត្រូវបានអត់ឱនទោសនោះទេ ។ អ្វីដែលគាត់បានប្រព្រឹត្តគឺអាក្រក់និងហួសហេតុពេកហើយ ។ គាត់គួរតែទទួលខុសត្រូវចំពោះរឿងនោះ ។ នៅពេលមើលខ្សែភាពយន្តខ្លី ខ្ញុំសង្កេតឃើញភាពសាហាវរបស់ ឌុច នៅពេលដែលគាត់ឈរសើចទៅកាន់អ្នកទោសស្ត្រីម្នាក់ដែលកំពុងត្រូវបានធ្វើទារុណកម្ម ។ ខ្ញុំមិនយល់ទេថា ហេតុអ្វីបានជាគាត់ទើបតែសោក



អ្នកភូមិកំពុងទស្សនាភាពយន្តអំពីសវនាការ ឌុច

ស្តាយចំពោះទង្វើដែលគាត់បានធ្វើនៅថ្ងៃនេះ ។ ហេតុអ្វីបានជាគាត់មិនសោកស្តាយដល់អ្នកទាំងអស់នោះ នៅពេលដែលគាត់ធ្វើជាប្រធានមន្ទីរស-២១? ក្នុងនាមជាប្រធានគុក ហេតុអ្វីបានជាគាត់មិនជួយអ្នកទោសនៅពេលនោះ?»

យឹម ដួង អាយុ៨៥ឆ្នាំ បាននិយាយថា «ខ្ញុំបានដឹងពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ក៏ប៉ុន្តែខ្ញុំមិនដែលបានឃើញសវនាការផ្ទាល់ភ្នែកទេ ។ នៅក្នុងរបបខ្មែរក្រហម ប្រជាជនកម្ពុជាទាំងអស់លំបាកវេទនាណាស់ ។ ខ្ញុំគិតថា ការនាំយកមេដឹកនាំទាំងអស់នោះទៅកាត់ទោសគឺជារឿងត្រឹមត្រូវ» ។

កៅ ទឹម អាយុ៨០ឆ្នាំ បាននិយាយថា «ខ្ញុំយល់ថា ឌុច បានទទួលស្គាល់រាល់ឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្ត ។ ខ្ញុំគិតថា យើងគួរតែអភ័យទោសឲ្យ ឌុច» ។

គិត អ៊ី អាយុ៨៤ឆ្នាំ បាននិយាយថា «អំពើឃោរឃៅរបស់ខ្មែរក្រហមបានកើតឡើងជាច្រើនឆ្នាំមកហើយ ហើយបច្ចុប្បន្ន ឌុច កំពុងតែត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលកើតឡើងនៅ ស-២១ ព្រោះគាត់ជាអ្នកគ្រប់គ្រង ។ ដូច្នេះយើងគួរតែអភ័យទោសឲ្យគាត់ ។

សំ សុខា បាននិយាយថា «ខ្ញុំមិនអាចអភ័យទោសឲ្យគាត់បានទេ ពីព្រោះបងប្អូនខ្ញុំ៦នាក់បានស្លាប់នៅមន្ទីរម-១៣ ខ្ញុំស្ទើរតែមិនរស់ ។ ខ្ញុំសារភាពថា ខ្ញុំស្ទើរតែមិនអាចទប់ទឹកភ្នែកបាននៅពេលដែលខ្ញុំស្តាប់ការផ្តល់សក្ខីកម្មរបស់ នង ចាន់ផល តាមរយៈខ្សែភាពយន្ត» ។

## ការវិភាគទៅលើការបញ្ចាំងភាពយន្ត និង ការចូលរួមរបស់អង្គជំនុំជម្រះនៅថ្ងៃអនាគត

នៅពេលបញ្ចាំងខ្សែភាពយន្ត មានការចាក់បញ្ចាំងឈុតខ្លីៗចំនួនបីឲ្យអ្នកភូមិមើល ។ ឈុតខ្លីៗនោះរួមមានការសុំទោសរបស់ ឌុច ភ័ស្តុតាងនៃអំពើឃោរឃៅដែលប្រព្រឹត្តឡើងនៅមន្ទីរ ម-១៣ និងការផ្តល់សក្ខីកម្មរបស់ នង ចាន់ផល ដែលជាជនរងគ្រោះនៅមន្ទីរស-២១ ។ នៅប៉ុន្មានខែខាងមុខនេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងសហការជាមួយអង្គជំនុំជម្រះដើម្បីបញ្ចាំង ទាំងករណី ឌុច និងករណីផ្សេងទៀតនៃសវនាការនៅទូទាំងប្រទេស ។

គោលបំណងនៃការបញ្ចាំងខ្សែភាពយន្តនេះគឺដើម្បីធ្វើឲ្យអ្នកភូមិស្គាល់ពីអង្គជំនុំជម្រះ និងដើម្បីបង្កើនការយល់ដឹងរបស់អ្នកភូមិអំពីដំណើរការរបស់អង្គជំនុំជម្រះ ។ ខ្សែភាពយន្តដែលត្រូវបានបញ្ចាំងនឹងធ្វើឡើងជាសាធារណៈ ។ ការបញ្ចាំងនេះនឹងមិនបង្ហាញពីព័ត៌មានថ្មីៗ ឬនិយាយអំពីអង្គហេតុដែលធ្លាប់មានរួចមកហើយទេ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងព្យាយាមចាក់បញ្ចាំងខ្សែភាពយន្តខ្លីល្មម ហើយព្យាយាមមិនបង្កើតឲ្យមានភាពលម្អៀងទៅតែម្ខាងទេ ។ ជាងនេះទៅទៀត ការបញ្ចាំងខ្សែភាពយន្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាយុទ្ធសាស្ត្រតែមួយដែលធ្វើឲ្យប្រជាជនកម្ពុជាអាចយល់ដឹងពីតុលាការកាន់តែច្រើន ។

នៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយអង្គជំនុំជម្រះដើម្បីបញ្ចាំងខ្សែភាពយន្តនេះ គេត្រូវតែមានការការពារទុកជាមុនដើម្បីធានាថា ការបញ្ចាំងខ្សែភាពយន្តនេះនឹងបង្ហាញពីតំណាងនៃដំណើរការសវនាការដែលមិនមានភាពលម្អៀងនិងមិនយុត្តិធម៌ ។ គោលបំណងត្រូវបានសម្រេចបានតាមការចង់បាននៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាមានភាពឯករាជ្យក្នុងការបញ្ចាំងខ្សែភាពយន្ត ប៉ុន្តែគោលបំណងនោះនឹងកាន់តែសំខាន់ឡើងនៅពេលដែលមានការចូលរួមរបស់អង្គជំនុំជម្រះ ។ ខ្សែភាពយន្តដែលនឹងត្រូវជ្រើសរើសយកមកបង្ហាញមិនត្រូវប៉ះពាល់នឹងភាពអព្យាក្រឹតរបស់តុលាការទេ ។

ដោយ យើងមិនអាចបញ្ចាំងពីដំណើរការសវនាការទាំងមូល នៅពេលបញ្ចាំងខ្សែភាពយន្ត ក្រុមការងារត្រូវតែបន្ទឹចិត្តជ្រើសរើសយកខ្សែភាពយន្តខ្លីណាមួយដើម្បីបង្ហាញដល់អ្នកភូមិ ។ ក្រុមបញ្ចាំងខ្សែភាពយន្តត្រូវតែប្រយ័ត្នប្រយែងក្នុងការជ្រើសរើសឈុតខ្លីដើម្បីចាក់បញ្ចាំង ។ មិនថាភស្តុតាងប្រឆាំងនឹងជនត្រូវចោទមានទម្ងន់យ៉ាងណាក៏ដោយ ទស្សនៈរបស់ជនត្រូវចោទនិងការបកស្រាយពន្យល់របស់ជនត្រូវចោទអំពីភាពស្លូតត្រង់របស់ខ្លួនចាំបាច់ត្រូវតែយកមកបង្ហាញ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាគួរតែខិតខំឲ្យអស់ពីសមត្ថភាពដើម្បីបញ្ចាំងខ្សែភាពយន្តឲ្យមានតុល្យភាព ទើបអ្នកភូមិអាចសម្រេចពីកម្រិតនៃការទទួលខុសត្រូវរបស់ជនត្រូវចោទ ។

ប្រភេទខ្លីៗនៃខ្សែភាពយន្តគួរតែរួមបញ្ចូលការអះអាងរបស់ជនត្រូវចោទដើម្បីបង្ហាញពីភាពស្លូតត្រង់របស់គេ ការអះអាងរបស់ព្រះរាជអាជ្ញាសម្រាប់ការចោទប្រកាន់ ការផ្តល់សក្ខីកម្មដែលពាក់ព័ន្ធនឹងជនរងគ្រោះ ហើយប្រសិនបើអាចទៅរួចគួររួមបញ្ចូលភាពយន្តខ្លីដែលមានការជាប់ពាក់ព័ន្ធរវាងរបបខ្មែរក្រហមនិងដំណើរការនិតិវិធីផងដែរ ។ ការបញ្ចាំងភាពយន្តនៅថ្ងៃអាទិត្យ រួមមានការសុំអភ័យទោសរបស់ ឌុច ការផ្តល់សក្ខីកម្មអំពីមន្ទីរម-១៣ (នៅជិតកន្លែងបញ្ចាំងខ្សែវីដេអូ) និងការផ្តល់សក្ខីកម្មរបស់ជនរងគ្រោះ នង ចាន់ផល ។ ដោយសារតែ ឌុច បានសុំអភ័យទោសពីឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្ត និងមិនបានបដិសេធពីទោសរបស់ខ្លួន ភាពយន្តខ្លីៗប្រហែលជាការបង្ហាញពីភាពយុត្តិធម៌របស់សវនាការ ។ ទោះបីជា ឌុច បានព្យាយាមនិយាយលុបលាងទោសរបស់ខ្លួន ដើម្បីសម្រាលការផ្តន្ទាទោសដោយបង្ហាញពីកត្តាដែលមិនធ្ងន់ធ្ងរមួយចំនួនក៏ដោយ ប៉ុន្តែការបង្ហាញពីភាពខុសគ្នានេះតម្រូវឲ្យប្រើពេលវេលាច្រើន ហើយវាមិនមានសារសំខាន់ក្នុងការវែកញែកចេញពីការអះអាងនេះឡើយ ។


អ្នកភូមិកំពុងអានប្រវត្តិរូបរបស់ ឌុច

នៅក្នុងសវនាការបន្តបន្ទាប់ វានឹងមានការលំបាកក្នុងការស្វែងរក និងបង្ហាញខ្សែភាពយន្តខ្លីៗដែលច្បាស់ និងអាចតំណាងពីករណីរបស់ជនត្រូវចោទ ដូចជាករណីការសុំទោសរបស់ ឌុច ។ ជនត្រូវចោទដែលនឹងត្រូវកាត់ទោសត្រូវបានរំពឹងទុកថា គេនឹងអះអាងពីភាពស្លូតត្រង់របស់ខ្លួន ហើយនឹងផ្តល់ភស្តុតាងដើម្បីគាំទ្រភាពស្លូតត្រង់នោះ ។ ដោយធ្វើការរៀបចំដោយយកចិត្តទុកដាក់និងការយល់ដឹងពីសារសំខាន់ក្នុងការនិយាយពីភាពស្មើគ្នា ជនត្រូវចោទនឹងទទួលបានតំណាងដោយយុត្តិធម៌ ។ គំរូទាំងនេះក៏បានយកមកប្រើសម្រាប់ជ្រើសរើសខ្សែភាពយន្តខ្លី ដែលមានការចោទប្រកាន់ និងទស្សនៈរបស់ជនរងគ្រោះ ។

ការបញ្ចាំងខ្សែភាពយន្តនៅថ្ងៃអាទិត្យ បានរួមបញ្ចូលការរំលោភបំពានដែលកើតឡើងនៅមន្ទីរម-១៣ ។ ខ្សែភាពយន្តខ្លីនេះត្រូវបានជ្រើសរើសយកមកបង្ហាញដោយសារតែភូមិនេះមានទីតាំងនៅជិតមន្ទីរម-១៣ និងមានទំនាក់ទំនងដែលមិនអាចចៀសផុតរវាងអ្នកភូមិ និងអតីតមន្ទីរស្លូបម្ហើយនោះ ។ សម្រាប់ការបញ្ចាំងពេលខាងមុខនេះ ប្រសិនបើមានខ្សែភាពយន្តខ្លីដែលពាក់ព័ន្ធនឹងទីតាំងណាមួយដែលពាក់ព័ន្ធសវនាការ រឿងនោះគួរតែយកមកបង្ហាញនៅកន្លែងដែលពាក់ព័ន្ធនោះ ។ ការបញ្ចាំងខ្សែភាពយន្តខ្លីនេះអាចផ្តល់ភាពងាយស្រួលដល់សវនាការ និងអ្នកភូមិ ។ នៅពេលក្រុមការងារជ្រើសរើសខ្សែភាពយន្តដើម្បីបញ្ចាំង គេត្រូវតែខិតខំប្រឹងប្រែងដើម្បីធានាឲ្យមានការតំណាងដ៏មានយុត្តិធម៌អំពីសវនាការ ។ ការបញ្ចាំងខ្សែភាពយន្តទាំងនេះនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ដំណឹងដល់សាធារណជនអំពីដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ ហើយប្រតិកម្មរបស់អ្នកភូមិនឹងមានតម្លៃក្នុងការវាយតម្លៃពីភាពជោគជ័យរបស់អង្គជំនុំជម្រះ ។ មានតែតាមរយៈការបង្ហាញឲ្យមានតុល្យភាពរវាងការចោទប្រកាន់ និងទស្សនៈរបស់ជនត្រូវចោទទេ ទើបមជ្ឈមណ្ឌលឯកសារកម្ពុជាអាចទទួលបានការឆ្លុះបញ្ចាំងដ៏ស្មោះត្រង់ ច្បាស់លាស់និងមានសារប្រយោជន៍ ។ **លី សុខឃាង, ស៊ី សាទីណា និង អាដាម ខូឌី**

# សង្ខេបប្រវត្តិសាស្រ្តប្រទេសកម្ពុជា

នេះជាកិត្តិយសខ្លាំងណាស់ដែលខ្ញុំមានវត្តមាននៅទីនេះ ហើយនេះក៏ជាការខិតខំដ៏លំបាកមួយក្នុងការផ្តល់នូវប្រវត្តិសាស្រ្តកម្ពុជាដ៏យូរលង់មួយរហូតមកទល់នឹងពេលដែលកម្ពុជាទទួលបានឯករាជ្យ ដែលមានរយៈពេលពីរពាន់ឆ្នាំ ឬក៏ច្រើនជាងនេះឲ្យបានច្បាស់លាស់តែក្នុងរយៈពេលកន្លះម៉ោងនោះ ។

មនុស្សភាគច្រើន ជាពិសេសជនបរទេសតែងតែគិតទៅលើប្រវត្តិសាស្រ្តកម្ពុជាតែក្នុងអំឡុងសម័យកាលអង្គរ និងសម័យទំនើប ឬក៏ថាឲ្យច្បាស់ជាងនេះ គឺសម័យកាលអង្គរនិងសម័យកាលខ្មែរក្រហមប៉ុណ្ណោះ ។ ដូចដែលខ្ញុំចង់បង្ហាញនៅក្នុងការនិយាយដោយសង្ខេបរបស់ខ្ញុំ គឺកម្ពុជាមានប្រវត្តិជាច្រើនលើសពីអ្វីដែលបានលើកឡើងនេះទៅទៀត ។

ខ្ញុំចង់ឲ្យអ្នកទាំងអស់គ្នាយល់ថា រាល់ប្រវត្តិសាស្រ្តរបស់កម្ពុជា រាប់តាំងពីសម័យកាលដ៏យូរលង់មកហើយ រហូតមកទល់នឹងឆ្នាំ២០០៩នេះ គឺមានភាពសម្បូរសប្បាយគួរឲ្យចាប់អារម្មណ៍ និងមានលក្ខណៈបន្តបន្ទាប់គ្នាឥតដាច់ ។ អ្នកទាំងអស់គ្នាគួរតែមានមោទនភាពក្នុងនាមជាទាយាទនៃប្រវត្តិសាស្រ្តដ៏អស្ចារ្យនិងយូរអង្វែងមួយនេះ ។

និយាយរួម ខ្ញុំសូមបែងចែកប្រវត្តិសាស្រ្តដ៏យូរលង់នេះជាបួនសម័យកាល ដោយរាប់ចាប់ពីការកកើតដំបូងនៃប្រវត្តិសាស្រ្តកម្ពុជារហូតដល់ឆ្នាំ១៩៥៣ ជាពេលដែលកម្ពុជាទទួលបានឯករាជ្យពីអាណានិគមបារាំង ។ សម័យកាលនីមួយៗអាចនឹងត្រូវមើលឃើញថាមានសាច់រឿងគោលមួយឬក៏ពីរ ។

១) បុរេប្រវត្តិសាស្រ្ត ៖ សម័យហ្វូណននិងសម័យចេនឡា ។ សាច់រឿងគោល ៖ ការទទួលឥទ្ធិពលពីឥណ្ឌា, កាលបរិច្ឆេទៈ ៥០០០ឆ្នាំមុនគ.ស ដល់ឆ្នាំ៨០០នៃគ.ស ។

២) សម័យអង្គរ, សាច់រឿងគោល ៖ អំណាចរាជាធិរាជ, នគរូបនីយកម្មនិងប្រជាជនសាមញ្ញ, កាលបរិច្ឆេទៈ ឆ្នាំ៨០០ ដល់ឆ្នាំ១៤៥០នៃគ.ស ។

៣) សម័យកណ្តាល, សាច់រឿងគោល ៖ បរិវត្តន៍, ការដាច់ឆ្ងាយពីពិភពខាងក្រៅ និងការគាបសង្កត់ពីពិភពខាងក្រៅ, កាលបរិច្ឆេទ ៖ ឆ្នាំ១៤៥០ ដល់ឆ្នាំ១៨៦៣នៃគ.ស ។

៤) សម័យអាណានិគម, សាច់រឿងគោលៈ សង្គមកម្ពុជាចាប់ផ្តើមបើកចំហទៅពិភពខាងក្រៅច្រើនជាងមុន, កាលបរិច្ឆេទៈ ឆ្នាំ១៨៦៣ ដល់ឆ្នាំ១៩៥៣ ។

## បុរេប្រវត្តិសាស្រ្ត ៖ សម័យហ្វូណន និងសម័យចេនឡា

យើងមានភស្តុតាងបញ្ជាក់ថា មានមនុស្សរស់នៅក្នុងរូងថ្មនៅភាគពាយព្យនៃប្រទេសកម្ពុជាជាយូរលង់ណាស់មកហើយ គឺ



លោក ឆាំង យុ ដឹកនាំសាស្រ្តាចារ្យ និងគ្រូបង្គោលថ្នាក់ជាតិចូលជួបសម្តែងការគួ

ចាប់ពី៥០០០ឆ្នាំ មុនគ្រិស្តសករាជមកម្ល៉េះ ។ មនុស្សទាំងនោះស្ថិតនៅក្នុងយុគសម័យមួយដែលបានរស់នៅជាច្រើនកន្លែង ហើយរហូតមកដល់សព្វថ្ងៃនេះ កន្លែងជាច្រើននៃសម័យកាលនោះទើបនឹងត្រូវជីកកកាយដើម្បីសិក្សា ។ មកដល់១០០០ឆ្នាំ មុនគ.ស មនុស្សរស់នៅតំបន់ដែលបច្ចុប្បន្នស្ថិតនៅជិតខេត្តកំពង់ឆ្នាំងបានប្រើប្រាស់ស្ពាន់ធ្វើជារបស់របរប្រើប្រាស់ (របស់របរល្អៗ

ជាច្រើនរបស់ក្រុមមនុស្សទាំងនេះមានតាំងនៅសារមន្ទីរជាតិ) ។ របស់របរប្រើប្រាស់ ឧបករណ៍លម្អផ្សេងៗ និងអាវុធមានលក្ខណៈប្រហាក់ប្រហែលនឹងវត្ថុដែលគេរកឃើញនៅទីតាំងដែលស្គាល់ថាជា "យុគសម័យស្ពាន់" ស្ថិតនៅភាគឦសាននៃប្រទេសថៃ ។ ប៉ុន្តែវាមិនមែនមានន័យថា ជនជាតិដើមរបស់កម្ពុជាជាថៃនោះទេ ។ ត្រូវចងចាំថា ពុំមានព្រំដែនរវាងប្រទេសនីមួយៗនៅអាស៊ីអាគ្នេយ៍ទេរហូតមកដល់សម័យកាលអាណានិគម ។ ដូច្នេះ ក្រុមមនុស្សដើមដែលបច្ចុប្បន្នស្ថិតនៅភាគឦសាននៃប្រទេសថៃប្រហែលនៅប្រើប្រាស់ភាសាខ្មែរនៅឡើយ ឬក៏ថាភាសាដែលស្រដៀងនឹងភាសាខ្មែរ ។ មនុស្សទាំងនោះធ្វើស្រែនិងបរិភោគត្រីជាអាហារ ដូច្នេះរបបអាហារសំខាន់ដែលប្រជាជនកម្ពុជារស់


ក្ខរសមជាមួយ ឯកឧត្តម អ៊ឹម សុីទ្ធី

នៅតាមជនបទក្នុងឆ្នាំ២០០៩នេះ គឺដូចគ្នានឹងរបបអាហារដែលមនុស្សបរិភោគកាលពី១០០០ឆ្នាំមុនគ.សដែរ ។ នេះអាចបង្ហាញអំពីទំនាក់ទំនងគ្មានដាច់នៃប្រវត្តិសាស្ត្រកម្ពុជាមួយ ។

ព្រឹត្តិការណ៍នេះ ខ្ញុំឲ្យឈ្មោះថា "ការទទួលឥទ្ធិពលពីឥណ្ឌា" ដែលខ្ញុំបានជ្រើសជាសាច់រឿងគោលនៃសម័យកាលនេះ ។ សម័យកាលនេះទើបតែកត់ត្រាឡើងនៅប៉ុន្មានឆ្នាំដំបូងនៃសម័យកាលគ្រិស្តសាសនាប៉ុណ្ណោះ ដែលគ្រឿងអលង្ការនិងរបស់របរប្រើប្រាស់របស់ប្រជាជនឥណ្ឌាត្រូវបានរកឃើញនៅតាមតំបន់ឆ្នេរដែលសម្បូរទៅដោយអ្នកប្រាជ្ញជាច្រើន ។ សម័យកាលនោះហើយ ដែលជនជាតិចិនហៅថាសម័យហ្វូណន ។

ហ្វូណន ជារដ្ឋពាណិជ្ជកម្មដ៏សំខាន់មួយ ដោយសារជាទីតាំងសម្បូរទៅដោយទំនាក់ទំនងផ្លូវទឹកជាច្រើនដែលអាចផ្តល់កម្លាំងពលកម្មដ៏មហិមានៅពេលដែលមានតម្រូវការ ។ ប៉ុន្តែ ជាអកុសលពុំមានឯកសារសំណេរណាមួយនៅសេសសល់ទេ បន្ទាប់ពីសម័យកាលនោះ ។ ព័ត៌មានទាំងឡាយអំពីសម័យកាលនោះបានមកពីកំណាយជាច្រើននៃក្រុមបុរាណវិទូ និងឯកសារជាច្រើនទៀតបានមកពីប្រទេសចិន ដែលត្រូវបានចងក្រងឡើងរាប់រយឆ្នាំមកហើយ ។ ក្រោយមកទៀត ការសិក្សាគឺមានសារប្រយោជន៍ណាស់ ដោយគេចាប់ផ្តើមមើលទៅលើសភាពប្រែប្រួលនៃសម័យហ្វូណន ដោយសារអ្នកគ្រប់គ្រងនៃសម័យកាលនេះបានជ្រើសយកភាសា វប្បធម៌ និងលក្ខណៈធ្វើកិច្ចការរដ្ឋបាលពីប្រទេសឥណ្ឌា ប្រកបដោយដំណើរការដ៏ប្រសើរ និងស្មុគស្មាញមួយ ដែលយើងឲ្យឈ្មោះថា ការទទួលឥទ្ធិពលពីឥណ្ឌា ។

ការទទួលឥទ្ធិពលពីឥណ្ឌានេះមិនមែនមានន័យថា ប្រទេសកម្ពុជាបានធ្លាក់ក្នុងអាណានិគមឥណ្ឌានោះទេ ប៉ុន្តែជាជម្រើសមួយដែលក្រុមវរជននៅសម័យនោះបានយកមកប្រើប្រាស់នៅពេលដែលពួកគេបានប្រទះនឹងវប្បធម៌របស់ឥណ្ឌានៅប្រទេសឥណ្ឌាដូចជាអ្នកកាន់សាសនាឬតាមរយៈការធ្វើពាណិជ្ជកម្ម ឬនៅប្រទេសកម្ពុជា (ហ្វូណន) តាមរយៈអ្នកធ្វើជំនួញឥណ្ឌា អ្នកធ្វើការនិងអ្នកដឹកនាំសាសនាជាដើម ។ ដំណើរការនៃការទទួលឥទ្ធិពលនេះកើតឡើងនៅចន្លោះ៥០០ឆ្នាំមុនគ.ស និង៥០០ឆ្នាំក្រោយគ.ស ឬមុននិងក្រោយបន្តិច ដែលដំណើរការនេះពុំត្រូវបានកត់ត្រាឡើងឡើយ ។ ដំណើរការនេះកើតឡើងដោយសារទំនាក់ទំនងពាណិជ្ជកម្មជាមួយកម្ពុជាដែលបានលក់ផលិតផលដ៏កម្រពីព្រៃឈើ ហើយឥណ្ឌាទិញយកផលិតផលទាំងនេះ ដើម្បីផលិតរបស់របរជាច្រើន ជាពិសេសផលិតគ្រឿងក្រអូបផ្សេងៗ ។ ឥទ្ធិពលវប្បធម៌ឥណ្ឌាដែលកម្ពុជាទទួលខ្លាំងបំផុតនោះគឺអាទិទេព (ដែលមានប្រជាប្រិយភាពខុសៗគ្នា) និងគំនិតនៃការរៀបចំការគ្រប់គ្រង ។

ប៉ុន្តែ ខ្មែរពុំដែលយករបៀបបែងចែកវណ្ណៈដែលមានមកពីឥណ្ឌាមកអនុវត្តន៍ទេ។ នៅពេលដែល «ខ្មែរ» បានក្លាយទៅជាភាសាសរសេរនៅប្រហែល៣០០ឆ្នាំក្រោយគ.សនោះ តួអក្សរឥណ្ឌាត្រូវបានកែសម្រួលសម្រាប់ជាព្យញ្ជនៈនៃភាសាថ្មីនេះ ។ ការទទួលឥទ្ធិពលពីឥណ្ឌាមិនមែនជាលើកដំបូង ហើយក៏មិនមែនជាលើកចុងក្រោយដែរចំពោះលក្ខណៈលាយឡំនិងការយកលំនាំតាមវប្បធម៌ផ្សេងៗបង្កើតជាប្រវត្តិសាស្ត្រវប្បធម៌មួយសម្រាប់ប្រទេសនេះ ។ ចំណុចសំខាន់នោះគឺថា ការទទួលឥទ្ធិពលពីឥណ្ឌានេះមិនមែនជាការដាក់ការគ្រប់គ្រងឬអាណានិគមដូចករណីចិនធ្វើមកលើវៀតណាមខាងជើងនោះទេ ។

នៅសតវត្សរ៍៨និង៩ ក្រោយគ.ស ទីតាំងរដ្ឋបាលសំខាន់បានប្តូរពីតំបន់ឆ្នេរនៅលើដីនៃអាណាចក្រហ្វូណនទៅភាគខាងត្បូងនៃកម្ពុជា ដោយមានទីក្រុងមួយដែលបច្ចុប្បន្នជាភូមិមួយនៅស្រុកអង្គរបុរី ។ «ចេនឡា» ជាឈ្មោះដែលចិនបានដាក់ឲ្យអាណាចក្រនេះ ។ រាជធានីនៃចេនឡាប្រហែលជា «ឥសានាកុរា» ឬស្គាល់ថាសម្បូរព្រៃគុហ៍នៅខេត្តកំពង់ធំ ។ នៅអំឡុងរយៈពេលប៉ុន្មានឆ្នាំនោះហើយដែលមានការចារឹកជាភាសាខ្មែរនិងសំស្ក្រឹតនៅលើផ្ទាំងថ្មជាលើកដំបូង និងចាប់ផ្តើមមានការរៀបចំចងក្រងឯកសារស្តីអំពីប្រវត្តិនិងសង្គមរបស់កម្ពុជា ។ កិច្ចការដ៏មានសារប្រយោជន៍របស់លោក ម៉ៃខល វីឃើរី ដែលសិក្សាលើសិលាចារឹកទាំងនេះត្រូវបានបង្ហាញឡើងនៅក្នុងឆ្នាំ២០០៥ ហើយបានផ្លាស់ប្តូរការយល់ដឹងរបស់យើងចំពោះប្រវត្តិសាស្ត្រនៅប៉ុន្មានឆ្នាំចុងក្រោយនៃសម័យកាលនេះ ។

អ្នករាល់គ្នាតែងតែនឹកឃើញដល់អង្គរជារៀងរាល់ថ្ងៃដូចជានៅពេលដែលអ្នកឃើញទង់ជាតិកម្ពុជា ពូក្លែងជាតិ ឬឈ្មោះហាងទំនិញជាច្រើន ។ អ្នកក៏អាចឃើញកំពូលដែលមានលក្ខណៈស្រដៀងនឹងអង្គរចេញពីវិមានឯករាជ្យ ។ ភាគច្រើននៃអ្នកទាំងអស់គ្នាសុទ្ធសឹងតែបានទៅទស្សនាអង្គរ ឬថា អ្នកខ្លះថែមទាំងបានទស្សនាជាច្រើនលើកទៀតផង ។ អង្គរ គឺជាមណ្ឌលទេសចរណ៍ដ៏គួរឲ្យស្ញប់ស្ញែងសម្រាប់អ្នកទេសចរណ៍ដែលមកទស្សនាប្រមាណជាង១លាននាក់ក្នុងមួយឆ្នាំ ប៉ុន្តែសម្រាប់អ្នកដែលជាជនជាតិខ្មែរវិញនោះ អង្គរគឺជាអ្វីដែលខុសពីអ្នកទេសចរណ៍បរទេសទាំងនេះ ៖ អង្គរជាទីរំឭកដ៏ស្អាតអស្ចារ្យនៃភាពជោគជ័យរបស់បុព្វបុរសខ្មែរ ផ្នែកសិល្បៈ និងស្ថាបត្យកម្ម ការរៀបចំទីក្រុង ការធ្វើផ្លូវថ្នល់ និងវិស្វកម្មដោយប្រើប្រាស់កម្លាំងទឹក ដែលនេះគ្រាន់តែការរៀបរាប់ត្រួសៗប៉ុណ្ណោះ ។

ជាច្រើនឆ្នាំមកហើយ បុរាណវិទ្យានៅកម្ពុជាដែលគ្រប់គ្រងដោយបារាំងនោះបានសិក្សាតែអំពីព្រះរាជា ប្រាសាទ និងសិលាចារឹកដែលគេរកឃើញនៅអង្គរ ដើម្បីបង្កើតជារូបភាពមួយ និងកាលបរិច្ឆេទនៃរាជាណាចក្រប៉ុណ្ណោះ ។ ការសិក្សានោះបានឲ្យឈ្មោះស្តេចចំនួន២៦អង្គដែលធាតុរបស់ស្តេចទាំងនោះមានតម្កល់នៅប្រាសាទជាងមួយពាន់ និងបកប្រែសិលាចារឹកដែលសរសេរជាភាសាខ្មែរ និងសំស្ក្រឹតមានចំនួនជាងមួយពាន់សិលាចារឹក ។ ក្នុងការស្ថាបនាឡើងវិញនូវប្រាសាទសំខាន់ៗជាច្រើននៅអង្គរ ជនជាតិបារាំងបានសិក្សាអំពីសាសនាកម្ពុជា និងមួយចំនួនទៀតលើការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនដែលបានពីគូទឹកនៃប្រាសាទបាយ័ន ។

សិលាចារឹកទាំងនោះបង្ហាញអំពីការព្រួយបារម្ភរបស់ស្តេច (ជាទូទៅមានលក្ខណៈថ្លៃថ្នូរនិងសរសេរជាភាសាសំស្ក្រឹត) និងមួយចំនួនទៀតស្តីអំពីកិច្ចការរដ្ឋបាលអាណាចក្រ បើឲ្យច្បាស់ជាងនេះ កិច្ចការរដ្ឋបាលទាំងនេះគឺមានទំនាក់ទំនងទៅនឹងប្រាសាទដែលសាងសង់ឡើងដោយស្តេចឬសមាជិកដ៏មានឥទ្ធិពលមួយរូបនៅក្នុងថ្នាក់ដឹកនាំជាន់ខ្ពស់ ។

អ្នកសិក្សាទាំងនោះបានផ្តល់នូវការស្វែងយល់អំពីប្រាសាទនិងអ្វីៗទាំងអស់ពីការស្រាវជ្រាវរបស់ខ្លួនទៅពិភពលោកក្នុងនាមជាអំណោយមួយ ហើយពួកគេផ្តល់អំណោយមួយទៀតសម្រាប់ប្រជាជនកម្ពុជា ។

ប៉ុន្តែអ្វីដែលការខិតខំរបស់ជនជាតិបារាំងបានមើលរំលងនោះ គឺការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនសាមញ្ញនៅអង្គរដែលជាបុព្វបុរសរបស់អ្នកទាំងអស់គ្នាពុំមានការកត់ត្រាជាប្រវត្តិសាស្ត្រនូវជីវភាពនៃមនុស្សប្រុសស្រីរាប់រយរាប់ពាន់រូបដែលធ្វើស្រែ ចិញ្ចឹមបីបាច់គ្រួសារ ប្រយុទ្ធនៅក្នុងសង្គ្រាមដើម្បីអាណាចក្ររបស់ខ្លួន និងសាងសង់ប្រាសាទជាច្រើន។ បារាំងមើលឃើញអង្គរថាជាការតស៊ូមួយ ជាការប្រមូលនៃសម្រស់ដែលខូចខាត

ជាច្រើន និងជាទីតាំងសម្រាប់ប្រវត្តិសាស្ត្រជាតិនិយមដែលលាតសន្ធឹងក្នុងរយៈពេល៦០០ឆ្នាំ ។

រយៈពេលប្រមាណ៥០ក្រោយនេះ មានការផ្លាស់ប្តូរមួយចំនួនដែលទាក់ទងនឹងការគិតរបស់យើងចំពោះអង្គរ និងប្រវត្តិសាស្ត្រដើមនៃកម្ពុជា ។ ការគាស់កកាយលំនៅឋានចាស់ៗនៅសម័យមុនអង្គរ និងទីតាំងកប់សាកសពមួយចំនួនបានបង្ហាញអំពីភាពស្មុគស្មាញនៃជីវិតរបស់ប្រជាជនសាមញ្ញ ។ ការធ្វើផែនទីនៃតំបន់អង្គរក៏ត្រូវបានគេប្រែក្លាយទៅជាសិល្បៈមួយដោយប្រើប្រាស់រូបភាពពីប្រព័ន្ធផ្កាយរណប ដើម្បីស្វែងរកវាលស្រែល្វឹងល្វើយ ប្រឡាយទឹក និងផ្លូវជាច្រើននៅអង្គរ ។ វាបានបង្ហាញថាអង្គរធ្លាប់ជាទីក្រុងដ៏ធំនិងកុះករមួយដែលផ្តល់ទីលំនៅដល់ប្រជាជនប្រមាណ៧០០.០០០នាក់នៅសតវត្សរ៍ទី១២ ជាពេលដែលអង្គរវត្តកំពុងត្រូវបានសាងសង់ឡើង ។

ឈ្មោះរបស់ទីក្រុងនេះគឺឥសានបុរៈ ។ ការពិតទៅ យើងដឹងច្រើនជាងអ្វីដែលយើងធ្លាប់បានដឹងអំពីទីក្រុងនេះចំពោះទម្រង់លំនៅឋាន ផ្លូវនានារបស់របរប្រើប្រាស់ ភាជន៍ និងប្រឡាយទឹកជាច្រើនទៀត ។ បុព្វបុរសប្រុសស្រីទាំងនោះបច្ចុប្បន្នបានលេចឡើងក្នុងនាមជាអ្នកស្រុកប្រកបដោយការច្នៃប្រឌិតនិងរស់រវើកនៃទីក្រុងដ៏ធំស្មុគស្មាញ និងគួរឲ្យចាប់អារម្មណ៍មួយ ទោះបីជាអ្នកទាំងនោះត្រូវបានចារនៅលើសិលាចារឹកក្នុងនាមជាទាសករក៏ដោយ ។ ក្រៅពីនោះ បុព្វបុរសទាំងនេះហើយដែលជាសិល្បករ និងស្ថាបត្យករដ៏អស្ចារ្យដែលយើងទាំងអស់គ្នាតែងតែស្គាល់ ។ ហើយអ្នកទាំងនេះគឺជាមនុស្សរបស់អ្នក ។

ទន្ទឹមនឹងនេះដែរ ការសិក្សាតាមបែបបុរាណនៃបុរាណវិទ្យាចំពោះស្តេច ប្រាសាទ និងសិលាចារឹករបស់រាជាទាំងនេះបានផ្តល់នូវព័ត៌មានថ្មីៗជាច្រើននៅរជ្ជកាលស្តេចជ័យវរ្ម័នទី៧ អត្ថន័យនៃអង្គរវត្តតាមលក្ខណៈតារាសាស្ត្រនិងប្រសគល់និងដែនកំណត់នៃការធ្វើពាណិជ្ជកម្មអន្តរជាតិ ។ នៅឆ្នាំ២០០៩នេះ យើងគ្រប់គ្នាបានដឹងអំពីប្រវត្តិសាស្ត្រច្រើនបំផុតលើអ្វីដែលយើងធ្លាប់ដឹងក៏ដូចជាជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សប្រុសស្រីនិងទីលំនៅរបស់បុព្វបុរសទាំងនេះ ដែលមានប្រមាណ១០០០គីឡូម៉ែត្រការ៉េ ។ ផុយពីការយល់ឃើញថាជាអាថ៌កំបាំងដ៏មហិមាមួយ អង្គរគឺបានក្លាយទៅជាការរួមផ្សំនៃអាណាចក្រដ៏អស្ចារ្យមួយ និងស្នាដៃនៃបុព្វបុរសដែលភាសា ការរស់នៅ និងអត្តចរិត ដែលអ្នកទាំងអស់គ្នាយល់ថាគួរឲ្យចូលចិត្តនិងងាយស្រួលយល់ ។

**សម័យកណ្តាល ៖ ការផ្លាស់ប្តូរ និង ការរងសម្ពាធពីខាងក្រៅ**

មិនមានឯកសារណាមួយនៅសេសសល់ដើម្បីប្រាប់យើងអំពីពេលវេលានិងមូលហេតុដែលនាំអង្គរធ្លាក់ចុះពីទីក្រុងដ៏អស្ចារ្យមួយនាក្រោយសតវត្សរ៍ទី១៥ទេ ហើយដំណាក់កាលនេះពិតជាមានភាពស្មុគស្មាញណាស់ ដោយលាតសន្ធឹងរាប់រយឆ្នាំ ប៉ុន្តែបំលាស់ប្តូរនានាបានកើតឡើងរួចទៅហើយ នៅក្នុងសង្គមខ្មែរជាច្រើនសតវត្សរ៍មុនរាជធានី យសោធបុរៈ (មិនមែនអង្គរវត្តទេ) ត្រូវបានបោះបង់ចោល ។

ចំណុចសំខាន់បំផុតនៃបម្រែបម្រួលនេះគឺថា សង្គមកម្ពុជាដ៏ធំមួយបានផ្លាស់ប្តូរដោយការប្រែក្លាយទៅជាអ្នកកាន់និកាយពុទ្ធសាសនាថេរវាទ ដែលប្រជាជនកម្ពុជាប្រណិប័តន៍ជាទូទៅនាពេលបច្ចុប្បន្ន ។ ការផ្លាស់ប្តូរនូវការប្រណិប័តន៍សាសនានេះប្រហែលជាកើតឡើងនៅសតវត្សរ៍ទី១៣ ព្រោះនៅពេលដែលអ្នកការទូតចិនម្នាក់មកធ្វើទស្សនកិច្ចរដ្ឋធានី យសោធរបុរៈនៅក្នុងឆ្នាំ១២៩៦ ប្រជាពលរដ្ឋបានកំពុងតែប្រណិប័តន៍ព្រះពុទ្ធសាសនារួចទៅហើយ ។ បំលាស់ប្តូរនេះធ្វើឲ្យកម្ពុជាមានភាពស្រដៀងគ្នាទៅនឹងប្រទេសមួយដែលប្រតិបត្តិព្រះពុទ្ធសាសនាដូចគ្នានៅអំឡុងពេលជាមួយគ្នាដែរ នោះគឺប្រទេសជិតខាងសៀម ហើយពីរបីរយឆ្នាំក្រោយមកឃើញមានការទទួលឥទ្ធិពលវប្បធម៌ពីគ្នាទៅវិញទៅមករវាងប្រទេសទាំងពីរនេះ ។ ជាអកុសលសម្រាប់កម្ពុជា នៅក្នុងសតវត្សរ៍ទី១៦ ប្រទេសសៀមក្លាយទៅជាមានឥទ្ធិពលមួយ ហើយទទួលស្នួយសារអាករពីជនជាតិខ្មែរ ហើយបានបន្តធ្វើរហូតដល់ពេលបារាំងមកដល់ឆ្នាំ១៨៦៣ ។ ប្រជាជនកម្ពុជាមិនបានចាញ់គ្រប់សង្គ្រាមទាំងអស់ដែលបានច្បាំងជាមួយសៀមទេ ហើយចំណុចមួយដែលកម្ពុជាបានចាញ់គឺការបាត់បង់ចំនួនប្រជាជនយ៉ាងច្រើនសន្ធឹកសន្ធាប់នៅពេលដែលសៀមចាប់ជនជាតិខ្មែរជាឈ្លើយសឹក ។ ព្រឹត្តិការណ៍ដ៏សំខាន់នៅសម័យកណ្តាលគឺការរួញទឹកដីក្រោមការគ្រប់គ្រងដោយស្តេចខ្មែរមួយអង្គ ព្រមទាំងការបាត់បង់ប្រជាជនកម្ពុជាផង ។

បញ្ហាមួយទៀតសម្រាប់ប្រទេសកម្ពុជានៅក្នុងសម័យកណ្តាលគឺការលេចចេញជារូបរាងឡើងនូវប្រទេសជិតខាងដ៏មានឥទ្ធិពលមួយនៅប៉ែកខាងកើត ។ មកដល់សតវត្សរ៍ទី១៧ មេដឹកនាំត្រកូល ង្វៀន របស់វៀតណាមខាងត្បូងបានធ្វើឲ្យមានការបែកបាក់ក្នុងព្រះរាជវាំងរវាងអ្នកដែលធ្លាប់យកប្រទេសសៀមជាមេ និងអ្នកដែលត្រូវគ្នាជាមួយនឹងវៀតណាម ។ វៀតណាមក៏បានបិទប្រកដូវទៅកាន់កំពង់ផែសមុទ្រ ហើយប្រហែលជាឆ្នាំ១៦៥០ ដល់១៨៥០ ព្រះរាជាណាចក្រនេះបានស្ថិតនៅក្នុងភាពឯកោពីពិភពខាងក្រៅ ហើយមានជំនួញដូញដូរជាមួយអន្តរជាតិយ៉ាងតិចតួចបំផុត ។

ទោះជាយ៉ាងនេះក្តី មិនអាចនិយាយបានថាស្ថានភាពកម្ពុជាឋិតនៅក្នុងសភាពរងគ្រោះនិងហិនហោចនោះទេ ។ សម័យនេះហើយដែលសមិទ្ធផលអក្សរសាស្ត្រខ្មែរមួយចំនួនបានផុសត្រដែតឡើងដូចជាច្បាប់នានានិងរឿងរាមកេរ្តិ៍ជាដើម ហើយសម័យនេះហើយដែលបានផ្សារភ្ជាប់អរិយធម៌អង្គរទៅនឹងសង្គមមួយដែលបារាំងបានជួបប្រទះពេលមកដល់ប្រទេសនេះដំបូងនៅឆ្នាំ១៨៦០ ។ ការផ្សារភ្ជាប់រវាងអង្គរ និងសម័យអាណានិគមរួមមានវប្បធម៌ដ៏ត្រចះត្រចង់របស់ខ្មែរ ភាសាដែលពោរពេញទៅដោយភាពសម្បូរបែបនិងភាពត្រចះត្រចង់នៃការរៀបចំសង្គម ។ ម្យ៉ាងវិញទៀត ជនជាតិខ្មែរគឺជាអ្នកទទួលមរតកនៃសម័យកាលនេះប្រហែលជាច្រើនជាងសម័យអង្គរ ឬសម័យអាណានិគមទៅទៀត ។

## សម័យអាណានិគម ៖ កម្ពុជាចូលរួមជាមួយពិភពខាងក្រៅច្រើនជាងមុន

នៅពេលដែលអ្នករុករកជាតិបារាំងមកដល់ទឹកដីកម្ពុជានៅទសវត្សរ៍៦០ ជាតិបារាំងទាំងនោះកំពុងតែរុករកទីតាំងដើម្បីពង្រីកផលប្រយោជន៍ពាណិជ្ជកម្មរបស់ខ្លួននៅអាស៊ីអាគ្នេយ៍ ហើយពួកគេមានជំនឿថា កម្ពុជា ឬ ប្រហែលជាទន្លេមេគង្គគឺជាទ្វារទឹកដ៏សំខាន់ទៅកាន់ប្រទេសចិន ។ នៅពេលនោះ បារាំងបានកាន់កាប់វៀតណាមខាងត្បូងជាអាណានិគមរួចទៅហើយ ហើយមានបំណងចង់ពង្រីកការគ្រប់គ្រងលើទឹកដីអាស៊ីអាគ្នេយ៍ទាំងមូល ។

សង្គ្រាមស៊ីវិល អំពើបះបោរ ការឈ្លានពានពីសំណាក់សៀមនិងការឋិតនៅក្រោមអាណាព្យាបាលរបស់វៀតណាមអស់រយៈពេលដ៏យូរអង្វែងបានរឹតរួមប្រទេសកម្ពុជាអស់រយៈពេល៥០ឆ្នាំ ។ កងទ័ពថៃនិងវៀតណាមបានប្រយុទ្ធគ្នានៅលើទឹកដីកម្ពុជា ហើយសង្គ្រាមនេះបានបង្កវិនាសកម្មដល់ប្រទេសកម្ពុជា ។ ប្រជាជនកម្ពុជាបានបាត់បង់ជីវិតនិងចាប់ជាឈ្លើយសឹកអស់យ៉ាងច្រើនសន្ធឹកសន្ធាប់ វត្តអារាមជាច្រើនត្រូវបានបំផ្លាញ ហើយព្រះរាជាដែលទើបតែទទួលបានរាជបល្ល័ង្កថ្មីគឺព្រះបាទនរោត្តម ដែលធ្លាប់តែខ្ចបខ្ចាចសៀមបានស្វែងរកការការពារពីបារាំង (ឬបើជាក់ច្បាស់ជាងនេះទៅទៀត ព្រះអង្គបានទទួលយកនូវអ្វីដែលបារាំងបានដាក់អាណាព្យាបាល) ។ បារាំងមានការពេញចិត្តនិងដាក់ប្រទេសកម្ពុជាជាអាណាព្យាបាល ប៉ុន្តែព្រះបាទនរោត្តមមានការភ្ញាក់ផ្អើលហើយមិនពេញចិត្តត្រង់ថា បារាំងបានគ្រប់គ្រងវិស័យសេដ្ឋកិច្ចនិងនយោបាយប្រមាណជា៣០ឆ្នាំក្រោយមក ។ ព្រះមហាក្សត្រក្លាយជាបុគ្គលដែលគ្មានសារសំខាន់ ។ ទោះបីប្រទេសកម្ពុជាមានឈ្មោះជាផ្លូវការថាក្រោមអាណាព្យាបាលបារាំង ហើយមានព្រះមហាក្សត្រដឹកនាំក៏ដោយ មកដល់ចុងសតវត្សរ៍ទី១៩ ប្រទេសបារាំងបានដាក់ប្រទេសកម្ពុជាជាអាណានិគមរួចទៅហើយ ហើយបារាំងដែលបានសាងវិមានសម្រាប់ខ្លួនឯង និងបានតាំងខ្លួនឯងជាអ្នកដែលដើរតួយ៉ាងសំខាន់ក្នុងការសម្រេចកិច្ចការសំខាន់ៗនៅប្រទេសកម្ពុជា ហើយបារាំងជាអ្នកលើកបន្តុបព្រះមហាក្សត្រខ្មែរបីអង្គទៀតនាដំណាក់កាលក្រោយមក ។

ដើម្បីថ្លឹងថ្លែងមើលអំពីគុណភាពនៃអាណានិគមនិយមបារាំងនៅប្រទេសកម្ពុជា ជាការសំខាន់ណាស់ដែលត្រូវកំណត់ចំណាំថា បារាំងបានរួមចំណែកក្នុងការកសាងជាច្រើនផងដែរ (ដោយការប្រើប្រាស់ពលករខ្មែរដើម្បីស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ ការរៀបចំទីក្រុង និងការស្រាវជ្រាវផ្នែកបុរាណវិទ្យា) ។

ខេត្តបាត់ដំបងនិងសៀមរាបគឺជាខេត្តចំណុះរបស់សៀមក្នុងឆ្នាំ១៧៩០ ហើយត្រូវបានប្រគល់ឲ្យកម្ពុជាវិញក្រោយពីបារាំងដាក់សម្ពាធទៅលើថៃ ។ ទឹកដីអង្គរត្រូវបានកាន់កាប់ដោយខ្មែរឡើងវិញ ដូច្នេះបុរាណវិទូបារាំងអាចចាប់ផ្តើមធ្វើការដោយប្រើប្រាស់កម្មករខ្មែរក្នុងកិច្ចការជួលជុលប្រាសាទបុរាណឡើង

វិញ ។

មានចំណុចអវិជ្ជមានខ្លះនៃរបបអាណានិគមដែលខ្ញុំនឹងលើកមកពិភាក្សានៅពេលបន្តិចទៀតនេះ ។ ខ្ញុំគិតថា បើយើងមើលពីឆ្នាំ២០០៩នេះថយទៅក្រោយ យើងអាចនិយាយបានថា បារាំងមិនបានបំផ្លិចបំផ្លាញកម្ពុជាច្រើនដូចអ្វីដែលបានខូចខាតដោយឥទ្ធិពលបរទេសក្នុងអំឡុងសង្គ្រាមវៀតណាម និងអំឡុងសង្គ្រាមរវាងខ្មែរនិងខ្មែរ ខ្មែរនិងបរទេស ក្រោយមកទៀត ឬក្រោមរបបខ្មែរក្រហមទេ ។ ជាមួយគ្នានោះដែរ សម័យអាណានិគមបានបន្សល់នូវទិដ្ឋភាពអវិជ្ជមានច្រើនផងដែរ ហើយទិដ្ឋភាពខ្លះបានបន្តមកដល់ឆ្នាំ២០០៩នេះទៀត ។

ប្រហែលជាចំណុចអវិជ្ជមានដ៏សំខាន់មួយគឺថា អាណាព្យាបាលបារាំងមិនបានអប់រំបណ្តុះបណ្តាលប្រជាជនកម្ពុជា ហើយមិនបានផ្តល់ឱកាសដល់ប្រជាជនកម្ពុជាក្នុងការចូលរួមក្នុងឆាកនយោបាយនានាដំណាក់កាលមុនឆ្នាំ១៩៤០ ។ បារាំងបានរៀបចំប្រទេសក្នុងសភាពមិនបានល្អទេ ។ រហូតមកដល់សម័យសង្គ្រាមលោកលើកទី២ ទូទាំងប្រទេសទាំងមូលមានវិទ្យាល័យតែមួយគត់ ហើយគ្មានមហាវិទ្យាល័យទេ ។

ចំណុចដែលមើលទៅមានភាពខ្វះខាតនៅក្នុងសម័យអាណានិគមដែរនោះគឺប្រព័ន្ធតុលាការ ។ បារាំងមិនបានកំណត់ប្រព័ន្ធយុត្តិធម៌ច្បាស់លាស់ទេ ហើយសឹងតែគ្មានមេធាវីនិងចៅក្រមជាជនជាតិខ្មែរដែលទទួលនូវការបណ្តុះបណ្តាលផ្នែកច្បាប់គ្រប់គ្រាន់ផង ។

ទោះជាយ៉ាងណា បារាំងបានរួមចំណែកផ្តល់នូវផលវិជ្ជមានដល់កម្ពុជាផងដែរ ដូចជាកម្ពុជាបានរួចរស់ជីវិត ហើយបានក្លាយជារដ្ឋមួយឯករាជ្យ ដោយគ្មានការជ្រៀតជ្រែកពីសំណាក់ប្រទេសជិតខាងដែលមើលទៅដូចជាមានសភាពទន់ជ្រាយណាស់ទៅហើយ មុននឹងបារាំងមកដល់ ។ បារាំងក៏មិនបានជួយខ្មែរឲ្យច្រើនដូចអ្វីដែលខ្លួនបានបង្កើនអំណាច និងឥទ្ធិពលរបស់ខ្លួនទេ ។

ក្នុងឆ្នាំ១៩៧៥ អ្នកនាំពាក្យខ្មែរក្រហមម្នាក់បានប្រកាសដោយមោទនភាពថា «២០០០ឆ្នាំ» នៃប្រវត្តិសាស្ត្រកម្ពុជាបានមកដល់ទីបញ្ចប់ ។ ខ្ញុំសង្ឃឹមថា ខ្ញុំបានបកស្រាយយ៉ាងច្បាស់នៅក្នុងសេចក្តីថ្លែងការណ៍សង្ខេបមួយនេះ ដោយមិនត្រឹមតែបានរៀបរាប់ប្រវត្តិកម្ពុជាត្រឡប់ទៅលើស២០០០ឆ្នាំប៉ុណ្ណោះទេ ថែមទាំងបានសិក្សាអំពីកម្ពុជា ដែលពិតជារឿងគួរឲ្យចាប់អារម្មណ៍ ហើយដែលជនជាតិកម្ពុជាមានមោទនភាពផង ។

**ដេវីដ ឆេនល័រ**



បណ្ឌិត ឆាត កុសល និង សាស្ត្រាចារ្យ ដេវីដ ឆេនល័រ

# យុត្តិធម៌ដែលមិនបង្ហាញឱ្យឃើញ ៖ ការសម្ងាត់នៃការស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

៣០ឆ្នាំមុនគឺជាការបញ្ចប់នៃរបបខ្មែរក្រហមដ៏ឃោរឃៅ ដែលបានសម្លាប់មនុស្សប្រមាណ១,៧លាននាក់ ។ សម្រាប់មនុស្សជាច្រើន របួសនោះហាក់ដូចជានៅថ្មីៗ ហើយដំណើរការព្យាបាលទើបតែចាប់ផ្តើមខណៈពេលជនដែលដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មកំពុងតែប្រឈមមុខនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលទទួលខុសត្រូវក្នុងការកាត់ទោសឧក្រិដ្ឋកម្មកម្រិតធ្ងន់ដែលបានប្រព្រឹត្តនៅក្នុងរបបខ្មែរក្រហមតាមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា ។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះត្រូវបានបង្កើតឡើងដោយច្បាប់កម្ពុជា ហើយត្រូវបានចាត់ទុកថាជាផ្នែកមួយនៃប្រព័ន្ធតុលាការកម្ពុជាដែលទទួលឥទ្ធិពលយ៉ាងខ្លាំងពីប្រព័ន្ធច្បាប់ស៊ីវិលរបស់បារាំង ។ ផ្នែកពិសេសដែលមានតែមួយរបស់ប្រព័ន្ធនេះគឺចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបអង្កេតដោយប្រើឯកសារដែលដាក់ដោយភាគីទាំងអស់ ។

បញ្ហានៅចំពោះមុខមួយរបស់អង្គជំនុំជម្រះគឺការសម្ងាត់នៃការស៊ើបអង្កេតរបស់តុលាការ ។ បញ្ហានេះក៏ដូចជាបញ្ហាផ្សេងៗដែរ វាតម្រូវឲ្យមានភាពស្មើគ្នារវាងផលប្រយោជន៍ គឺថាការសម្ងាត់អាចរក្សាផលប្រយោជន៍របស់ភាគី ប៉ុន្តែការធ្វើជាសាធារណៈអាចបម្រើដល់ផលប្រយោជន៍របស់សាធារណជនឲ្យយល់ពីដំណើរការរបស់តុលាការ និងឲ្យអ្នកទាំងនោះគាំទ្រដល់តុលាការ ។ អាស្រ័យហេតុនេះ សេចក្តីសម្រេចរបស់តុលាការថាតើនឹងធ្វើឡើងជាសាធារណៈគឺពឹងផ្អែកទៅលើទម្ងន់នៃបញ្ហាផ្សេងៗគ្នាដែលពាក់ព័ន្ធនឹងកិច្ចការនោះ ។ ដោយពិចារណាទៅលើការរិះគន់ជាច្រើនចំពោះភាពស្របច្បាប់របស់តុលាការ និងសារសំខាន់នៃការធ្វើជាសាធារណៈដើម្បីពង្រីកការផ្សះផ្សា តុលាការគួរតែធ្វើការពិចារណាទៅលើតម្លៃនៃការបង្កើនការផ្សព្វផ្សាយជាសាធារណៈ ។

## ប្រវត្តិនៃការខ្វែងយោបល់គ្នាក្នុងការរក្សាការសម្ងាត់

បញ្ហាការអនុវត្តការសម្ងាត់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតបានលេចឡើងនៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៨ នៅពេលដែលការិយាល័យសហចៅក្រមស៊ើបអង្កេតបានចេញលិខិតមួយទៅគ្រប់ភាគីទាំងអស់ ដោយរំឭកអំពីតួនាទីនៃការរក្សាការសម្ងាត់នៅអំឡុងពេលស៊ើបអង្កេត ហើយមានតែការិយាល័យសហចៅក្រមស៊ើបអង្កេតតែមួយគត់ដែលមានសិទ្ធិកំណត់ការរក្សាការសម្ងាត់ ។ បន្ទាប់ពីការជួបប្រជុំនៅថ្ងៃទី១១ ខែធ្នូ របស់មេធាវី



អៀង សារី

ការពារក្តី អៀង សារី និង លោក ខឹត រ៉ូសេតហុក នាយករងការិយាល័យរដ្ឋបាលរបស់អង្គជំនុំជម្រះនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ២០០៨ មេធាវីការពារក្តីបានផ្ញើលិខិតមួយច្បាប់ទៅឲ្យលោក រ៉ូសេតហុក ដោយនិយាយអំពីការអនុវត្តការងារទៅលើសំណុំរឿងដោយសម្ងាត់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ។ មេធាវីការពារក្តីបានអះអាងថា ការិយាល័យសហចៅក្រមស៊ើបអង្កេតធ្វើការដោយសម្ងាត់គឺមិនមែនដើម្បីការពារប្រយោជន៍

របស់ភាគីទេ ប៉ុន្តែការពារខ្លួនឯងដោយធ្វើការលាក់បាំងនូវសេចក្តីសម្រេចដែលអាចបង្ហាញឲ្យឃើញពីភាពអសមត្ថភាពរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ។ តាមពាក្យសម្តីរបស់មេធាវីការពារក្តី ការរក្សាការសម្ងាត់គឺគ្រាន់តែជា «ការលាក់កំបាំង» ដើម្បីបិទបាំងនូវសេចក្តីសម្រេចដែលមិនត្រឹមត្រូវរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតប៉ុណ្ណោះ ។ នៅក្នុងលិខិតដដែល មេធាវីការពារក្តីរបស់ អៀង សារី បានលើកឡើងពីសិទ្ធិក្នុងការបោះពុម្ពផ្សាយសារណារបស់ខ្លួន ។ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានឆ្លើយតបនឹងមេធាវីការពារក្តីដោយលើកឡើងម្តងទៀតនូវសេចក្តីព្រមានកាលពេលពីមុន ។ នៅថ្ងៃទី២០ ខែមករា មេធាវីការពារក្តីបានអះអាងម្តងទៀតនូវសិទ្ធិរបស់ខ្លួនក្នុងការបោះពុម្ពផ្សាយនូវសារណារបស់ខ្លួន ។ នៅថ្ងៃទី២៦ ខែមករា មេធាវីការពារក្តីព្យាយាមនិយាយនូវអ្វីដែលល្អទៅលើការព្រមាននោះ ហើយបោះពុម្ពផ្សាយសារណាចំនួន៩នៅលើគេហទំព័រ ដោយមិនមានការអនុញ្ញាតពីការិយាល័យសហចៅក្រមស៊ើបអង្កេតទេ ។



នៅថ្ងៃទី៣ ខែមីនា ការិយាល័យសហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់មេធាវីការពារក្តីថារំលោភនូវការរក្សាការសម្ងាត់នៅពេលស៊ើបអង្កេត ដោយអះអាងថា មេធាវីការពារក្តីគ្មានសិទ្ធិធ្វើបែបនោះទេ ។ ក្រៅពីឯកសារដែលមិនទាន់បានបោះពុម្ពផ្សាយនៅលើគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការិយាល័យសហចៅក្រមស៊ើបអង្កេតបានចេញដីកាឲ្យមេធាវីការពារក្តីយកឯកសារដែលបោះពុម្ពផ្សាយចេញពីគេហទំព័រ និងមិនឲ្យបោះពុម្ពផ្សាយម្តងទៀត ដោយមិនបានបង្ហាញថាឯកសារណាមួយជាឯកសារសម្ងាត់ឡើយ ។ ដោយប្រមាថទៅលើសកម្មភាពរបស់មេធាវីការពារក្តី ការិយាល័យសហចៅក្រមស៊ើបអង្កេតបានផ្ញើដីកានោះទៅឲ្យសមាគមមេធាវីការពារក្តី ។

មេធាវីការពារក្តីបានធ្វើការប្តឹងឧទ្ធរណ៍សុំពន្យារពេលសវនាការទៅកាន់អង្គបុរេជំនុំជម្រះ ។ នៅថ្ងៃទី២៧ ខែមីនា សហព្រះរាជអាជ្ញាបានអះអាងថា ជនត្រូវចោទមានសិទ្ធិទទួលបានការកាត់ក្តីដ៏យុត្តិធម៌នៅគ្រប់ដំណើរការ ហើយសិទ្ធិនោះរួមមានសិទ្ធិទទួលបានការកាត់សេចក្តីដ៏មានតម្លាភាពផង ។ ជាងនេះទៅទៀត ដោយសារតែការសម្ងាត់អាចជួយការពារផលប្រយោជន៍ភាគី ដូច្នេះវាគឺជាសិទ្ធិរបស់ភាគីថាតើគេចង់បោះបង់ចោលការរក្សាការសម្ងាត់ឬក៏អត់ ។ សហព្រះរាជអាជ្ញាបានអះអាងបន្ថែមអំពីសារសំខាន់នៃការផ្តល់ព័ត៌មានដល់ជនរងគ្រោះអំពីសកម្មភាពរបស់អង្គជំនុំជម្រះ ហើយការធ្វើបែបនេះគឺដើម្បីផ្តល់ជាឧទាហរណ៍មួយដល់តុលាការជាតិនៅក្នុងប្រទេសកម្ពុជា ។ ជាទីបញ្ចប់ សហព្រះរាជអាជ្ញាអះអាងថា ការធ្វើជាសម្ងាត់ស័ក្តិសមនឹងយកមកប្រើនៅក្នុងកាលៈទេសៈចាំបាច់ដើម្បីការពារភាគី ឬផលប្រយោជន៍យុត្តិធម៌ ដូច្នេះការរក្សាការសម្ងាត់មិនអាចយកមកប្រើនៅពេលនេះបានឡើយ ពីព្រោះអត្តសញ្ញាណរបស់ជនត្រូវចោទត្រូវបានគេស្គាល់យ៉ាងទូលំទូលាយ ។ នៅពេលលើកឡើងពីអំណះអំណាងម្តងៗ សហព្រះរាជអាជ្ញាសម្អាងទៅលើតុលាការព្រហ្មទណ្ឌអន្តរជាតិ ច្បាប់របស់បារាំង និង គណៈកម្មការសិទ្ធិមនុស្សរបស់អឺរ៉ុប ។

ដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញពីការយល់ឃើញស្រដៀងគ្នានឹងមេធាវីការពារក្តីនៅក្នុងរបាយការណ៍ថ្ងៃទី២៥ ខែមីនា ក្នុងការឆ្លើយតបនឹងដីការបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ។ ដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា ដោយសារតែសារណាដែលពាក់ព័ន្ធនឹងសំណុំរឿងមិនមានឥទ្ធិពលទៅលើសិទ្ធិ ឬផលប្រយោជន៍របស់ភាគី សារណានោះមិនគួររក្សាជាការសម្ងាត់ទេ ។

## ជំហានបន្ទាប់សម្រាប់អង្គបុរេជំនុំជម្រះ

ដោយភាគីទាំងអស់សុទ្ធតែមិនយល់ស្របនឹងដីការបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះកំពុងតែប្រឈមមុខនឹងបញ្ហានេះដើម្បីស្វែងរកដំណោះស្រាយ ។ បញ្ហាដែលកើតឡើងមុនសវនាការអង្គបុរេជំនុំជម្រះតម្រូវឲ្យមានការស្វែងយល់អំពីការរក្សាការសម្ងាត់ និងតម្រូវឲ្យមានការកំណត់ថាតើភាគីណាអាចបោះបង់នូវការរក្សាការសម្ងាត់នោះបាន ។ ចំណុចសំខាន់នៃការជជែកពិភាក្សា គឺមាត្រា៥៦នៃវិធានផ្ទៃក្នុង ។ មាត្រា

៥៦នៃវិធានផ្ទៃក្នុងចែងថា «ដើម្បីការពារសិទ្ធិនិងផលប្រយោជន៍របស់ភាគី ការស៊ើបសួរមិនត្រូវធ្វើឡើងជាសាធារណៈឡើយ ។ បុគ្គលទាំងអស់ដែលចូលរួមក្នុងការស៊ើបសួរត្រូវរក្សាឲ្យបាននូវការសម្ងាត់» ។ ទោះបីជាមាត្រា៥៦ នៃវិធានផ្ទៃក្នុងបានបកស្រាយបញ្ជាក់យ៉ាងច្បាស់លាស់ ប៉ុន្តែការមិនបានបញ្ជាក់ថា ប្រសិនបើមានការស្នើសុំរបស់ភាគីឲ្យធ្វើឡើងជាសាធារណៈ នោះការស៊ើបអង្កេតនៅតែធ្វើជាសម្ងាត់បង្កើតជាបញ្ហាដ៏ពិបាកដោះស្រាយមួយដល់អង្គបុរេជំនុំជម្រះ ។ អង្គបុរេជំនុំជម្រះត្រូវតែសម្រេចថា តើការសម្ងាត់គឺជាអំណាចនៃការស៊ើបអង្កេតដែលការិយាល័យសហចៅក្រមស៊ើបអង្កេតធ្វើតាមដើម្បីការពារភាគីដោយមិនគិតថាភាគីនោះចង់បានការស៊ើបអង្កេតជាសាធារណៈឬក៏អត់ ឬសម្រេចថាតើការសម្ងាត់ធ្វើឡើងគ្រាន់តែដើម្បីការពារភាគីឬអត់ ដូច្នេះវាគឺជាសិទ្ធិរបស់ភាគីថាតើគេចង់បោះបង់សិទ្ធិរក្សាការសម្ងាត់នោះឬទេ ។

ដោយគិតទៅដល់ទំនាស់ដែលមិនច្បាស់លាស់នៃច្បាប់ វាអាចបណ្តាលមានបញ្ហាខ្វះប្រឆាំងនឹងមេធាវីការពារក្តី ។ ទោះបីជាមិនមានភាពច្បាស់លាស់ថា តើការដឹកនាំការចោទប្រកាន់គោរពតាមវិន័យឬក៏អត់ វិធីសាស្ត្រដែលត្រូវបានអនុម័តឲ្យប្រើត្រូវបានអង្គជំនុំជម្រះយកមកប្រើប្រាស់គ្រាន់តែដើម្បីប្រឆាំងនឹងមេធាវីការពារក្តីប៉ុណ្ណោះ ។ ការយល់ឃើញទៅលើការលម្អៀងអាចមានឥទ្ធិពលទៅដល់ដំណើរការនីតិវិធីទាំងមូល ដូច្នេះអង្គបុរេជំនុំជម្រះគួរតែគ្រប់គ្រងបញ្ហានេះដោយយកចិត្តទុកដាក់ ។

អង្គបុរេជំនុំជម្រះគួរតែស្វែងរកការណែនាំពីអង្គភាពសិទ្ធិមនុស្សនិងតុលាការព្រហ្មទណ្ឌដទៃទៀត (ដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូននិងតុលាការព្រហ្មទណ្ឌអន្តរជាតិ) ។ ប៉ុន្តែតុលាការទាំងនេះអាចផ្តល់គំរូដោយផ្ទាល់តែបន្តិចបន្តួចប៉ុណ្ណោះដល់អង្គជំនុំជម្រះ ។ ផ្ទុយពីអង្គជំនុំជម្រះ តុលាការទាំងនោះមិនបានអនុវត្តតាមច្បាប់ស៊ីវិលឡដែលមានការស៊ើបអង្កេតជាសម្ងាត់ឡើយ ។ ជាលទ្ធផល ការគ្រប់គ្រងរបស់តុលាការទាំងនោះបានសន្មតថាឯកសារទាំងអស់អាចរក្សាជាសម្ងាត់នៅពេលដែលចាំបាច់តែប៉ុណ្ណោះ ។ ជាឧទាហរណ៍ វិធាន៥៣របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានអះអាងថា «ដើម្បីផលប្រយោជន៍យុត្តិធម៌ នៅក្នុងករណីលើកលែងខ្លះ ចៅក្រមឬតុលាការអាចចេញដីកាឲ្យរក្សាព័ត៌មានឬឯកសារខ្លះជាសម្ងាត់រហូតដល់មានមានដីកាផ្សេងទៀត» ។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះគួរតែមើលទៅលើការអនុវត្តតាមប្រព័ន្ធច្បាប់ស៊ីវិលឡក្នុងស្រុកដែលជាប្រព័ន្ធច្បាប់បារាំង ។

## តម្លៃនៃការធ្វើជាសាធារណៈ

នៅក្នុងការសម្រេចទៅលើបញ្ហានេះ អង្គបុរេគួរតែទទួលស្គាល់តម្លៃនៃការធ្វើជាសាធារណៈដែលធ្វើឡើងដោយតុលាការដែលត្រូវកាត់ទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ ការផ្តល់ព័ត៌មានជាសាធារណៈអំពីដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ វាមានសារសំខាន់ក្នុងការបង្កើនការជឿជាក់របស់តុលាការដែលអាចលុបបំបាត់ការចោទប្រកាន់និងការសង្ស័យអំពីតុលាការនៅកម្ពុជា ។ អ្វីដែលសំខាន់ជាងភាពស្របច្បាប់ទូទៅរបស់តុលាការ គឺផលប៉ះពាល់ទៅដល់កិច្ចខំប្រឹងប្រែងដើម្បីផ្សះផ្សា ។ ប្រសិនបើដំណើរការរបស់អង្គជំនុំជម្រះត្រូវបានចាត់ទុកថាមានអំពើពុករលួយ នោះវាមិនអាចផ្តល់យុត្តិធម៌ ឬធ្វើឲ្យប្រជាជនកម្ពុជាប្រមាណ ១,៧លាននាក់ដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម និងប្រជាជនជាច្រើនដែលរស់នៅជាមួយកេរដំណែលនៃអំពើប្រល័យពូជសាសន៍ខ្មែរក្រហមអស់ចិត្តបានឡើយ ។ ដូច្នេះ អង្គបុរេជំនុំជម្រះគួរតែប្រើឱកាសដ៏មានតម្លៃនេះមកបង្កើនភាពត្រឹមត្រូវនៃច្បាប់របស់អង្គជំនុំជម្រះនិងគាំទ្រដល់ការធ្វើជាសាធារណៈ ។

បញ្ហាការសម្ងាត់អាចធ្វើឲ្យអង្គបុរេរកឃើញនូវការពិតដែលអាចពង្រឹងដល់ការជឿជាក់របស់អង្គជំនុំជម្រះដល់គ្រប់ភាគីនិងប្រជាជនកម្ពុជានៅទូទាំងប្រទេស ។ នៅពេលធ្វើសេចក្តីសម្រេច អង្គបុរេជំនុំជម្រះគួរតែយកចិត្តទុកដាក់ទៅលើសារសំខាន់នៃតម្លាភាពដើម្បីធ្វើឲ្យប្រជាជនកម្ពុជា និងជនរងគ្រោះនៃរបបប្រល័យពូជសាសន៍នៅទូទាំងប្រទេសដែលសិទ្ធិទទួលបានសំណងរបស់គេស្ថិតនៅក្នុងដៃរបស់តុលាការនោះអស់ចិត្ត ។

**គុននី ហ្វូលីរណាស**

# អ្នករស់រានមានជីវិតដែលបានចំណាយពេលរាប់ម៉ោងនៅក្រោមសាកសពជាច្រើននៅក្នុងរណ្តៅរួមមុនពេលគេចខ្លួនចេញពីវាលពិឃាតរបស់ ឌុច

***ឌុច ជំទាស់នឹងសក្ខីកម្មរបស់អ្នករស់រានមានជីវិតផ្សេងទៀតពីមន្ទីរស-២១***

*ថ្ងៃនេះ កាំង ហ្គេកអ៊ាវ ហៅ (ឌុច) បានជំទាស់ទៅនឹងសក្ខីកម្មរបស់អ្នករស់រានមានជីវិតទីបីពីគុកទួលស្លែង (ស-២១) ។ ទោះបីជា ឌុច ទទួលស្គាល់ពីទុក្ខវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ ឡាយ ចាន់ ក៏ដោយ ក៏គាត់បានប្រកែកថា មិនមានឯកសារដែលបង្ហាញពីទុក្ខវេទនារបស់ ឡាយ ចាន់ ដែលបានកើតឡើងនៅស-២១នោះទេ ។ មេធាវីការពារក្តីរបស់ ឌុច បានក្រោកឈរឡើងនិយាយជំទាស់បន្ទាប់ពី ឡាយ ចាន់ ចាប់ផ្តើមផ្តល់សក្ខីកម្ម ។*

*ឡាយ ចាន់ ដែលជាកសិករម្នាក់អាយុ៥០ឆ្នាំ ប្រហែលជាត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៦ នៅពេលដែលគាត់ធ្វើជានិរសារខ្មែរក្រហម ។ បន្ទាប់ពីត្រូវបានដោះខោអាវចេញ បិទមុខ និងដាក់បញ្ចូលទៅក្នុងយានជំនិះផ្សេងៗជាបន្តបន្ទាប់ ឡាយ ចាន់ បានមកដល់កន្លែងឃុំឃាំងមួយដែលឥឡូវនេះ គាត់ជឿថាជាមន្ទីរស-២១ ។ នៅអំឡុងពេលប្រហែលបីខែ គាត់ត្រូវបានគេធ្វើទារុណកម្មនិងសួរចម្លើយចំនួនពីរដង ។ គាត់ត្រូវបានចោទប្រកាន់ថាបានលួចស្រូវឲ្យ «ខ្មាំង» និងមានគម្រោងក្បត់ជាមួយនឹងមេរបស់គាត់ពីរនាក់ទៀត ។ គាត់ត្រូវបានឃុំឃាំងនៅក្នុងគុកសម្រាប់ដាក់អ្នកទោសម្នាក់ៗ ហើយគាត់គិតថាមានអ្នកដែលត្រូវគេឃុំខ្លួនផ្សេងទៀត ពីព្រោះគាត់បានស្តាប់ឮសំឡេងស្រែកនិងសម្រិបជើង ។ គាត់ត្រូវបានបិទមុខនៅរាល់ពេលដែលគេនាំគាត់ចេញពីបន្ទប់ឃុំឃាំង ។ នៅពេលយប់គាត់ត្រូវនាំចេញទៅក្រៅឲ្យជីករណ្តៅដែលគេប្រាប់ថារណ្តៅនោះគឺជីកសម្រាប់ដាំចេក ។*

*ក្នុងពេលផ្តល់សក្ខីកម្ម ឡាយ ចាន់ បានយំនៅខណៈពេលដែលគាត់រៀបរាប់អំពីការស្រេកទឹកខ្លាំងពេករហូតដល់ផឹកទឹកនោមខ្លួនឯង ។*

*នៅថ្ងៃមួយ គាត់ត្រូវបានគេបោះចូលទៅក្នុងរថយន្តមួយគ្រឿង យកទៅទម្លាក់ចោលនៅជាយក្រុងភ្នំពេញតែម្នាក់ឯងដោយមិនដឹងពីមូលហេតុអ្វីសោះ ។ ក្រោយមកទៀត គាត់សុំដោយសាររថយន្តត្រឡប់មកភ្នំពេញវិញ ដែលនៅទីនោះមានសមមិត្តម្នាក់បានចាត់តាំងឲ្យគាត់ធ្វើដំណើរទៅស្ថានីយរទេះភ្លើង ។ ទៅដល់ទីនោះ គាត់ដឹងថាកន្លែងនោះគឺជាកន្លែងលត់ដំ ហើយគាត់ត្រូវបានបញ្ជូនទឲ្យដើរទៅរើសខសយកមកដុតធ្វើស្ករត្នោត ។ មួយឆ្នាំក្រោយមក គាត់ត្រូវបានបញ្ជូនត្រឡប់ទៅធ្វើស្រែនិងដាំបន្លែនៅក្នុងកងធ្វើស្រែចម្ការដែលគាត់ធ្លាប់នៅពីមុន ។ គាត់ធ្វើការនៅទីនោះរហូតដល់ពេលដែលកងទ័ពវៀតណាមចូលមកកាន់កាប់ភ្នំពេញ ។*

*អង្គជំនុំជម្រះហាក់ដូចជាមានការសង្ស័យអំពីដំណើររឿងរបស់គាត់ ។ លោកប្រធាន និល ណុន និងចៅក្រម ធូ មុនី បានព្យាយាមសួរដេញដោល ឡាយ ចាន់ ថាតើគាត់ដឹងថាខ្លួនគាត់បានជាប់នៅស-២១ដោយរបៀបណា ។ គាត់បានរៀបរាប់ថាគាត់បានឮអ្នកយាមនៅទីនោះនិយាយថា កន្លែងនោះជា «សាលាទួលស្លែង» ។ នៅពេលដែលត្រូវបានសួរថាតើគាត់ស្គាល់ទួលស្លែងទេ នៅពេលដែលគាត់ត្រឡប់មកមើលកន្លែងនោះក្នុងពេលថ្មីៗនេះ គាត់និយាយថា បរិវេណនៅក្នុងគុកទួលស្លែងត្រូវបានគេ «កែប្រែ» ហើយទីតាំងក៏មានការខុសប្លែកពីមុនដែរ ។ ឡាយ ចាន់ មិនអាចផ្តល់នូវភស្តុតាងបន្ថែមទៀត ដើម្បីបញ្ជាក់ថាគាត់បានជាប់នៅស-២១ទេ ហើយចៅក្រមក៏ព្យាយាមសួរដេញដោលទៅកាន់មេធាវីរបស់ ឡាយ ចាន់ អំពីឯកសារ «ជីវិតតូច» ដែលបាន*

ផ្តល់ឲ្យសម្រាប់ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ មេធាវីរបស់ ឡាយ ចាន់ ក៏បានពន្យល់ថា គាត់មិនមានឯកសារដែលជាប់ពាក់ព័ន្ធទេ ។ មានលក្ខណៈប្លែកពីព្រោះថា គ្មានចៅក្រមអន្តរជាតិមួយណាសួរសំណួរទេ ។ ចៅក្រមទាំងនេះប្រហែលជាបានសម្រេចថាមិនទទួលស្គាល់សក្ខីកម្មរបស់ ឡាយ ចាន់ រួចទៅហើយ ។

បន្ទាប់ពីសហព្រះរាជអាជ្ញាជាតិសួរពីរ-បីសំណួរ សហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជាក់ថា គាត់គ្មានសំណួរអ្វីដែលត្រូវសួរទៅដើមបណ្តឹងរដ្ឋប្បវេណីនេះទេ ប៉ុន្តែគាត់បានជម្រាបអង្គជំនុំជម្រះថានឹងធ្វើសារណាជាលាយលក្ខណ៍អក្សរទាក់ទងទៅនឹងទម្ងន់ដែលអង្គជំនុំជម្រះគួរផ្តល់ទៅឲ្យសក្ខីកម្មរបស់ ឡាយ ចាន់ ។ ដោយដឹងថា សូម្បីតែខាងព្រះរាជអាជ្ញាក៏មានភាពស្រពេចស្រពិលនឹងសាក្សី ខ្ញុំរំពឹងថាដើមបណ្តឹងរដ្ឋប្បវេណីនឹងចេញមកបញ្ជាក់ថា ឡាយ ចាន់ ពិតជាអ្នកទោសនៅស-២១មែន ។ ខណៈពេលដែលសំណួរតែពីរ-បីអាចបង្ហាញពីការពិត សំណួរជាច្រើនដែលស្វែងរកព័ត៌មានលម្អិតអំពីស្ថានភាពដែលគាត់ធ្លាប់ជួបប្រទះនិងការដែលខ្មែរក្រហមធ្វើទៅលើគាត់ហាក់ដូចជាមិនមានប្រយោជន៍ ។

អង្គជំនុំជម្រះបានទុកឱកាសឲ្យ ឌុច ធ្វើការបញ្ចេញយោបល់ទៅលើសក្ខីកម្មរបស់ ឡាយ ចាន់ ។ ឌុច បានពន្យល់ថា ស-២១ នៅក្រោមការគ្រប់គ្រងរបស់គាត់ ហើយគ្មានអ្នកណាត្រូវបានដោះលែងទេ ។ ហេតុដូច្នេះហើយ ឡាយ ចាន់ ប្រាកដជាទទួលរងទុក្ខវេទនានៅកន្លែងផ្សេងទេ ។ មេធាវីការពារក្តីជាតិ កា សាវុត្ថ សួរសំណួរមួយចំនួនដែលបង្ហាញពីភាពខុសគ្នារវាងសក្ខីកម្មរបស់ ឡាយ ចាន់ ជាមួយនឹងស្ថានភាពនៅស-២១ ដែលអ្នករស់រានមានជីវិតផ្សេងទៀតបានបកស្រាយ ។ ទោះបីជាគាត់បានលើកឡើងនូវចំណុចល្អមួយចំនួនក៏ដោយ ក៏របៀបដែលគាត់លើកឡើងនោះមិនមានលក្ខណៈសមរម្យឡើយ ។ កាលពីម្សិលមិញ កា សាវុត្ថ បានសុំការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីធ្វើសេចក្តីសន្និដ្ឋាន ប៉ុន្តែគាត់មិនត្រូវបានអនុញ្ញាតទេ ដោយសារតែប្រធានសហព្រះរាជអាជ្ញាអន្តរជាតិ រ៉ូបឺត ពេទី បានជំទាស់ថាការធ្វើសេចក្តីសន្និដ្ឋាននេះដូចទៅនឹងសារណាជាលាយលក្ខណ៍អក្សរ ។ នៅថ្ងៃនេះ ដោយមិនធ្វើសេចក្តីសន្និដ្ឋានឯករាជ្យ កា សាវុត្ថ បានប្រែក្លាយការសន្និដ្ឋានរបស់គាត់ទៅជាសំណួរវិញ ។ ជាឧទាហរណ៍ ទាក់ទងទៅនឹងសំណួរមួយ គាត់បានអះអាងថា «ខ្ញុំគិតថាស-២១ មិនដែលដោះលែងអ្នកណាម្នាក់ទេ» ។ បន្ទាប់ពីចោទសួរបានពីរ-បីសំណួរ គាត់បានពន្យល់នូវភាពដែលមិនចាំបាច់ទៅកាន់សាក្សីដែលគាត់បានចោទសួរ ពីព្រោះថា អ្នកផ្សេងទៀតបកស្រាយស-២១ ខុសប្លែកពីការបកស្រាយរបស់ ឡាយ ចាន់ ហើយប្រហែលជាសាក្សីនេះច្រឡំកន្លែងដែលគាត់ត្រូវបានឃុំខ្លួន ។ សហព្រះរាជអាជ្ញាអន្តរជាតិផ្សេងទៀតមានវត្តមាននៅក្នុងអង្គសវនាការនៅថ្ងៃនេះ ហើយអ្នកទាំងនេះមិនបានជំទាស់ទៅនឹងយុទ្ធសាស្ត្ររបស់ កា សាវុត្ថ ទេ ។



មេធាវីអន្តរជាតិ ហ្វ្រង់ស័រ រូ

ការលេចឡើងនូវព័ត៌មានទាក់ទងនឹងអ្នករស់រានមានជីវិតពីស-២១ ផ្សេងទៀតដែលត្រូវបានបដិសេធដោយទុកឲ្យអ្នកតាមដានស្វែងយល់នូវចម្ងល់ទាក់ទងទៅនឹងកន្លែងដែល ឡាយ ចាន់ ត្រូវបានឃុំឃាំង សក្ខីកម្មរបស់ ឡាយ ចាន់ នៅថ្ងៃនេះមានភាពច្បាស់លាស់ជាងសក្ខីកម្មរបស់ លី ហ៊ កាលពីម្សិលមិញ ។ បើទោះជាអង្គជំនុំជម្រះស្តីបន្ទោសឲ្យមេធាវីរបស់ លី ហ៊ កាលពីម្សិលមិញចំពោះការដែលមិនបានរៀបចំឲ្យបានត្រឹមត្រូវ វាក៏ហាក់ដូចជាបានបង្ហាញពីការមិនបានរៀបចំទុកមុនឲ្យបានត្រឹមត្រូវ

ក្នុងនាមជាអង្គជំនុំជម្រះដែរ ។ វាហាក់ដូចជាគ្មាននរណាម្នាក់នៅ ឯអ.វ.ត.ក បានជួបជាមួយ លី ហ៊ ឬក៏ស៊ើបអង្កេតប្រវត្តិរបស់ គាត់ឲ្យបានត្រឹមត្រូវជាមុនសោះ ។ ដោយយោងទៅតាមអ្នក តំណាងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានឲ្យដឹងថា មានបុគ្គលិក របស់អង្គភាពអ.វ.ត.កម្នាក់បានទាក់ទងជាមួយនឹងមជ្ឈមណ្ឌល ឯកសារកម្ពុជានៅមុនពេលដែល លី ហ៊ ឡើងផ្តល់សក្ខីកម្ម ដើម្បី ស្វែងរកឯកសារសម្រាប់ឲ្យអង្គជំនុំជម្រះយកទៅពិចារណា ។

កាលពីអាទិត្យមុន ឌុច ក៏បានប្រកែកមិនទទួលស្គាល់



សក្ខីកម្មរបស់ នង ចាន់ផល ដែលបានអះអាងថា គាត់និងម្តាយ គាត់បានចូលទៅស-២១នៅជិតពេលដែលវៀតណាមចូល កាន់កាប់ក្រុងភ្នំពេញថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ ដោយមិន មានឯកសារឬក៏រូបថតដើម្បីបញ្ជាក់ថាម្តាយរបស់ នង ចាន់ផល ឈ្មោះ មុំ យ៉ូវ ត្រូវបានជាប់ឃុំនៅស-២១ ឌុច បាននិយាយថា គាត់មិនអាចទទួលស្គាល់ទុក្ខវេទនារបស់ នង ចាន់ផល នៅស-២១ ទេ ។ ឌុច បញ្ជាក់ថា ប្រសិនបើមានឯកសារមកបញ្ជាក់មែន គាត់នឹងទទួលស្គាល់សក្ខីកម្មរបស់ នង ចាន់ផល ទាំងស្រុង ។

មានភាពគួរឲ្យភ្ញាក់ផ្អើលមួយតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រវត្តិរូបរបស់ មុំ យ៉ូវ ត្រូវបានគេរកឃើញ និងផ្តល់ទៅឲ្យ អង្គជំនុំជម្រះ ។ បន្ទាប់ពី ឌុច បដិសេធនឹងសក្ខីកម្មរបស់ នង ចាន់ផល បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ហ៊ិន សុផានី និង សុខ វណ្ណៈ ត្រូវបានជំរុញឲ្យធ្វើការស្រាវជ្រាវបន្ថែមទៅក្នុងបណ្ណសារ របស់ខ្លួន ហើយក៏បានរកឃើញប្រវត្តិរូបនោះ ។ ឆាំង យុ បាន បញ្ជាក់ថា ទោះបីជាមជ្ឈមណ្ឌលឯកសារកម្ពុជាមានការយល់ដឹង ច្រើន ហើយអាចស្វែងរកឯកសារដែលពាក់ព័ន្ធនិងឯកសាររបស់ សាក្សីក៏ដោយ ក៏មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ករណីទាំងអស់ ទៅឲ្យអង្គជំនុំជម្រះ ហើយមជ្ឈមណ្ឌលឯកសារក៏មិនធ្វើការស៊ើប អង្កេតតាមផ្លូវច្បាប់អ្វីដែរ ។

ចៅក្រមបដិសេធនឹងរឿងរ៉ាវអ្នកនៅរស់ពីជើងឯកដែល មិនគួរឲ្យមាន នៅរសៀលនេះ អង្គជំនុំជម្រះបានសួរដើមបណ្តឹង រដ្ឋប្បវេណីម្នាក់ដែលមានអាយុ៥៧ឆ្នាំ ឈ្មោះ ភោគ ខន ។ ភោគ ត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៧ នៅពេលដែលគាត់ធ្វើជា ទាហានខ្មែរក្រហម ហើយបានបញ្ជូនមកកន្លែងឃុំឃាំងមួយ ។ ដូចគ្នានឹង ឡាយ ចាន់ ដែរ ភោគ ខន មិនផ្តល់សក្ខីកម្មឲ្យបានល្អិតល្អន់ ទាក់ទងទៅនឹងបរិវេណស-២១ទេ ពីព្រោះគ្រប់ពេលដែលគាត់ នៅក្រៅគុក គាត់ត្រូវបានគេបិទមុខ ។ ក៏ប៉ុន្តែ គាត់ជឿថា គាត់ បានជាប់នៅ ស-២១ ។

នៅពេលដំបូង គាត់ត្រូវបានគេដាក់នៅក្នុងគុកធំមួយដែល មានអ្នកជាប់ឃុំប្រហែលជា១៥នាក់ ហើយគាត់ស្គាល់មនុស្ស ម្នាក់ដែលធ្លាប់ធ្វើការនៅក្នុងកងយោធាចាស់របស់គាត់ ។ បីថ្ងៃ ក្រោយមក គាត់ត្រូវបានបុរសពីរនាក់នាំយកទៅសួរចម្លើយ ។ នៅពេលមួយនោះ គាត់ត្រូវបានគេសម្គុតថា «បងខាងកើត» ហៅ ឌុច មកមើលការធ្វើទារុណកម្ម ។ ឌុច អង្គុយនៅលើកៅអីមើល បុរសទាំងនោះសួរចម្លើយនិងធ្វើទារុណកម្ម ភោគ ខន ប្រហែលជា ១៥ឬ២០នាទី ។ ភោគ ខន មិនច្បាស់ថាតើមានពេលមួយនោះ ឌុច បានទាត់គាត់មុនពេលចាកចេញទៅនោះទេ ។ បន្ទាប់ពីសួរ ចម្លើយហើយ ភោគ ខន ត្រូវបានគេដាក់នៅក្នុងគុកមួយសម្រាប់ ដាក់អ្នកទោសម្នាក់ៗ ។

បន្ទាប់ពីបីទៅបួនខែនៅស-២១ ភោគ ខន និងអ្នកទោស

ប្រហែលជា៣០នាក់ទៀត ត្រូវបានគេបិទមុខ ចងស្លាបសេក និង ដាក់ច្រវាក់ជើង ហើយដឹកតាមរថយន្តមួយ ។ មួយម៉ោងក្រោយមក រថយន្តនោះបានទៅដល់កន្លែងមួយដែលស្គាល់ថា ជើងឯក ហើយអ្នកទោសទាំងអស់ត្រូវបានអ្នកនាំទៅយកទៅដាក់នៅក្នុងផ្ទះឈើមួយ ។ អ្នកទោសមួយចំនួនត្រូវបានយកចេញ ហើយមិនដែលត្រឡប់មកវិញទេ ។ ក្រុមចុងក្រោយរបស់ ភោក ខន មានគ្នា ៦នាក់ក៏ត្រូវបាននាំចេញទៅ ។ គាត់និយាយថា គាត់ឈរនៅមុខរណ្តៅ ហើយដឹងខ្លួនថាពេលវេលារបស់គាត់បានមកដល់ហើយ ។ បន្ទាប់ពីវាយត្រូវជង្គង់និងឆ្អឹងជំនីរ គាត់ក៏ធ្លាក់ទៅក្នុងរណ្តៅ ។ ចំណែក អ្នកទោសដ៏ទៃទៀតត្រូវបានសម្លាប់ពីក្រោយគាត់ ហើយធ្លាក់ទៅលើគាត់ ។ គាត់គិតថា ខ្លួនគាត់បានសន្លប់ក្នុងរណ្តៅនៅក្រោមសាកសពទាំងនោះជាច្រើនម៉ោង ។ នៅពេលដែលគាត់ដឹងខ្លួន ខ្លួនរបស់គាត់ប្រឡាក់សុទ្ធតែឈាម ហើយមានក្លិនស្អុយយ៉ាងខ្លាំង ។ បើទោះបីជាវិលមុខ មានការឈឺចាប់ និងទន់ខ្សោយយ៉ាងណាក៏ដោយ គាត់បានដើរនិងវារទៅកាន់ទន្លេជិតនោះ ហើយបានប្រើកំណាត់ឈើមួយដើម្បីបណ្តែតខ្លួន២-៣ថ្ងៃរហូតដល់ភ្នំពេញដែលជាកន្លែងគាត់ត្រូវបានគេជួយសង្គ្រោះ ។ ក្នុងអំឡុងពេលរត់គេចខ្លួនពីវាលពិឃាដ គាត់បានឮសូរសំឡេងកាំភ្លើងដូច្នេះហើយទើបគាត់ជឿថា គាត់បានរត់គេចខ្លួនកាលពីថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ជាពេលដែលកងទ័ពវៀតណាមចូលកាន់កាប់ទីក្រុង ។

អង្គជំនុំជម្រះហាក់ដូចជាមានការសង្ស័យនិងចោទសួរសំណួរមួយចំនួនដើម្បីឲ្យកាន់តែច្បាស់អំពីសក្ខីកម្មរបស់ ភោក ខន ។ សំណួរភាគច្រើនរបស់អង្គជំនុំជម្រះផ្តោតទៅលើពាក្យបណ្តឹងសុំតាំងខ្លួនធ្វើដើមបណ្តឹងរដ្ឋប្បវេណីរបស់ ភោក ខន ដែលមាននៅក្នុងកំណត់ហេតុដែលត្រូវបានធ្វើឡើងដោយសមាគមសិទ្ធិមនុស្សកម្ពុជានិងការអភិវឌ្ឍ **(ADHOC)** ដែលជាអង្គការក្រៅរដ្ឋាភិបាលមួយ ។ លោកប្រធាន និល ណុន បានមានប្រសាសន៍ថា កំណត់ហេតុជាលាយលក្ខណ៍អក្សរគឺ «ផ្ទុយ» ពីអ្វីដែល ភោក ខន បានប្រាប់អង្គជំនុំជម្រះ ។ លោកប្រធានបានអានផ្នែកខ្លះនៃព័ត៌មានដែលមាននៅក្នុងពាក្យបណ្តឹងរបស់គាត់ហើយ ចោទសួរថា «តើអ្វីទៅជាអង្គហេតុពិតប្រាកដ?» គាត់ក៏បានសួរ ភោក ខន ផងដែរថាតើគាត់ចេះអាននិងសរសេរដែរទេ? ហើយបានអានកំណត់ហេតុនោះដែរឬទេ? ។ ភោក ខន បញ្ជាក់ថា គាត់ «មិនបានអានអង្គហេតុនោះឲ្យបានច្បាស់ទេ» ។ ជាឧទាហរណ៍ កំណត់ហេតុនោះបញ្ជាក់ថា ភោក ខន បានរត់គេចដោយលបទៅលាក់ខ្លួនក្នុងស្រះនៅជើងឯកជាជាងត្រូវបានគេវាយទម្លាក់ចូលទៅក្នុងរណ្តៅ ហើយត្រូវបានគេគិតថាស្លាប់ដូចអ្វីដែលគាត់បានផ្តល់សក្ខីកម្មនៅថ្ងៃនេះ ។ បញ្ហាដូចគ្នានេះដែរបានលេចឡើងនៅពេលអង្គជំនុំជម្រះធ្វើការប្រៀបធៀបកំណត់ហេតុដែលមាននៅក្នុងបណ្តឹងរបស់ ឡាយ ចាន់ ជាមួយសក្ខីកម្មរបស់គាត់ ។ ជាឧទាហរណ៍ នៅក្នុងកំណត់ហេតុបានបញ្ជាក់ថា ម៉ាស៊ីនភ្លើងត្រូវបានគេបញ្ឆេះនៅពេលសួរចម្លើយដើម្បីកុំឲ្យឮសំឡេងស្រែក ។ ឡាយ ចាន់ ផ្តល់សក្ខីកម្មថា គាត់ឮសំឡេងនៅពេលសួរចម្លើយ ប៉ុន្តែគាត់មិនអាចកំណត់បានថាតើសំឡេងនោះចេញមកពីយានជំនិះឬម៉ាស៊ីនភ្លើងទេ ។ ឡាយ ចាន់ មិនបានបញ្ជាក់ពីស្នូរលាន់ឮរបស់សំឡេងនោះទេ ។

មេធាវីរបស់ ភោក ខន ព្យាយាមពន្យល់អង្គជំនុំជម្រះថា កំណត់ហេតុរបស់សាក្សីនៅថ្ងៃនេះនិងកាលពីម្សិលមិញត្រូវបានកត់ត្រាដោយបុគ្គលិកស្ម័គ្រចិត្តដែលមានបទពិសោធន៍តិចតួចក្នុងការពង្រាងឯកសារ ។ គាត់បានទទួលស្គាល់ការខ្វះខាតច្បាស់លាស់ដែលមាននៅក្នុងរបាយការណ៍ ហើយស្នើឲ្យអង្គជំនុំជម្រះពិចារណាទៅលើកំណត់ហេតុទាំងនោះតាម «បរិបទត្រឹមត្រូវ» ។ ជនរងគ្រោះរបស់ ឌុច ភាគច្រើនត្រូវបានទទួលស្គាល់ដោយអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ដែលបានសម្ភាស៍ជនរងគ្រោះនិងប្រមូលបែបបទជាដើមបណ្តឹងរដ្ឋប្បវេណី ។ អង្គការទាំងនោះបញ្ជូនដើមបណ្តឹងរដ្ឋប្បវេណីដែលគេបានទទួលស្គាល់ទៅកាន់ក្រុមមេធាវី ហេតុដូច្នេះទើបមេធាវីទាំង៤ក្រុមត្រូវបានបង្កើតឡើង ។ អាស្រ័យហេតុនេះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទទួលបានកំណត់ហេតុពាក្យបណ្តឹងទាំងនោះពីអង្គការក្រៅរដ្ឋាភិបាល និងមិនបានចូលរួមក្នុងការពង្រាងឯកសារទាំងអស់នោះដោយខ្លួនឯងទេ ។

ភោក ខន នឹងត្រឡប់ទៅកាន់ អ.វ.ត.ក ម្តងទៀតនៅថ្ងៃស្អែកដើម្បីឲ្យអង្គសវនាការសួរចម្លើយបន្ថែម ។ គាត់គឺជាអ្នករស់រានមានជីវិតទី៧ដែលផ្តល់សក្ខីកម្មនៅក្នុងសវនាការរបស់ ឌុច ។

**ឡូរ៉ា ម៉ាដូណាល**

# សេចក្តីលម្អិតស្តីពីតួនាទីរបស់ ឌុច នៅមន្ទីរស-២១ ត្រូវបានរកឃើញ ផ្ទុយទៅវិញ សេចក្តីលម្អិតស្តីពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងតុលាការត្រូវបានចៀសវាង

ក្រោយពីការសួរសំណួរដ៏ស្មុគស្មាញទាក់ទងនឹងប្រតិបត្តិការរបស់គុកទួលស្លែង និងវាលពិឃាដនៅជើងឯករបស់ចៅក្រមទាំងប្រាំរូបតាំងពីអាទិត្យមុនមក នៅព្រឹកនេះ ឌុច បានចូលទៅកាន់កន្លែងសម្រាប់ជនត្រូវចោទដែលមានរាងក្របកសេះដើម្បីឆ្លើយនឹងសំណួរដ៏វែងៗពីចៅក្រមនិងពីដើមបណ្តឹងរដ្ឋប្បវេណីលើប្រធានបទដដែល ។

សហព្រះរាជអាជ្ញាកម្ពុជាបានចោទសួរសំណួររបស់ខ្លួនក្នុងបំណងផ្ទុះបញ្ចាំងពីការចូលរួមរបស់ ឌុច ក្នុងប្រតិបត្តិការចាប់ខ្លួន សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់អ្នកទោសនៅមន្ទីរស-២១ ។ ផ្ទុយពីសេចក្តីលម្អិត លើកលែងតែសំណួរទូទៅរបស់ចៅក្រមកាលពីសប្តាហ៍មុន ព្រះរាជអាជ្ញា បានអានឯកសារជាក់លាក់មួយចំនួនដែលភាគច្រើនទាក់ទងនឹងចម្លើយសារភាពរបស់អ្នកទោសដែល ឌុច បានសរសេរដោយផ្ទាល់ដៃ និង សក្ខីភាពដ៏គួរឲ្យចាប់អារម្មណ៍ដែលមាន ។ ក្រៅពី ឌុច បានទទួលបញ្ជាពីថ្នាក់លើដែលជាបក្សកុម្មុយនីស្តកម្ពុជាទាក់ទងនឹងរបៀបសួរចម្លើយ និងរបៀបធ្វើទារុណកម្មលើអ្នកទោសដែលមានឋានៈខ្ពស់ និង អ្នកទោសសំខាន់ៗដទៃទៀត ឌុច បានទទួលស្គាល់ថាខ្លួនក៏មានទំនួលខុសត្រូវ និងអំណាចក្នុងការបញ្ជាឲ្យធ្វើទារុណកម្មលើអ្នកទោសធម្មតាដែរ ។ អត្ថបទឯកសារទាំងនេះបានបង្ហាញថា ឌុច បានផ្តល់នូវវិធីសាស្ត្របង្រៀនពីរបៀបសួរចម្លើយថា តើគួរតែសួរសំណួរអ្វីខ្លះ និងគួរតែប្រើវិធីធ្វើទារុណកម្មកម្រិតមួយណាលើអ្នកទោស ។ ជាឧទាហរណ៍ ឌុច បានបង្រៀនអ្នកសួរចម្លើយម្នាក់ឲ្យវាយទៅលើស្ត្រីជាអ្នកទោសម្នាក់រហូតដល់នាងយល់ព្រមសារភាពថានាងបានធ្វើដំណើរទៅប្រទេសវៀតណាមមិនមែនដើម្បីព្យាបាលជំងឺទេ ប៉ុន្តែដើម្បីធ្វើសកម្មភាពក្បត់ ។

ព្រះរាជអាជ្ញាក៏បានអានសំបុត្រសរសេរដោយដៃរបស់ ឌុច ផ្ញើទៅឲ្យអ្នកសួរចម្លើយដែល ឌុច បានអនុញ្ញាតឲ្យអ្នកសួរចម្លើយនោះធ្វើទារុណកម្មលើអ្នកទោសដែលមានឋានៈខ្ពស់ម្នាក់រហូតដល់ស្លាប់ ។ ឌុច បានពន្យល់ថា សំបុត្រនេះគឺជា «សំបុត្របោកបញ្ឆោតមួយ» ដែលក្រោយមកត្រូវយកទៅបង្ហាញដល់អ្នកទោសនោះដើម្បីបញ្ចុះបញ្ចូលអ្នកទោសឲ្យសហការ និងសារភាពតែប៉ុណ្ណោះ ។ ឌុច នៅតែប្រកាន់គោលជំហរដែលថាគាត់បានហាមឃាត់អ្នកសួរចម្លើយដាច់ខាតមិនឲ្យធ្វើទារុណកម្មលើអ្នកទោសរហូតស្លាប់ឡើយ ទោះបី ឌុច បានទទួលស្គាល់ថាអ្នកសួរចម្លើយដែលរំលោភលើបទបញ្ជានេះមិនបានទទួលនូវទារុណកម្មអ្វីក៏ដោយ ។

ក្នុងដំណាក់កាលដំបូងសម្រាប់ថ្ងៃនេះ ឌុច បានសារភាពថាការធ្វើទារុណកម្មពេលខ្លះត្រូវបានប្រើដើម្បីដាក់ទណ្ឌកម្មចំពោះអាកប្បកិរិយាមិនល្អរបស់ពួកគេ ជាជាងដើម្បីស្រង់យកចម្លើយសារភាពតែមួយមុខ ។ ដោយនិយាយរៀបរាប់ពេលមួយដែល ឌុច បានទទួលស្គាល់ថាខ្លួនបានវាយលើអ្នកទោសម្នាក់នោះ ឌុច បានបន្ថែមថា បានទះកំផ្លៀងអ្នកទោសនោះដើម្បីជាទារុណកម្មសម្រាប់ការនិយាយកុហករបស់អ្នកទោសនោះតែប៉ុណ្ណោះ ។

ដោយឆ្លើយនឹងសំណួរលើប្រធានបទដ៏គួរឲ្យចាប់អារម្មណ៍ស្តីពីរបបអាហារសម្រាប់អ្នកទោស ឌុច ព្យាយាមនិយាយដោះសាចំពោះរបបអាហារដ៏តិចតួចបំផុតនេះទេដោយបានពន្យល់ថា មន្ទីរស-២១ គឺមិនមែនជាគុកដែលអនុវត្តនីតិវិធីច្បាប់ច្បាស់លាស់ឡើយ ។ មន្ទីរស-២១នេះ គឺជា «កន្លែងសម្រាប់សម្លាប់មនុស្ស» ឬក៏ជា «មន្ទីរកាត់ទោសប្រហារជីវិត» ។ ឌុច បាននិយាយថា គាត់មិនបដិសេធចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរបស់ខ្លួនដែលជាប់ទាក់ទងនឹងរបបអាហាររបស់អ្នកទោសឡើយ ។

ខណៈពេលដែលត្រូវសួរថា ក្រោយពេលដែលគាត់បានសម្លាប់ក្មេងៗនៅពេលថ្ងៃ តើ ឌុច មើលថែរក្សាក្រុមគ្រួសាររបស់ខ្លួនដោយរបៀបណានៅពេលយប់ ឌុច បានពន្យល់ថា ការរស់រានជីវិតរបស់កូនគាត់ គឺអាស្រ័យលើការរស់រានជីវិតរបស់គាត់ ដូច្នេះហើយគាត់ត្រូវតែធ្វើតាមបញ្ជាគេដើម្បីការពារប្រពន្ធ បងប្អូនទាំងប្រាំមួយនាក់ និងឪពុកម្តាយរបស់គាត់ ។

## មាគ៌ាបដិវត្តន៍អូសទាញរបស់ ឌុច

យោងតាមដំណើរការតាំងពីអាទិត្យមុនមក វាពិតប្រាកដ

ណាស់ថា ឌុច បានធ្វើឲ្យមានភាពខុសប្លែកគ្នាលើគោលការណ៍អនុវត្តដែលមិនត្រូវបានបែងចែកដាច់ពីគ្នាដោយសមហេតុផលឡើយ ។ ជាឧទាហរណ៍ គាំងពីសប្តាហ៍មុន ហើយនៅថ្ងៃនេះម្តងទៀត ឌុច បានពន្យល់ពីវិធីដែលគាត់បានលួចបំផ្លាញការពិសោធន៍ថ្នាំរបស់មេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាម្នាក់គឺ នួន ជា ដោយ ឌុច បានប្តូរម្សៅនៅក្នុងបំពង់ថ្នាំដែលគាត់សង្ស័យថា មានជាតិពុលជាមួយនឹងម្សៅសុវត្ថិភាពមុនពេលប្រគល់បំពង់ថ្នាំទាំងនោះទៅឲ្យអ្នកទោស ។ ឌុច បានពន្យល់ដោយមនោសញ្ចេតនាថា គាត់មិនចង់សម្លាប់អ្នកទោសទាំងនោះដោយដៃរបស់ខ្លួនឯងឡើយ ប៉ុន្តែ ឌុច មិនបានបង្ហាញនូវមនោសញ្ចេតនារបស់គាត់ ខណៈពេលដែលគាត់រៀបរាប់ពីការចេញបញ្ជាឲ្យនាំអ្នកទោសដែលទាំងអស់នោះទៅកម្ទេចចោលភ្លាមៗឡើយ ។ តើវាខុសគ្នាប៉ុនណាទៅរវាងការបញ្ជាឲ្យអ្នកទោសត្រូវចងបិទមុខនិងត្រូវវាយចំកញ្ចឹងកពីក្រោយ និងការឲ្យថ្នាំពុលដល់អ្នកទោសទាំងនោះ? ខណៈពេលដែល ឌុច ទទួលស្គាល់ថា តួនាទីរបស់គាត់បានធ្វើឲ្យគាត់មានទំនួលខុសត្រូវលើការសម្លាប់អ្នកទោសជាងអ្នកដែលសម្លាប់ដោយផ្ទាល់នោះ ឌុច ហាក់បីដូចជាព្យាយាមធ្វើឲ្យមានភាពស្មើគ្នារវាងការអនុវត្តដោយផ្ទាល់លើរូបរាងកាយនិងការត្រូវទទួលខុសត្រូវដោយផ្ទាល់ ។

ឌុច ក៏បានបង្ហាញពីភាពខុសប្លែកគ្នារវាងទម្រង់នៃការធ្វើទារុណកម្មច្រើនបែបផងដែរ ។ ខណៈពេល ឌុច ទទួលស្គាល់ថាខ្លួនបានបញ្ជាឲ្យធ្វើទារុណកម្មដោយការវាយតប់ ទារុណកម្មធ្វើឲ្យថប់ដង្ហើមស្លាប់ ទារុណកម្មបញ្ចូកទឹកចូលក្នុងច្រមុះ និង ទារុណកម្មឆក់ខ្សែភ្លើងលើអង្គជាតិរបស់អ្នកទោសប្រុស ឌុច បានប្រកែកយ៉ាងមានះលើទារុណកម្មដកក្រចកដៃក្រចកជើង ។ ឌុច បាននិយាយថា របៀបធ្វើទារុណកម្មបែបនេះជា «សកម្មភាពឧក្រិដ្ឋកម្ម» ដែល ឌុច បានហាមឃាត់ភ្លាមៗបន្ទាប់ពីបានដឹងពីរឿងនេះ ។ ខណៈពេលដែល ឌុច ហាក់បីដូចជាប្រឆាំងនឹងរបៀបនៃការធ្វើទារុណកម្មបង្ខំឲ្យស៊ីលាមក ដោយសារតែទារុណកម្មនេះមិនមានការអនុញ្ញាតក៏ដោយ ក៏គាត់បានទទួលស្គាល់ថា បានអនុញ្ញាតឲ្យអ្នកសួរចម្លើយបន្តអនុវត្តការធ្វើទារុណកម្មលើផ្នែកសតិអារម្មណ៍ដោយបង្ខំឲ្យអ្នកទោសខ្ទិនគោរពសត្វឆ្កែ ដោយបន្តប្រើប្រាស់វិធីដែលមិនបានអនុញ្ញាតបែបនេះតទៀត ពីព្រោះដោយសារតែការអនុវត្តបែបនេះមានប្រសិទ្ធភាពខ្ពស់ ។ ឌុច ក៏បានបង្ហាញឲ្យឃើញពីភាពស្អប់ខ្ពើមទៅលើការរំលោភសេពសន្ថវៈលើស្ត្រីម្នាក់ដែលធ្លាប់កើតមានម្តងនៅក្នុងគុក ។


ឌុច

នៅពេលដែលមានការពន្យល់យ៉ាងក្បោះក្បាយថា មនុស្សម្នាក់អាចផ្តល់ការពន្យល់ពីភាពខុសប្លែកគ្នាបែបនេះបាន ឌុច មិនបានផ្តល់នូវការពន្យល់នៃភាពខុសប្លែកគ្នាណាមួយឡើយ ។ ឌុច សម្តែងនូវអាកប្បកិរិយាដែលហាក់បីដូចជាភាពខុសប្លែកគ្នាទាំងនោះគ្រាន់តែជារឿងធម្មតាប៉ុណ្ណោះ ។

## តើ ឌុច ធ្វើការងារច្រើនជាងហូបនៅពេលបាយថ្ងៃត្រង់ឬទេ?

នៅក្នុងសំណួរខ្លីៗបន្តបន្ទាប់ លោក វីល្លៀម ស្មីត សហព្រះរាជអាជ្ញាអន្តរជាតិបានព្យាយាមសួរសំណួរបែបប្រយោលដើម្បីប្រមូលយកព័ត៌មានទាក់ទងនឹងទម្លាប់ការងាររបស់ ឌុច ដោយធ្វើការសង្កត់ធ្ងន់លើពេលសម្រាកអាហារថ្ងៃត្រង់ និងល្ងាច ។ ឌុច បានរៀបរាប់ពីការធ្វើការក្នុងមួយថ្ងៃ១២ម៉ោង ជាពេលដែល ឌុច បានហូបអាហារទាំងពីរពេលនៅឯរោងបាយរួមនិងបានចំណាយពេលរបស់គាត់ដែលសេសសល់នៅក្នុងបន្ទប់ធ្វើការដោយមានការចូលជួបពិភាក្សាជាប្រចាំជាមួយថ្នាក់លើ សមមិត្ត ហ៊ី និង ជួបជាមួយជំនួយការលេខាធិការទំនាក់ទំនងទាំងបីនាក់របស់គាត់ ។ លោក ស្មីត បានខិតខំស្វែងរកព័ត៌មានដើម្បីបង្ហាញថា ឌុច ហូបអាហារពីរពេល ក្នុងមួយថ្ងៃនៅក្នុងបន្ទប់ដែលមានអ្នកយាម អ្នក



សួរចម្លើយ និងបុគ្គលិកក្នុងមន្ទីរស-២១នៅជុំវិញ ។ ឌុច បាន អះអាងថា គាត់មិនដែលនិយាយជាមួយនរណាឡើយ ក្រៅពីអ្នក ហូបបាយរួមតុជាមួយគាត់ ដូចជាសមមិត្ត ហ៊ី ជាដើម ហើយ ឌុច និយាយទៀតថា គាត់ហូបបាយលឿនណាស់ដើម្បីប្រញាប់ទៅ សម្រាក ហើយត្រឡប់មកធ្វើការវិញ ។ បើពិនិត្យទៅតាមការ អះអាងរបស់ ឌុច ដែលថាខ្លួនបានទៅត្រួតពិនិត្យមន្ទីរស-២១ ម្តងម្កាល និងបានដឹងពីប្រតិបត្តិការប្រចាំថ្ងៃរបស់មន្ទីរនេះបាន តិចតួចនោះ យើងអាចសន្មតបានថា លោក ស្មីត នឹងព្យាយាម ធ្វើឲ្យ ឌុច ទទួលស្គាល់ថា គាត់បានចេញបញ្ជា ឬក៏មានទំនាក់ទំនង ស្និទ្ធស្នាលក្នុងអំឡុងពេលហូបអាហារពេលល្ងាចតាមរយៈសក្ខីកម្ម របស់សាក្សី ។

បើពិនិត្យទៅតាមការអះអាងរបស់ ឌុច ដែលថា គាត់បាន ធ្វើតាមបញ្ជាថ្នាក់លើបក្សកុម្មុយនីស្តកម្ពុជាដោយសារតែភាព ភ័យខ្លាចនោះ លោក ស្មីត បានសួរសំណួរច្រើនប្រភេទក្នុងបំណង ចង់បង្ហាញថា តាមពិត ឌុច មិនមានភាពភ័យខ្លាចអ្វីសោះឡើយ ។ ឌុច បានទទួលស្គាល់ថា ថ្នាក់លើរបស់គាត់មិនដែលរអ៊ូរទាំពីការងារ របស់គាត់ឡើយ ហើយថែមទាំងជឿទុកចិត្តគាត់ថែមទៀតផង ដោយសារតែភាពស្មោះស្ម័គ្រ និងស្មោះត្រង់របស់គាត់ ។ ប៉ុន្តែ ឌុច បានរៀបរាប់ពីការរស់នៅក្នុងភាពភ័យខ្លាច ដែលកើតមានខ្លាំង ឡើងខណៈពេលដែលអតីតថ្នាក់លើរបស់គាត់គឺ វ៉ន វ៉េត ត្រូវបាន ចាប់ខ្លួន ។ ឌុច បានបញ្ជាក់នៅត្រង់ចំណុចនេះថា គាត់មិនហូប ឬ ធ្វើការឡើយ ពីព្រោះខ្លួនគាត់កំពុងតែរង់ចាំស្លាប់ ។ យ៉ាងណាមិញ លោក ស្មីត បានអាននូវឯកសារមួយភ្ជាប់ជាមួយនឹងចំណារដោយ ផ្ទាល់ដៃរបស់ ឌុច ក្នុងអំឡុងពេលនោះដែលចំណារនេះបានបញ្ជាក់ ថា តាមពិត ឌុច នៅតែបន្តធ្វើការតាមធម្មតា ។

### ការពិភាក្សាវែកញែកបន្តលើតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី

គ្មាននរណាក្នុងបន្ទប់សវនាការបដិសេធលើសារសំខាន់នៃដើម បណ្តឹងរដ្ឋប្បវេណីឡើយ ប៉ុន្តែ គ្មាននរណាម្នាក់អាចនិយាយយ៉ាង ច្បាស់ថា តើតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានអ្វីខ្លះនោះទេ ។

កាលពីថ្ងៃទី១៦ ខែកក្កដា បន្ទាប់ពីចៅក្រមបានផ្តល់ពេល វេលាបន្ថែមដល់ដើមបណ្តឹងរដ្ឋប្បវេណីដើម្បីសួរសំណួរ ឌុច អំពី ប្រតិបត្តិការរបស់មន្ទីរស-២១ ក្រុមប្រឹក្សាមេធាវីការពារក្តីអន្តរ ជាតិ ហ្វ្រង់ស្វ័រ រូ បានចាប់ផ្តើមពិភាក្សាវែកញែកពីតួនាទីរបស់ដើម បណ្តឹងរដ្ឋប្បវេណីដោយនិយាយរួមបញ្ចូលទាំងតួនាទីរបស់ព្រះរាជ អាជ្ញាជាមួយគ្នា ។ លោក រូ បាននិយាយទទូចថា ពេលវេលាដែល មិនស្មើគ្នារយៈពេលប្រាំមួយម៉ោងសម្រាប់ព្រះរាជអាជ្ញាជាន់ខ្ពស់ ហើយរយៈពេលតែបួនម៉ោងសម្រាប់មេធាវីការពារក្តី អាចក្លាយជា ប្រធានបទមួយសម្រាប់បណ្តឹងឧទ្ធរណ៍នៅដំណាក់កាលក្រោយ ។ នៅថ្ងៃនោះ ព្រះរាជអាជ្ញាបាននិយាយបញ្ជាក់យ៉ាងច្បាស់លាស់ ពីតួនាទីជាក់លាក់របស់ខ្លួន ស្របពេលដែលដើមបណ្តឹងរដ្ឋប្បវេណី បានពន្យល់ថា ដើមបណ្តឹងរដ្ឋប្បវេណីមិនមានតួនាទីដូចនឹងព្រះរាជ អាជ្ញាទេ ប៉ុន្តែមានតួនាទីធ្វើយ៉ាងណាឲ្យសំឡេងនិងទស្សនៈរបស់ ជនរងគ្រោះបានទទួលការដឹងឮតែប៉ុណ្ណោះ ។ ចៅក្រមបានបញ្ឈប់ ការពិភាក្សាវែកញែកនេះ ហើយបន្តដំណើរការទៅមុខទៀត ដោយគ្មានការបញ្ចេញនូវមតិយោបល់អ្វីឡើយ ។

ថ្ងៃនេះ ការពិភាក្សាវែកញែកប្រហាក់ប្រហែលគ្នាបានកើត មានឡើងម្តងទៀតនៅក្នុងទិដ្ឋភាពផ្សេងមួយ ។ ខណៈពេលដែល មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់កំពុងចោទសួរ ឌុច អំពី ដំណើរពិសោធន៍ថ្នាំពេទ្យដែល ឌុច បានបំផ្លាញនោះ មេធាវីការពារក្តី លោក រូ បានធ្វើការបដិសេធថា ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវ បានទទួលផលប៉ះពាល់ដោយផ្ទាល់ពីអង្គហេតុនៅចំពោះមុខនេះទេ

ពីព្រោះថាមិនមានដើមបណ្តឹងរដ្ឋប្បវេណីណាមួយបានទទួលរងគ្រោះថ្នាក់ឡើយ ។ លោក រូ បាននិយាយថា សំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណីគួរតែបង្ហាញពីទស្សនៈរបស់ជនរងគ្រោះមិនមែនសួរសំណួររបស់ព្រះរាជអាជ្ញាសាឡើងវិញនោះទេ ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណី អ្នកស្រី ស៊ីលកេ ស្ទូដហ្ស៊ីនស្គី បានសុំសេចក្តីណែនាំពីចៅក្រមថា តើអ្នកស្រីត្រូវធ្វើការឆ្លើយតបទៅនឹងការចោទសួរជាមូលដ្ឋានទាក់ទងនឹងតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីបែបនេះដោយរបៀបណា ខណៈពេលនោះមេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោក អាឡាំង វែណឺ បានផ្តល់នូវដំណោះស្រាយលើចម្ងល់នេះ ដោយបញ្ចេញយោបល់ថា លោក រូ មិនបានធ្វើការចោទសួរពីតួនាទីដែលដើមបណ្តឹងរដ្ឋប្បវេណីមាននៅក្នុងអង្គជំនុំជម្រះក្តីនេះទេ ប៉ុន្តែ លោក រូ គ្រាន់តែសូមឲ្យដើមបណ្តឹងប្បវេណីមិនសួរសំណួរដដែលសាឡើងវិញម្តងទៀតប៉ុណ្ណោះ ។

តាមពិត លោក រូ បានកំពុងតែធ្វើឲ្យមាននូវបញ្ហាធំ ។ លោក រូ បានឆ្លើយតបថា លោកមិនមែនធ្វើការរឹតបន្តឹងទៅលើតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីទេ លោកគ្រាន់តែចង់ឲ្យតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានភាពខុសប្លែកគ្នាដាច់ដោយឡែកពីតួនាទីព្រះរាជអាជ្ញា ។ លោក រូ បានអានអត្ថបទដែលសរសេររៀបរាប់ពីជនរងគ្រោះដែលដើរ «តួនាទីបន្ទាប់...» ។ លោក រូ បាននិយាយថា សំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណីគួរតែពាក់ព័ន្ធទៅនឹងភាពរងទុក្ខវេទនារបស់ជនរងគ្រោះតែមួយគត់ ហើយដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែប្រកាន់ខ្ជាប់តួនាទីរបស់ពួកគេដើម្បីធានាឲ្យបាននូវការជំនុំជម្រះក្តីប្រកបដោយសមធម៌មួយ ។

ក្រោយពីការបញ្ចេញមតិយោបល់ក្តៅគគុកជាបន្តបន្ទាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីមក ចៅក្រមបានចូលអន្តរាគមន៍ ។ ក្នុងការបញ្ចេញយោបល់យ៉ាងខ្លី លោកប្រធាន និល ណុន បានស្រង់វិធានផ្ទៃក្នុងលេខ២៣.១ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយបាននិយាយថា អង្គជំនុំជម្រះនឹងអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីសួរសំណួរដើម្បីគាំទ្រព្រះរាជអាជ្ញា ។ លោកប្រធាន បានផ្តល់នូវសេចក្តីក្រើនរំឭកខ្លះដល់ដើមបណ្តឹងរដ្ឋប្បវេណីអំពីការសួរសំណួរណាដែលខ្លី ហើយទាក់ទងនឹងអង្គហេតុ ប៉ុន្តែលោកប្រធានមិនបានផ្តល់នូវសេចក្តីបញ្ជាក់បន្ថែមអំពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ ។ ដោយគ្មានការបញ្ចេញយោបល់បន្ថែមលើបញ្ហានេះ យើងអាចសន្និដ្ឋានបានថា នេះមិនមែនជាលើកចុងក្រោយដែលតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានយកមកពិភាក្សាវែកញែកទេ ។

វិធានផ្ទៃក្នុងលេខ២៣.១ បានចែងថា គោលដៅនៃសកម្មភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺ «ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌរបស់ជនត្រូវចោទដែលទទួលខុសត្រូវលើឧក្រិដ្ឋកម្មក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយធ្វើការគាំទ្រព្រះរាជអាជ្ញា» (ការបញ្ជាក់បន្ថែម) ។ ជាមួយគ្នាផងដែរ វិធានលេខ៩០ បានចែងថា បន្ទាប់ពីចៅក្រមចោទសួរជនត្រូវចោទ «សហព្រះរាជអាជ្ញា និងភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ រួមទាំងមេធាវីការពារក្តីមានសិទ្ធិចោទសួរទៅកាន់ជនត្រូវចោទបាន» ។ វិធានផ្ទៃក្នុងទាំងនេះមិនបាននិយាយអំពីព្រំដែនកំណត់ណាមួយលើតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ ។

## ការគ្រប់គ្រងពេលវេលាពេលខ្លះអាចខាតបង់ពេលវេលា

ចាប់តាំងពីការប្រជុំអំពីការគ្រប់គ្រងដោយសម្ងាត់របស់តុលាការកាលពីថ្ងៃទី១១ ខែកក្កដា មក ចៅក្រមបានបង្កើនការយកចិត្តទុកដាក់ទៅលើការគ្រប់គ្រងពេលវេលា និងបានអនុវត្តលើព្រំដែនកំណត់ថ្មីសម្រាប់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ។ ថ្ងៃនេះគឺជាលើកដំបូងបង្អស់ដែលការកំណត់ពេលវេលាបែបនេះត្រូវបានគោរពជាផ្លូវការ ។ ក្រោយពីរយៈពេលកំណត់៣ម៉ោងសម្រាប់ការចោទសួរទៅកាន់ ឌុច ព្រះរាជអាជ្ញាបានស្នើសុំ២០នាទីបន្ថែមដើម្បីសួរលើប្រធានបទ «ស្នូល» ។ បន្ទាប់ពីរយៈពេល១០នាទីនៃការពិភាក្សាវែកញែកដែលមេធាវីការពារក្តីបានជជែកវែកញែកថា ព្រះរាជអាជ្ញាគួរតែគ្រប់គ្រងពេលវេលារបស់ខ្លួនឲ្យបានល្អប្រសើរជាងនេះ ហើយដើមហេតុនៃសារសំខាន់បែបនេះគួរតែត្រូវបានផ្តល់អាទិភាពចម្បង ចៅក្រមបានចេញនូវសេចក្តីបញ្ជាក់ស្របតាមសំណូមពររបស់ព្រះរាជអាជ្ញាដែលមានបំណងចង់បញ្ចប់នូវសំណួររបស់ខ្លួន ហើយអនុញ្ញាតឲ្យព្រះរាជអាជ្ញាបន្តការចោទសួរតទៅទៀត ។

**ឡូរ៉ា ម៉ាក់ដូណាល**

# ការឆ្លើយតបទៅនឹងអំពើប្រល័យពូជសាសន៍ ៖ តួនាទីរបស់ស្ថាប័នផ្សេងៗ

## នៅក្រោយរបបប្រល័យពូជសាសន៍ តើអ្វីជាគោលបំណងដ៏សំខាន់របស់យើងដែលត្រូវបំពេញ?

ក្រោយពីរបបប្រល័យពូជសាសន៍ យើងគួរតែឆ្លើយតបទៅនឹងគោលបំណងសំខាន់ចំនួនពីរ ។ ទីមួយ គឺត្រូវដោះស្រាយនូវទុក្ខវេទនារបស់ជនរងគ្រោះផ្ទាល់ ដែលគេហៅជាទូទៅថា «ដំណាក់កាលនៃការព្យាបាលរបួសផ្លូវចិត្ត» ។ ដំណាក់កាលនេះគឺទាក់ទងទៅនឹងការព្យាយាមព្យាបាលស្មារតីរបស់ជនរងគ្រោះក្នុងនោះគឺការជួយជនរងគ្រោះឲ្យស្គាល់ពីតម្លៃខ្លួនឯងឡើងវិញ និងបង្កើតនូវទំនុកចិត្តរបស់ជនរងគ្រោះចំពោះអ្នកដទៃដែលបានបាត់បង់ក្នុងអំឡុងនៃរបបប្រល័យពូជសាសន៍ ព្រោះតម្លៃនិងទំនុកចិត្តរបស់បុគ្គលពិតជាមានតម្លៃខ្លាំងណាស់ ។ ការទទួលស្គាល់ថា អំពើប្រល័យពូជសាសន៍ពិតជាកើតមានមែន ការដឹងកំហុសរបស់ជនដៃដល់ និងភាពគ្មានកំហុសរបស់ជនរងគ្រោះ គឺជាសមាសភាពដ៏សំខាន់នៃការព្យាបាលរបួសផ្លូវចិត្តរបស់ជនគ្រោះ ។ គោលបំណងទីពីរគឺទាក់ទងទៅនឹងការស្វែងរកការពិតនិងយុត្តិធម៌ក្នុងកម្រិតសហគមន៍ កម្រិតជាតិ និងអន្តរជាតិ ។ ក្នុងន័យនេះ យើងអាចមើលឃើញកាន់តែច្បាស់ថា ការសន្យាមួយរបស់សហគមន៍អន្តរជាតិនៅតែមិនអាចធ្វើបាន គឺពាក្យស្លោកដែលគេតែងតែនិយាយថា «អំពើប្រល័យពូជសាសន៍មិនអាចកើតមានជាថ្មីម្តងទៀតបានជាដាច់ខាត» ។ នៅពេលនេះ យើងរកឃើញនូវភាពច្នៃប្រឌិតជាច្រើនដើម្បីស្តាបនាសង្គមស៊ីវិលក្នុងការបង្កើតនីតិរដ្ឋ និងការចងចាំជាប្រវត្តិសាស្ត្រទាំងនៅក្នុងប្រទេសដែលកើតមានអំពើប្រល័យពូជសាសន៍និងទាំងក្នុងកម្រិតអន្តរជាតិ ។ គោលបំណងទាំងពីរខាងលើនេះ គឺនៅតែត្រូវបានបន្តដោះស្រាយឥតឈប់ឈរ ហើយការឆ្លើយតបឲ្យបានពេញលេញនោះពិតជាមិនអាចធ្វើទៅបានឡើយ ។ ជនរងគ្រោះភាគច្រើនមិនដែលទទួលបាននូវការព្យាបាល ឬអាចបំភ្លេចបាននូវអ្វីដែលខ្លួនបានជួបប្រទះនោះទេក្រោយពីរបបប្រល័យពូជសាសន៍ត្រូវបានបញ្ចប់ ។ ហើយការគំរាមកំហែងចំពោះលទ្ធភាពនៃការកើតមានឡើងនូវអំពើប្រល័យពូជសាសន៍នាពេលអនាគតនៅតែបន្តកើតមាន ។

## តើអ្វីជាឧបសគ្គនៅពេលដែលយើងកំពុងបំពេញកិច្ចការដើម្បីសម្រេចគោលបំណងនេះ?

ទោះជាមានផលវិបាកខ្លាំងក្នុងការសម្រេចគោលបំណងរបស់យើងក៏ដោយ ក៏ភាពបរាជ័យមិនមានទំហំធំឡើយ ។ សម្រាប់ជនរងគ្រោះ អ្វីដែលជាបញ្ហាគឺសមត្ថភាពនៃការគ្រប់គ្រងអារម្មណ៍ខ្លួនឯងចំពោះហេតុការណ៍នៃការប៉ះទង្គិចផ្លូវចិត្តទាំងឡាយដែលគាត់បានជួបប្រទះ ដែលហេតុការណ៍ទាំងនោះអាចជាការរំខានដល់ភាពសុខសាន្តរបស់បុគ្គលនិងគ្រួសារ ចាប់ពីការរំខានដល់ការសម្រាន្តនៅពេលយប់រហូតដល់ការប៉ះពាល់ដល់អារម្មណ៍នៃការស្រឡាញ់និងសុភមង្គល ។ សម្រាប់សាធារណជនទូទៅវិញ (ឧទាហរណ៍ ដូចជាអ្នកដែលមិនបានឆ្លងកាត់របបប្រល័យពូជសាសន៍ដោយផ្ទាល់) និងសម្រាប់ជនរងគ្រោះផ្ទាល់ អ្វីដែលជាបញ្ហាគឺទាក់ទងទៅនឹងជំនឿជាមូលដ្ឋានទៅលើមនុស្សធម៌និងសមត្ថភាពរបស់យើងក្នុងការទប់ស្កាត់ ឬយ៉ាងហោចណាស់យើងត្រូវបញ្ឈប់នូវអ្វីដែលលោក រ៉ាហ្វែល លីមគិន និយាយថាជាឧក្រិដ្ឋកម្មដ៏អាក្រក់បំផុតរបស់មនុស្សជាតិ ។

## តើការសម្រេចគោលបំណងរបស់យើងមានប្រសិទ្ធភាពប៉ុនណា?

នៅក្រោយពីរបបប្រល័យពូជសាសន៍ យើងបានឃើញជនរងគ្រោះ និងអ្នកផ្សេងទៀតនៅក្នុងសង្គមទាំងមូល មានដូចជាអ្នកនយោបាយ អ្នកច្បាប់ អ្នកសិក្សា អ្នកផ្តល់ប្រឹក្សា សកម្មជនប្រជាជនទូទៅបានធ្វើការរួមគ្នាដើម្បីបង្កើតឡើងនូវកម្មវិធីព្យាបាលរបួសផ្លូវចិត្ត និងដើម្បីស្វែងរកបុព្វហេតុយុត្តិធម៌ ។ ទោះបីជាយើងខិតខំប្រឹងប្រែងខ្លាំងប៉ុនណាក៏ដោយ ការសម្រេចបានតាមគោលបំណងរបស់យើង ហាក់បីដូចជាទទួលលទ្ធផលតិចតួចនៅឡើយ ។ ពេលដែលអំពើប្រល័យពូជសាសន៍ កំពុងតែកើតមានឡើងនៅតំបន់ដាហ្វ៊ូរ ប្រទេសស៊ូដង់ ជាការពិតអំពើប្រល័យពូជសាសន៍នៅតែបន្តមានឡើង ។ ភាពខ្វាចផ្សារបស់ប្រជាជននៅតែជាក្តីបារម្ភរបស់យើង ហើយម្យ៉ាងវិញទៀតចំនួននៃជនរងគ្រោះ

ដែលទទួលរងនូវការប៉ះទង្គិចខាងផ្លូវចិត្តកំពុងតែកើនឡើងដល់រាប់លាននាក់ ។ អំពើប្រល័យពូជសាសន៍នៅតែជាបញ្ហាដ៏ស្មុគស្មាញជាទីបំផុត ដែលមានចំណាស់ដូចគ្នានឹងមនុស្សជាតិដែរ ចំណែកឯការខិតខំប្រឹងប្រែងរបស់យើងដើម្បីដោះស្រាយជាមួយបញ្ហាទាំងអស់នោះនៅមានលក្ខណៈថ្មីសន្ធាងនៅឡើយ ។ យើងទើបតែចាប់ផ្តើមធ្វើការដោះស្រាយបញ្ហាទាំងនោះបានតែប្រមាណជា ៥០ឆ្នាំប៉ុណ្ណោះ ហើយយើងដឹងច្បាស់ថា យើងត្រូវធ្វើដំណើរទៅមុខយូរទៀត ។ ខណៈពេលដែលយើងព្យាយាមដើម្បីធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃការឆ្លើយតបទៅនឹងការដោះស្រាយចំពោះអំពើប្រល័យពូជសាសន៍ យើងត្រូវតែបន្តសួរខ្លួនឯងថាតើអ្វីខ្លះដែលជួយយើងនិងជាការរាំងស្ទះដល់កិច្ចប្រឹងប្រែងរបស់យើងក្នុងការសម្រេចឲ្យបាននូវគោលបំណងនេះ ។

**តើស្ថាប័នទាំងឡាយប៉ះពាល់ដល់កិច្ចប្រឹងប្រែងរបស់យើងយ៉ាងដូចម្តេច?**

ចំណុចដែលខ្ញុំតែងតែធ្វើការសន្និដ្ឋានគឺថា ៖ ទោះជាលទ្ធផលនៃការប្រឹងប្រែងរបស់យើង (ល្អផងនិងមិនល្អផង) អាចផ្តល់ជូនក្នុងកម្រិតបុគ្គលក៏ដោយ ក៏លទ្ធផលដែលទទួលបាននោះគឺអាចជាជំនួយដល់បុគ្គលបាន (ដូចជាជំនួយផ្នែកហិរញ្ញវត្ថុ ឬក៏ម្យ៉ាងទៀតជំនួយខាងការចាត់ចែង) ដោយស្ថាប័នដែលមានស្រាប់ដូចជាប្រពន្ធ័យុត្តិធម៌និងនយោបាយ សាកលវិទ្យាល័យ អង្គការមូលនិធិនិងស្ថាប័នបោះពុម្ពផ្សាយនានាដែលអាចជាជំនួយនិងអាចជាការរាំងស្ទះដល់កិច្ចខំប្រឹងប្រែងជាបុគ្គលរបស់យើង ។ យើងប្រកាន់គោលជំហរថា បើយើងដឹងថាស្ថាប័នទាំងនេះមានឥទ្ធិពលមកលើយើងកាន់តែខ្លាំង នោះលទ្ធផលរបស់យើងដែលទទួលបានពីការស្វែងរកគោលដៅចុងក្រោយរបស់យើងមានចំនួនកាន់តែច្រើនដែរ ។ ក្នុងការដែលយើងដឹងថា ស្ថាប័ននានាដូចជាស្ថាប័ននយោបាយ ច្បាប់ សិក្សាធិការនិងអប់រំជះឥទ្ធិពលដល់កិច្ចការងាររបស់យើងក្នុងការជួយផ្តល់នូវការព្យាបាល និងដំណើរការស្វែងរកយុត្តិធម៌ កត្តាមួយក្នុងចំណោមកត្តាដំបូង ដែលយើងសង្កេតឃើញគឺថា អ្វីដែលស្ថាប័នទាំងអស់នោះកំពុងធ្វើដោយអនុលោមតាមក្រឹត្យក្រមច្បាប់ អាទិភាព និងអនុសញ្ញារបស់គេគឺមិនសុទ្ធតែស្របគ្នាទៅនឹងគោលបំណងរបស់យើងទេ ។ ដើម្បីឲ្យយល់ពីបញ្ហានេះកាន់តែជ្រាលជ្រៅជាងនេះថែមទៀត យើងនឹងតាមដានមើលគ្រប់ស្ថាប័ននីមួយៗ ដោយចាប់ផ្តើមពីស្ថាប័ននយោបាយឬរដ្ឋាភិបាលទៅ ។

**តើស្ថាប័ននយោបាយនានា មានដូចជាអង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ អាចជួយដល់កិច្ចការងាររបស់យើងដោយវិធីណាដើម្បីជួយក្នុងព្យាបាលរបួសផ្លូវចិត្ត និងការស្វែងរកយុត្តិធម៌?**

ស្ថាប័ននយោបាយមួយចំនួនបានជះឥទ្ធិពលដល់កិច្ចការងាររបស់យើងច្រើនជាងស្ថាប័នដទៃទៀត ព្រោះស្ថាប័ននយោបាយទាំងនោះមានឥទ្ធិពលមកលើស្ថានភាពការងាររបស់យើងពេលដែលយើងកំពុងបំពេញការងារ ។ បើសិនជាគ្មានការគាំទ្រពីរដ្ឋាភិបាលទេ នោះនឹងមានការលំបាកក្នុងការទទួលបាននូវការអនុញ្ញាតការគាំទ្រខាងផ្លូវច្បាប់ ហិរញ្ញវត្ថុ និងសន្តិសុខ ដើម្បីអនុវត្តកិច្ចការរបស់យើង ។ ហេតុដូច្នេះហើយស្ថាប័ននយោបាយមានឥទ្ធិពលយ៉ាងខ្លាំងដល់ដំណើរការការងាររបស់យើង ហើយជាអ្នកកំណត់ថាតើត្រូវជួយឬបង្កើតជាការរាំងស្ទះដល់គោលដៅរបស់យើង ។

**តើស្ថាប័ននយោបាយអាចជាការរាំងស្ទះដល់ដំណើរការងាររបស់យើងយ៉ាងដូចម្តេច?**

មនុស្សភាគច្រើននឹងយល់ស្របថា ការទទួលខុសត្រូវខ្ពស់បំផុតរបស់រដ្ឋាភិបាល គឺការរក្សាបាននូវសន្តិសុខជាតិនិងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ។ ប៉ុន្តែដោយសារតែរដ្ឋាភិបាលមានយុទ្ធសាស្ត្រផ្សេងៗគ្នាដើម្បីសម្រេចបាននូវគោលបំណងទាំងពីរខាងលើនេះ គោលនយោបាយរបស់រដ្ឋាភិបាលអាចជាការរាំងស្ទះ ហើយការបំពេញការងាររបស់យើងអាចត្រូវបានកំណត់ដោយរដ្ឋាភិបាល ក្នុងការបង្កើតឲ្យមាននូវការព្យាបាលរបួសផ្លូវចិត្ត និងដំណើរការស្វែងរកយុត្តិធម៌ ។ គោលនយោបាយរបស់រដ្ឋាភិបាលអាចគ្របដណ្តប់ដល់ការងាររបស់យើង ។ ចំណុចមួយសំខាន់គឺថាជនរងគ្រោះអាចនឹងមិនអើពើដល់រដ្ឋាភិបាល ដោយសាររដ្ឋាភិបាលផ្តល់អាទិភាពទៅលើតែសេដ្ឋកិច្ចនិងនយោបាយជាជាងទៅលើជនរងគ្រោះផ្ទាល់ ។ ចំណុចម្យ៉ាងទៀត គឺថាអាចនឹងមានការយកចិត្តទុកដាក់ដ៏ស្មោះស្ម័គ្រដល់សេចក្តីត្រូវការនិងយុត្តិធម៌សម្រាប់ជនរងគ្រោះ ខណៈពេលដែលរដ្ឋាភិបាលព្យាយាមរក្សា

បាននូវស្ថិរភាព សន្តិសុខជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ។ ជាទូទៅយើងមើលឃើញថា រដ្ឋាភិបាលមិនបានផ្តល់អាទិភាពសម្រាប់សេចក្តីត្រូវការនិងយុត្តិធម៌ដល់ជនរងគ្រោះដូចការដែលខ្លួនផ្តល់អាទិភាពទៅលើអ្វីដែលគេហៅថា ផែនការជាយុទ្ធសាស្ត្រសម្រាប់ប្រទេសជាតិ ដែលប្រការនេះហើយអាចឲ្យមានការរាំងស្ទះដល់កិច្ចការងាររបស់យើង ។

***តើយើងគួរធ្វើអ្វីខ្លះដើម្បីធ្វើឲ្យស្ថាប័ននយោបាយជះឥទ្ធិពលមកលើយើងឲ្យបានតិចបំផុតក្នុងការរាំងស្ទះដល់កិច្ចការងាររបស់យើង?***

រហូតមកដល់ពេលថ្មីៗនេះ សេចក្តីត្រូវការរបស់ជនរងគ្រោះនិងបុព្វហេតុស្វែងរកយុត្តិធម៌កំពុងតែប្រកួតប្រជែងជាមួយនឹងផែនការជាអាទិភាពរបស់រដ្ឋាភិបាល ។ បើតាមការគិតឃើញរបស់យើង រដ្ឋត្រូវតែជ្រើសរើសផែនការជាអាទិភាពមួយឬផ្សេងទៀត ហើយមិនអាចជ្រើសរើសទាំងពីរបានទេ ។ ទោះជាយ៉ាងនេះក្តី ការគិតឃើញរបស់យើងនេះគឺកំពុងតែជាបញ្ហាដ៏សំខាន់ ហើយទស្សនវិស័យនយោបាយថ្មីមួយទៀតក៏កំពុងតែលេចចេញជារូបរាងផងដែរ ។

អ្នកស្រី សាម៉ាន់ថា ផាវវ័រ បានសរសេរយ៉ាងក្បោះក្បាយអំពីរដ្ឋាភិបាលសហរដ្ឋអាមេរិកក្នុងការឆ្លើយតបទៅនឹងអំពើប្រល័យពូជសាសន៍ក្នុងសតវត្សរ៍ទី២០នេះ ដោយបញ្ជាក់ថាតម្រូវការរបស់ជនរងគ្រោះនិងសង្គមស៊ីវិល ហាក់បីដូចជាមិនមែនជាអាទិភាពនៅក្នុងនយោបាយរដ្ឋបាលទេ ព្រោះសាធារណជនទូទៅមិនបានដោះស្រាយទៅនឹងអ្វីដែលបានកើតឡើង ដោយសារតែអំពើប្រល័យពូជសាសន៍ ហើយរដ្ឋាភិបាលហាក់បីដូចជាមានការបារម្ភខ្លាំងចំពោះការធ្លាក់ចុះនូវវិស័យនានា ដូចជាវិស័យសេដ្ឋកិច្ចនយោបាយ និងយោធាដែលមានអាទិភាពធំជាងសេចក្តីត្រូវការរបស់ជនរងគ្រោះ ហើយរដ្ឋមិនបានដោះស្រាយបទឧក្រិដ្ឋដ៏ព្រៃផ្សៃបំផុតនោះទេ ។ ដាហ្វ័រគឺជាអ្វីដែលយើងមើលឃើញច្បាស់ ។

តាំងពីឆ្នាំ២០០៣មក ប្រតិកម្មរបស់សាធារណជនជុំវិញពិភពលោកបានសាយភាយដើម្បីឆ្លើយតបទៅនឹងអំពីប្រល័យពូជសាសន៍នៅដាហ្វ័រ ប្រទេសស៊ូដង់ ហើយប្រតិកម្មទាំងនោះបានបង្ហាញនូវការទាមទារដ៏រៀបរយមួយ ដើម្បីឲ្យរដ្ឋាភិបាលឆ្លើយតបឲ្យមានប្រសិទ្ធភាពទៅនឹងអំពើប្រល័យពូជសាសន៍ក្នុងការផ្តល់ជាអាទិភាពដល់តម្រូវការរបស់ប្រជាជន និងបុព្វហេតុស្វែងរកយុត្តិធម៌ ។ លើសពីនេះទៅទៀត នេះជាលើកទីមួយហើយនៅក្នុងប្រវត្តិសាស្ត្រ ដែលប្រធានរដ្ឋស្តីទីត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ខណៈពេលដែលអំពើប្រល័យពូជសាសន៍កំពុងតែកើតមានឡើង ។ ជាបណ្តើរៗ ការឆ្លើយតបទៅ



ចច ដីហ្គាស កំពុងធ្វើបឋកថាទៅកាន់គ្រូបង្គោលថ្នាក់ជាតិ

នឹងអំពើប្រល័យពូជសាសន៍ក្នុងក្របខ័ណ្ឌនយោបាយគឺកំពុងតែដំណើរការទៅមុខដោយការមើលឃើញថាបុព្វហេតុយុត្តិធម៌និងផែនការយុទ្ធសាស្ត្រ ជាអាទិភាពរបស់រដ្ឋគឺមិនមែនស្ថិតក្នុងទិសដៅផ្ទុយគ្នាដូចមុនទៀតទេ ។ តាមការអះអាងខាងលើនេះ បុព្វហេតុយុត្តិធម៌និងផែនការយុទ្ធសាស្ត្រជាអាទិភាពរបស់រដ្ឋាភិបាលគឺត្រូវផ្សារភ្ជាប់គ្នាទៅវិញទៅមក អាចនិយាយបានថាមិនអាចមានមួយដោយគ្មានមួយទៀតបានទេ ។ តាមការសន្យាទាក់ទងទៅនឹងបញ្ហាខាងលើនេះ រដ្ឋបាលអូបាម៉ា ដែលទើបចូលកាន់ដំណែងបានបញ្ជាក់ថារដ្ឋនីមួយៗត្រូវតែដាក់ច្បាស់ក្នុងឆន្ទៈរបស់ខ្លួនដោយមិនត្រូវព្រងើយកន្តើយអំពីបញ្ហាសន្តិសុខ ឬតម្រូវការរបស់រដ្ឋឡើយ ។ គោលជំហរថ្មីនេះបានបង្ហាញនូវការចាប់ផ្តើមទំព័រដ៏មានសារសំខាន់ថ្មីមួយ ក្រោយពីគោលនយោបាយចាស់ ដោយសំដៅទៅលើគោលនយោបាយពិតប្រាកដ ។ ក្នុងការពិភាក្សារបស់យើងនៅពេលនេះគឺថា ការផ្លាស់ប្តូរវិស័យជាអាទិភាពអាចផ្តល់ផលល្អជាទូទៅ ដែលស្ថាប័ននយោបាយនៅតែមានតួនាទីក្នុងការជួយឬការធ្វើឲ្យរាំងស្ទះដល់កិច្ចការរបស់យើងនាពេលអនាគត ។

## តើស្ថាប័នច្បាប់អាចជួយដល់កិច្ចការរបស់យើងដោយវិធីណាដើម្បីជួយដល់ការព្យាបាលរបួសផ្លូវចិត្តសម្រាប់ជនរងគ្រោះនិងបុព្វហេតុស្វែងរកយុត្តិធម៌?

ខណៈពេលដែលយើងលើកយកស្ថាប័នជាច្រើនមកពិភាក្សានៅពេលនេះ ហើយសុទ្ធតែមានសារសំខាន់និងចាំបាច់តាមបែបផែនផ្សេងៗគ្នា ការឆ្លើយតបខាងផ្លូវច្បាប់អាចផ្តល់ជាជំនួយធំបំផុត និងដោយផ្ទាល់ទៅនឹងកិច្ចការរបស់យើងក្នុងការព្យាបាលរបួសផ្លូវចិត្តនិងការស្វែងរកយុត្តិធម៌ ។ យើងត្រូវកត់ចំណាំថាតាមការអនុវត្តជាក់ស្តែង ប្រព័ន្ធផ្លូវច្បាប់មិនមានអំណាចអ្វីទេប្រសិនបើគ្មានការគាំទ្រពីស្ថាប័ននយោបាយ ។ ស្រដៀងគ្នានោះដែរ ក្នុងការដែលស្ថាប័ននយោបាយផ្តល់នូវលទ្ធភាពគ្រប់យ៉ាងសម្រាប់កិច្ចការរបស់យើងក្នុងការជួយព្យាបាលរបួសផ្លូវចិត្តនិងស្វែងរកយុត្តិធម៌ ស្ថាប័ននយោបាយក៏បានផ្តល់នូវការគាំទ្រដ៏ចាំបាច់ដល់ប្រព័ន្ធផ្លូវច្បាប់ផងដែរដើម្បីដោះស្រាយករណីបណ្តឹងនិងស្វែងរកជនដៃដល់មកកាត់ទោស ។ ដោយមានការគាំទ្រផ្នែកនយោបាយ ប្រព័ន្ធផ្លូវច្បាប់អាចជួយដល់កិច្ចការរបស់យើងក្នុងករណីដែលស្ថាប័នដទៃទៀតមិនអាចមានលទ្ធភាព ។ តាមផ្លូវច្បាប់មានតែតុលាការមួយគត់ដែលអាចកំណត់ថា ជនដៃដល់គឺជាជនដែលបានប្រព្រឹត្តបទល្មើសពិតប្រាកដ ហើយជនរងគ្រោះគឺជាជនសុចរិតដែលត្រូវបានទទួលស្គាល់ជាសាធារណៈ ។ អំឡុងពេលនៃដំណើរការតាមផ្លូវច្បាប់ ភស្តុតាងត្រូវបានបង្ហាញ ហើយកំណត់ត្រាប្រវត្តិសាស្ត្រជាផ្លូវការក៏ត្រូវបានបង្កើតឡើងដែរ ។ នៅពេលនេះហើយ ដែលជនរងគ្រោះតាមរយៈការស្បថមានឱកាសនឹងធ្វើជាសាក្សីក្នុងរឿងបទឧក្រិដ្ឋនូវអ្វីដែលគាត់បានទទួលរង ហើយក៏អាចផ្តល់ឱកាសដល់សាធារណជនទូទៅឲ្យបានដឹងឮជាសាធារណៈផងដែរ ។ នៅក្នុងមន្ទីរឃុំឃាំងតាមផ្លូវច្បាប់ជនដៃដល់ត្រូវបានដកអស់នូវអំណាច និងសិទ្ធិទាមទារនិទ្ទណ្ឌភាព ហើយក៏ត្រូវបានបញ្ជាក់នូវការទទួលខុសត្រូវសម្រាប់បទឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្ត ។ ក្នុងមតិសាធារណជន តម្លៃរបស់ជនរងគ្រោះដែលធ្លាប់ទទួលរងការបន្ទាបបន្ថោកក្នុងអំឡុងនៃរបបប្រល័យពូជសាសន៍ អាចនឹងជួយស្តារឡើងវិញបានខ្លះតាមផ្លូវច្បាប់ ។ ជារួម បុព្វហេតុយុត្តិធម៌ត្រូវបានបន្តប្រើប្រាស់ជាជំហានដំបូង ដែលចាំបាច់ត្រូវតែមាន ហើយក៏អាចជាជំនួយដល់ការស្ថាបនាស្ថាប័នច្បាប់អន្តរជាតិនានាដែលនៅមានភាពប្រេះស្រាំនៅឡើយក្នុងការប្រឆាំងនឹងអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ហេតុដូច្នេះ ដោយមានការគាំទ្រពីស្ថាប័ននយោបាយ ប្រព័ន្ធផ្លូវច្បាប់ផ្តល់នូវបរិបទដ៏សំខាន់ដើម្បីតាមរកគោលដៅរបស់យើង ។ ហើយក៏ដូចគ្នាទៅនឹងប្រព័ន្ធនយោបាយដែរ យើងរកឃើញថា ភាពជាអាទិភាពនិងគថភាពដែលមានលក្ខណៈជាប្រព័ន្ធនៃវិស័យផ្លូវច្បាប់អាចជាជំនួយនិងជាការរាំងស្ទះដល់កិច្ចការរបស់យើង ។

## តើស្ថាប័នច្បាប់អាចជាការរាំងស្ទះដល់កិច្ចខំប្រឹងប្រែងរបស់យើងយ៉ាងដូចម្តេច?

ដូចគ្នាទៅនឹងស្ថាប័ននយោបាយដែរ នៅមានហេតុផលជាប្រព័ន្ធជាច្រើនដែលស្ថាប័នច្បាប់មិនមែនសុទ្ធតែជួយដល់កិច្ចការរបស់យើងតាមអ្វីដែលយើងចង់បានទាំងអស់នោះទេ ។ ស្ថាប័ននយោបាយគឺមានឥទ្ធិពលលើប្រព័ន្ធផ្លូវច្បាប់យ៉ាងច្បាស់ ។ ទោះបីជាប្រព័ន្ធផ្លូវច្បាប់ត្រូវបានមើលឃើញថាមានភាពឯករាជ្យពី

វិស័យនយោបាយក៏ដោយ នេះមានត្រឹមតែក្នុងគំនិតប៉ុណ្ណោះ ។ ក្នុងការអនុវត្តជាក់ស្តែង ការជ្រៀតជ្រែកផ្នែកនយោបាយអាចធ្វើឲ្យមានការពន្យារពេល ឬធ្វើឲ្យរាំងស្ទះដល់វិស័យច្បាប់ក្នុងការទាមទារយកជនដែលដល់មកទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ។ ប្រសិនបើអំពើពុករលួយនិងឥទ្ធិពលនយោបាយដែលមានលក្ខណៈលើសលប់ អាចបង្អាក់ដល់ដំណើរការកាត់ទោសដែលមានភាពមិនស្របច្បាប់ក្នុងក្រសែភ្នែករបស់សហគមន៍ជាតិនិងអន្តរជាតិ ការផ្តល់សក្ខីកម្មរបស់ជនរងគ្រោះនិងកំណត់ត្រាប្រវត្តិសាស្ត្រដែលកើតឡើងក្នុងអំឡុងពេលដំណើរការតុលាការក៏មិនមានតម្លៃដែរ ។ គ្មានអ្វីអាចជាមហន្តរាយដល់ដំណើរការព្យាបាលរបួសផ្លូវចិត្តសម្រាប់ជនរងគ្រោះ ដូចការដែលមិនទទួលស្គាល់ដល់ភាពឈឺចាប់របស់ជនរងគ្រោះដោយសាធារណជនទូទៅនោះឡើយ ។ ចំណុចចុងក្រោយមួយទៀតគឺភាពសុចរិតខាងផ្លូវច្បាប់ដើម្បីឲ្យសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ។ ក៏មានរឿងមិនទឹកស្អាតដល់ផងដែរ ក្នុងករណីខ្វះការខិតខំព្យាយាមរបស់តុលាការដើម្បីធានាបាននូវយុត្តិធម៌ដោយអនុលោមតាមបទដ្ឋានយុត្តិធម៌ ខ្វាំងពេកក៏នាំទៅរកភាពយឺតយ៉ាវនិងចំណាយថវិកាច្រើនហួសហេតុ ដែលទីបញ្ចប់ក៏អាចអាក់ខានដល់ដំណើរការព្យាបាលនិងការស្វែងរកយុត្តិធម៌ផងដែរ ។ ក្នុងករណីអំពើប្រល័យពូជសាសន៍វិញ បញ្ហាទាំងអស់នេះកើតឡើងដោយសារកង្វះខាតនៃយុត្តិសាស្ត្រនិងបទពិសោធន៍ដើម្បីដោះស្រាយបទឧក្រិដ្ឋដែលមានលក្ខណៈស្មុគស្មាញទាំងនេះ ។ ខណៈពេលដែលប្រព័ន្ធផ្លូវច្បាប់កំពុងរកដំណោះស្រាយទៅនឹងបញ្ហាទាំងអស់នេះ ជាការសំខាន់ណាស់ដែលអ្នកចូលរួមនិងអ្នកឃ្លាំមើលធ្វើការព្យាយាមឲ្យបានច្រើនតាមដែលអាចធ្វើទៅបានក្នុងការឆ្លុះបញ្ចាំងតាមការពិចារណាល្អិតល្អន់និងវែងឆ្ងាយ ។ ជាមួយគ្នានោះដែរ ដូចមានស្ថាប័ននយោបាយជាឧទាហរណ៍ស្រាប់ ជាការសំខាន់ណាស់សម្រាប់សាធារណជនទូទៅក្នុងការដាក់ប្រព័ន្ធច្បាប់ឲ្យស្ថិតក្នុងបទដ្ឋានខ្ពស់បំផុតតាមតែអាចធ្វើទៅបាន ។ វាជាដំណាក់កាលដ៏លំបាកនិងស្មុគស្មាញផងដែរ ជាពិសេសសម្រាប់ជនរងគ្រោះនិងគ្រួសារ នៅពេលដែលយើងព្យាយាមធ្វើឲ្យមានតុល្យភាពរវាងការផ្តល់ជូននូវយុត្តិធម៌ឆាប់ៗ និងការផ្តល់នូវប្រព័ន្ធច្បាប់និងពេលវេលាក្នុងការកសាងសមត្ថភាពដើម្បីដោះស្រាយករណីស្មុគស្មាញទាំងអស់នេះ ។

## តើស្ថាប័នអប់រំអាចជួយដល់កិច្ចការរបស់យើងយ៉ាងដូចម្តេច?

ស្ថាប័នអប់រំបានរួមចំណែកយ៉ាងសំខាន់នៅក្នុងដំណាក់កាលព្យាបាលរបួសផ្លូវចិត្ត និងបុព្វហេតុស្វែងរកយុត្តិធម៌ តាមរយៈការផ្តល់នូវធនធានដ៏ចាំបាច់សម្រាប់ការកត់ត្រានូវទិន្នន័យពិតប្រាកដនៃអំពើប្រល័យពូជសាសន៍ ។ យើងគួរកំណត់ចំណាំថា ដោយសារតែពេលវេលានិងទឹកន្លែងមានភាពជាក់លាក់ ស្ថាប័នអប់រំ ជាទូទៅមានភាពឯករាជ្យពីការគាំទ្ររបស់រដ្ឋាភិបាលជាងស្ថាប័នច្បាប់ ហើយក៏អាចឆ្លើយតបទៅនឹងករណីនៃអំពើប្រល័យពូជសាសន៍បានឆាប់រហ័សជាង និងមានសេរីភាពច្រើនជាងស្ថាប័នច្បាប់ផងដែរ ។ អ្នកប្រវត្តិសាស្ត្រនិងអ្នកវិទ្យាសាស្ត្រនយោបាយជានិច្ចជាកាលបានធ្វើការស្រាវជ្រាវនិងវិភាគយ៉ាងលម្អិត ដែលត្រូវបានប្រើប្រាស់ដោយស្ថាប័ននយោបាយរហូតដល់មានការកែប្រែគោលនយោបាយ ។ ហេតុដូច្នេះ ស្ថាប័នអប់រំអាចមានឥទ្ធិពលដល់ការគាត់តែងក្របខ័ណ្ឌ នយោបាយគ្រប់ផ្នែក ដែលអាចឲ្យកិច្ចការរបស់យើងព្រមទាំងស្ថាប័នឯទៀតដំណើរការទៅមុខបាន ។ លើសពីនេះទៅទៀតក្រោយពេលដែលប្រព័ន្ធច្បាប់ទទួលបានការគាំទ្រផ្នែកនយោបាយ ក្នុងការដោះស្រាយករណីប្រល័យពូជសាសន៍ ប្រព័ន្ធតុលាការក៏ត្រូវពឹងផ្អែកយ៉ាងសំខាន់ទៅលើកិច្ចការរបស់ស្ថាប័នអប់រំផងដែរ ដើម្បីកំណត់អំពីការពិតនៃករណីនីមួយៗ ។ ក្នុងវិធីដ៏សំខាន់នេះ ស្ថាប័នអប់រំអាចជួយដល់កិច្ចការរបស់យើងដោយផ្ទាល់ ដោយមានទំនាក់ទំនងទៅនឹងស្ថាប័នច្បាប់និងនយោបាយ តាមរយៈការចងក្រងជាឯកសារទុកនូវការពិតជាប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍ជាទូទៅ និងការទទួលខុសត្រូវ ជាពិសេសសម្រាប់ជនដែលប្រព្រឹត្តបទល្មើស ។ ការផ្តល់ជាជំនួយនេះគឺមានសារសំខាន់ណាស់ ដើម្បីបំពេញគោលដៅទាំងពីររបស់យើង គឺការព្យាបាលរបួសផ្លូវចិត្តនិងការស្វែងរកយុត្តិធម៌ ។

## តើស្ថាប័នអប់រំអាចរាំងស្ទះដល់កិច្ចការងាររបស់យើងដូចម្តេច?

ដូចគ្នាទៅនឹងស្ថាប័នច្បាប់និងនយោបាយដែរ ស្ថាប័នអប់រំអាចមានដែនកំណត់ឬរាំងស្ទះដល់ដំណើរការនៃការព្យាបាលរបួសផ្លូវចិត្តនិងការស្វែងរកយុត្តិធម៌ដោយហេតុផលមួយចំនួន ។ ចំណុច

មួយគឺគោលនយោបាយនៃស្ថាប័នអប់រំនេះឯង ។ ជាការប្រសើរណាស់ដែលថាសាកលវិទ្យាល័យនីមួយៗមានកាតព្វកិច្ចនិងផ្តល់ការគាំទ្រដល់ការស្វែងរកចំណេះដឹងនិងការពិតតាមរយៈរូបភាពដោយឯករាជ្យនិងមិនលម្អៀង ។ តាមការអនុវត្តជាក់ស្តែង ធនធានរបស់សាកលវិទ្យាល័យនីមួយៗមានកំណត់ ក្នុងការផ្តល់ដល់មហាវិទ្យាល័យក្នុងការស្រាវជ្រាវ ហើយការផ្តល់ធនធាននេះគឺសម្រាប់តែជនណាដែលអាចលើកកម្ពស់និងកិត្យានុភាពដល់ស្ថាប័នតែប៉ុណ្ណោះ ។ ក្នុងកាលៈទេសៈនេះ ទោះបីជាស្ថាប័នអប់រំដែលមានភាពមិនលម្អៀងនិងទៀងត្រង់បំផុតក្នុងការស្រាវជ្រាវព្រឹត្តិការណ៍ប្រវត្តិសាស្ត្រពិតក៏ដោយ ក៏អាចទទួលផលប៉ះពាល់ផងដែរតាមរយៈការប្រកួតប្រជែង ឬជម្លោះផ្ទៃក្នុងដែលអាចជះឥទ្ធិពលដល់មុខមាត់របស់សាកលវិទ្យាល័យទាំងមូល ។ ដោយសារតែអំពើប្រល័យពូជសាសន៍ជាប្រធានបទដែលទាក់ទងនឹងអារម្មណ៍ ដូច្នេះការប្រកួតប្រជែងក្នុងការចងក្រងឯកសារជាប្រវត្តិសាស្ត្រ ឬការសិក្សាអំពីមនោគមន៍វិជ្ជានិងការជំរុញលើកទឹកចិត្ត ដែលនាំឲ្យមានការប្រព្រឹត្តអំពើប្រល័យពូជសាសន៍គឺជាកិច្ចការដែលមានសារសំខាន់ជាទីបំផុតដែលមិនអាចប្រកែកបាន ។ ការតាមរកកេរ្តិ៍ឈ្មោះតាមរយៈការចងក្រងឯកសារទាំងនេះ អាចនឹងលែងមានការចាប់អារម្មណ៍ពីសំណាក់បញ្ញាជន ដែលធ្លាប់តែបានរួមចំណែកដ៏សំខាន់ដល់កិច្ចការយល់ដឹងនិងចំណេះដឹងអំពីព្រឹត្តិការណ៍ពីអតីតកាល ហើយជំហរជាលក្ខណៈបុគ្គលអាចនឹងលែងមានភាពរឹងមាំនិងមានលក្ខណៈផ្ទាល់ខ្លួន ។ នៅក្នុងចំណុចសំខាន់ចុងក្រោយ គឺកាតព្វកិច្ចដ៏សុចរិតរបស់ស្ថាប័នអប់រំ «ដើម្បីសិក្សាតាមប្រវត្តិសាស្ត្រពិត» ។ ប្រវត្តិវិទូនិងអ្នកវិទ្យាសាស្ត្រសង្គមដ៏ឆ្នើមជាច្រើនរូបមានការទទួលខុសត្រូវដ៏ខ្លាំងចំពោះខ្លួនឯង ចំពោះស្ថាប័នដែលខ្លួនជាអ្នកតំណាង ចំពោះបុព្វហេតុយុត្តិធម៌និងការពិតនិងចំពោះសមត្ថភាពនិងឋាមពលជាបញ្ញវន្តរបស់ខ្លួនដើម្បីរួមចំណែករកដំណោះស្រាយដល់ហេតុការណ៍ដែលមានសភាពព្រៃផ្សៃនេះ ។ ជាថ្មីម្តងទៀត ទោះជាយ៉ាងនេះក្តី ដោយសារតែមានការប្រថុយប្រថានខ្ពស់ គោលបំណងចុងក្រោយនៃកិច្ចការរបស់ជនម្នាក់ៗអាចប្រាសចាកពីការសម្រេចបាននូវគោលបំណងរបស់ខ្លួន ហើយបែរជាផ្តោតតែទៅលើការតវ៉ាគ្នាទៅវិញទៅមកដោយអះអាងពីភាពត្រឹមត្រូវរៀងៗខ្លួន ហើយបន្ទុចបន្ទាក់ទៅលើទ្រឹស្តីរបស់អ្នកផ្សេងទៀត ។ ស្របពេលដែលការពិភាក្សាតវ៉ាគ្នាជាកិច្ចការសំខាន់សម្រាប់បញ្ញវន្ត និងសម្រាប់ប្រធានបទនៃការសិក្សាស្រាវជ្រាវដើម្បីបញ្ជាក់នូវការពិតបន្ថែមនូវអ្វីដែលបានស្រាវជ្រាវ ការពិភាក្សា តវ៉ាគ្នានោះក៏មានលក្ខណៈផ្ទាល់ខ្លួនផងដែរ ដែលអាចនាំឲ្យមានផលប៉ះពាល់ដល់ដំណើរការព្យាបាលរបួសផ្លូវចិត្តនិងការស្វែងរកយុត្តិធម៌ ។

## តើស្ថាប័នផ្សព្វផ្សាយអាចជួយយ៉ាងដូចម្តេចខ្លះដល់កិច្ចការរបស់យើង?

ស្ថាប័នផ្សព្វផ្សាយ (ឧទាហរណ៍ដូចជាស្ថាប័នបោះពុម្ពផ្សាយ ស្ថាប័នវប្បធម៌ ។ល ។) បានផ្តល់នូវភាពចាំបាច់យ៉ាងច្រើនសម្រាប់ជនរងគ្រោះក្នុងការធ្វើជាសាក្សីដល់បទឧក្រិដ្ឋដែលគាត់បានជួបប្រទះ ។ តាមរយៈការចងចាំប្រវត្តិរូបផ្ទាល់ខ្លួននិងរឿងរ៉ាវពីអតីតកាល ជនរងគ្រោះអាចនឹងនិយាយចេញមកនូវបទពិសោធន៍របស់គាត់ ហើយការធ្វើបែបនេះអាចជួយដល់ខ្លួនគាត់ផ្ទាល់ ក្នុងការទទួលបាននូវការគ្រប់គ្រងអារម្មណ៍ខ្លួនឯងចំពោះហេតុការណ៍ប៉ះទង្គិចផ្លូវចិត្តពីអតីតកាល ដែលតែងតែយាយីនិងរំខានដល់កិច្ចការប្រចាំថ្ងៃរបស់គាត់ ។ តាមរយៈការនិយាយក្នុងនាមអ្នកដែលបានស្លាប់ទៅហើយ អ្នកនិពន្ធនិងអ្នកស្រាវជ្រាវក៏អាចផ្សះផ្សាជម្លោះរវាងការនិយាយចេញនិងភាពស្ងប់ស្ងាត់ដែលតែងតែតាមលងដល់ជនរងគ្រោះដែរ ។ តាមរយៈការបោះពុម្ពផ្សាយ ហេតុការណ៍ឈឺចាប់ផ្ទាល់ខ្លួនដែលអាចធ្វើឲ្យសាធារណជនទូទៅដឹងពូរឿងរ៉ាវរបស់គាត់ ស្ថាប័នបោះពុម្ពផ្សាយក៏អាចធ្វើឲ្យមានការផ្លាស់ប្តូរបទពិសោធន៍ និងចំណេះដឹងទៅវិញទៅមករវាងជនរងគ្រោះនិងសាធារណជនទូទៅ ដែលជាដំណើរការដ៏សំខាន់ក្នុងការព្យាបាលរបួសផ្លូវចិត្តនិងបុព្វហេតុយុត្តិធម៌ ។

## តើស្ថាប័នបោះពុម្ពផ្សាយអាចរារាំងដល់ដំណើរការរបស់យើងយ៉ាងដូចម្តេច?

ពេលដែលស្ថាប័នអប់រំមានកាតព្វកិច្ចក្នុងការផ្តល់នូវ «ការពិត» ដើម្បីថែរក្សានូវហេតុការណ៍ពិតជាប្រវត្តិសាស្ត្រនៃរបបប្រល័យពូជសាសន៍ និងថែរក្សានូវការចងចាំដល់អ្នកដែលបានស្លាប់បាត់បង់ជីវិត ស្ថាប័នផ្សព្វផ្សាយអាចមានឧបសគ្គមួយចំនួន

ដែលអាចធ្វើឲ្យប៉ះពាល់ដល់គោលបំណងរបស់យើងក្នុងការជួយព្យាបាលរបួសផ្លូវចិត្តនិងស្វែងរកយុត្តិធម៌ ។ អ្នកនិពន្ធម្នាក់ឈ្មោះ ធើរ៉េនស៍ ដេសប្រេស បានបកស្រាយថា ការឆ្លើយតបទៅនឹងអំពើប្រល័យពូជសាសន៍របស់ជនជាតិជ្វីហ្វ ត្រូវបានធ្វើឡើងជាយូរមកហើយ ដោយវិធានបីយ៉ាង ៖ ទី១) គឺការមិនព្រងើយកន្តើយនូវអ្វីដែលបានកើតឡើង ទី២) គឺការកត់ត្រាទុកឲ្យបានត្រឹមត្រូវនូវហេតុការណ៍ជាប្រវត្តិសាស្ត្រ និងទី៣) ត្រូវចាត់ទុកអំពើប្រល័យពូជសាសន៍ថាជាព្រឹត្តិការណ៍ដ៏សំខាន់ក្នុងប្រវត្តិសាស្ត្រ ។ ជាការពិតណាស់ វិធានទាំងបីនេះគឺជាហេតុផលដ៏សមស្រប ។ ការមិនព្រងើយកន្តើយនូវអ្វីដែលបានកើតឡើងបានបង្ហាញនូវការគោរពដល់មនុស្សរាប់លាននាក់ដែលបានស្លាប់ដោយរបបណាហ្ស៊ី ។ ការរក្សាបាននិងការចងក្រងឯកសារពិតជាប្រវត្តិសាស្ត្រធានាបានថា អ្នកដែលគាំទ្រអំពើកាប់សម្លាប់មិនត្រូវបានអនុញ្ញាតឲ្យប្រែក្រឡាស់ការពិតដែលបានកើតឡើងនោះទេ ។ ហើយជាចុងក្រោយ ការចាត់ទុកអំពើប្រល័យពូជសាសន៍ជាព្រឹត្តិការណ៍ដ៏សំខាន់ជាកត្តាមួយក្នុងការទប់ស្កាត់ការប្រៀបធៀបជាមួយនឹងហេតុការណ៍ដទៃទៀត ដែលអាចនាំឲ្យមានភាពអមនុស្សធម៌ដល់ភាពជាជនរងគ្រោះដែលបានឆ្លងកាត់នូវអំពើឧក្រិដ្ឋកម្ម ។ នៅពេលដែលជនរងគ្រោះនៃរបបប្រល័យពូជសាសន៍ជ្វីហ្វទទួលបាននូវលក្ខខណ្ឌទាំងបីនេះ ជនរងគ្រោះទាំងនោះមានអារម្មណ៍ថាខ្លួនជាជនស្របច្បាប់និងមានតម្លៃក្នុងសង្គម ។ បើសិនជាជនរងគ្រោះមិនទទួលបាននូវវិធានទាំងបីនេះទេ ហើយខណៈពេលដែលយុត្តិធម៌ខាងផ្លូវច្បាប់ដែលទទួលបានកាន់តែមានភាពតិចទៅៗ ជនរងគ្រោះទាំងនោះនឹងមិនទទួលស្គាល់និងថ្កោលទោសចំពោះអ្វីដែលមិនបានគោរពដល់វិញ្ញាណក្ខន្ធរបស់អ្នកដែលបានស្លាប់ទៅហើយម្ដងវិញទៀត ជនរងគ្រោះអាចចោទថា មានការជួយដល់ជនដៃដល់និងបក្សពួកដើម្បីបំភ្លៃការពិតនៃបទឧក្រិដ្ឋដែលបានប្រព្រឹត្ត ។ ជាថ្មីម្ដងទៀតគ្មានអ្វីធ្ងន់ធ្ងរជាងការមិនបានព្យាបាលរបួសផ្លូវចិត្តនិងការស្វែងរកយុត្តិធម៌នោះទេ ។ ជាមួយគ្នានោះដែរ វិធានទាំងនេះអាចនាំឲ្យមានការបដិសេធពីសំណាក់ជនរងគ្រោះនៃរបបប្រល័យពូជសាសន៍លើជនជាតិជ្វីហ្វ ដោយសារតែមិនមានភាពសុខចិត្តសុខកាយជាមួយនឹងវិធានទាំងនោះ ។ ហេតុដូច្នេះការរួមចំណែកដល់ការយល់ដឹងនូវព្រឹត្តិការណ៍និងការនាំទៅដល់បុព្វហេតុយុត្តិធម៌នៅទីបំផុតនៅតែមិនអាចទទួលបាន ។ ឧទាហរណ៍ដូចជារហូតមកដល់ថ្មីៗនេះ ការប្រើប្រាស់ការសម្ដែងក្នុងលក្ខណៈកំប្លែង ដើម្បីតំណាងឲ្យរបបប្រល័យពូជសាសន៍ជ្វីហ្វ ត្រូវបានចាត់ទុកថាមិនអាចទទួលយកបាន ។ ស្រដៀងគ្នាទៅនឹងការក្រឡៃប្រវត្តិសាស្ត្រ ដូចក្នុងករណីខ្សែភាពយន្តដែលមានចំណងជើងថា «ជនសំណើចអំពើប្រល័យពូជសាសន៍ជ្វីហ្វ» ។ រឿងនេះត្រូវបានជឿថា បានបំផ្លាញដល់ភាពថ្លៃថ្នូររបស់ជនរងគ្រោះជ្វីហ្វ ហើយភាពពិតនៃបទឧក្រិដ្ឋដែលពួកគេបានទទួលរង ។

## តើយើងអាចធ្វើអ្វីបានខ្លះដើម្បីបន្ថយនូវភាពរាំងស្ទះ ពេលស្ថាប័នផ្សព្វផ្សាយមានកំណត់ក្នុងការជួយដល់កិច្ចការរបស់យើង?

កន្លងមកក៏មានករណីលើកលែងមួយចំនួនផងដែរ ដែលបង្កើតឡើងសម្រាប់ជនរងគ្រោះដែលមិនអាចទទួលយកវិធានទាំងបីនេះបាន ។ បច្ចុប្បន្ននេះ ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ជ្វីហ្វ បានទទួលស្គាល់យ៉ាងទូលំទូលាយជាងមុន តាមរយៈការមិនលេងសើចនូវអ្វីបានកើតឡើងដូចជាករណីរឿងប្រលោមលោករបស់ ស្ពៀលឡេម៉ាន់ ដែលក្នុងសៀវភៅនោះ គាត់បានប្រើប្រាស់រូបភាពកំប្លែង ដើម្បីពណ៌នាអំពីហេតុការណ៍ជីវិតផ្ទាល់ខ្លួនរបស់គាត់ក្រោមរបបប្រល័យពូជសាសន៍ ។ ឧទាហរណ៍ថ្មីមួយទៀត គឺខ្សែភាពយន្តដែលផលិតនៅឆ្នាំ១៩៩៧ ដោយ រ៉ូប៊ើតតូ បេនីគនី ដែលមានចំណងជើងថា «ជីវិតស្រស់ស្អាត» ។ នៅក្នុងខ្សែភាពយន្តនោះ គ្រួសារអ៊ីតាលី-ជ្វីហ្វម្នាក់ត្រូវបាននាំទៅកាន់ជំរំពិឃាដមួយរបស់ពួកណាហ្ស៊ី ។ ដើម្បីការពារអាយុជីវិតកូនប្រុសពីអំពើឃោឃៅ នៅពេលដែលស្ថានភាពកំពុងស្ថិតក្នុងសភាពគ្រោះថ្នាក់ ឪពុកបានលួងលោមកូនប្រុសដោយប្រាប់ថា អ្នកប្រយុទ្ធកំពុងតែលេងល្បែងប្រជាប្រិយ ហើយបើសិនជានរណាម្នាក់ទទួលបានពិន្ទុច្រើនជាងគេដោយមិនចេះត្អូញត្អែរ ឬរត់គេចនឹងឈ្នះបានរថក្រោះពិតប្រាកដមួយ ។ អ្នករិះគន់ខ្លះបានចម្អកឡកឡឺយដល់ខ្សែភាពយន្តនេះ ហើយថាការប្រើប្រាស់ការកំប្លែងនេះហាក់ដូចជាមិនសមស្រប ហើយជាការបដិសេធនូវភាពពិត ដែលបានកើតឡើងក្នុងរបបប្រល័យពូជសាសន៍លើជនជាតិជ្វីហ្វ ដែលមានភាពធ្ងន់ធ្ងរជាងខ្សែភាពយន្តនេះទៅទៀត ។ ទោះ

ជាមានការរិះគន់យ៉ាងនេះក្តី មនុស្សមួយចំនួនក៏បានយល់ឃើញផ្ទុយវិញថា ខ្សែភាពយន្តនោះនឹងអាចទាក់ទាញទស្សនិកជនឲ្យចាប់អារម្មណ៍កាន់តែខ្លាំងឡើងអំពីសោកនាដកម្មនៃអំពើប្រល័យពូជសាសន៍លើជនជាតិជ្វីហ្វ ។ តាមរយៈការអះអាងបែបនេះ ការប្រើប្រាស់រូបភាពកំប្លែងដែលគ្មានប្រយោជន៍របស់ឪពុកក្មេងម្នាក់នោះ គឺជាការខ្វះសមានចិត្ត ខ្វះការជួយទុក្ខធុរៈរបស់ឪពុកម្តាយក្នុងអំឡុងរបបប្រល័យពូជសាសន៍លើជនជាតិជ្វីហ្វ ក្នុងការការពារកូនជាទីស្រលាញ់របស់ខ្លួននិងផ្តល់សុភមង្គលដល់កូនៗ និងតម្លៃជាសាកលរបស់ជនគ្រប់រូប ។ តាមរយៈវិធីនេះ ទោះជាខ្សែភាពយន្តនោះមិនត្រូវបានចាត់ទុកថាជាអ្នកផ្តល់ចំណេះដឹងពីអំពើប្រល័យពូជសាសន៍លើជនជាតិជ្វីហ្វក៏ដោយ ក៏ខ្សែភាពយន្តនេះអាចភ្ជាប់យើងទៅនឹងភាពភ័យរន្ធត់នៃបទពិសោធន៍របស់ជនរងគ្រោះ ដែលជាធម្មតាត្រូវបានគេមើលឃើញថាមានភាពភ័យរន្ធត់ខ្លាំងពេក ដែលនាំឲ្យមានការលំបាកយល់ឬក៏លើសនូវអ្វីដែលបានកើតមានឡើង ។ ចំណុចសំខាន់នេះគឺថា ភាពជោគជ័យរបស់ខ្សែភាពយន្ត «ជីវិតស្រស់ស្អាត» គឺពិតជាមិនអាចកើតមានបានឡើយកាលពី១៥ឬ២០ឆ្នាំមុន នៅពេលដែលការទទួលស្គាល់នូវការឆ្លើយតបទៅនឹងអំពើប្រល័យពូជសាសន៍នៅមានលក្ខណៈចង្អៀតចង្អល់និងតឹងរ៉ឹងនៅឡើយ ។

## សេចក្តីសន្និដ្ឋាន

ដើម្បីធ្វើការសង្ខេប យើងរកឃើញថាកិច្ចខំប្រឹងប្រែងរបស់យើង ដើម្បីបង្កើននូវការព្យាបាលរបួសផ្លូវចិត្ត និងដើម្បីបម្រើបុព្វហេតុយុត្តិធម៌ គឺអាចត្រូវបានជួយនិងរាំងស្ទះដោយស្ថាប័ននយោបាយ ច្បាប់ អប់រំ និងស្ថាប័នផ្សព្វផ្សាយដែលបានគាំទ្រដល់ដំណើរការងាររបស់យើង ។ លើសពីនេះទៀត អ្វីដែលស្ថាប័នទាំងអស់នេះមានការប៉ះពាល់ដល់ដំណើរការងាររបស់យើង គឺមុខងារនៃភាពជាអាទិភាព ក្រិត្យក្រម និងអនុសញ្ញាដែលអនុវត្តសកម្មភាពរបស់ខ្លួន ។ នៅពេលដែលមានហេតុផលមួយចំនួន ដែលថាស្ថាប័នទាំងនេះរាំងស្ទះដល់កិច្ចការងាររបស់យើង អាចនឹងឆ្ងាយហួសពីការឈានដល់របស់យើងក្នុងការផ្លាស់ប្តូរឬកែប្រែការងារជាអាទិភាពរបស់ស្ថាប័នទាំងនោះដើម្បីឲ្យសមស្របទៅតាមគោលបំណងរបស់យើង ។ ទីបញ្ចប់ ជាការសំខាន់ណាស់ដើម្បីយល់ដឹងថា ទោះបីជាអ្វីដែលស្ថាប័នទាំងនោះផ្តល់ឲ្យយើងមានដែនកំណត់និងមិនគ្រប់គ្រាន់ក៏ដោយ ក៏យើងមិនបដិសេធមិនទទួលយកនោះទេ ។ ស្ថាប័នទាំងនោះគឺមានសារសំខាន់ណាស់ក្នុងការជួយយើងឲ្យសម្រេចកិច្ចការរបស់យើង ។ ការទទួលយកនូវតថភាពនិងការធ្វើការជាមួយនឹងក្នុងស្ថាប័នទាំងនោះ ក៏អាចធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពរបស់ស្ថាប័នទាំងនោះផងដែរ ស្របពេលដែលយើងកំពុងតែធ្វើកិច្ចការយ៉ាងមមាញឹកដើម្បីសម្រេចគោលដៅរបស់យើងដែលជាទិសដៅដ៏ចម្បងបំផុត ។ តាមរយៈការអត់ធ្មត់ការចំណាយពេលយូរអង្វែង និងការព្យាយាមដោះស្រាយបញ្ហាយើងនឹងទទួលបាននូវលទ្ធផលល្អដូចដែលយើងបានគ្រោងទុក ។ ស្របពេលជាមួយគ្នានេះដែរ យើងក៏ត្រូវថ្លឹងថ្លែងមើលរវាងពេលវេលា និងប្រសិទ្ធភាពនៃសកម្មភាពរបស់យើងផងដែរ ។

## ការសន្និដ្ឋាននិងការអង្កេតជាទូទៅ

ដើម្បីធ្វើការសន្និដ្ឋានដល់ប្រធានបទនេះ ខ្ញុំសូមធ្វើការណែនាំជាទូទៅមួយចំនួន ។ ដូចបានរៀបរាប់ខាងលើរួចហើយ ទោះជាកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើននូវគោលដៅរបស់យើងត្រូវបានជួយគាំទ្រដោយស្ថាប័នទាំងនោះក៏ដោយ បន្តិចម្តងៗកិច្ចខិតខំប្រឹងប្រែងរបស់យើងនឹងកើតឡើងតាមរយៈបុគ្គលក្នុងសណ្ឋានជាការផ្លាស់ប្តូរយោបល់ ។ ការផ្លាស់ប្តូរជាធម្មតាកើតឡើងទាក់ទងតែទៅនឹងវត្ថុប៉ុណ្ណោះ (គោលនយោបាយ តុលាការ ច្បាប់ សៀវភៅ ខ្សែភាពយន្ត និងអត្ថបទ សារព័ត៌មានជាដើម) ដែលត្រូវបានគាំទ្រនិងបង្កើតឡើងដោយស្ថាប័ននីមួយៗ ។ មានឧទាហរណ៍ជាច្រើនទាក់ទងទៅនឹងការផ្លាស់ប្តូរនេះ ។ នៅប្រទេសកម្ពុជា សៀវភៅអំពីកំណត់ត្រាប្រវត្តិសាស្ត្រដែលសរសេរឡើងដោយ ឌី ខាំបូលី នឹងចាប់បង្រៀននៅថ្នាក់វិទ្យាល័យរវាងគ្រូនិងសិស្ស ។ លើសពីនេះទៅទៀត ការផ្លាស់ប្តូរគំនិតពីប្រវត្តិសាស្ត្រនេះក៏បានកើតឡើងនៅតាមផ្ទះនីមួយៗផងដែរ តាមរយៈការនិយាយប្រាប់កូនចៅនិងការមើលព័ត៌មាននៅពេលដែលការកាត់ទោស ឌុច កំពុងតែបន្តនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ហើយការផ្លាស់ប្តូរយោបល់នេះ ក៏កើតមាននៅតាមបណ្តាញអ៊ិនធើណេតរវាងអ្នកអាននិងអ្នករិះគន់អំពីសៀវភៅមួយរបស់អ្នកនិពន្ធ លឿង អ៊ុង ដែលមានចំណងជើងថា «មុនដំបូង

ខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ» ។ ការផ្លាស់ប្តូរយោបល់នេះ ក៏កើតមានឡើងនៅតាមសាកលវិទ្យាល័យរវាងសាស្ត្រាចារ្យនិងនិស្សិត ដែលពិភាក្សាគ្នាទាក់ទងទៅនឹងសៀវភៅរបស់អ្នកស្រាវជ្រាវ ដេវីដ ឆេនល័រ ប៉ែន យៀនិន និង ស៊ីវ ហេងដ័រ ដែលបានស្រាវជ្រាវអំពីមនោគមន៍វិជ្ជារបស់ថ្នាក់ដឹកនាំខ្មែរក្រហម ។ ម្យ៉ាងវិញទៀត ការផ្លាស់ប្តូរនូវការពិភាក្សាគ្នានេះក៏កើតមានផងដែរនៅតាមមន្ទីរព្យាបាលរវាងអ្នកផ្តល់ប្រឹក្សានិងជនរងគ្រោះដែលផ្លាស់ប្តូរយោបល់គ្នាអំពីហេតុការណ៍នៃបទឧក្រិដ្ឋនូវអ្វីដែលជនរងគ្រោះបានឆ្លងកាត់កាលពីកុមារភាព ។ ម្យ៉ាងវិញទៀត ការផ្លាស់ប្តូរគំនិតគ្នាក្នុងលក្ខណៈបុគ្គលនេះអាចកើតមានឡើងតាមវិធីផ្សេងៗជាច្រើនរាប់មិនអស់ ។

ការអះអាងជាសំខាន់របស់ខ្ញុំនៅពេលនេះគឺថាការផ្លាស់ប្តូរគំនិតនេះអាចជួយ និងរាំងស្ទះដល់ដំណើរការព្យាបាលរបួសផ្លូវចិត្តនិងបុព្វហេតុយុត្តិធម៌ គឺថាតើយើងក្នុងនាមជាបុគ្គលម្នាក់អាចយល់និងអាចឆ្លើយតបទៅនឹងផលប៉ះពាល់ដែលបណ្តាលមកពីស្ថាប័នទាំងអស់នេះយ៉ាងដូចម្តេច ដើម្បីសម្រេចបាននូវកិច្ចការរបស់យើង ។ កិច្ចការរបស់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការចងក្រងទុក ដូចជារណ្តៅសាកសពរួម ទីកន្លែងសម្លាប់ ផ្នូរ និងមន្ទីរឃុំឃាំងនៅទូទាំងប្រទេស ការសម្ភាសជនរងគ្រោះ និងជនដៃដល់នៅតាមទីជនបទឆ្ងាយៗ ការទាក់ទងជាមួយសាធារណជនទូទៅអំពីតុលាការខ្មែរក្រហម និងការធ្វើការងារជាមួយរដ្ឋាភិបាលជាតិនិងអន្តរជាតិ ស្ថាប័នច្បាប់ និងសាកលវិទ្យាល័យបានផ្តល់ជាគំរូដ៏ល្អសម្រាប់ស្ថាប័នដទៃទៀតយកគំរូតាម ។ ពេលដែលខ្ញុំចុះទៅជាមួយក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីចងក្រងហេតុការណ៍នៃអំពើប្រល័យពូជសាសន៍ ថែរក្សា និងស្វែងរកការពិតនិងយុត្តិធម៌ ខ្ញុំហាក់បីដូចជាយល់ឃើញថា កត្តាសំខាន់មួយចំនួនដែលមជ្ឈមណ្ឌលនេះទទួលជ័យជម្នះគឺ ៖ ភាពមនុស្សធម៌និងការយល់ដឹងរបស់មជ្ឈមណ្ឌលដែលកំណត់នូវអ្វីដែលខ្លួនត្រូវធ្វើការជម្នះនិងភាពអត់ធ្មត់នៃកិច្ចខំប្រឹងប្រែងដើម្បីស្ថាបនាសមត្ថភាពសហគមន៍និងខ្លួនឯង គឺការតាំងខ្លួនជាអ្នកស្តាប់ដ៏ល្អនិងការលើកកម្ពស់បំណងប្រាថ្នានិងគោរពគ្នាទៅវិញទៅមក ការដោះស្រាយបញ្ហាដោយសំដៅទៅលើការយល់ដឹងនៃដំណើរការព្យាបាលរបួសផ្លូវចិត្ត និងបុព្វហេតុយុត្តិធម៌គឺជាការស្វែងរកដ៏យូរអង្វែង ។ តម្លៃនិងវិធីទាំងអស់នេះនឹងមានសារប្រយោជន៍ចំពោះគ្រូបង្រៀនទូទាំងប្រទេស នៅពេលដែលគ្រូបង្រៀនទាំងនោះចាប់ផ្តើមបើកទំព័រប្រវត្តិសាស្ត្រដ៏សំខាន់នេះសម្រាប់ការរីកចម្រើននិងការអភិវឌ្ឍប្រទេស ។

**ចច ជីហ្គាស**



វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិនៅថ្ងៃទី២៩ ខែមិថុនា ដល់ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៩

# ព្រះពុទ្ធសាសនានៅក្រោមរបប ប៉ុលពត

ការសិក្សាអំពីវាសនារបស់ព្រះសង្ឃនិងវត្តអារាមនៅក្នុងរបបកុម្មុយនីស្តនៅកម្ពុជា គឺផ្តោតទៅលើការវិភាគទៅលើបទសម្ភាសន៍ និងផ្នែកជាច្រើននៃអត្ថបទសរសេរដោយដៃដែលភាគច្រើននៃអត្ថបទនោះត្រូវបានរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានទីតាំងនៅភ្នំពេញ ។ ការសិក្សានេះតំណាងឲ្យការព្យាយាមវិភាគយ៉ាងល្អិតល្អន់នូវទស្សនៈរបស់អង្គការដែលជាអង្គការបដិវត្តន៍នៅក្នុងបេះដូងរបស់បក្សកុម្មុយនីស្តកម្ពុជាមានផែនការរួមដើម្បីកម្ចាត់ចោលនូវព្រះសង្ឃនៅអំឡុងកម្ពុជាប្រជា-ធិបតេយ្យ ។

ខណៈពេលដែលមិនមានការរៀបរាប់ពីមធ្យោបាយដើម្បីបន្ថយការស្លាប់របស់បព្វជិតយ៉ាងគួរឲ្យរន្ធត់ និងការបំផ្លាញដល់សាសនាព្រះពុទ្ធ បញ្ញវន្ត និង វប្បធម៌ សៀវភៅនេះនឹងបង្ហាញឲ្យឃើញថា នៅពេលដែលមានភស្តុតាងជាក់លាក់បញ្ជាក់ថាមេដឹកនាំខ្មែរក្រហមត្រូវបានកំណត់ឲ្យតាមដាននិងកម្ទេចអតីតសមាជិកបព្វជិតមុនឆ្នាំ១៩៧៥ ហេតុផលតាមរចនាសម្ព័ន្ធដែលពាក់ព័ន្ធនឹងសេដ្ឋកិច្ចរបស់ព្រះសង្ឃនៃព្រះពុទ្ធសាសនាក៏ជាមូលហេតុលំបាកមួយក្នុងការជួយដល់សាសនាដែលស្ថិតនៅក្រោមកាលៈទេសៈមួយដែលប្រជាជនសាមញ្ញមិនត្រូវបានជំរុញឲ្យជួយឧបត្ថម្ភខាងផ្នែកសម្ភារៈ ។


វត្តអារាម ដែលបំផ្លាញដោយខ្មែរក្រហម

ការកាត់បន្ថយយ៉ាងខ្លាំងនូវព្រះសង្ឃ និងកម្លាំងពលកម្មចាប់តាំងពីការបះបោររបស់បក្សកុម្មុយនីស្តនៅឆ្នាំ១៩៧០ រហូតដល់ការរលាយសាបសូន្យស្ទើរតែទាំងអស់នៅឆ្នាំ១៩៧៧ គឺជាលទ្ធផលបណ្តាលមកពីកត្តាមួយចំនួនដូចជា ការប្រឆាំងនឹងបព្វជិតរបស់យោធានៅក្នុងចំណោមកម្មាភិបាលថ្នាក់ខ្ពស់មួយចំនួន លទ្ធផលនៃការបង្ខំប្រជាជនទាំងអស់ កម្រិតមិនល្អនៃការគ្រប់គ្រងសេដ្ឋកិច្ចមិនត្រឹមត្រូវ ការជះឥទ្ធិពលដោយសង្គ្រាម ការអត់អាហារនិងជំងឺ និងទំនាក់ទំនងមិនមាំទាំរវាងបព្វជិត និងអ្នកគាំទ្របព្វជិត ។ ដោយហេតុផលនេះ អ្នកនិពន្ធនឹងបង្ហាញពីភាពមិនច្បាស់លាស់មួយចំនួនថាតើនៅពេលនោះមានផែនការរួមសម្រាប់គាបសង្កត់ទាំងស្រុងទៅលើសាសនាដែរឬទេ បន្ទាប់មកនឹងចោទជាសំណួរថាតើការចង់ស្វែងរកមនុស្សមកទទួលខុសត្រូវចំពោះកិច្ចការគ្រប់គ្រងមិនត្រឹមត្រូវតាំងពីដើមរហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យអាចបង្ហាញឲ្យយើងយល់ដឹងពីភស្តុតាងដែរឬទេ ។

ព្រះពុទ្ធសាសនាបានរីកសុះសាយយ៉ាងខ្លាំងនៅអាស៊ីអាគ្នេយ៍នៅពេលគម្រប់ខួបការត្រាស់ដឹងរបស់ព្រះពុទ្ធនៅឆ្នាំ២៥០០ ព្រះអង្គម្ចាស់ សីហនុ ដែលជាអ្នកដឹកនាំព្រះរាជាណាចក្រឯករាជ្យថ្មីបានឆ្លៀតឱកាសនេះបង្កើតមនោគមន៍នយោបាយសម័យទំនើបមួយដែលស្រដៀងគ្នានឹងការអភិវឌ្ឍនៅភូមា និងស្រីលង្កា ដោយគាត់បានឲ្យឈ្មោះវាថាជា «សង្គមអ្នកកាន់ព្រះពុទ្ធសាសនា» ។

សម្រាប់ហេតុផលផ្សេងៗ ទស្សនៈព្រះពុទ្ធសាសនាដែលប្រមូលផ្តុំគ្នានៅក្នុងផ្នែកនយោបាយមានលក្ខណៈមិនត្រឹមត្រូវ ហើយសមាជិកព្រះសង្ឃដែលពាក់ព័ន្ធនឹងនយោបាយកាន់តែកើនឡើងបានយល់ស្របនឹងការទម្លាក់ព្រះអង្គម្ចាស់នៅឆ្នាំ១៩៧០របស់លន់ នល់ ។ ជាងនេះទៅទៀត មនុស្សមួយចំនួនតូចបានយល់ព្រមចូលរួមគាំទ្រសង្គ្រាមដែលដឹកនាំដោយអ្នកកាន់សាសនាព្រះពុទ្ធប្រឆាំងនឹងកុម្មុយនីស្តនៃរបបសាធារណរដ្ឋខ្មែរថ្មី ។

ការទម្លាក់ព្រះអង្គម្ចាស់ សីហនុ គឺជាការបញ្ចប់ព្រះពុទ្ធសាសនាដែលជាខ្សែរយៈបណ្តោយដ៏សំខាន់នៃជំនឿរបស់កម្ពុជា ។ ភាគច្រើននៃប្រជាជននៅក្នុងប្រទេស ជាពិសេសអ្នកនៅជនបទបានចាត់ទុកភាពស្របច្បាប់នៃអ្នកគ្រប់គ្រងប្រទេសថាកើតចេញពីទស្សនៈរបស់ព្រះពុទ្ធ ។ ដូច្នេះ ការចាកចេញរបស់ព្រះអង្គម្ចាស់បានបង្កឲ្យមានគ្រោះមហន្តរាយយ៉ាងខ្លាំង ហើយតាមរយៈការធ្វើបែបនេះ រចនាសម្ព័ន្ធទាំងអស់របស់នយោបាយ សេដ្ឋកិច្ច និងវប្បធម៌នឹងត្រូវបានរាំងស្ទះ ។

នេះជាអ្វីដែលបានកើតឡើង ។ រដ្ឋាភិបាលមជ្ឈិមថ្មីមិនអាចគ្រប់គ្រងប្រទេស ហើយជនកុម្មុយនីស្តចាប់ផ្តើមសាកល្បងនូវអ្វីដែលគេជឿថាត្រឹមត្រូវដើម្បីផ្លាស់ប្តូរវប្បធម៌កម្ពុជា និងសង្គមនៅក្នុងតំបន់ដែលងាយស្រួលនឹងកែប្រែ ។ មេដឹកនាំខ្លះប្រាកដជាបានដឹងពីការធ្វើទៅលើសាសនារបស់បារាំងនៅសតវត្សរ៍ទី១៨និងនៅអំឡុងពេលធ្វើបដិវត្តន៍វប្បធម៌របស់ចិន ។ ជាមួយនឹងការដឹងមុនអំពីប្រវត្តិសាស្រ្ត យុទ្ធសាស្ត្រប្រឆាំងនឹងសាសនាត្រូវបានយកមកប្រើប្រាស់នៅតំបន់រំដោះដើម្បីធ្វើឲ្យអ្នកដែលគោរពព្រះសង្ឃនៅទីនោះគាំទ្រ «ជាប់រហូត» ។ ប៉ុន្តែនៅពេលដែលដំណើរការគ្រប់គ្រងនេះត្រូវបានសម្រេចតាមគោលដៅ (ដោយមានបញ្ហានៅករណីខ្លះ) កង់ប្រវត្តិសាស្ត្របានដើរយ៉ាងលឿនក្នុងការជម្នះរាល់ឧបសគ្គដើម្បីដំណើរការបដិវត្តន៍ ។

សៀវភៅនេះបានបញ្ជាក់ថា ដើមកំណើតនៃទម្រង់ច្បាស់លាស់របស់មនោគមន៍វិជ្ជាកុម្មុយនីស្ត ខ្មែរក្រហមបានទទួលឥទ្ធិពលពីព្រះពុទ្ធសាសនាដែលបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងប្រទេស ។ យើងអាចមើលឃើញយ៉ាងច្បាស់តាមរយៈចំណុចសំខាន់របស់បដិវត្តន៍ដែលមានភាពផើតឆាយ ការលះបង់ចោលនូវអ្វីៗទាំងអស់ ការប្រកាន់ខ្ជាប់តាមគោលការណ៍ ការប្រកាន់វិន័យដូចៗគ្នានិងគំនិតឯករាជ្យម្ចាស់ការ ។ អ្នកនិពន្ធមានគោលបំណងបញ្ចូលគំនិតទាំងនេះទៅក្នុងប្រវត្តិរូបរបស់អ្នកដឹកនាំជាន់ខ្ពស់សំខាន់ៗ ដែលភាគច្រើននៃអ្នកទាំងនោះធ្លាប់បានទទួលការអប់រំបែបព្រះពុទ្ធសាសនាបុរាណ ។ ខណៈពេលដែលការជះឥទ្ធិពលនេះបានធ្វើឲ្យមនុស្សមួយចំនួនឈប់ជឿទៅលើសាសនា មនុស្សមួយចំនួនផ្សេងទៀតនៅតែគោរពប្រណិប័តន៍ព្រះពុទ្ធសាសនាដដែល ។ យ៉ាងហោចណាស់ ក៏មានការបះបោរផ្ទៃក្នុងរបស់អ្នកដែលមិនមានបំណងលុបបំបាត់ការគ្របដណ្តប់ព្រះពុទ្ធសាសនាទាំងស្រុងប្រឆាំងនឹងអង្គការដឹកនាំ ទោះបីជាការប្រឆាំងនោះមិនទទួលបានជោគជ័យក្តី ។

ការប្រណិប័តន៍តាមព្រះពុទ្ធសាសនាត្រូវបានដាក់កំហិត ហើយវាស្ទើរតែត្រូវបានរារាំងមិនឲ្យមានការប្រណិប័តន៍ទាល់តែសោះ ។ ទោះបីជាវាមានលក្ខណៈសមហេតុផលក្នុងការអនុវត្តយុទ្ធសាស្ត្រខ្លះ ប៉ុន្តែអង្គការមិនអាចបង្កើតការដាក់កំហិតនៅក្នុងស្រុកដូចជា ការធ្វើទៅលើការបំបួសព្រះសង្ឃ ការប្រារព្ធពិធីបុណ្យប្រចាំឆ្នាំ ឬការប្រារព្ធពិធីបុណ្យសពតាមប្រពៃណីយ៉ាងនេះឡើយ ។ មានការធ្វើដូចគ្នាទៅលើវត្តអារាម រូបបដិមានិងគម្ពីរធម៌ព្រមទាំងទម្រង់ផ្សេងៗដែលពាក់ព័ន្ធព្រះពុទ្ធសាសនា ។ ភាពច្របូកច្របល់នៃរបបអាចត្រូវយកមកបង្ហាញតាមបែបនេះបាន ។ អ្នកជឿជាក់លើខ្លួននៅតែបន្តអនុវត្តន៍យុទ្ធសាស្ត្រប្រឆាំងនឹងសាសនា ប៉ុន្តែនៅជិតទីបញ្ចប់នៃរបបនេះនៅតែមានបុគ្គលខ្លះបន្តគោរពសាសនាដើម្បីរក្សាសាសនាដែលនៅសល់បន្តិចបន្តួច ។ ព្រះសង្ឃចាស់ៗ និងប្រជាជនសាមញ្ញមួយចំនួនដែលស្លៀកសម្លៀកបំពាក់សនៅតែគោរពសាសនា ។ ក្រុមមួយចំនួនបានប្តេជ្ញាចិត្តប្រឆាំងនឹងអ្នកគោរពសាសនា ហើយលួចប្រណិប័តន៍សាសនាដោយសម្ងាត់ ។ ភាគច្រើននៃអ្នកដែលកាន់ព្រះពុទ្ធសាសនាបានបោះបង់សាសនាយ៉ាងលឿននិងទាំងស្រុង ។ ការសម្រេចចិត្តបែបនេះដោយសារតែកាលៈទេសៈនៅចំពោះមុខនិងភាពភ័យខ្លាចដែលទាំងអស់នេះធ្វើដើម្បីរស់ ។

អ្នកនិពន្ធបង្ហាញអំពីដំណើរការបីដែលខ្មែរក្រហមធ្វើទៅលើព្រះពុទ្ធសាសនា គឺការរំខាន ការិយាធិបតេយ្យនិងការរារាំង ការ

រំខានជាបន្តបន្ទាប់ និងការចាត់វិធានការទៅលើអ្នកដែលមានការតាំងចិត្តនិងអ្នកដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយរបប លន់ នល់ ។ ការបង្កើតទម្រង់គ្រប់គ្រងព្រះសង្ឃបែបបដិវត្តន៍ដាច់ដោយឡែកពីគ្នាដោយបំបែកព្រះសង្ឃជាពីរផ្នែក ៈ ផ្នែក «មូលដ្ឋាន» រួមមានព្រះសង្ឃតាមជនបទដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមតាំងពីដើមដំបូងនៃបដិវត្តន៍ និងផ្នែក «ថ្មី» រួមមានអ្នកដែលត្រូវបានជម្លៀសចេញពីទីប្រជុំជននិងទីក្រុង បន្ទាប់ពីថ្ងៃជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលទាំងអស់នេះបង្កើតបានជាដំណាក់ការការិយាធិបតេយ្យ ។ ការរំខានដល់ព្រះសង្ឃមួយអង្គៗប្ចុទាំងអស់ គឺជាលទ្ធផលមួយចំណែកនៃការបំបិទផ្លូវសេដ្ឋកិច្ចរបស់ព្រះសង្ឃដោយប្រជាជនសាមញ្ញមិនត្រូវបានលើកទឹកចិត្តឲ្យផ្តល់ជំនួយដល់ព្រះសង្ឃដែលមិនអាចបង្កើតអ្វីបាន ។ កិច្ចខំប្រឹងប្រែងនៅគ្រប់ទីកន្លែងដើម្បីបង្ខំសមាជិកព្រះសង្ឃក្មេងៗឲ្យរៀបការប្ចូលបម្រើទ័ព និងគោលនយោបាយផ្សឹកព្រះសង្ឃដើម្បីធានាឲ្យមានពលកម្មច្រើនក៏ជាការរំខានមួយដល់ព្រះពុទ្ធសាសនាដែរ ។

ការជម្លៀសព្រះសង្ឃបែបនេះមានន័យថា គេអាចយកព្រះសង្ឃមកធ្វើការក្នុងគោលបំណងមិនឲ្យមានសាសនា ។ ប៉ុន្តែលក្ខណៈសម្គាល់មួយនៃរបបនេះគឺថា ព្រះសង្ឃមួយចំនួននៅតែតស៊ូបានយូរ ដែលនេះប្រហែលជាព្រះពុទ្ធសាសនាមិនត្រូវបានធ្វើបាបដូចសាសនាផ្សេងទេ ។ ជាងនេះទៅទៀត នេះប្រហែលជាហេតុផលមួយដែលជនជាតិភាគតិចចាមមូស្លីមទទួលការធ្វើបាបខ្លាំងនៅក្រោមរបបខ្មែរក្រហម ។ ព្រះសង្ឃមួយចំនួនតូចបានរត់គេចខ្លួនទៅប្រទេសជិតខាងដែលមានសន្តិសុខ ។ ទោះបីជាយ៉ាងនេះក្តី ព្រះសង្ឃចាស់ៗនិងសមាជិកព្រះសង្ឃខ្លះនៅតែតស៊ូនៅក្នុងប្រទេស ។ ការលុបបំបាត់សមាជិកជាន់ខ្ពស់របស់សាសនា «ឈ្លប» ផ្សេងៗគ្នាធ្វើឲ្យមានសោកនាដកម្មដល់ព្រះពុទ្ធសាសនានៅក្រោមរបបខ្មែរក្រហម ។

អ្នកនិពន្ធបានអះអាងថា «ការទស្សន៍ទាយមុន» អំពីការស្លាប់របស់ព្រះសង្ឃមានលក្ខណៈមិនត្រឹមត្រូវ ហើយការប៉ុនប៉ងប៉ាន់ប្រមាណអត្រាស្លាប់របស់ព្រះសង្ឃរវាងឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៩ ដោយផ្អែកទៅលើភ័ស្តុតាងជាមូលដ្ឋាននៃការធ្វើស្ថិតិក៏មិនអាចត្រឹមត្រូវដែរ ។ ជនកុម្មុយនិស្តក៏មាននិន្នាការដូចគ្នាដើម្បីធ្វើទៅលើវត្តអារាមដែរ ។ បញ្ហាមិនត្រឹមត្រូវទាំងនេះរួមមាន ផលលំបាកធំៗមួយចំនួនដែលខុសពីគេវាជាការមិនហ៊ាននិយាយស្តីធ្វើឲ្យកម្រិតត្រឹមត្រូវនៃការប៉ាន់ប្រមាណការស្លាប់របស់ព្រះសង្ឃគឺជាបញ្ហា ។

អ្នកនិពន្ធបានប៉ាន់ប្រមាណថា ចំនួនស្លាប់របស់ព្រះសង្ឃមានប្រហែល១២.៥០០អង្គ នៅឆ្នាំ១៩៦៩ ដែលប្រហែល១៩ភាគរយនៃចំនួនប្រជាជន៦៥.០៦២នាក់គឺជាព្រះសង្ឃ ។ ចំនួនស្លាប់នេះអាចត្រូវបានបំបែកជា៣ប្រភេទគឺ ២.២០០អង្គស្លាប់ដោយសារការទម្លាក់គ្រាប់បែកនៅក្នុងប្រទេសរហូតដល់ខែសីហា ឆ្នាំ១៩៧៣ ។ ប្រហែល៩០០អង្គនៃសមាជិកជាន់ខ្ពស់របស់ព្រះពុទ្ធសាសនាត្រូវបានសម្លាប់នៅប៉ុន្មានថ្ងៃបន្ទាប់ពីភ្នំពេញត្រូវបានវាយបែកនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ការសម្លាប់នេះកើតឡើងដោយសារការស្អប់របបលន់ នល់ ជាជាងស្អប់ក្រុមសាសនា ។ ព្រះសង្ឃដែលនៅសល់ប្រមាណ៩.៣០០អង្គ ត្រូវបានសម្លាប់ ។ យើងមិនអាចប៉ាន់ប្រមាណនូវចំនួនស្លាប់ពិតប្រាកដដែលកើតឡើងនៅអំឡុងពេលសង្គ្រាមស៊ីវិលក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ។ ប្រាកដជាមានព្រះសង្ឃផ្សេងទៀតស្លាប់បន្ទាប់ពីត្រូវបានផ្សឹក ។ ទាំងនេះមិនអាចកើតឡើងដោយការរួមគំនិតគ្នារបស់បុគ្គលដើម្បីធ្វើទៅលើព្រះពុទ្ធសាសនាទេ វាប្រហែលជាកើតឡើងដោយមូលហេតុផ្សេងទៀត ។

សៀវភៅនេះបានធ្វើសេចក្តីសន្និដ្ឋានដោយពិភាក្សាទៅលើការស្តារប្រទេសឡើងវិញដ៏យឺត និង ការគ្រប់គ្រងក្រុមអ្នកកាន់ព្រះពុទ្ធសាសនានៅអំឡុងសាធារណរដ្ឋប្រជាមានិតកម្ពុជាដោយភ្ជាប់ជាមួយនឹងសេចក្តីលម្អិតខ្លះៗ ការទូន្មានរបស់ព្រះពុទ្ធសាសនា ការឆ្លុះបញ្ចាំងទៅលើតុលាការខ្មែរក្រហម (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា) ជាមួយនឹងការពិភាក្សាអំពីជម្រើសដែលអាចធ្វើទៅរួច ។ កថាក្រោយរៀបរាប់ពីរឿងរ៉ាវដោយសង្ខេបពីស្ថានភាពជនជាតិភាគតិចដែលកាន់ព្រះពុទ្ធសាសនារស់នៅតំបន់ដីសណ្តទន្លេមេគង្គនៃភាគខាងត្បូងប្រទេសវៀតណាម (កម្ពុជាក្រោម) នៅក្រោមការគ្រប់គ្រងរបស់ជនកុម្មុយនិស្ត ។

**អៀន ហារីស**

# ខ្មែរកម្ពុជាក្រោមៈ
## ពីដំណើរស្វែងរកយុត្តិធម៌ ឆ្ពោះទៅកាន់ការស្ថាបនាបូជនីយដ្ឋាន

ឧក្រិដ្ឋកម្មដែលខ្មែរក្រហមបានប្រព្រឹត្តឡើងប្រឆាំងនឹងប្រជាជនកម្ពុជាបានបង្ហាញឲ្យឃើញពីអំពើដ៏សាហាវឃោរឃៅជាងគេបំផុតក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ។ ក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ ការគ្រប់គ្រងរបស់ខ្មែរក្រហមបានបណ្តាលឲ្យប្រជាជនជាង១,៧លាននាក់ស្លាប់យ៉ាងវេទនា ។ ក្នុងចំណោមជនរងគ្រោះទាំងអស់ ខ្មែរក្រោមគឺជាក្រុមប្រជាជនមួយដែលត្រូវបានចោទប្រកាន់ថាជាជនក្បត់ជាតិ ។ ប្រជាជនខ្មែរក្រោមជាច្រើនគ្រួសារត្រូវបានសម្លាប់បំផុតពូជ ចំណែកអ្នកដែលនៅរស់វិញគឺត្រូវតស៊ូព្យុះពារដើម្បីជម្នះនូវអ្វីដែលពួកគេបានបាត់បង់ ។ ចំពោះអតីតកាលដ៏ជូរចត់នេះបានរុករានជីវិតរបស់ពួកគាត់ទាំងស្រុង ហើយធ្វើឲ្យពួកគាត់មានកំហឹងឈឺចាប់យ៉ាងខ្លាំង ។ ក្នុងករណីខ្លះទៀត អ្នកទាំងនោះថែមទាំងមានបំណងចង់សងសឹកនឹងជនដៃដល់ទាំងឡាយដែលធ្វើបាបនិងសម្លាប់សមាជិកគ្រួសាររបស់ពួកគាត់ផង ។ យ៉ាងណាមិញ កំហឹងទាំងនេះក៏បានរសាត់បាត់បន្តិចម្តងៗទៅតាមពេលវេលាដែលកន្លងផុតទៅ ។

អត្ថបទនេះនឹងធ្វើការពិភាក្សាទៅលើប្រវត្តិរបស់ប្រជាជនខ្មែរក្រោម រួមទាំងមូលហេតុដែលគោលការណ៍នៃរបបខ្មែរក្រហមនេះបានធ្វើការកំណត់គោលដៅក្នុងការបោសសម្អាតប្រជាជនខ្មែរក្រោម ។ ឆ្លងកាត់ការកាប់សម្លាប់ដ៏គួរឲ្យភ័យខ្លាចនិងច្រើនសន្ធឹកសន្ធាប់បែបនេះ សមាជិកនៃសហគមន៍នេះដែលបានមកចូលរួមសវនាការរបស់ ឌុច ដែលជាប្រធានមន្ទីរស-២១ ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានណែនាំឲ្យធ្វើការសម្តែងពីអារម្មណ៍ចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងសម័យនោះ ។ ទោះបីជានាពេលបច្ចុប្បន្ននេះ យុត្តិធម៌ស្ថិតនៅចំពោះមុខពួកគាត់ក៏ដោយ ក៏មានប្រជាជនខ្លះស្នើសុំបន្ថែមឲ្យមានបូជនីយដ្ឋានដែលជាកន្លែងមួយសម្រាប់ឲ្យប្រជាជនអាចប្រារព្ធពិធីបុណ្យបែបសាសនាដើម្បីឧទ្ទិសកុសលផលបុណ្យជូនជនរងគ្រោះខ្មែរក្រោមដែលបានស្លាប់ក្នុងសម័យនោះ ។

### ប្រវត្តិរបស់ប្រជាជនខ្មែរក្រោម

ប្រជាជនខ្មែរកម្ពុជាក្រោម ដែលក្រោយមកត្រូវបានដាក់ឈ្មោះថាជាខ្មែរក្រោម គឺរស់នៅតាមតំបន់ដីសណ្តនៃទន្លេមេគង្គក្រោម ប៉ុន្តែពួកគាត់មានពូជសាសន៍និងអត្តសញ្ញាណជាជនជាតិខ្មែរចាប់តាំងពីការកកើតឡើងនៃនគរគោកធ្លកក្នុងអំឡុងសតវត្សរ៍ទីមួយមកម្ល៉េះ ។ យ៉ាងណាមិញ អាណានិគមបារាំងបានផ្លាស់ប្តូរព្រំដែនកម្ពុជា ដោយគ្រប់គ្រងទឹកដីកូសាំងស៊ីនរហូតដល់ពាក់កណ្តាលសតវត្សរ៍ទី២០ ហើយបន្ទាប់មកកាត់ទឹកដីនោះទៅឲ្យវៀតណាម ។

ចាប់តាំងពីពេលនោះមក មានប្រជាជនខ្មែរក្រោមយ៉ាងច្រើនបានធ្វើការផ្លាស់ប្តូរនិងតាំងទីលំនៅតាមបណ្តោយព្រំដែនបច្ចុប្បន្ននៃប្រទេសកម្ពុជា ។ នៅក្នុងរជ្ជកាលរបស់ព្រះបាទមុនីវង្ស (១៩២៧-១៩៤១) មានប្រជាជនខ្មែរក្រោមជាច្រើនបានចាកចេញពីខេត្តព្រះត្រពាំងរបស់ប្រទេសវៀតណាមទៅកាន់ស្រុកបាកាននៃខេត្តពោធិ៍សាត់ ដែលជាតំបន់អំណោយផលដល់កសិកម្ម ។ លោក មាស ច័ន្ទថន ដែលមានឈ្មោះជាខ្មែរក្រោមថា គឹម



មាស ច័ន្ទថន

យ៉ាំថាយ បាននិយាយថា មុនពេលដែលខ្មែរក្រោមមករស់នៅខេត្តពោធិ៍សាត់ គឺគាត់ធ្លាប់មករស់នៅឃុំរាំងស៊ី ខេត្តបាត់ដំបងនៅក្នុងឆ្នាំ១៩៧០ ហើយទើបផ្លាស់ប្តូរទីលំនៅមកខេត្តពោធិ៍សាត់នៅពេលដែលស្រុកទេសមានសង្គ្រាមជាមួយប្រទេសថៃ ។

ទាំង ថាយ និង ទេព ហួយ ដែលសុទ្ធតែជាខ្មែរក្រោម បាននិយាយថា ភូមិព្រៃឈើទាលដែលឥឡូវនេះហៅថាភូមិរំលេច គឺធ្លាប់ជាចំណុចនៃកន្លែងចងសម្ព័ន្ធមិត្តរបស់ប្រជាជនខ្មែរក្រោម ។ ឪពុកម្តាយរបស់ ហួយ បានផ្លាស់ពីខេត្តត្រាវិញមកនៅទីនោះដែលរួមមានអ្នកភូមិខ្មែរក្រោមចំនួន១៦គ្រួសារផងដែរ ។ អ្នកភូមិខ្មែរក្រោមម្នាក់ឈ្មោះ វ៉ាន់ សាន បាននិយាយថា ដូនតារបស់ពួកគាត់ក៏មកពីខេត្តត្រាវិញនៃប្រទេសវៀតណាមដែរ ហើយមករស់នៅភូមិកំពង់នៅក្នុងឆ្នាំ១៩២២ ។ នៅពេលនោះ គឺមានតែប្រជាជន១០គ្រួសារប៉ុណ្ណោះដែលមកជាមួយគាត់ តែនៅដើមឆ្នាំ១៩៧០គឺមានអ្នកស្នាក់នៅកើនឡើងដល់ទៅ១៥០គ្រួសារឯណោះ ។ ក្នុងការធ្វើបំលាស់ប្តូរទីលំនៅនេះ យ៉ាងហោចណាស់មានមូលហេតុ២យ៉ាង ៖ ដើម្បីចៀសផុតពីសង្គ្រាមនៅវៀតណាម និងដើម្បីស្វែងរកដីធ្វើស្រែចម្ការ ។

ចៅ នី ដែលជាជនជាតិខ្មែរក្រោមកើតនៅអានយ៉ាង បាននិយាយថា កាលពីដើមខ្មែរក្រោមអាចធ្វើដំណើរទៅមកពីប្រទេសវៀតណាមមកកម្ពុជាដោយស្រួល ។ តួយ៉ាងកូនរបស់ពួកគាត់ត្រូវបានបញ្ជូនឲ្យមកសិក្សានៅប្រទេសកម្ពុជា ។ ចៅ សៅ ជាជនជាតិខ្មែរក្រោមម្នាក់ដែលមកសិក្សានៅប្រទេសកម្ពុជា ហើយបានបន្តថ្នាក់បណ្ឌិតផ្នែកច្បាប់នៅប្រទេសបារាំង ។ ប៉ុន្តែបំលាស់ប្តូរទីលំនៅនេះត្រូវបានហាមឃាត់ ឬកាត់បន្ថយនៅពេលដែលស្ថានភាពនយោបាយរវាងវៀតណាមនិងកម្ពុជាប្រជាធិបតេយ្យមានលក្ខណៈរកាំរកូសនៅទសវត្សរ៍៧០ ។

ក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ប្រជាជនខ្មែរក្រោមភាគច្រើនរស់នៅខេត្តពោធិ៍សាត់ កំពង់ចាម កំពង់ឆ្នាំង និងតាកែវ ។ ដោយសារតែហេតុនេះហើយ ទើបធ្វើឲ្យអ្នកខ្លះពិបាកនឹងសម្គាល់ថាតើនរណាជាជនជាតិខ្មែរក្រោមណាស់ ។ តាមដែល ប៉ែន យៀវនិន បានប្រាប់គឺថាជនជាតិខ្មែរក្រោមអាចសម្គាល់បានតាមការបញ្ចេញសំនៀងរបស់ពួកគាត់ ដែលនេះជាចំណុចពិសេសមួយខុសពីជនជាតិវៀតណាម ។ អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជា គីម កែវកន្និដ្ឋា ដែលជាជនជាតិខ្មែរក្រោមមួយរូបដែរនោះបានសរសេរថា ក្នុងការសម្គាល់ជនជាតិខ្មែរក្រោម គឺមើលទៅលើសម្លៀកបំពាក់របស់ពួកគាត់ ។ ចំណែកឯ នី វិញក៏យល់ស្របនឹងការអង្កេតទាំងពីរនេះដែរ ។ បន្ថែមពីលើនេះ គាត់ក៏ប្រាប់ទៀតថា ជនជាតិខ្មែរក្រោមភាគច្រើនមានត្រកូល ចៅ, ថាច់, គីម, សឿន, តាំង, និង ទេព ដែលធ្វើឲ្យមានភាពងាយស្រួលក្នុងការតាមដានពីអត្តសញ្ញាណរបស់ពួកគាត់ ។

## ខ្មែរក្រោម ៖ ជនរងគ្រោះនៃគោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យ

ទោះបីជាជនជាតិខ្មែរក្រោមមានសញ្ជាតិសាសនាប្រពៃណីនិងវប្បធម៌ដូចជនជាតិខ្មែរធម្មតាក៏ដោយ ក៏ជនជាតិខ្មែរក្រោមត្រូវបានខ្មែរក្រហមកំណត់គោលដៅដែរ ។ អ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាលោក ទៀង សុភវិជ្ជា បានផ្តល់នូវទឡ្ហីករណ៍ចំនួនបីសម្រាប់ការសម្លាប់រង្គាលនេះ ទី១) ខ្មែរក្រោមត្រូវបានគេចោទប្រកាន់ថាបម្រើការជាគិញឲ្យជនជាតិវៀតណាមក្នុងបក្សពលករហូជីមិញ ។ ទី២) ខ្មែរក្រោមត្រូវបានយល់ឃើញថាជាសមាជិកនៃចលនាសាមគ្គីដើម្បីរំដោះឥណ្ឌូចិនដឹកនាំដោយ ចៅ ដារ៉ា ដែលត្រូវបានគេស្គាល់ច្បាស់ថាជាសេនាប្រមុខលន់ នល់ ។ ទី៣) ខ្មែរក្រោមត្រូវបានគេចាប់ខ្លួននិងឃុំឃាំងពីបទសង្ស័យថាជាគិញរបស់វៀតណាម នៅពេលដែលខ្មែរក្រហមធ្វើការវាយប្រហារប្រទេសវៀតណាមនៅឆ្នាំ១៩៧៧-៧៨ ។ ដូច្នេះហើយ ការធ្វើបាបនេះមានប្រភពមកពីការពាក់ព័ន្ធទៅនឹងផ្នែកនយោបាយនិងយោធានៅក្នុងរបបចាស់ ។ សាន បានទទួលស្គាល់ថា ជនជាតិខ្មែរក្រោមជាច្រើនពិតជាបានបម្រើការឲ្យរបបលន់ នល់មែន ។

ជាទូទៅ ត្រូវបានគេទទួលស្គាល់ថា ភ្លាមបន្ទាប់ពីការទទួលជោគជ័យពេញលេញ ខ្មែរក្រហមចាប់ផ្តើមធ្វើការស្វែងរកមុខសញ្ញាជាអតីតរដ្ឋការចាស់ ពួកមូលធននិយម ចក្រពត្តិនិយម និងក្រុមជាច្រើនទៀតដែលខ្មែរក្រហមចាត់ទុកថាជាធាតុផ្សំនៃក្រុមប្រឆាំង ។ នី បាននិយាយថា នៅក្នុងឆ្នាំ១៩៧៥ ចៅ សៅ គឺ

ជនរងគ្រោះដំបូងនៃរបបខ្មែរក្រហម ។ នៅពេលនោះ ខៀវ សំផន បានបញ្ជាឲ្យទាហានពីរនាក់ទៅស្វែងរក សៅ ។ ៥ថ្ងៃបន្ទាប់មកទៀត គេក៏ប្រទះឃើញគាត់នៅព្រែកក្ដាមប្រហែលជា៣៥គីឡូម៉ែត្រពីប៉ែកខាងជើងក្រុងភ្នំពេញ ។ ខៀវ សំផន បានសរសេរសំបុត្រមួយទៅសួរ សៅ ពីការវិលត្រឡប់មកទីក្រុងភ្នំពេញវិញ ។ យ៉ាងណាមិញ សៅ បានបដិសេធពីការវិលត្រឡប់មកទីក្រុងភ្នំពេញ លុះត្រាតែអ្នកដែលត្រូវបានគេជម្លៀសទាំងអស់ត្រូវបានគេអនុញ្ញាតឲ្យត្រឡប់មកវិញទាំងអស់គ្នា ។ បន្ទាប់មក មានបញ្ហាថ្មីមួយទៀតធ្លាក់មក ដោយជំរុញឲ្យគាត់ធ្វើតាម បើមិនអ៊ីចឹងទេគាត់នឹងត្រូវបានគេសម្លាប់ចោល ។ ចុងក្រោយ គាត់ត្រូវបានគេសម្លាប់ទាំងគ្រួសារ ។

ថាយ បាននិយាយថា នៅក្នុងឆ្នាំ១៩៧៦ និង១៩៧៧ គឺមានជនជាតិខ្មែរក្រោមជាច្រើនដែលបម្រើការជាកម្មាភិបាលឃុំនិងស្រុកត្រូវបានសម្លាប់ចោលទាំងអស់ ។ គាត់បានបញ្ជាក់ថាដំបូង ជនជាតិខ្មែរក្រោមមិនត្រូវបានគេចោទប្រកាន់ថាជាវៀតណាមនោះទេ ។ ប៉ុន្តែ ស្ថានភាពកាន់តែអាក្រក់ទៅៗចាប់ពីខែកក្កដា ឆ្នាំ១៩៧៨ នៅពេលដែលសង្គ្រាមរវាងកម្ពុជា-វៀតណាមកើនឡើង ។ ការកាប់សម្លាប់ត្រូវបានកំណត់ទៅលើកម្លាំងសំខាន់របស់ខ្មែរក្រោមគឺមនុស្សចាស់ មនុស្សស្រី និងបន្ទាប់មកក្មេងៗ ។

ហួយ យល់ស្របនឹងអ្វីដែល ថាយ បាននិយាយ ។ គាត់និយាយថា ខ្មែរក្រោមនៅក្នុងឃុំរំលេចត្រូវបានពិនិត្យយ៉ាងល្អិតល្អន់ ហើយបញ្ជូនទៅរស់នៅថ្នល់ទទឹងចាប់តាំងពីខែកក្កដាឆ្នាំ១៩៧៨ ។ ខ្មែរក្រហមបានទុកពេលឲ្យពួកគាត់បី-បួនថ្ងៃដើម្បីអំពាវនាវហៅបងប្អូនខ្មែរក្រោមរបស់ពួកគាត់មករស់នៅនិងធ្វើការនៅទីនោះជាមួយគ្នា ។ ប៉ុន្តែ ការប្រមូលផ្តុំគ្នារបស់ក្រុមគ្រួសារខ្មែរក្រោមនេះគឺគ្រាន់តែជាល្បិចនយោបាយដើម្បីកម្ចាត់ចោលជនជាតិខ្មែរក្រោមទាំងអស់ក្នុងពេលតែមួយប៉ុណ្ណោះ ។ ការសម្លាប់ម្តងៗគឺចាប់ពី៥០០ទៅ៧០០នាក់ ។ គីម សួរ ដែលជាខ្មែរក្រោមដែលនៅរស់បាននិយាយថា គាត់អាចរួចផុតពីការសម្លាប់ ដោយសារតែគាត់ធ្លាប់ជាប់គុកនៅភូមិវាល ។ ចំណែកឯឪពុកម្តាយរបស់គាត់វិញមិនបានដឹងថាគាត់ធ្លាប់នៅទីនោះទេ ។

ឆ្លងកាត់ការអង្កេតទៅលើបទសម្ភាសន៍ទាំងអស់នេះរួចមកបញ្ជាក់ឲ្យឃើញថា ខ្មែរក្រហមបានកំណត់គោលដៅទៅលើខ្មែរក្រោមនៅពេលដែលពួកវាអុជភ្លើងសង្គ្រាមព្រំដែនជាមួយនឹងវៀតណាម ។ ថាយ និយាយថាជាដំបូងប្រជាជនវៀតណាមត្រូវបានស្វែងរកនិងសម្លាប់ ។ បន្ទាប់មក ខ្មែរក្រោមត្រូវបានកំណត់គោលដៅដោយសារតែខ្មែរក្រហមយល់ឃើញថាខ្មែរក្រោមគឺជាជនជាតិវៀតណាមឬជាគិញវៀតណាម ។ នី បានបញ្ជាក់ទៀតថា ខ្មែរក្រោមត្រូវបានដាក់ងារថាជាពួក «ក្បាលយួនខ្លួនខ្មែរ» ។ ហើយក្នុងករណីខ្លះទៀត ខ្មែរក្រោមត្រូវបានយល់ឃើញថាជាមនុស្សក្បាលពីរ ។

សាន ដែលបាត់បង់ឪពុកម្តាយនិងបងប្អូន៥នាក់បានលើកឡើងថា ការសម្លាប់ត្រូវបានបញ្ឈប់ នៅពេលដែលប្រជាជនមកពីភូមិភាគបូព៌ាត្រូវបានបញ្ជូនទៅខេត្តពោធិ៍សាត់ ។ នៅពេលនោះខ្មែរក្រហមប្រើប្រាស់ខ្មែរក្រោមដើម្បីសម្លាប់ប្រជាជនមកពីភូមិភាគបូព៌ា ។ ហើយបន្ទាប់មកទៀតគឺ ជាវេនរបស់ពួកគេ ។ ប៉ុន្តែជាមួយនឹងជ័យជម្នះដែលកងទ័ពវៀតណាមបានផ្តួលរំលំកងទ័ពខ្មែរក្រហមនៅឆ្នាំ១៩៧៩ ទើបធ្វើឲ្យប្រជាជនខ្មែរក្រោមខ្លះអាចនៅរស់រានមានជីវិតខ្លះ ។

កនិដ្ឋា អតីតអ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលសិក្សាពីជនជាតិខ្មែរក្រោមបានរៀបរាប់ថា «យោងទៅតាមឯកសារដែលរកឃើញនៅមន្ទីរស-២១ បានឲ្យដឹងថាជនជាតិខ្មែរក្រោមចំនួន៤០នាក់ត្រូវបានបញ្ជូនទៅមន្ទីរស-២១.... ហើយក្នុងឆ្នាំ១៩៧៧ អ្នកទោស៨នាក់ត្រូវបានសម្លាប់ ហើយឆ្នាំ១៩៧៨មានចំនួន៣នាក់ទៀត» ។ នៅក្នុងភូមិរំលេច កនិដ្ឋា បានជួបជាមួយ ប្រាក់ សារិន ដែលលោកបាននិយាយប្រាប់ថាកាលពីឆ្នាំ១៩៦៤ មានប្រជាជនខ្មែរក្រោមចំនួន៥០០គ្រួសារស្មើនឹងសមាជិកជាង៤០០០នាក់ ហើយតាមការអង្កេតរបស់គាត់បានឲ្យដឹងថា ប្រជាជនខ្មែរក្រោមដែលរស់នៅក្នុងភូមិនេះត្រូវបានសម្លាប់ទាំងអស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

## ទស្សនៈទូទៅស្តីពីកិច្ចដំណើរការនីតិវិធីរបស់តុលាការ

អ្នកភូមិទាំង១៣០នាក់ដែលមកចូលរួមក្នុងសវនាការ ឌុច នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាមួយនឹងមជ្ឈ-

មណ្ឌលឯកសារកម្ពុជា ជាពិសេសជនជាតិខ្មែរក្រោមបានយល់ឃើញថាខ្លួនឯងគឺជាអ្នកតំណាងឲ្យប្រជាជនដែលបានស្លាប់នៅក្នុងសម័យនោះ ។ ពួកគាត់ចង់បានយុត្តិធម៌ជូនដល់ជនជាតិខ្មែរក្រោមក៏ដូចជាប្រជាជនខ្មែរទាំងអស់ផងដែរ ។ អារម្មណ៍នៃការពេញចិត្ត ការសប្បាយរីករាយ កំហឹង ការឈឺចាប់ និងសេចក្តីសង្ឃឹមបានកើតមានឡើងក្នុងទឹកចិត្តរបស់ពួកគាត់ នៅពេលដែលពួកគាត់ឈានជើងចូលទៅក្នុងបន្ទប់សវនាការជាលើកដំបូង ។ ហួយ និង នីបាននិយាយថាពួកគាត់ទន្ទឹងរង់ចាំជាយូរមកហើយដើម្បីចូលរួមនិងអង្កេតកិច្ចដំណើរការនីតិវិធីរបស់តុលាការប្រឆាំងនឹង ឌុច នេះ ។

ថាយ បានបញ្ចេញមតិថា ជាមួយនឹងការរួមសហការរវាងអង្គការសហប្រជាជាតិនិងកម្ពុជា ប្រជាជនខ្មែរនឹងអាចទទួលបានយុត្តិធម៌ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាមិនខាន ដោយសារតែដំណើរការនីតិវិធីនេះនឹងត្រូវបានត្រួតពិនិត្យយ៉ាងល្អិតល្អន់ ។ គាត់បានបន្ថែមទៀតថា នេះគឺយោងទៅតាមនីតិរដ្ឋតែប៉ុណ្ណោះ កាលដែលថាជនដៃដល់ត្រូវបានផ្តន្ទាទោសទៅតាមឧក្រិដ្ឋដែលពួកគេបានប្រព្រឹត្ត ។ ប៉ុន្តែ គាត់ព្រួយបារម្ភពីឥទ្ធិពលដែលនឹងអាចប៉ះពាល់ដល់ឯករាជ្យភាពនិងយុត្តិធម៌របស់តុលាការ ។ នី បានបញ្ជាក់បន្ថែមទៀតថា សវនាការរបស់ ឌុច ដែលជាប្រធានគុកទួលស្លែងគឺតំណាងឲ្យដំណើរការដំបូងប្រឆាំងទៅនឹងមេដឹកនាំខ្មែរក្រហមចាប់តាំងពីឆ្នាំ១៩៧៩ ។ តុលាការនេះបានធ្វើឲ្យប្រជាជននឹកឃើញឡើងវិញពីការចងចាំដ៏ជូរចត់ ដែលពួកគាត់បានទទួលរងក្នុងសម័យរបបខ្មែរ ក្រហម ។

គីម សួរ ដែលជាប្រជាជនខ្មែរក្រោមម្នាក់បាននិយាយថា «នេះធ្វើឲ្យខ្ញុំនឹកឃើញកាលដែលខ្ញុំត្រូវបានគេដាក់ខ្នោះអស់រយៈពេល៣ថ្ងៃ ហើយថែមទាំងត្រូវគេធ្វើទារុណកម្មទៀតផង ។ ពួកវាសួរខ្ញុំថាតើឯងជានរណា? ខ្ញុំឆ្លើយថាខ្ញុំគ្រាន់តែជាកសិករម្នាក់ប៉ុណ្ណោះ ។ បន្ទាប់មក ពួកវាបន្តសួរដេញដោលពីរឿងរ៉ាវផ្សេងៗរបស់ខ្ញុំ ។ ពួកវាធ្វើទារុណកម្មខ្ញុំរហូតដល់ខ្ញុំសន្លប់បី-បួនដង ។ ខ្ញុំត្រូវបានពួកវាចោទប្រកាន់ថាជាកិញវៀតណាម ។ តែតាមការពិត ខ្ញុំអត់មានពាក់ព័ន្ធនឹងសកម្មភាពនោះទេ ។ បន្ទាប់មក ខ្ញុំចូលធ្វើជាកងចល័តឲ្យអង្គការ» ។ ទាំងនេះហើយទើបធ្វើឲ្យ សួរ សន្និដ្ឋានថា មេគុកដូចជា ឌុច ធ្វើបាបអ្នកទោសយ៉ាងកាចសាហាវណាស់ ។ ដោយសារតែកំហឹងរបស់គាត់កាន់តែខ្លាំងឡើងៗ ទើបធ្វើឲ្យគាត់សម្រេចចូលបម្រើជាកងទ័ពក្រោយឆ្នាំ១៩៧៩ ដើម្បីសងសឹកនឹងខ្មែរក្រហមដែលបានធ្វើបាបគាត់ ។ ជីវិតជាកងទ័ពរបស់គាត់មិនបានធ្វើឲ្យគាត់សម្រេចនូវគោលបំណងនោះទេ ប៉ុន្តែបែរជាធ្វើឲ្យគាត់ពិការជើងម្ខាងទៅវិញ គួបផ្សំនឹងការបាត់បង់ញាតិសន្តានទាំងអស់ដែលត្រូវបានខ្មែរក្រហមសម្លាប់ដោយចោទប្រកាន់ថាជាសត្រូវនឹងអង្គការ ។

ដោយធ្វើការអង្កេត និងបញ្ចេញយោបល់ទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលអ្នកភូមិទាំងអស់បានឆ្លងកាត់នៅក្នុងសហគមន៍របស់ពួកគាត់ ធ្វើឲ្យអ៊ំស្រី ហួយ លើកឡើងថា ជនត្រូវចោទគួរតែត្រូវបានឃុំខ្លួននៅកន្លែងដែលមានស្ថានភាពដូចដែលអ្នកទោសកាលពីសម័យខ្មែរក្រហមអ៊ីចឹង ។ ប៉ុន្តែ ទន្ទឹមនឹងពេលនេះដែរ គាត់ក៏បានបញ្ជាក់ថា អ្នកដែលនៅរស់ពីរបបខ្មែរក្រហមមិនគួរសម្តែងចេញសកម្មភាពហិង្សាផ្សេងៗនោះទេ ។ យុត្តិធម៌អាចទប់ស្កាត់ប្រជាជនមិនឲ្យចូលរួមក្នុងសកម្មភាពហិង្សា ។ តាមទស្សនៈរបស់គាត់គឺថា ការផ្សះផ្សាជាតិជាទ្រឹស្តីមួយដែលយើងម្នាក់ៗគួរតែចងចាំទុកក្នុងចិត្ត ហើយងាកមករកការអនុវត្តផ្ទាល់ដើម្បីជួយប្រជាជនម្នាក់ៗក៏ដូចជាប្រទេសជាតិទាំងមូលផងដែរ ។ ចំណែកឯអ៊ំ សាន វិញក៏បានបញ្ជាក់បន្ថែមទៀតដែលថា គាត់មានអារម្មណ៍ធូរស្បើយខ្លាំងណាស់នៅពេលដែលឃើញមានតុលាការកើតឡើងដូច្នេះ ។ ជាពិសេសគាត់គិតថា យ៉ាងហោចណាស់ ការឈឺចាប់របស់គាត់មិនត្រូវគេបានព្រងើយកន្តើយឡើយ ។ រីឯ នីវិញមិនមានមតិជំទាស់ទៅនឹងទស្សនៈ របស់ ហួយ និង សាន នោះទេ ។ ប៉ុន្តែ គាត់សង្កត់ធ្ងន់ថា ការផ្សះផ្សាជាមួយនឹងការបាត់បង់ដ៏សម្បើមនិងការបង្ខំឲ្យឃ្លាតឆ្ងាយពីបងប្អូននេះគឺជារឿងមួយដ៏ពិបាកណាស់ ។ គាត់ជឿជាក់ថា យុត្តិធម៌តែម្ខាងគ្រាន់តែអាចផ្តល់នូវការធូរស្បើយត្រឹមតែ២០ទៅ៣០ភាគរយប៉ុណ្ណោះជូនដល់អ្នកនៅរស់ ។ នៅក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ទាំងអស់ ភាគច្រើនបាននិយាយថា យុត្តិធម៌អាចផ្តល់នូវភាពជិតស្និទ្ធជាក់លាក់មួយដល់ពួកគាត់បាន ។

## បួជនីយដ្ឋានសម្រាប់ខ្មែរក្រោម

ក្នុងអំឡុងពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ របបកម្ពុជាប្រជាធិបតេយ្យបានប្រហារជីវិតមនុស្សយ៉ាងច្រើនសន្ធឹកសន្ធាប់ ហើយនាំមកនូវការឈឺចាប់ដែលមិនអាចពិពណ៌នាបានសម្រាប់ប្រជាជនខ្មែរគ្រប់រូប ។ យុត្តិធម៌នឹងកើតមានដល់អ្នកដែលនៅរស់ នៅពេលដែលអង្គជំនុំជម្រះចាប់ផ្ដើមកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនៅក្នុងឃុំទាំងប្រាំរូបនោះ ។ ឌុច គឺជាមេដឹកនាំខ្មែរក្រហមទីមួយដែលត្រូវនាំយកមកកាត់ទោសនៅចំពោះមុខអង្គជំនុំជម្រះ ។ ក្រៅពីយុត្តិធម៌ អ្នកដែលនៅរស់ពីរបបខ្មែរក្រហមត្រូវតស៊ូពុះពារជម្នះនឹងស្នាមរបួសផ្លូវចិត្ត ក៏ដូចជាជំងឺផ្លូវចិត្តនេះផងដែរ ។ ការណ៍នេះបណ្ដាលឲ្យពួកគាត់ព្យាយាមស្វែងរកដំណាក់កាលជាច្រើនទៀតដែលអាចជួយពួកគាត់បាន ។

ទោះបីជារបបនេះបានកន្លងផុតទៅ៣០ឆ្នាំក៏ពិតមែន ប៉ុន្តែកិច្ចខំប្រឹងប្រែងរបស់ប្រជាជនខ្មែរក្រោមក្នុងការកសាងបូជនីយដ្ឋានមួយសម្រាប់រំឭកដល់ក្រុមគ្រួសាររបស់ពួកគេបានបង្ហាញឲ្យឃើញថាជាការងារមួយដែលត្រូវចំណាយពេលវេលាច្រើនណាស់ ។ ថាយ ដែលជាអ្នកបង្កើតនូវគំនិតក្នុងការស្ថាបនាបូជនីយដ្ឋាននេះបានរៀបរាប់អំពីមូលហេតុដែលគាត់បានផុសគំនិតនេះឡើង ។ គាត់បានបញ្ជាក់ថា ក្រោយឆ្នាំ១៩៧៩ភ្លាមបូជនីយដ្ឋានធ្វើពីឈើមួយត្រូវបានសាងសង់ឡើងក្នុងគោលបំណងដើម្បីតម្កល់អដ្ឋិធាតុប្រជាជនខ្មែរក្រោមនិងជនរងគ្រោះដទៃទៀតឲ្យបានសមរម្យ ។ តែបន្ទាប់មកទៀត ភាពចាស់ទ្រុឌទ្រោមនៃបូជនីយដ្ឋាននេះបានធ្វើឲ្យប៉ះពាល់ដល់អដ្ឋិធាតុរបស់ជនរងគ្រោះ ។ បន្ទាប់មក លោកសង្ឃជាច្រើនអង្គមានបំណងការពារអដ្ឋិធាតុទាំងអស់នេះ ដោយធ្វើការរកប់អដ្ឋិធាតុនេះជាបណ្ដោះអាសន្នសិន ។ ថាយ ក៏សម្រេចចិត្តជួលឡានបួនគ្រឿង ដើម្បីដឹកអដ្ឋិធាតុទាំងអស់នេះយកទៅកប់នៅវត្តរំលេចដោយរង់ចាំរហូតទល់តែបូជនីយដ្ឋានថ្មីមួយត្រូវបានស្ថាបនារួច ។ តែជាអកុសល រហូតដល់ថ្ងៃនេះ អ្វីដែលគាត់គ្រោងទុកនោះគឺមិនបានទទួលជោគជ័យទេ ។ អដ្ឋិធាតុទាំងអស់នោះទទួលរងការប៉ះពាល់យ៉ាងខ្លាំងពីភាពសើករេចរិល ក៏ដូចជាសត្វគោជ្រូកជាដើមដែលមកស៊ីចំណីនៅជិតនោះ ។

នៅពេលដែលគម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញ ថាយ ឲ្យមកចូលរួមក្នុងដំណើរការសវនាការរបស់ ឌុច ឆ្លៀតឱកាសដ៏ល្អនេះ ថាយ ក៏បានបញ្ចេញយោបល់របស់គាត់ក្នុងការស្នើសុំឲ្យមានការសាងសង់បូជនីយដ្ឋាននេះឡើង ។ គាត់បានពន្យល់ប្រាប់ខ្ញុំថា បូជនីយដ្ឋានដែលបានស្នើឡើងនេះ គឺដើរតួនាទីយ៉ាងសំខាន់ខ្លាំងណាស់ក្នុងការជួយជនរងគ្រោះខ្មែរក្រោមនិងអ្នកដែលនៅរស់ទាំងអស់ ។ ទីមួយ ប្រជាជនខ្មែរក្រោមមានបំណងចង់បង្ហាញពីសេចក្ដីស្រឡាញ់និងការគោរពចំពោះសាច់ញាតិរបស់ពួកគាត់ដែលត្រូវបានសម្លាប់ក្នុងរបបខ្មែរក្រហម ហើយចង់ឲ្យវិញ្ញាណក្ខន្ធរបស់ពួកគាត់បានទៅកាន់សុគតិភពផងដែរ ។ ទីពីរ បូជនីយដ្ឋាននេះក៏អាចក្លាយជាដំណើរការមួយដ៏មានប្រយោជន៍និងមានន័យជាទីបំផុតក្នុងការជួយកាត់បន្ថយរបួសផ្លូវចិត្តរបស់អ្នកដែលនៅរស់ ។ ទីបី បូជនីយដ្ឋាននេះអាចបម្រើការជាមជ្ឈមណ្ឌលអប់រំមួយដើម្បីបង្ហាត់បង្រៀនកូនចៅជំនាន់ក្រោយឲ្យចងចាំពីអតីតកាល ជាពិសេសអាចជួយទប់ស្កាត់ការកើតមានឡើងម្ដងទៀតនៃរបបដ៏ឃោរឃៅនេះ ។

ថាយ នៅតែប្រកាន់យ៉ាងខ្ជាប់ខ្ជួនចំពោះសំណើរបស់គាត់ ។ គាត់ជឿជាក់ថា បូជនីយដ្ឋានដែលគាត់បានស្នើសុំនេះមានឈ្មោះថា «បូជនីយដ្ឋានប្រវត្តិសាស្ត្រភូមិរំលេច» នឹងអាចទាក់ទាញការយកចិត្តទុកដាក់ពីសំណាក់សាធារណជន ឬសប្បុរសជនផ្សេងៗ ។ សួរ, ហួយ និង នី ក៏បានសម្ដែងនូវការថ្លែងអំណរគុណចំពោះគំនិតស្ថាបនាបូជនីយដ្ឋាននេះ ហើយគាត់ក៏បានលើកឡើងផងដែរថា បូជនីយដ្ឋាននេះនឹងជួយគាំទ្រអ្នកដែលនៅរស់ទាំងផ្នែកស្មារតី វប្បធម៌និងសាសនា ។ សាន ដែលមានបងប្អូនស្លាប់អស់៧នាក់មានសេចក្ដីរីករាយណាស់ចំពោះការបង្កើតបូជនីយដ្ឋាននេះ ប៉ុន្តែគាត់នៅតែមិនទាន់ច្បាស់ពីការស្ថាបនានេះនៅឡើយ ។ ការខ្វល់ខ្វាយរបស់ សាន គឺដោយសារតែសំណង់បូជនីយដ្ឋាននេះត្រូវការថវិកានិងការយល់ព្រមផ្នែកនយោបាយទៀត ។ ដោយសារតែហេតុផលនេះហើយ ថាយ បានអំពាវនាវឲ្យសាធារណជននិងសហគមន៍អន្តរជាតិចូលរួមចំណែកក្នុងការសាងសង់បូជនីយដ្ឋាននេះ ដើម្បីទុកជាការចងចាំមួយជូនដល់ជនរងគ្រោះខ្មែរក្រោមដែលត្រូវបានសម្លាប់ក្នុងរបបខ្មែរក្រហម ។

**លី សុខឃាង**

# លិខិតថ្លែងអំណរគុណ

*យើងខ្ញុំទាំងអស់គ្នាមានចំនួន១០នាក់មានដើមកំណើតជាខ្មែរកម្ពុជាក្រោមមកពីឃុំចំនួនបី គឺឃុំរំលេច ឃុំខ្នារទទឹង និងឃុំស្វាយដូនកែវ នៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ។*

*យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានលោក ឆាំង យុ ជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបានអនុញ្ញាតឲ្យបងប្អូនខ្មែរកម្ពុជាក្រោម ដែលជាជនរងគ្រោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានចូលរួមធ្វើទស្សនកិច្ចសិក្សារយៈពេលដ៏ខ្លីមួយនៅសាលាក្តីខ្មែរក្រហម សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងសារមន្ទីរប្រល័យពូជសាសន៍វាលពិឃាដជើងឯក ។*

*លោកនាយកបានអនុញ្ញាតឲ្យរូបខ្ញុំបាទជាតំណាងបងប្អូនទាំងអស់មកពីខេត្តពោធិ៍សាត់ បានជួបសំណេះសំណាលដោយផ្ទាល់ដើម្បីស្វែងយល់ពីការកាប់សម្លាប់បងប្អូនខ្មែរកម្ពុជាក្រោមអស់រាប់ម៉ឺននាក់នៅលើទឹកដីនៃភូមិព្រៃឈើទាលទាំងមូល ដែលបច្ចុប្បន្នស្ថិតនៅក្នុងឃុំរំលេច ឃុំខ្នារទទឹង ឃុំត្រពាំងជង ឃុំបឹងខ្នារ ឃុំអូរតាប៉ោង នឹងឃុំស្វាយដូនកែវ នៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ។ នេះជាឱកាសដ៏ល្អមួយដែលខ្ញុំបានសំណេះសំណាលនិងលើកជាយោបល់ជូនទៅលោក ឆាំង យុ ដើម្បីសុំសាងសង់កន្លែងប្រវត្តិសាស្ត្រមួយ ឬសារមន្ទីរប្រវត្តិសាស្ត្រនៅក្នុងឃុំរំលេច ដើម្បីនាំយកអដ្ឋិធាតុ ភ័ស្តុតាងនិងឯកសារផ្សេងៗមកតម្កល់នៅទីនោះ និងដើម្បីប្រាប់បងប្អូនជនរួមជាតិទាំងក្នុងនិងក្រៅប្រទេសឲ្យបានដឹងនិងជ្រាបថាតើនៅក្នុងពេលដែលខ្មែរក្រហមឡើងកាន់អំណាចមានរឿងអ្វីខ្លះដែលបានកើតឡើងទៅលើបងប្អូនខ្មែរក្រោមក្នុងទឹកដីដ៏អភ័ព្វមួយនេះ ។*

*ក្រោយពីសំណើនេះត្រូវបានលោកនាយកទទួលយកទៅធ្វើការពិចារណានិងស្រាវជ្រាវបន្ថែម ធ្វើឲ្យពួកយើងខ្ញុំទាំងអស់គ្នាមានការសប្បាយរីករាយជាខ្លាំងនិងមានជំនឿជឿជាក់ទៅលើស្មារតីទទួលខុសត្រូវខ្ពស់របស់លោកនាយកក្នុងការស្វែងរកការពិតក្នុងសង្គមកម្ពុជា ក៏ដូចជាបងប្អូនខ្មែរកម្ពុជាក្រោម ។*

*មួយវិញទៀត មជ្ឈមណ្ឌលបានចាត់តំណាងម្នាក់ឈ្មោះលោក លី សុខឃាង ជាប្រធានផ្នែកគម្រោងឯកសាររស់ឲ្យមកទទួលស្វាគមន៍បងប្អូនយើងយ៉ាងកក់ក្តៅនៅពេលដែលយើងមកចូលរួមសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ លោក លី សុខឃាង បានយកចិត្តទុកដាក់ចំពោះបងប្អូនខ្មែរកម្ពុជាក្រោមយើងយ៉ាងខ្លាំង ហើយថែមទាំងបានសម្ភាសន៍អំពីជីវិតរស់នៅក្នុងរបបខ្មែរក្រហមដែលបានសម្លាប់បងប្អូនខ្មែរកម្ពុជាក្រោមនៅទីនេះ ។ បងប្អូនដែលត្រូវបានសម្ភាសន៍បានមានប្រសាសន៍ឲ្យដឹងអំពីការបាត់បង់ឪពុកម្តាយ បងប្អូន ជីដូនជីតាដែលជាទីស្រឡាញ់ និងទម្ងន់នៃការធ្វើទារុណកម្មក្នុងរបបខ្មែរក្រហមបានធ្វើមកលើរូបគាត់ម្នាក់ៗ និងបានឃើញពីសកម្មភាពផ្ទាល់ក្នុងការកេណ្ឌបងប្អូនខ្មែរកម្ពុជាក្រោមទាំងក្មេង ទាំងចាស់យកទៅសម្លាប់ជាប្រព័ន្ធរយៈពេល៣ថ្ងៃនៅលើទឹកដីនេះ ។*

*នៅទីបញ្ចប់យើងទាំងអស់គ្នា សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះការយកចិត្តទុកដាក់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាមកលើបងប្អូនខ្មែរកម្ពុជាក្រោម និងសូមគោរពជូនពរសុំឲ្យលោកនាយកនិងបុគ្គលិកទាំងអស់ទទួលបាននូវជោគជ័យថ្មីៗក្នុងការស្វែងរកការពិតជូនប្រជាជនកម្ពុជាតរៀងទៅ ។*

*សូមគោរពជូនលោកនាយកនិងក្រុមគ្រួសារទទួលបាននូវពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។*

*ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។*

*ខេត្តពោធិ៍សាត់ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩*

**មាស ច័ន្ទថន**

# ប្រតិកម្មរបស់ជនរងគ្រោះចំពោះការសុំអត់ឱនទោសរបស់ឌុច: តើការអត់ឱនទោសអាចទៅរួចដែរឬទេ?

«អ្វីដែលខ្ញុំសូមស្នើសុំគឺការអត់ឱនទោស ។ ទោះបីជាអ្នកទាំងអស់គ្នាមិនអាចអត់ឱនទោសឲ្យខ្ញុំបាននៅពេលនេះក៏ដោយ ក៏ខ្ញុំសូមឲ្យអ្នកទាំងអស់គ្នាបើកទ្វារសម្រាប់ខ្ញុំនៅពេលអនាគត» ឌុច បាននិយាយពាក្យទាំងនេះក្នុងការចាប់ផ្តើមដំណើរការកាត់ទោសរបស់ខ្លួននៅភ្នំពេញដើម្បីស្វែងរកនូវការអត់ឱនទោស សម្រាប់អំពើសាហាវឃោរឃៅដែលគាត់បានប្រព្រឹត្តក្នុងសម័យខ្មែរក្រហម ។ ប្រសិនបើយើងគិតពិចារណាលើសារជាតិឧក្រិដ្ឋកម្មដ៏ឃោរឃៅរបស់ ឌុច ទោះបីជាអាចទៅរួច ក៏វាមានភាពលំបាកដែរក្នុងការទស្សន៍ទាយពីប្រតិកម្មរបស់ជនរងគ្រោះចំពោះសំណូមពរឲ្យអត់ឱនទោសរបស់ ឌុច នេះ ។ ដើម្បីធ្វើការស្វែងយល់អំពីប្រតិកម្មប្រជាជនឲ្យកាន់តែប្រសើរឡើង ខ្ញុំបានសម្រេចចិត្តរៀបចំធ្វើការសម្ភាសជាមួយនឹងជនរងគ្រោះរបស់ ឌុច និងជនរស់រានមានជីវិតដទៃទៀត ។ អ្នកទាំងអស់ដែលត្រូវបានធ្វើការសាកសួរសុទ្ធតែជាអ្នកដែលរួចរស់ជីវិតពីមន្ទីរធ្វើទារុណកម្ម ស-២១ និងត្រូវជាសាច់ញាតិរបស់ជនរងគ្រោះដែលត្រូវបានសម្លាប់នៅក្រោមការគ្រប់គ្រងរបស់ ឌុច ក្នុងមន្ទីរស-២១ ។ ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីទាំងប្រាំមួយនាក់លើកលែងតែម្នាក់ដែលមិនប្រាកដអំពីចម្លើយរបស់ខ្លួនបាននិយាយថា ពួកគេមិនអាចអត់ឱនទោសឲ្យ ឌុច សម្រាប់អំពើសាហាវឃោរឃៅដែលគាត់បានប្រព្រឹត្តមកលើពួកគេបានទេ ។

នៅមជ្ឈមណ្ឌលឯកសារកម្ពុជា គម្រោងជួយជនរងគ្រោះបានរៀបចំអង្គប្រជុំជាច្រើនលើកដើម្បីផ្តល់ព័ត៌មានដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានតុលាការទទួលស្គាល់ក្នុងសំណុំរឿងរបស់ ឌុច ឲ្យដឹងពីដំណើរការទៅមុខរបស់តុលាការ ។ កាលពីថ្ងៃទី២៧ ដល់ ២៩ គម្រោងជួយជនរងគ្រោះបានអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីចំនួន២៨នាក់ ឲ្យចូលរួមក្នុងអង្គប្រជុំមួយនៅភ្នំពេញដែលមេធាវីរបស់ពួកគាត់គឺ (ដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ) និងខ្ញុំបានផ្តល់ព័ត៌មានសង្ខេបស្តីអំពីដំណើរការទៅមុខរបស់តុលាការជូនដល់ពួកគាត់ ។ លើសពីនេះទៅទៀត ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះបានចូលរួមស្តាប់សវនាការក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ប្រតិកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីលើការសូមអត់ឱនទោសរបស់ ឌុច មានសេចក្តីដូចខាងក្រោម ៖

ហ៊ា មកពីខេត្តបន្ទាយមានជ័យ ៖ ហ៊ា ជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ ហើយក៏ជាជនរងគ្រោះផ្ទាល់របស់មន្ទីរស-២១ដែរ ។ គាត់គឺជាអ្នកទោសម្នាក់ក្នុងចំណោមអ្នកទោសមួយចំនួនតូចដែលមានសំណាងត្រូវបានដោះលែងពីមន្ទីរធ្វើទារុណកម្មស-២១ ។ ហ៊ា បានពិការដៃឆ្វេងពាក់កណ្តាល ដែលនេះជាលទ្ធផលនៃការវាយធ្វើបាប និងធ្វើទារុណកម្មដែលគាត់បានទទួលរងនៅក្នុងគុកទួលស្លែង ។ យោងតាមអត្ថបទចម្លើយសារភាពរបស់គាត់ ហ៊ា ត្រូវបានដោះលែងចេញពីមន្ទីរស-២១ នៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ក្រោយពីបានរស់នៅក្នុងគុកទួលស្លែងអស់រយៈពេលប្រាំខែ ។ ខណៈពេលដែលឃើញ ឌុច នៅក្នុងតុលាការ ហ៊ា បានប្រាប់ខ្ញុំថា អតីតកាលរបស់គាត់ទាំងអស់បានវិលត្រឡប់មកវិញ ។ ហ៊ា បាននិយាយថា «ខ្ញុំចាប់ផ្តើមចាំរឿងរ៉ាវគ្រប់បែបយ៉ាងទាំងអស់តាំងពីការហូបចុក ការដេក និង ការបន្ទោបង់» ។ ទោះបីជា ហ៊ា ទទួលស្គាល់ថា ឌុច ត្រូវបានបង្ខំឲ្យបំពេញតួនាទីដ៏លំបាកដោយសារតែភាពភ័យខ្លាចអំពីសុវត្ថិភាពខ្លួនគាត់និងគ្រួសារគាត់ក៏ដោយ ក៏ ហ៊ា នៅតែជឿថា ឌុច មានជម្រើសសម្រាប់គាត់ដែរ ។

សុផាន មកពីខេត្តកំពង់ចាម ៖ សុផាន គឺជាដើមបណ្តឹងរដ្ឋប្បវេណីដែលតុលាការបានទទួលស្គាល់រួចហើយនៅក្នុងសំណុំរឿងរបស់ ឌុច ។ បងស្រីរបស់ សុផាន ត្រូវបានចាប់ខ្លួនបញ្ជូនទៅគុកទួលស្លែង ។ សុផាន បានប្រាប់ថា បងស្រីរបស់គាត់ត្រូវបានចាប់ខ្លួនពីបទមាន «កំហុសក្នុងការជាប់ពាក់ព័ន្ធ» ដោយសារតែប្តី

របស់បងស្រីគាត់ធ្លាប់ធ្វើការឲ្យស្ថានទូតនៅទីក្រុងប៉េកាំង ប្រទេសចិន ។ សុផាន បាននិយាយថា គាត់បានសម្រេចចិត្តធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីស្វែងរកយុត្តិធម៌ សម្រាប់បងស្រីរបស់គាត់និងជនរងគ្រោះដទៃទៀត ។ ខណៈពេលដែល សុផាន ត្រូវបានសួរនូវសំណួរមួយថាតើគាត់អាចអត់ឱនទោសឲ្យ ឌុច បានដែរឬទេ? សុផាន និយាយថា «ខ្ញុំមិនអាចអត់ឱនទោសឲ្យ ឌុច បានទេប្រសិនបើពិនិត្យមើលទៅលើទុក្ខវេទនាដែលជនរងគ្រោះបានទទួលរង ។ ឌុច ត្រូវតែកាត់ទោស និងសមតែទទួលនូវទណ្ឌកម្មដែលសម្រេចដោយតុលាការ ។ ខ្ញុំមិនអាចអត់ឱនទោសឲ្យ ឌុច បានឡើយ» ។ សុផាន ជឿជាក់ថា ឌុច ពិតជាមានសារជាតិឃោរឃៅតាំងពីកំណើតដែលឲ្យគាត់ប្រព្រឹត្តនូវអំពើឃោរឃៅដែលអាចធ្វើទៅរួច ។ សុផាន បាននិយាយបន្ថែមទៀតថា «ខ្ញុំមិនជឿថា ឌុច ធ្វើតាមបញ្ជាថ្នាក់លើទេ ។ យោងតាមបទពិសោធន៍ដែលខ្ញុំបានឆ្លងកាត់ក្នុងរបបនេះ ខ្មែរក្រហមទុកជីវិតឲ្យតែអ្នកមានចរិតសាហាវប៉ុណ្ណោះ» ។

ពិសិដ្ឋ មកពីខេត្តស្វាយរៀង ៖ ប្រពន្ធរបស់ ពិសិដ្ឋ មានបងស្រីដែលត្រូវបានសម្លាប់នៅក្នុងគុកទួលស្លែងត្រូវបានទទួលស្គាល់ដោយតុលាការនៅឆ្នាំ២០០៨ ថាជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងរបស់ ឌុច ។ ជាអកុសល ដោយសារតែមានជំងឺធ្ងន់ធ្ងរ ប្រពន្ធរបស់ ពិសិដ្ឋ បានស្លាប់នៅចុងឆ្នាំ២០០៨ មុនពេលបានឃើញ ឌុច ត្រូវបានកាត់ទោសនៅក្នុងតុលាការ ។ បងស្រីរបស់ប្រពន្ធ ពិសិដ្ឋ ត្រូវបានចាប់ខ្លួនបញ្ជូនទៅគុកទួលស្លែង ហើយសន្មតថាត្រូវបានសម្លាប់នៅទីនោះរួមជាមួយនឹងអ្នកទោសរាប់ពាន់នាក់ផ្សេងទៀត ។ ឥឡូវនេះ ពិសិដ្ឋ បានធ្វើជាតំណាងឲ្យប្រពន្ធរបស់គាត់នៅក្នុងតុលាការ ។ គោលបំណងដ៏សំខាន់របស់ ពិសិដ្ឋ គឺដើម្បីសម្រេចនូវក្តីសុបិនដែលមិនអាចទទួលជ័យជម្នះបានរបស់ប្រពន្ធគាត់ និងដើម្បីដាក់សំណុំរឿងប្រឆាំងនឹង ឌុច និង ចង់ឃើញ ឌុច ត្រូវបានកាត់ទោសនិងទទួលទណ្ឌកម្មតាមផ្លូវច្បាប់ ។ យោងតាមសម្តីរបស់ ពិសិដ្ឋ គាត់ព្យាយាមទាមទារនូវសំណងផ្លូវចិត្តទោះបីជាលក្ខណៈផ្ទាល់ខ្លួន ឬ ផ្លូវចិត្ត ឬ លក្ខណៈជារួមក៏ដោយ ក៏ការស្វែងរកយុត្តិធម៌សម្រាប់គ្រួសារប្រពន្ធរបស់គាត់និងជនរងគ្រោះទាំងអស់ដែលត្រូវបានសម្លាប់នៅក្រោមការគ្រប់គ្រងរបស់ ឌុច ក្នុងគុកទួលស្លែង ។ ឆ្លើយតបទៅនឹងការសូមអត់ឱនទោសរបស់ ឌុច ពិសិដ្ឋ បាននិយាយថា «ខ្ញុំជឿថា មនុស្សទូទៅរួមទាំងខ្ញុំមិនអាចអត់ឱនទោសឲ្យ ឌុច បានទេ ។ ឌុច ត្រូវតែកាត់ទោស ហើយទទួលទណ្ឌកម្មសម្រាប់ឧក្រិដ្ឋកម្មដែល ឌុច បានប្រព្រឹត្ត» ។ ពិសិដ្ឋ បានបន្ថែមទៀតថា នៅពេលដែលប្រពន្ធរបស់គាត់នៅរស់ ប្រពន្ធគាត់ចង់ប្រឈមមុខជាមួយ ឌុច ណាស់ ។

ខន មកពីខេត្តកំពង់ធំ ៖ ខន ជាដើមបណ្តឹងរដ្ឋប្បវេណីសកម្មម្នាក់នៅក្នុងដំណើរការកាត់ទោស ឌុច ។ បងប្រុសរបស់ ខន ត្រូវបានចាប់ខ្លួននិងជាប់ឃុំឃាំងនៅមន្ទីរស-២១ ហើយបានបាត់ខ្លួនតាំងពីពេលនោះរហូតមក ។ គាត់បានចូលរួមនិយាយក្នុងកិច្ចសន្ទនារវាងខ្ញុំនិង ពិសិដ្ឋ ថា «បើគិតពីកំហឹងដែលខ្ញុំមាន ខ្ញុំចង់ឲ្យ ឌុច ត្រូវបានតុលាការកាត់ទោសប្រហារជីវិត ។ ខ្ញុំចង់ឲ្យ ឌុច រស់នៅ និងឃើញការអភិវឌ្ឍជឿនលឿននៃប្រទេសដែល ឌុច បានធ្វើឲ្យធ្លាក់ក្នុងភាពក្រីក្រ ។ បច្ចុប្បន្ននេះ ខ្ញុំចង់ឲ្យ ឌុច ឃើញថាប្រទេសនេះកំពុងតែអភិវឌ្ឍពីភាពក្រីក្រទៅរកភាពរីកចម្រើន» ។ ខន មានការពេញចិត្តនឹងដំណើរការកាត់ទោសរបស់តុលាការ ។ សម្រាប់ ខន ការសងសឹកនៅតែមានសារសំខាន់ ទោះបីជាការសងសឹកនេះមិនចាំបាច់បង្កើតឡើងក្នុងទម្រង់ជាការសងសឹកបែបអំពើហិង្សាលើផ្នែករាងកាយក៏ដោយ ។ ខន បាននិយាយថា «ទោះបីជាយើងមិនអាចវាយធ្វើបាប ឌុច ដូចដែល ឌុច បានធ្វើចំពោះពួកយើងក៏ដោយ ក៏ខ្ញុំមិនចង់ឲ្យ ឌុច ទទួលបាននូវសេរីភាពដូចដែលយើងទទួលបានក្នុងពេលបច្ចុប្បន្នឡើយ» ។ ខន មានបំណងស្នើសុំឲ្យមេធាវីការពារក្តីបញ្ឈប់ការសួរដេញដោលដែលមិនមានសារសំខាន់ ដើម្បីធ្វើឲ្យដំណើរការកាត់ទោសរបស់តុលាការមានរយៈពេលខ្លី ។ ជនរងគ្រោះទាំងអស់ដូចជារូបគាត់ជាដើមបានរង់ចាំយុត្តិធម៌អស់រយៈយ៉ាងយូរមកហើយមកដល់ពេលនេះ ។

ផល្លី មកពីខេត្តកំពង់ធំ ៖ ផល្លី ក៏ជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ដែលតុលាការបានទទួលស្គាល់ក្នុងសំណុំរឿងរបស់ ឌុច ។ បងប្រុសរបស់ ផល្លី ដែលជាទាហានបដិវត្តន៍ខ្មែរក្រហមនៅភូមិភាគបូព៌ា ត្រូវបានចាប់ខ្លួនបញ្ជូនទៅមន្ទីរសន្តិសុខស-២១ ។ តាំងពីពេលនោះមក ផល្លី មិនដែលបានជួបបងប្រុសរបស់

គាត់ឡើយ ។ ផល្លី បានដាក់ពាក្យបណ្តឹងធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីស្វែងរកយុត្តិធម៌សម្រាប់បងប្រុសរបស់គាត់ ។ យុត្តិធម៌សម្រាប់ ផល្លី គឺចង់ឃើញ ឌុច ត្រូវបានតុលាការកាត់ទោសដោយត្រឹមត្រូវ ។ ផល្លី បានបង្ហាញពីអារម្មណ៍ពេញចិត្តជាមួយនឹងដំណើរការរបស់តុលាការ ។ ផល្លី បាននិយាយថា «តុលាការខ្មែរក្រហមបានបំពេញនូវសេចក្តីរំពឹងទុករបស់ខ្ញុំបាន ៧០ភាគរយហើយ» ។ បន្ថែមលើនេះ ផល្លី មានបំណងចង់បាននូវសំណងជំងឺចិត្តជាប្រាក់និងជាលក្ខណៈផ្ទាល់ខ្លួនសម្រាប់ការបាត់បង់បងប្រុសរបស់គាត់ ។ ផល្លី មានគម្រោងយកប្រាក់សំណងជំងឺចិត្តនេះមកប្រារព្ធពិធីបុណ្យសពសម្រាប់បងប្រុសរបស់គាត់ដែលបានបាត់បង់ជីវិតទៅ ។ សម្រាប់ ផល្លី បើតាមវប្បធម៌ជាតិ ការប្រារព្ធពិធីបុណ្យសពពិតជាមានសារសំខាន់ណាស់សម្រាប់ប្រជាជនទាំងអស់ដែលបានស្លាប់ ។ ផល្លី មិនប្រាកដថា គាត់អាចអត់ឱនទោសឲ្យ ឌុច ឬ ទុកឲ្យច្បាប់ក្នុងប្រទេសធ្វើការកាត់ទោស ឌុច យ៉ាងណានោះទេ ។ ផល្លី និយាយថា «ទោះបីជាយើងធ្វើការសងសឹងក៏ដោយ ក៏យើងមិនអាចស្រោចស្រង់ជីវិតរបស់ជនរងគ្រោះរបស់យើងឲ្យត្រឡប់មកវិញបានដែរ» ។

សុភា មកពីខេត្តកំពង់ធំ ៖ ឪពុករបស់ សុភា ត្រូវបានចាប់ខ្លួនបញ្ជូនទៅគុកទួលស្លែងបីសប្តាហ៍មុនពេលដែល សុភា កើត ។ សុភា មិនដែលដឹងច្បាស់ពីមូលហេតុដែលឪពុករបស់គាត់ត្រូវបានចាប់ខ្លួននោះទេ ។ សុភា ធ្លាប់សង្ឃឹមថា ឪពុករបស់គាត់អាចនៅរស់រានមានជីវិតនៅកន្លែងណាមួយ ហើយអាចនឹងវិលត្រឡប់មករកគាត់វិញនៅថ្ងៃណាមួយមិនខាន ។ រហូតមកដល់ឆ្នាំ ២០០៦ ទើបគាត់ដឹងពីជោគវាសនារបស់ឪពុកគាត់ ។ «រូបថតរបស់គាត់ដែលរកឃើញនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ឪពុកខ្ញុំមើលទៅជាមនុស្សសុភាពរាបសារម្នាក់» ។ គោលបំណងរបស់ សុភា គឺស្វែងរកយុត្តិធម៌ឲ្យឪពុករបស់គាត់ដែលគាត់មិនដែលបានធ្វើនិងមិនបានឃើញមុខ ។ ការបាត់បង់ឪពុករបស់ សុភា បានជះឥទ្ធិពលយ៉ាងខ្លាំងលើជីវភាពរស់នៅរបស់គ្រួសារគាត់និងឱកាសរៀនសូត្ររបស់គាត់ ។ «អស់រយៈពេល៣០ឆ្នាំហើយ ដែលខ្ញុំមិនអាចធ្វើឲ្យជីវិតរបស់ខ្ញុំរួចផុតពីភាពក្រីក្រដោយសារតែខ្ញុំមិនមានឪពុក» ។ ដើម្បីជួយគ្រួសាររបស់គាត់ សុភា បានសម្រេចចិត្តឈប់រៀនដោយបំផ្លាញសុបិនចង់ក្លាយជាគ្រូបង្រៀនរបស់គាត់ចោល ។ សុភា មិនជឿថាជនត្រូវចោទ ឌុច បានសារភាពយ៉ាងស្មោះត្រង់និងរីករាយទេ ទោះបីជា ឌុច បានបង្ហាញពីការសហការជាមួយនឹងតុលាការក៏ដោយ ។ សុភា និយាយថា «ការសហការរបស់ ឌុច គឺគ្រាន់តែចង់ចៀសវាងការកាត់ទោសឲ្យជាប់គុករយៈពេលយូរប៉ុណ្ណោះ» ។ សុភា មិនអាចទទួលយកការសូមអត់ឱនទោសរបស់ ឌុច ហើយក៏មិនទទួលស្គាល់ជារៀងរហូតទោះបីជានៅក្នុងកាលៈទេសៈណាក៏ដោយ ។ សុភា បានបន្ថែមថា «ខ្ញុំមិនអាចធ្វើការផ្សះផ្សាជាមួយ ឌុច បានទេ» ។ សម្រាប់សំណងជំងឺចិត្តវិញ សុភា យល់ថា តុលាការអាចផ្តល់ឲ្យនូវសំណងជំងឺចិត្តមួយដែលមានលក្ខណៈជារួមនិងផ្លូវចិត្តតែប៉ុណ្ណោះ ។ ប៉ុន្តែ សុភា ក៏សង្ឃឹមថា តុលាការនឹងផ្តល់ឲ្យនូវអ្វីដែលមានប្រយោជន៍ដល់ប្រជាជនកម្ពុជាជំនាន់ក្រោយក្នុងពេលអនាគតផងដែរ ។ សម្រាប់ សុភា គឺចង់ឲ្យប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជាត្រូវបានបង្រៀនតាមសាលារៀនដើម្បីឲ្យប្រជាជនកម្ពុជាជំនាន់ក្រោយចងចាំនូវអតីតកាល សោកនាដកម្មដែលបានកើតឡើងក្នុងប្រទេស ។ បន្ថែមលើនេះ សុភា សង្ឃឹមថា មូលដ្ឋាននៃក្តីសង្ឃឹមនឹងត្រូវបានបង្កើតឡើងដើម្បីជួយដល់ស្ត្រីជាជនរងគ្រោះក្រីក្រនិងអភ័ព្វពីរបបខ្មែរក្រហម ។

**ឌី ឆេរិទ្ធិ**

## កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយលោក ឌី ខាំបូលី ដែលអ្នកទាំងអស់គ្នាអាចស្តាប់ថតចម្លងនិងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រ http://www.voanews.com/ khmer/democratic-kampuchea.cfm របស់វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ពិភពលោកនៅសែនឆ្ងាយ

**(តពីលេខមុន)**

រយៈពេលពីរខែ ជំងឺរបស់ខ្ញុំនៅតែដដែល ទោះបីជាខ្ញុំប្តូរថ្នាំលេបជាច្រើនប្រភេទក៏ដោយ ។ នៅទីនេះ អ្នកជំងឺណាដែលហូបបបរច្រើន អង្គការនឹងធ្វើលិខិតឲ្យចេញ ។ កន្លះខែក្រោយមក អង្គការបានប្រារព្ធកម្មវិធីសម្តែងសិល្បៈមួយរហូតដល់ម៉ោង១១យប់ទើបចប់ នៅក្នុងបរិវេណមន្ទីរពេទ្យដែលមានសិល្បករវ័យក្មេងស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ បង់កក្រមា ពាក់ស្បែកជើងកង់ឡានរាំរបាំបដិវត្តន៍ដូចជា កាប់ដី ច្រូតកាត់ បេះផ្លែ និងរបាំកងទ័ពដែលពាក់ឯកសណ្ឋានជាយោធាកាន់កាំភ្លើងគ្រវីទង់ក្រហមនិងនិយាយរឿងកម្សាន្ត ។ កម្មវិធីនេះមានប្រជាជននៅភូមិជិតៗនិងអ្នកជំងឺជាច្រើនទៀតបានមកមើលការសម្តែងនេះយ៉ាងច្រើនកុះករ ។

ស្អែកឡើង ពេទ្យបានចេញលិខិតឲ្យអ្នកជំងឺចេញទាំងអស់ នៅសល់តែខ្ញុំម្នាក់គត់ ពីព្រោះមន្ទីរពេទ្យនេះលែងមានភ្លើងអគ្គិសនីសម្រាប់បំភ្លឺនៅតាមបន្ទប់ទៀតហើយ ដោយអង្គការផ្តល់ប្រេងឲ្យតែក្នុងកម្រិតតិចតួចសម្រាប់តែបន្ទប់វះកាត់ប៉ុណ្ណោះ ។ ប្រហែលកន្លះខែក្រោយមក ស្រាប់តែអាការៈជំងឺរបស់ខ្ញុំធ្វើទុក្ខយ៉ាងខ្លាំង ដោយបេះដូងមិនចង់ដើរ រហូតដល់ធ្វើឲ្យអ្នកជំងឺនៅជិតខាងបានរត់ទៅហៅពេទ្យជាប្រញាប់ដើម្បីមកចាក់ថ្នាំ និងព្យួរសេរ៉ូម ហើយសែងខ្ញុំចូលបន្ទប់សង្គ្រោះបន្ទាន់ ។ ក្នុងបន្ទប់នោះមានអ្នកជំងឺខ្លះសន្លប់ដកចង្កាមាន់និងស្លាប់ ។ ពីរថ្ងៃក្រោយពីជំងឺរបស់ខ្ញុំបានជាសះស្បើយបន្តិច ទើបខ្ញុំត្រូវបញ្ជូនទៅបន្ទប់ថ្មីមួយទៀត ។ រហូតដល់ចូលឆ្នាំសកលថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៧ ពេទ្យបានឲ្យថ្នាំចម្លែកម៉្យាងពណ៌លឿងក្រមៅឲ្យខ្ញុំលេប ស្រាប់តែធ្វើឲ្យខ្ញុំមានកម្លាំងហាក់ដូចជាគ្មានជំងឺសោះ ។ បីថ្ងៃក្រោយពេទ្យក៏ចេញលិខិតឲ្យខ្ញុំចេញពីមន្ទីរពេទ្យនិងឲ្យថ្នាំខ្លះៗសម្រាប់លេបបន្ត ។

**ឆ្លងកាត់កូនវាលខ្សាច់**

ប្រហែលម៉ោង៨ព្រឹកថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៧ ខ្ញុំបានទៅយកលិខិតចេញពីមន្ទីរពេទ្យនិងបើកថ្នាំពេទ្យមួយចំនួនសម្រាប់លេបនៅបន្ទប់បុគ្គលិកពេទ្យម្នាក់ ។ ទោះបីមានសភាពធូរស្បើយហើយក្តី ក៏ខ្ញុំនៅតែព្រួយបារម្ភខ្លាចជំងឺរបស់ខ្ញុំរើឡើងវិញ ហើយម៉្យាងខ្ញុំមិនស្គាល់ភូមិសាស្រ្ត និងត្រូវដើរទៅផ្ទះទៀតផង ។ មកដល់ផ្លូវជាតិ ដោយសារមិនឃើញអ្នកភូមិផ្សេងទៀតធ្វើដំណើរមក ខ្ញុំក៏សម្រេចចិត្តដើរតាមផ្លូវលំមួយឆ្ពោះទៅដងទន្លេ ។ ដើរកាត់ពីភូមិមួយទៅភូមិមួយ ខ្ញុំនៅតែពុំឃើញកង់ ម៉ូតូ ឬ រទេះគោធ្វើដំណើរកាត់ទេ ឃើញតែមនុស្សធ្វើការនៅតាមការដ្ឋានប៉ុណ្ណោះ ។ ធ្វើដំណើរមកដល់ភូមិមួយ ពេលខ្ញុំឃើញបុរសចំណាស់ម្នាក់ ខ្ញុំក៏បានសួរគាត់ដើម្បីរកផ្លូវដើរទៅកាន់ទន្លេតូច ។ ក្រោយពីចាកចេញបានបន្តិច ខ្ញុំសង្កេតឃើញមានរោងបាយសហករណ៍រួមដែលសង់មានលក្ខណៈស្រដៀងៗគ្នានៅជាប់ផ្លូវនិងនៅក្រោយភូមិមានតុវែងៗតម្រៀបគ្នាជាជួរ មានខ្ទះត្នោតធំៗ និងមានចុងភៅ៤-៥នាក់កំពុងចិតបន្លែ ។ នៅម៉ោង១០ព្រឹក ខ្ញុំឃើញក្មេងៗមកពីការដ្ឋានដើរចូលរោងបាយអង្គុយតាមតុរៀងៗខ្លួនរួចនាំគ្នាដួសបាយហូបយ៉ាងប្រញាប់ ។ ពេលនោះ ខ្ញុំក៏ហុចលិខិតរបស់មន្ទីរពេទ្យទៅឲ្យប្រធានចុងភៅដើម្បីសុំបាយហូប ។ ដោយក្តីអាណិតអាសូរ ចុងភៅបានយកបាយ សម្ល ព្រមទាំងត្រសក់ចាវមកឲ្យខ្ញុំទៀតផង ។ ក្រោយពីហូបបាយរួច ខ្ញុំក៏ដើរត្រឡប់ក្រោយរកម្លប់ត្នោតជ្រកវិញ ព្រោះផ្លូវដែលខ្ញុំត្រូវដើរឆ្លងកាត់វាលនោះ អ្នកស្រុកតែងតែនិយាយថា យន្តហោះធ្លាប់បានស្ទាក់បាញ់សម្លាប់ ។ នៅខណៈពេលនោះ ស្រាប់តែមានរទេះសេះពីរគ្រឿងមកដល់ ខ្ញុំអរយ៉ាងខ្លាំងរួចក៏សុំឡើងជិះជាមួយ ។

ក្រោយពីចុះពីរទេះ រយៈពេលមួយថ្ងៃខ្ញុំធ្វើដំណើរដោយពុំមានពាក់ស្បែកជើងទេ រហូតធ្វើឲ្យបាតជើងទាំងពីររបស់ខ្ញុំរលាកឡើងក្រហមនិងមានកន្ទួលទៀតផង ។ ខ្ញុំដើរទាំងមានរបួសរហូតដល់មាត់ទន្លេដែលមានសភាពរីងស្ងួត និងមានដើមឈើខ្ពស់ៗដុះអមសងខាង ។ ខណៈនោះ អាកាសធាតុចាប់ផ្តើមក្តៅហប់ ហើយខ្ញុំស្រាប់តែហត់ហេវអស់កម្លាំងយ៉ាងខ្លាំងបណ្តាលឲ្យចង់គ្រុនក្តៅ ។ ដោយសារមិនអាចបន្តដំណើរទៅមុខទៀតបាន ខ្ញុំក៏ឈប់សម្រាក និងយកថ្នាំមកលេប ។ នៅពេលនោះ ស្រាប់តែខ្ញុំឮសូរសំឡេងត្រដោកនិងឃើញរទេះគោដឹកឈើពេញជាច្រើនគ្រឿងបរតម្រង់មកខ្ញុំ ខ្ញុំក៏សុំអ្នកបររទេះគោឡើងជិះបន្តដំណើរទៅមុខទៀត ។ នៅតាមផ្លូវលំប្រកចូលភូមិនីមួយៗ ខ្ញុំឃើញមានកងឈ្លបខ្មែរក្រហមជាច្រើននាក់ឈរយាមការពារ ។ រហូតដល់ម៉ោង៨ល្ងាច កងឈ្លបមួយកងឈរឃាត់រទេះដើម្បីឆែកឆេររកសំបុត្រស្នាម ខ្ញុំក៏ហុចសំបុត្រពេទ្យនិងប្រាប់ឈ្មោះជីតារបស់ខ្ញុំ ក្រោយពិនិត្យមើលរួចគេក៏អនុញ្ញាតឲ្យខ្ញុំទៅមុខទៀត ។ កន្លះម៉ោងក្រោយមក ខ្ញុំក៏បានមកដល់ផ្ទះដែលមានសភាពស្ងាត់ជ្រងំ ។ ក្រោយពីដឹងថាខ្ញុំត្រឡប់មកដល់ផ្ទះវិញ ម្តាយរបស់ខ្ញុំក៏សុំអនុញ្ញាតពីប្រធានកងមកជួបខ្ញុំ ។ គ្រាន់តែឃើញខ្ញុំភ្លាម គាត់រន្ធត់ចិត្តយ៉ាងខ្លាំងរហូតពោលពាក្យថា «ម្តាយស្មានតែកូនស្លាប់បាត់ទៅហើយ» ។ គាត់បានទៅដាំទឹកក្តៅឲ្យផ្ទូតនិងយកសម្លៀកបំពាក់ មុននិងភួយទៅបោកសម្អាត ។ បន្ទាប់មក គាត់យកថ្នាំក្រហមដែលនៅសេសសល់ក្នុងដបមកលាបបាតជើងរបស់ខ្ញុំ ។ នៅម៉ោងសម្រាកពីការងារ ក្រុមគ្រួសាររបស់ខ្ញុំបានមកជួបជុំគ្នា ។

## ***សហករណ៍រួម***

សម្រាកនៅផ្ទះពីរថ្ងៃ និងមិនបានចេញទៅធ្វើការងារដូចអ្នកភូមិដទៃ ខណៈនោះ ប្រធានរោងបាយបានទាមទារលិខិតបញ្ជាក់ពីមន្ទីរពេទ្យ ។ ប៉ុន្តែសំបុត្រនោះមិនដឹងទុកនៅទីកន្លែងណាទេ ដូច្នេះជីតារបស់ខ្ញុំក៏បានទៅសូមអង្វរប្រធានរោងបាយដើម្បីសុំការអនុគ្រោះ ។ ខ្ញុំខិតខំរកលិខិតបញ្ជាក់នោះអស់រយៈពេលពីរថ្ងៃ នៅតែមិនឃើញទាល់តែសោះ ។ ដោយគ្មានសង្ឃឹមថានឹងរកឃើញ ខ្ញុំគិតថាមានតែត្រឡប់ទៅមន្ទីរពេទ្យភូមិភាគដើម្បីសុំលិខិតបញ្ជាក់ថ្មីមួយទៀតប៉ុណ្ណោះ ។ ស្រាប់តែពេលល្ងាច ឪពុកខ្ញុំត្រឡប់មកពីភ្ជួរស្រែវិញក៏ដោះអាវទៅព្យួរលើសសរ ចៃដន្យគាត់បានលូកដៃចូលក្នុងហោប៉ៅអាវក៏ប្រទះឃើញសំបុត្រ ។ ក្រោយពីម្តាយខ្ញុំបានយកទៅប្រគល់ជូនប្រធានរោងបាយរួចមក គេក៏បានអនុញ្ញាតឲ្យខ្ញុំទៅហូបបាយនៅបាយរួមជាមួយកងតាៗ ។ សហករណ៍ភូមិខ្ញុំបានយកក្បាលគ្រាប់បែករបស់អាមេរិកប្រវែងជាងមួយម៉ែត្រមកចងព្យួរនៅក្បែរមន្ទីរឃុំធ្វើជាជួង ។ រាល់ពេលម៉ោង៦ព្រឹក គេចាប់ផ្តើមគោះជួងនេះចំនួនបីដងជាប់គ្នាដើម្បីជាសញ្ញាប្រាប់ប្រជាជនថាត្រូវចេញទៅការដ្ឋាន ។ កសិករទាំងអស់ត្រូវសម្រាកហូបបាយនៅម៉ោង១១ និងធ្វើបន្តរហូតដល់ឮសំឡេងជួងនៅម៉ោង៥ល្ងាចទើបត្រឡប់មកផ្ទះវិញ ។ ជីតារបស់ខ្ញុំត្រូវគ្រប់គ្រងលើកងតាៗក្នុងការផលិតនង្គ័ល រនាស់ ដងវែក ដងចប បង្គី ល្អី ជាល កញ្ច្រែង នៅរោងសិប្បកម្មឃុំ ។ ឪពុកខ្ញុំដឹកជញ្ជូនខសនិងស្បៀងទៅការដ្ឋាន ព្រមទាំងមើលថែទាំគោ ។ ម្តាយខ្ញុំត្រូវទៅដកស្ទូង កិនស្រូវ បុកអង្ករសម្រាប់ផ្គត់ផ្គង់រោងបាយ ។ ចំណែកប្អូនខ្ញុំដែលមានអាយុ៨ឆ្នាំ ត្រូវក្រោកឡើងពីព្រលឹមដើម្បីកើបអាចម៍គោ បោសសំរាមសម្រាប់ធ្វើជី ។ ថ្ងៃមួយដោយសារតែប្អូនរបស់ខ្ញុំប្រញាប់ប្រញាល់ខ្លាំងពេកមិនបានចងខ្សែគោឲ្យបានជាប់ល្អ បណ្តាលឲ្យរបូតគោទៅស៊ីស្ពៃក្តោបចេកអស់៤-៥ធាង ឃើញដូច្នេះ ក្មេងៗដទៃក៏រត់ទៅរាយការណ៍បន្តទៅប្រធានកង ។ បន្ទាប់មក ដោយសារតែប្រធានកងកុមារបានបង្អត់បាយប្អូនរបស់ខ្ញុំមួយពេល ប្អូនរបស់ខ្ញុំក៏បានទៅលួចបេះក្តឹបត្របែកហូបដើម្បីឲ្យមានកម្លាំងចេញទៅឃ្វាលគោបន្តទៀត ។ នៅក្នុងសហករណ៍ឃុំ ក្មេងៗអាយុក្រោម៥ឆ្នាំ ត្រូវកងនារីជាអ្នកមើលថែទាំបញ្ចុកអាហារ ក្មេងអាយុ៦-១៨ឆ្នាំ ប្រធានកងកុមារជាមើលការខុសត្រូវ និងក្មេងអាយុចាប់ពី១៥ឆ្នាំឡើងទៅត្រូវបញ្ជូនទៅធ្វើការនៅកងចល័តតាមការដ្ឋាន ។ នៅពេលបើករបបអាហារម្តងៗ គ្រូបានឲ្យក្មេងៗឈរតម្រៀបគ្នាជាពីរជួរនៅមុខរោងបាយ បន្ទាប់មកតម្រូវឲ្យច្រៀងចម្រៀងបដិវត្តន៍ដែលមានចំណងជើងថា «អង្គការមានគុណធំធេងចំពោះកុមារ» ទើបអនុញ្ញាតឲ្យហូបបាយ ដោយបែងចែកជា៥ក្រុម ។ រោងបាយនីមួយៗមានប្រធាន អនុប្រធាន និង សមាជិកពីរ-បីនាក់ដែលជាមនុស្សជិតស្និទ្ធជាមួយមេៗ ដែលមានអ្នកខ្លះជា

ប្រពន្ធរបស់ប្រធាន «ខ» ឬប្រធាន «គ» ដើម្បីធ្វើជាភ្នែកច្រមុះរបស់អង្គការ ។ ក្រៅពីកងទាំងនោះ មានកងនេសាទប្រុសៗរកត្រីសម្រាប់ផ្គត់ផ្គង់នៅរោងបាយនិងតាមការដ្ឋាននានា និងមានកងឈ្លបជាយុវជនសម្រាប់ត្រួតពិនិត្យអ្នកដែលធ្វើដំណើរគ្មានលិខិតស្នាមឬមនុស្សចម្លែក ។ លើសពីនេះ នៅពេលយប់ មានឈ្លបដើរលបចាំស្តាប់ការជជែកគ្នានៅក្រោមផ្ទះរបស់ប្រជាជនចំពោះអ្នកណាដែលនិយាយប៉ះពាល់ដល់អង្គការ ។ ប្រធាន «គ» ក្តាប់រួមទាំងក្នុងរោងបាយនិងចាត់តាំងកម្លាំងចុះធ្វើពលកម្មនៅតាមភូមិដើម្បីធ្វើយ៉ាងណាអូសបន្ទាយឲ្យលើសម៉ោង ហើយលើកឡើងថា ថ្នាក់ដឹកនាំសកម្មជាងប្រជាជន ។ ចំពោះប្រធាន «ឃ» មានតួនាទីគ្រប់គ្រងលើសហករណ៍ភូមិនិងរោងបាយភូមិទាំងអស់ ប៉ុន្តែមិនសូវនៅធ្វើការជាប់ក្នុងភូមិទេ គឺត្រូវចុះទៅមើលខុសត្រូវលើកងចល័តវិញ ។ ចំណែកប្រធាន «ង» ជាប្រធានឃុំនិងមានសមាជិកគណៈកម្មការ៥នាក់ទៀត មានតួនាទីដើរត្រួតពិនិត្យប្រជាជនតាមភូមិនិងចូលរួមប្រជុំនៅស្រុក ។

អង្គការក៏បានលុបបំបាត់ការប្រើប្រាស់ទោចក្រយានយន្តនិងគ្រឿងម៉ាស៊ីនដូចជា កង់ ម៉ូតូ ម៉ាស៊ីនកិនស្រូវ ម៉ាស៊ីនបូមទឹក ត្រាក់ទ័រនិងគោយន្តជាដើម ។ ខ្មែរក្រហមបានបង្ខំឲ្យប្រជាជនធ្វើពលកម្មដោយកម្លាំងខ្លួនឯង ហើយប្រសិនបើមាននរណាហ៊ានប្រកែកនឹងក្លាយទៅជាមុខសញ្ញាខ្មាំងរបស់អង្គការមិនខាន ។ អង្គការបានកេណ្ឌមនុស្សឲ្យទៅរស់នៅក្នុងជំរំប្រមូលផ្តុំ ដោយមិនបានផ្តល់អាហារឲ្យហូបគ្រប់គ្រាន់និងធ្វើការងារហួសកម្លាំង ដែលជាហេតុបណ្តាលឲ្យមនុស្សកាន់តែទ្រុឌទ្រោមនិងស្លាប់ជាបន្តបន្ទាប់ ។ ផ្ទុយទៅវិញ អង្គការបានលើកសរសើរតែក្រុមមនុស្សដែលមានកម្លាំងខ្លាំង (អាចទ្រាំនឹងលក្ខខណ្ឌការងារលំបាកបាន) ឬ កម្លាំងស្រួចប៉ុណ្ណោះ ។ ចំណែកលំនៅឋានតាមភូមិ-ឃុំនានា បានក្លាយទៅជារោងសហករណ៍រួម ហើយប្រជាជនទាំងក្មេង-ចាស់ ប្រុស-ស្រី ត្រូវតែបំពេញការងាររៀងៗខ្លួនតាមទិសកំណត់ និងមាគ៌ាដឹកនាំរបស់បដិវត្តន៍ជាដាច់ខាត ។

## បោសសម្អាតវប្បធម៌អក្សរសាស្ត្រពីសង្គមចាស់

បន្ទាប់ពីខ្ញុំហូបបាយនៅរោងបាយរយៈពេលប្រហែល ១សប្តាហ៍ ខ្ញុំហាក់មានកម្លាំងច្រើនជាងមុន ហើយថែមទាំងអាចចេញទៅធ្វើការបាន ។ ប្រធានសហករណ៍ដែលមានវ័យចំណាស់បន្តិចបានមកហៅខ្ញុំឲ្យទៅបាចទឹកបញ្ចូលស្រែប្រាំងដែលមានសន្ទូងបែកគុម្ពពណ៌បៃតងខៀវស្រងាត់នៅខាងក្រោយភូមិជាមួយគាត់ ។ ទោះបីខ្ញុំសង្កេតឃើញថា គាត់មិនសូវតឹងរ៉ឹងចំពោះខ្ញុំក៏ដោយ ក៏ខ្ញុំនៅតែបារម្ភនៅខាងមុខថា ខ្ញុំនឹងត្រូវបញ្ជូនឲ្យទៅធ្វើការងារធ្ងន់ធ្ងរនៅតាមមូលដ្ឋានមិនខាន ។ ខ្ញុំបាចទឹកស្នាចឆ្លាស់គ្នាបណ្តើរ សម្រាកបណ្តើរជាមួយប្រធាន «ខ» រហូតដល់ទឹកឡើងពេញប្រៀប ទើបគាត់លីចបដើរទៅមើលតាមភ្លឺស្រែខ្លាចក្រែងធ្លាយទឹកចេញ ។ ពេលនោះ ឆ្លៀតពេលដែលគ្មានមនុស្សឃើញខ្ញុំក៏លួចយកលបទៅដាក់បានក្តាមនិងត្រីមួយចំនួន ។ រយៈពេល៣ថ្ងៃក្រោយមក គាត់បានបន្ថែមការងារមួយទៀតគឺត្រូវយកគោស្គមដែលភ្លួរលែងកើតមួយក្បាលឲ្យស៊ីស្មៅ ។ នៅចុងខែមករា អង្គការបានធ្វើការកោះប្រជុំទូទាំងភូមិ ដោយប្រកាសឲ្យប្រជាជនទាំងអស់ប្រមូលសៀវភៅ ឯកសារ កាសែត ទស្សនាវដ្តីពីសង្គមចាស់ ព្រមទាំងគម្ពីធម៌ដែលនៅសេសសល់ទាំងប៉ុន្មានមកប្រគល់ឲ្យខាងរោងបាយរួម ។ ដោយសារការប្រមូលមានការយឺតយ៉ាវ នៅថ្ងៃបន្ទាប់ ប្រធាន «ខ» បានបញ្ជាឲ្យកូនសិស្សជួយជញ្ជូនមកដាក់គរនៅទីធ្លាមុខរោងបាយ រួចចាក់ប្រេងដុតឆេះយ៉ាងសន្ធោសន្ធៅ អមជាមួយសំឡេងទះដៃហ៊ោកញ្ជ្រៀវនិងសើចសប្បាយខ្ទៀវខ្ទារអឺងកងរបស់ក្មេងៗដែលឈរពទ្ធ័ជុំវិញ ។

នេះជាផែនការបោសសម្អាតរបស់អង្គការបដិវត្តន៍វប្បធម៌ អក្សរសាស្ត្រ ប្រវត្តិសាស្ត្រ និងកេរដំណែល ពីសង្គមចាស់ ។ ដោយជំនួសមកវិញ អង្គការបានបង្កើតវប្បធម៌ថ្មីមួយខុសប្លែកទាំងស្រុងពីសង្គមមុន គឺសង្គមកម្ពុជាថ្មីដែលត្រូវចាប់ផ្តើមពីដំបូងដោយក្មេងៗជំនាន់ក្រោយ មានអង្គការបដិវត្តន៍ជាម៉ែ និងត្រូវរស់នៅក្នុងសង្គមស្មើភាពគ្នា ។ ក្មេងៗមានចំណេះដឹងទាបទាំងនេះបានឆ្លងកាត់ត្រឹមតែការងារស្រែចម្ការនៅក្នុងភូមិឃុំរបស់ខ្លួនប៉ុណ្ណោះ ប៉ុន្តែពុំបានឆ្លងកាត់វិទ្យាល័យ មហាវិទ្យាល័យបច្ចេកវិទ្យាទំនើបទេ ។ ចំណែក កូនៗរបស់កម្មាភិបាលមជ្ឈិមនៅភ្នំពេញមានឱកាសបន្តរៀនសូត្រនៅក្រៅប្រទេសដើម្បីមកគ្រប់គ្រងលើសង្គមថ្មីដែលគ្មានអ្នកចេះដឹង ។

## បុណ្យចូលឆ្នាំបដិវត្តន៍

នៅដើមខែកុម្ភៈ ឆ្នាំ១៩៧៧ ប្រធានសហករណ៍ឃុំបាន វិលត្រឡប់មកធ្វើការនៅក្នុងមូលដ្ឋានវិញ ។ វត្តមានរបស់គាត់នៅក្នុងសហករណ៍មិនមែនជាការធម្មតាទេ ពីព្រោះគាត់បានប្រមូលកម្លាំងនារីទាំងអស់ឲ្យទៅជាកម្លាំងស្រួច ដើម្បីវាយសម្រុកជីកព្រែកមួយខ្សែកាត់ចំពាក់កណ្ដាលភូមិ ។ ពេលនោះ អង្គការបាននិយាយលើកតម្កើងសិទ្ធិនារីថា ក្នុងសង្គមចាស់ នារីវិលមិនជុំជើងក្រានទេ ប៉ុន្តែនៅក្នុងសង្គមបដិវត្តន៍ នារីមានសិទ្ធិស្មើនឹងបុរស ។ នារីមានសិទ្ធិចូលរួមក្នុងនយោបាយនិងកាន់មុខដំណែងតួនាទីខ្ពស់ដូចបុរសដែរ ។ អង្គការក៏បានធ្វើការកែប្រែតាមរយៈការជំរុញឲ្យកងនារីទៅជាកម្លាំងស្រួចខិតខំធ្វើការងារកាប់ដីរែកដីដូចកងបុរស ។ បន្ទាប់មក គាត់ក៏បានបានបង្កើតផែនការការងារជាបន្តបន្ទាប់ដែលធ្វើឲ្យម្នាក់ៗគ្មានពេលបានឈប់សម្រាកឡើយ ។ ម្ដាយខ្ញុំដែលធ្វើការងារពេញមួយថ្ងៃ ក្រោយពីត្រឡប់មកដល់ផ្ទះម្ដងៗ ខ្ញុំតែងតែសង្កេតឃើញគាត់ចូលសម្រាន្តទាំងហេវហត់អស់កម្លាំងយ៉ាងខ្លាំង ។ ចំណែកខ្ញុំ ក្រោយពីការបាចទឹកបញ្ចូលស្រែបានប្រហែល១០ថ្ងៃ អង្គការក៏ចាត់តាំងខ្ញុំឲ្យទៅអារខសនៅក្នុងភូមិដើម្បីផ្គត់ផ្គង់រោងបាយ និងដើររកសំរាមមកដុតធ្វើភ្នក់ភ្លើងសម្រាប់ការពារគោកុំឲ្យមូសខាំនៅពេលយប់ ។

នៅថ្ងៃរំឭកខួបជ័យជម្នះរបស់អង្គការបដិវត្តន៍ខ្មែរក្រហម យើងទាំងអស់គ្នាត្រូវបានអនុញ្ញាតឲ្យឈប់សម្រាកពីការងារចំនួន៣ថ្ងៃ ។ ថ្ងៃសម្រាកទីមួយ នៅពេលព្រឹក អង្គការបានឲ្យប្រជាជនទាំងអស់គ្នាទៅប្រជុំធ្វើមីទ្ទិងអបអរសាទរថ្ងៃបុណ្យនៅឯវត្តមួយស្ថិតនៅខាងចុងឃុំ ចំណែកក្មេងៗក៏ត្រូវប្រជុំនៅតាមក្រុមរបស់ក្មេងៗដែលមានគ្រូជាអ្នករៀបចំ ។ ប្រជាជនទាំងអស់គ្នាត្រូវស្លៀកសម្លៀកបំពាក់ឲ្យបានស្អាតបាតនិងបង់កក្រមាឲ្យត្រឹមត្រូវ មិនអីចឹងទេអង្គការនឹងចោទថាមើលងាយអង្គប្រជុំ ។ កិច្ចប្រជុំនេះរៀបចំឡើងដោយមានគណៈអធិបតីលើកឡើងពីអង្គការបដិវត្តន៍មហាភ្លឺស្វាងមហាឈ្លាសវៃ តស៊ូវាយឈ្នះចក្រពត្តិអាមេរិកជាមហាអំណាច ដណ្ដើមជ័យជម្នះបាននៅថ្ងៃ១៧ មេសា ជាប្រវត្តិសាស្ត្រ ។ បន្ទាប់មកលើកពីការកសាងប្រទេសដោយមាគ៌ាឯករាជ្យម្ចាស់ការ វាយសម្រុកធ្វើស្រែឲ្យបាន៣តោនមួយហិកតាជាដាច់ខាត រួចបោសសម្អាតខ្មាំងផ្ទៃក្នុងសេអ៊ីអានិងកាហ្សេបេ ។ បន្ទាប់មក តំណាងកសិករ មានកងយុវជន យុវនារី ប្រធានសហករណ៍បានឡើងប្ដេជ្ញាចិត្ត រហូតដល់ម៉ោង១១ទើបប្រធានឃុំឡើងបូកសរុបលទ្ធផលការងារដើម្បីបញ្ចប់កិច្ចប្រជុំ ។ អង្គការក៏បានឲ្យចុងភៅកាប់គោដែលខ្ញុំឃ្វាលរាល់ថ្ងៃ និងជ្រូក ដើម្បីធ្វើសម្មការី សម្លម្ជូរគ្រឿង ព្រមទាំងមានបង្អែមបបរស្ករទៀតផង ។ ប៉ុន្តែពុំមានកម្មវិធីច្រៀង រាំ ឬលេងល្បែងប្រជាប្រិយកម្សាន្តឡើយ ។ នៅថ្ងៃទីបីបន្ទាប់ពីហូបបាយថ្ងៃត្រង់រួច កងចល័តត្រូវវិលត្រឡប់ទៅការដ្ឋានដើម្បីសម្រុកធ្វើការងារតាមផែនការកំណត់របស់បក្ស ។

ក្រោយមកទៀត អង្គការបានបន្ថែមភារកិច្ចពីរទៀតមកឲ្យខ្ញុំ ដោយចាត់តាំងឲ្យខ្ញុំទៅកាប់រំលំដើមឈើក្នុងព្រៃក្រោយភូមិ ធ្វើខសនិងឃ្វាលគោមួយនឹមដែលមានលក្ខណៈកាចនៅវាលស្រែ ។ ចំណែកជីតារបស់ខ្ញុំ អង្គការបញ្ជាឲ្យដើររុះរើផ្ទះបាយរបស់ប្រជាជនគ្រប់ៗផ្ទះ ដែលនេះជាបោសសម្អាតកម្មសិទ្ធិ ស្បៀងអាហារឯកជនឲ្យអស់ រួចទៅហូបបាយរួមនៅរោងបាយសហករណ៍វិញ ។ ដោយសារហូបអាហារតែពីរពេលក្នុងមួយថ្ងៃ ដូច្នេះប្រជាជនដែលហូបមិនឆ្អែតក៏បានលួចគាស់ដំឡូង ឬចេក ដែលដាំនៅក្នុងរបងផ្ទះខ្លួន រហូតបណ្ដាលឲ្យមានប្រជាជនមួយចំនួនត្រូវអង្គការចាប់ខ្លួន ។

## បែងចែកសមាសភាពប្រជាជនជាបីប្រភេទ

ដោយសារតែផែនការរបស់អង្គការតម្រូវឲ្យជីកព្រែកឲ្យឆាប់ហើយ ម្ដាយខ្ញុំត្រូវធ្វើការបន្ថែមរហូតដល់ម៉ោង៩យប់ រយៈពេលមួយខែ ទើបធ្វើរួច ។ បន្ទាប់មក ប្រធានសហករណ៍បានហៅប្រជាជនទូទាំងភូមិធ្វើការប្រជុំដើម្បីប្រកាសផែនការថ្មីអំពីការបែងចែកសមាសភាពប្រជាជនជាបីប្រភេទគឺ ប្រជាជនពេញសិទ្ធិ ប្រជាជនត្រៀមដែលជាវណ្ណៈអនុធនពីសង្គមចាស់ និងប្រជាជនបញ្ញើ ឬ ប្រជាជន១៧មេសា ដែលសំដៅលើប្រជាជនថ្មី ។

## ផែនការថ្មីធ្វើដីលេខមួយ

បន្ទាប់ពីទទួលផែនការថ្មីពីអង្គការ សមមិត្តប្រធាន«យ» បានចាត់តាំងឲ្យម្ដាយខ្ញុំជួយលើកទំនប់ជាមួយកងចល័តនៅខាងក្រោយឃុំ ដែលមានចម្ងាយប្រហែល៥គីឡូម៉ែត្រ ។ ដូច្នេះ គាត់ត្រូវភ្ញាក់ពីព្រលឹមវេចបាយយកទៅហូប ព្រោះការងារធ្វើចាប់

ពីព្រឹករហូតដល់ម៉ោង៨ល្ងាច ទើបអនុញ្ញាតឲ្យវិលត្រឡប់មកផ្ទះវិញ ។

ស្របពេលដែលប្រជាជនមានការខ្វះខាតស្បៀង ខ្ញុំឮដំណឹងថាមានរថយន្តរបស់អង្គការជាច្រើនគ្រឿងបានមកដឹកជញ្ជូនស្រូវពីសហករណ៍ឃុំ ប៉ុន្តែគេបានលាក់ការណ៍មិនឲ្យប្រជាជនដឹងពីការខុបត្ថម្ភជូនទៅថ្នាក់លើទេ ។ មួយរយៈពេលក្រោយមកស្រាប់តែអង្គការបានធ្វើការប្រជុំដើម្បីប្រកាសប្រាប់ឲ្យប្រជាជនដឹងថា បរិមាណស្រូវនៅក្នុងជង្រុកមានការខ្វះខាតមិនអាចហូបបានដល់រដូវច្រូតកាត់ទេ ដូច្នេះតម្រូវឲ្យរោងបាយបន្ថយរបបអង្ករប្រចាំថ្ងៃ ដោយពេលថ្ងៃហូបបបរ និងពេលល្ងាចហូបបាយ ។ មិនយូរប៉ុន្មាន របបអាហារទាំងនេះត្រូវបានកាត់បន្ថយថែមទៀតដោយហូបបបររាវជាមួយសម្លម្ជូរដើមចេកនិងត្រីប្រឡាក់តូចមួយប៉ុណ្ណោះ ។ ប៉ុន្តែ ទោះបីជាប្រជាជនបាក់កម្លាំង ហេវហត់និងអស់កម្លាំងយ៉ាងណាក្តី ក៏អង្គការនៅតែបង្ខំឲ្យធ្វើការធ្ងន់រយៈពេលមួយខែដដែលដើម្បីបញ្ចប់ការងារលើកទំនប់ ។ បន្ទាប់មក អង្គការផ្លាស់ប្តូរកម្លាំងស្រួចទាំងនេះឲ្យសម្រុកដកស្ទូងវិញ ចំណែកនៅមូលដ្ឋានត្រូវកំណត់ផែនការថ្មី គឺធ្វើជីលេខមួយសម្រាប់ដាក់ស្រែដើម្បីបង្កើនទិន្នផលស្រូវឲ្យបាន៣តោនក្នុងមួយហិកតា ។ ជីនេះត្រូវធ្វើឡើងពីលាមកមនុស្សលាយជាមួយផេះ អង្កាមនិងដីដំបូកបុកឲ្យម៉ដ្ឋច្របល់បញ្ចូលគ្នា រួចសង្កត់ចូលក្នុងពុម្ពឈើយកទៅហាលឲ្យស្ងួត ។ នៅក្នុងក្រុមរោងបាយនីមួយៗ អង្គការបានជ្រើសរើសមនុស្សពីរនាក់ដើម្បីធ្វើកិច្ចការនេះ ប៉ុន្តែក៏មានប្រជាជនមូលដ្ឋានភាគច្រើនបានបដិសេធ ដោយខ្ពើមរអើមនឹងលាមកនៅបន្ទន់នេះដែរ ។ ទោះបីការងារកខ្វក់យ៉ាងនេះក្តី ក៏មានប្រជាជន១៧មេសា ឬប្រជាជនថ្មី បានស្ម័គ្រចិត្តចូលធ្វើដើម្បីឲ្យអង្គការមើលឃើញពីការខិតខំប្រឹងប្រែងលត់ដំខ្លួនតាមមាគ៌ាបដិវត្តន៍ ។

## ការរឹបអូសកម្មសិទ្ធិឯកជន

ក្រោយពីការងារដកស្ទូងធ្វើបានសម្រេចមួយភាគធំហើយ អង្គការក៏ដកកម្លាំងនារីឲ្យមកធ្វើការក្នុងភូមិវិញ ។ បន្ទាប់មក អង្គការបានកោះហៅប្រជាជនមកចូលរួមប្រជុំអំពីការលះបង់កម្មសិទ្ធិផ្ទាល់ខ្លួនមកដាក់ជាសមូហភាព ដោយអនុញ្ញាតឲ្យមានត្រឹមតែខោអាវពីរកំប្លេ ក្រមាមួយ ភួយមួយ មុងមួយប៉ុណ្ណោះ ។ ប្រសិនបងប្អូនលួចលាក់ទុកតទៅទៀត នៅពេលអង្គការរកឃើញបងប្អូនត្រូវទទួលខុសត្រូវដោយខ្លួនឯង ។ ក្រោយពីប្រជុំចប់ប្រជាជនដែលមាននៅសេសសល់ទ្រព្យសម្បត្តិបន្តិចបន្តួចបានប្រមូលយកមកជូនអង្គការ ។ ចំណែកផ្ទះជីតានិងឪពុកម្តាយខ្ញុំដែលនៅមានសល់ទ្រព្យសម្បត្តិដូចជា ក្រណាត់តេតារ៉ុង សំពត់ព្រែ សារុងពុម្ព ហូលផាមួង សារុងសូត្រ ក៏យកទៅដាក់ជារបស់សមូហភាព ដើម្បីឲ្យអង្គការជឿថាយើងមានភាពស្មោះត្រង់ជាមួយបដិវត្តន៍ ។ ប៉ុន្តែទោះបីជាមានការព្រមានក្តី ក៏ជីតាខ្ញុំបានលួចយកសណ្តែកខៀវជាងមួយល្អីចាក់ចូលក្នុងបំពង់ឫស្សីពីរកំណាត់វែងៗដាក់នៅខាងក្រោមរនូតផ្ទះដែរ ។ ស្របពេលនោះ ក៏នៅមានផ្ទះប្រជាជនខ្លះលួចលាក់អង្ករទុកក្នុងបង្ហេចខោអាវលើដំបូលផ្ទះក្នុងគុម្ពឫស្សី ជីកកប់ក្នុងដី និងខ្លះទៀតយកទៅទុកក្នុងគុម្ពព្រៃគ្រែងតាមទន្លេ ។ ដោយសារតែខ្លាចប្រជាជនមិនធ្វើតាម អង្គការបានបញ្ជូនឲ្យកងចម្រុះប្រមាណ២០នាក់ដើរឆែកឆេរដើម្បីរឹបអូសយករបស់របរប្រើប្រាស់តាមផ្ទះប្រជាជនគ្មានសេសសល់ ។ ប៉ុន្តែសំណាងល្អ ពួកគេមិនបានរកឃើញសណ្តែកដែលជីតាខ្ញុំលាក់ទុកទេ ។

នៅរដូវវស្សាឆ្នាំ១៩៧៧ រោងបាយរួមក៏អស់អង្ករសម្រាប់ដាំហូប ។ ដូច្នេះចុងភៅបានយកពោតដាំជំនួសវិញជាមួយទឹកនិងជ្រក់ប្រហុកពាកន្លុយសម្រាប់មនុស្ស៦នាក់ ។ ការខ្វះខាតអាហារនេះបានធ្វើឲ្យប្រជាជននៅក្នុងសហករណ៍ចាប់ផ្តើមបាក់កម្លាំង ចំណែកចាស់ៗមួយចំនួនក៏ធ្លាក់ខ្លួនឈឺ និងស្លាប់ជាបន្តបន្ទាប់ដោយពុំមានធ្វើពិធីបុណ្យទានទៅតាមប្រពៃណីឡើយ ។ នៅពេលនោះ ជីតាខ្ញុំក៏យកសណ្តែកខៀវដែលគាត់ខំលួចលាក់ទុកមកស្ងោរក្នុងកំសៀវទឹកឲ្យខ្ញុំបានបរិភោគរាល់ថ្ងៃ ។

## បុណ្យខួបកំណើតបក្ស

នៅដើមខែកញ្ញា ឆ្នាំ១៩៧៧ ខ្ញុំសង្កេតឃើញមានយុវជនកងចល័តត្រូវបានអង្គការអនុញ្ញាតឲ្យវិលត្រឡប់មកធ្វើការនៅសហករណ៍ភូមិវិញ ដើម្បីត្រៀមខ្លួនរៀបការ ដែលអាពាហ៍ពិពាហ៍នេះមិនអនុញ្ញាតឲ្យស្គាល់មុខគ្នាមុនឡើយ ហើយថែមទាំងមិនអាចប្រកែកតវ៉ាបានទៀតផង ។ ដោយសារថ្ងៃកំណត់ជិតមកដល់ធ្វើឲ្យយុវជនទាំងនេះមានអារម្មណ៍អន្ទះសាក្នុងចិត្តជាខ្លាំងព្រោះ

ចង់ឃើញមុខគូអនាគតរបស់ខ្លួនមានរូបរាងយ៉ាងដូចម្តេច ។

នៅថ្ងៃ៣០ ខែកញ្ញា ឆ្នាំ១៩៧៧ ក្រោយពីអង្គការបានប្រកាសតាមវិទ្យុថា ជាថ្ងៃបុណ្យខួបកំណើតបក្សកុម្មុយនីស្តកម្ពុជា ដែលជាថ្ងៃប្រវត្តិសាស្ត្រ ប្រជាជនគ្រប់រូបមានការសប្បាយចិត្តយ៉ាងខ្លាំង ព្រោះបានឈប់សម្រាកពីការងារ ថែមទាំងមានបាយនិងម្ហូបឆ្ងាញ់ៗសម្រាប់បរិភោគទៀតផង ទោះបីកំពុងធ្វើការនៅតាមការដ្ឋានក៏ដោយ ។ នៅម៉ោង៦ព្រឹក ប្រជាជនគ្រប់គ្នាបានស្លៀកសម្លៀកបំពាក់ស្អាតបាត រួចចេញដំណើរទៅប្រជុំនៅវត្តមួយដែលស្ថិតនៅខាងចុងភូមិដើម្បីធ្វើមីទ្ទីង ។ នៅថ្ងៃនោះ វេលាម៉ោង៩ព្រឹក គណៈអធិបតីនិងអង្គប្រជុំទាំងអស់បានអង្គុយស្តាប់សុន្ទរកថារបស់លេខាបក្ស ប៉ុល ពត ដែលផ្សាយតាមវិទ្យុរហូតដល់ម៉ោង១២ ។

នៅថ្ងៃបន្ទាប់ ពិធីរៀបការបានចាប់ផ្តើមធ្វើឡើង ដោយយុវជននិងយុវនារីដែលមានឈ្មោះនៅក្នុងបញ្ជីរបស់អង្គការត្រូវស្លៀកសម្លៀកបំពាក់អាវខ្មៅ ព្រមទាំងបង់កក្រមាទៅកន្លែងប្រារព្ធពិធីនៅក្នុងវត្តដែលស្ថិតនៅខាងចុងភូមិ ដោយមិនអនុញ្ញាតឲ្យបងប្អូនញាតិសន្តានឬឪពុកម្តាយចូលរួមឡើយ ។ នៅកន្លែងរៀបចំពិធីមានចងទង់បក្សពណ៌ក្រហមដែលមានសញ្ញាញញួរនិងកណ្តៀវពណ៌លឿងខ្វែងគ្នា មានសរសេរអក្សរពីក្រោមថា ពិធីរៀបអាពាហ៍ពិពាហ៍យុវជន-យុវនារីបដិវត្តន៍ និងមានតុបំពីមុខសម្រាប់គណៈឃុំនិងគណៈកងអង្គុយ ចំណែកកៅអីវែងអមសងខាងសម្រាប់ដាក់ឲ្យបុរសនិងនារីចំនួនប្រមាណ៣០គូអង្គុយទល់មុខគ្នា ។ នៅពេលកម្មវិធីចាប់ផ្តើម អង្គប្រជុំទាំងអស់ក្រោកឈរឡើងគោរពទង់ជាតិនិងទង់បក្ស បន្ទាប់មក ប្រធានភូមិ គណៈឃុំឡើងថ្លែងការចាប់អារម្មណ៍ពីមាគ៌ានយោបាយដឹកនាំប្រទេសរបស់បក្ស និងលើកសរសើរគុណសម្បត្តិយុវជននិងយុវនារីទាំងអស់គ្នាដែលខិតខំធ្វើការងារគួរឲ្យមានមោទនភាពរហូតដល់អង្គការផ្សំផ្គុំឲ្យមានគ្រួសារ ។ បន្ទាប់មក គណៈឃុំ បានហៅឈ្មោះខាងយុវជនយុវនារីមួយគូម្តងៗ មកឈរនៅមុខខាងគណៈអធិបតីដើម្បីប្តេជ្ញាថាគោរពដឹងគុណអង្គការ ព្រមទាំងត្រូវរស់នៅស្មោះត្រង់នឹងគ្នាជារៀងរហូត ។ កម្មវិធីចប់រួចរាល់នៅពេលថ្ងៃត្រង់ គូស្វាមីភរិយាថ្មីក៏បែកគ្នាត្រឡប់ទៅផ្ទះរៀងៗ រហូតដល់ពេលល្ងាចទើបមកប្រជុំគ្នានៅរោងបាយ ជ្រើសរើសថាត្រូវទៅរស់នៅខាងប្តីឬខាងប្រពន្ធដើម្បីងាយស្រួលចុះឈ្មោះក្នុងបញ្ជីជាសមាជិកថ្មី ។

## បាត់ខ្លួនសមាជិកគណៈឃុំ

នៅខែតុលា ឆ្នាំ១៩៧៧ ពេលទឹកទន្លេស្រកបន្តិច អង្គការដាក់ផែនការថ្មីឲ្យកម្លាំងកងចល័តនិងប្រជាជនក្នុងសហករណ៍វាយសម្រុកលើកទំនប់ដើម្បីរក្សាទឹកទុកធ្វើស្រែប្រាំង ។ ដើម្បីឲ្យការលើកទំនប់ធ្វើបានល្អ អង្គការបានផ្តល់រទេះសេះ គោ ក្របី ដឹកជញ្ជូនកម្ទេចឥដ្ឋនិងព្រះពុទ្ធរូបដែលគេវាយកម្ទេចនៅតាមវត្តនានាយកទៅចាក់ធ្វើគ្រឹះ និងយកដីប្រកបាវយកទៅទប់បន្ថែមទៀត ។ រយៈពេលប្រមាណ១០ថ្ងៃ ទំនប់ធំមួយបានលេចជារូបរាង ទើបអង្គការបានចាត់តាំងឲ្យប្រជាជនតាមភូមិនានាដាំដើមចេកនិងដាំបន្លែបន្ថែមទៀត ។

នៅក្នុងរបបនេះ ទោះបីជាកម្មាភិបាលខ្មែរក្រហមឬប្រជាជនស្លាប់ ក៏អង្គការពុំអនុញ្ញាតឲ្យធ្វើពិធីបុណ្យសពដែរ ។ លើសពីនេះទៅទៀត អង្គការហាមឃាត់មិនឲ្យសមាជិកគ្រួសារយំឡើយ ។ រយៈពេល១០ថ្ងៃក្រោយមក ខ្ញុំក៏ឮដំណឹងថា ស្រុកបានកោះហៅមេភូមិនិងសមាជិកឃុំទាំងអស់ទៅចូលរួមមហាសន្និបាត៣ថ្ងៃ ។ ពេលនោះ ខ្ញុំសង្កេតឃើញមានតែសមាជិកភូមិមួយចំនួនប៉ុណ្ណោះដែលបានវិលត្រឡប់មកវិញ ចំណែកមួយចំនួនទៀតបាត់ដំណឹងរហូត ។

## រឿងនាយហឿន

នៅយប់មួយ បន្ទាប់ពីលើកទំនប់រួច អង្គការបានប្រមូលក្មេងៗនិងកងចលត័ទាំងអស់ឲ្យទៅមើលខ្សែភាពយន្តឯកសារអំពីកម្មករផលិតម៉ាស៊ីនបូមទឹក ម៉ាស៊ីនបោកស្រូវ ម៉ាស៊ីនផលិតក្រណាត់នៅភ្នំពេញ ។ ក្រៅពីនោះបានបង្ហាញពីសកម្មភាពរោងចក្រចម្រាញ់ជ័រកៅស៊ូ ការងារលើកទំនប់ ជីកប្រឡាយភ្ជួររាស់ ដកស្ទូង ដាំដំណាំបន្លែបង្ការគ្រប់មុខនៅតាមការដ្ឋាននីមួយៗផង ជាពិសេស កាប្រមូលផលស្រូវ ពោត ដំឡូងមីយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ក្រៅពីសមិទ្ធផលដែលសម្រេចបានទាំងនេះ អង្គការក៏បានទទួលរថក្រោះជាច្រើនគ្រឿងដែលជាជំនួយរបស់ចិនផងដែរ ។

ទោះបីប្រជាជនអត់ងងុយដោយសារមើលកុនក៏ដោយ ក៏

អង្គការឲ្យកងចល័តទាំងអស់ភ្ជាក់ពីព្រលឹមចេញទៅដកស្ទូងឲ្យបានតាមផែនការនៅតាមការដ្ឋាន ។ នៅពេលនោះ អង្គការបានបន្ថែមការងារខ្ញុំនៅពេលយប់ទៀត ដោយឲ្យរវៃទឹកពីអណ្ដូងដាក់ពាងក្នុងរោងបាយ ។ នៅយប់មួយពេលកំពុងចាក់ទឹក ខ្ញុំបានឮប្រធាន «គ» ជជែកគ្នាជាមួយចុងភៅថានឹងបញ្ជូនខ្ញុំទៅការដ្ឋាននៅឆ្នាំក្រោយ ។ ប៉ុន្មានថ្ងៃបន្ទាប់ពីឮដំណឹងនេះ អង្គការក៏បានហៅឪពុកខ្ញុំទៅមន្ទីរឃុំ ដើម្បីប្រាប់ថា ខ្ញុំតែងយកគោទៅឃ្វាលមិនទាន់ពេលវេលា ធ្វើពុតជាឈឺ ។

នៅក្នុងភូមិអង្គការបានបង្ខំប្រជាជនឲ្យធ្វើការជាទម្ងន់ បំបិទសិទ្ធិសេរីភាពនិងផ្ដល់ចំណីអាហារឲ្យហូបមិនគ្រប់គ្រាន់ទេ ដែលធ្វើឲ្យមិត្ត ហឿន ជាកងទ័ពពិសេសរបស់ភូមិភាគបូព៌ារត់គេចខ្លួនពីកងពល ។ ក្រោយពីឮដំណឹងនេះ អង្គការបានចោទប្រកាន់គាត់ថាក្បត់បដិវត្តន៍និងចេញបញ្ជាឲ្យតាមរកចាប់ខ្លួនដើម្បីកម្ទេចចោល ។ ក្រោយមកទៀត ពេលឮដំណឹងថា ហឿន ទៅលេងផ្ទះ កងឈ្លបក៏បានទៅពទ្ធ័ផ្ទះគាត់ទៀត ។ រំលងបានមួយរយៈ ខ្ញុំក៏បានឮថា ហឿន បានទៅសម្ងំលាក់ខ្លួននៅក្នុងព្រៃមាត់បឹង ។

## បង្ករឿងជាមួយវៀតណាម

បន្ទាប់ពីរឿងរបស់នាយ ហឿន បានស្ងប់ស្ងាត់ទៅ ស្រាប់តែឮពាក្យចចាមអារ៉ាមថា នាយ ហឿន បានគេចខ្លួនចូលទៅភូមិភាគឧត្ដរបាត់ហើយ ។ ចំណែកនៅក្នុងសហករណ៍វិញ ប្រជាជនគ្រប់រូបមានជំងឺហើមស្ពឹកនៅលើមុខនិងដៃជើង ព្រមទាំងឆាប់អស់កម្លាំង ។ ចំពោះក្មេងៗវិញ ដោយសារតែហូបបបររាល់ថ្ងៃ ពោះរបស់ក្មេងៗទាំងនោះឡើងប៉ោងស្ដើងដែលយើងមើលទៅធំតែក្បាលពោះ ចំណែកដៃជើងស្គមនិងដើមទ្រូងចេញឆ្អឹងជំនីឡើងរវាម ។

នៅក្នុងរដូវប្រមូលផលកាត់នេះ អង្គការបានឲ្យកសិករធ្វើការបន្ថែមនៅពេលយប់ទៀត គឺពីម៉ោង៧យប់ទៅដល់ម៉ោង៩យប់ ។ បន្ទាប់មក ពេលចូលដល់ខែធ្នូ ឆ្នាំ១៩៧៧ ស្រាប់តែឮពាក្យចចាមអារ៉ាមថា កងទ័ពរបស់ខ្មែរក្រហមបានឈ្លានពានចូលយ៉ាងជ្រៅទៅក្នុងទឹកដីវៀតណាមចម្ងាយ១០ទៅ១៥គីឡូម៉ែត្រពីព្រំដែន ហើយបានបាញ់រះនិងសម្លាប់មនុស្សយ៉ាងសាហាវឃោរឃៅ ព្រមទាំងដុតផ្ទះសម្បែងអ្នកភូមិអស់គ្មានសល់ គឺចូលដល់ត្រឹមណាកម្ទេចឲ្យអស់ត្រឹមនោះ ។ ប្រហែលជា១០ថ្ងៃក្រោយមក នៅភាគខាងកើតប្រទេសកម្ពុជាក៏ចាប់ផ្ដើមឮសំឡេងផ្ទុះអាវុធ ដែលបញ្ជាក់ថាប្រទេសវៀតណាមបានវាយលុកចូលយ៉ាងជ្រៅមកក្នុងទឹកដីកម្ពុជាវិញហើយ ។ ដោយសារតែរឿងនេះទើបធ្វើឲ្យប្រជាជនទាំងអស់មានការព្រួយបារម្ភពីសុវត្ថិភាពរបស់ខ្លួនយ៉ាងខ្លាំង ។ ក្រោយពីហូបបាយថ្ងៃត្រង់រួច ខ្ញុំក៏បានស្ដាប់វិទ្យុឮការថ្លែងសុន្ទរកថារបស់សមមិត្ត ខៀវ សំផន ដែលជាគណៈប្រធានរដ្ឋប្រកាសថា វៀតណាមថាបានចូលឈ្លានពានប្រទេសកម្ពុជា ដូច្នេះសូមឲ្យប្រជាជនទាំងអស់រួបរួមគ្នាក្រោមការដឹកនាំរបស់អង្គការ ធ្វើការប្រយុទ្ធតទល់ជាមួយខ្មាំងយ៉ាងដាច់ខាត ។ សមមិត្ត ខៀវ សំផន ក៏បាននិយាយបន្តទៀតថា កងទ័ពបដិវត្តន៍កម្ពុជាយើងសុទ្ធតែមានវីរភាពអង់អាចក្លាហាន និងហ៊ានពលីជីវិតដើម្បីជាតិមាតុភូមិដោយគ្មានរាថយ ហើយគាត់នឹងអនុវត្តសង្គ្រាមឈ្លបវាយពីមុខ វាយពីក្រោយ និងវាយ ពីចំហៀង រួចកាត់ផ្ដាច់កម្លាំងខ្មាំងជាកង់ៗ ដោយវាយទាំងយប់វាយទាំងថ្ងៃលុះត្រាតែខ្មាំងវង្វេងស្មារតី ។ បើទាហានយើងពលីជីវិតម្នាក់ នោះទាហានវៀតណាមនឹងត្រូវស្លាប់១០នាក់ បើទាហានយើងពលីជីវិតកាន់តែច្រើន នោះទាហានវៀតណាមនឹងត្រូវស្លាប់កាន់តែច្រើន គឺទាំងកងពលតែម្ដង ហើយនៅទីបំផុតយើងនឹងទទួលបានជោគជ័យ ។ មិនបានប៉ុន្មានថ្ងៃផង នៅតាមសហករណ៍នីមួយៗ អង្គការបានកោះហៅប្រជាជនវៀតណាមដែលនៅសេសសល់តាំងពីសង្គមចាស់ឲ្យរៀបចំខោអាវបញ្ជូនទៅអង្គការលើ ដើម្បីធ្វើការដោះដូរចំណាប់ខ្មាំងក្នុងសង្គ្រាម ។ ពេលនោះ ស្រាប់តែអង្គការបានចាប់នារីម្នាក់ជាជនជាតិវៀតណាមមានកូនពីរនាក់ ដែលពីមុនរកស៊ីលក់ត្រីយកទៅបាត់ ។ ក្រោយមក មិត្តរួមថ្នាក់ខ្ញុំដែលគ្រួសាររបស់គាត់ជាជនជាតិវៀតណាមមានសមាជិក១០នាក់ក៏ត្រូវអង្គការចាប់យកទៅទាំងអស់ដែរ ។ ជនជាតិវៀតណាមទាំងនេះត្រូវអង្គការយកទៅសម្លាប់ចោលទាំងអស់ ដែលនេះជាការបោសសម្អាតជនវៀតណាមឲ្យអស់ពីរោងបាយសហករណ៍ ។ ក្រោយមកទៀត នៅតាមវិទ្យុតែងតែឮអង្គការចាក់ផ្សាយពីការចាប់ខ្លួនកងទ័ពវៀតណាមដែលខ្លះជាមេបញ្ជាការផ្កាយ១ ផ្កាយ២ ឬស័ក្តិធំៗ ។ ក្រោយហេតុការណ៍នេះ នៅតាមសហករណ៍នីមួយៗក៏

ចាប់ផ្តើមជ្រើសរើសកសិករឲ្យចូលបម្រើកងទ័ពដែរ ។ ពេលនោះឪពុករបស់ខ្ញុំត្រូវបានសមមិត្តប្រធាន «ឃ» និយាយបញ្ចុះបញ្ចូលរយៈពេល២ម៉ោង ឲ្យស្ម័គ្រចិត្តចូលបម្រើទ័ព លុះក្រោយមកទៀតគាត់ក៏បានឲ្យប្រជាជនគ្រប់រូបបញ្ចេញមតិយោបល់រៀងៗខ្លួន ។ ប៉ុន្តែគ្មាននរណាម្នាក់ហ៊ាននិយាយទេ រហូតទាល់តែសមមិត្តប្រធាន «ឃ» ចង្អុលទៅកាន់កសិករម្នាក់នៅកៀនជញ្ជាំងឲ្យឡើងបញ្ចេញមតិអំពីការចូលបដិវត្តន៍ ។ ដោយយល់ឃើញថា នៅតែមិនបានលទ្ធផល សមមិត្តប្រធាន«ឃ» ក៏ចាប់ផ្តើមខឹង រួចចង្អុលទៅកសិករនៅកៀនជញ្ជាំងដំបូងគេថា ជាអ្នកនាំអាទិ៍មិនឲ្យប្រជាជននិយាយនិងជាអ្នកបំបះបំបោរប្រឆាំងនឹងផែនការរបស់អង្គការ ។ មួយសន្ទុះក្រោយមក ក៏មានកសិករវ័យក្មេងម្នាក់ដែលទើបតែមានកូនមួយបានក្រោកឡើង រួចនិយាយថា គាត់ស្ម័គ្រចិត្តចូលបម្រើកងទ័ពតាមផែនការរបស់អង្គការ ។ ក្រោយពីឮអំពីការតាំងចិត្តរបស់ប្រជាជនហើយ សមមិត្តប្រធាន «ឃ» ក៏បិទអង្គប្រជុំឲ្យកសិករយើងទាំងអស់គ្នាត្រឡប់ទៅផ្ទះរៀងៗខ្លួន ដើម្បីពិចារណាសាជាថ្មីម្តងទៀត ។

**ចរិតកម្មាភិបាលស្រុកម្នាក់**

នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ មានពាក្យចចាមអារ៉ាមថាកងទ័ពវៀតណាម បានដកទ័ពចេញពីប្រទេសកម្ពុជាអស់ ។ ចំណែកវិទ្យុនៅតាមរោងបាយ បានចាក់ផ្សាយថាបានទទួលជោគជ័យលើប្រទេសវៀតណាម រួចក៏បានបញ្ជាឲ្យរោងបាយទាំងអស់ធ្វើពិធីអបអរសាទរ ដោយដាំបាយហូបនិងធ្វើម្ហូបឆ្ងាញ់ៗទៀតផង ។

ប៉ុន្មានថ្ងៃក្រោយមកទៀត ខ្ញុំចាប់អារម្មណ៍ថា នៅក្នុងក្រុមរោងបាយរបស់ខ្ញុំមានសមាជិកថ្មីពីរនាក់ប្តីប្រពន្ធមករស់នៅដោយមានការយកចិត្តទុកដាក់យ៉ាងកក់ក្តៅពីថ្នាក់ដឹកនាំ ។ ពេលនោះអ្នកអារខសជាមួយខ្ញុំបានប្រាប់ខ្ញុំថា អ្នកមកថ្មីនេះជាកម្មាភិបាលថ្នាក់ស្រុកទាំងប្តីទាំងប្រពន្ធធ្វើបដិវត្តន៍តាំងពីសម័យសង្គ្រាមម៉េ្ង៉ះ គាត់ជាបងប្អូនសាច់ញាតិសមមិត្តប្រធាន«ឃ» ហើយជួរថ្នាក់ដឹកនាំធំៗនៅក្នុងមូលដ្ឋានយើង គឺជាខ្សែស្រឡាយជិតស្និទ្ធរបស់គាត់ដែលគាត់បានឃិតយោងឲ្យឡើងធ្វើធំ អីចឹងហើយបានជាគេគោរពនិងកោតខ្លាចគាត់ ។ ពាក្យចចាមអារ៉ាមចេញពីថ្នាក់ដឹកនាំថាកម្មាភិបាលរូបនេះបានខ្វែងគំនិតគ្នាជាមួយគណៈស្រុក ហើយគេក៏រំសាយគាត់ឲ្យមកលត់ដំខ្លួនធ្វើជាប្រជាជនធម្មតានៅឯមូលដ្ឋានវិញ ។ នេះជារឿងមួយដែលគួរឲ្យចាប់អារម្មណ៍ ព្រោះថាតាំងពីមុនៗមកកម្រមានអង្គការរំសាយអ្នកមានកំហុសឲ្យមកធ្វើជាប្រជាជនណាស់ ភាគច្រើនគឺបាត់ខ្លួនតែម្តង ឬមួយក៏សភាពការណ៍នៅខាងលើៗមិនសូវល្អ ហើយគាត់សុំឲ្យគេដោះលែង រួចមកសម្ងំលាក់ខ្លួននៅតាមមូលដ្ឋានសិនរង់ចាំឱកាសល្អទើបគាត់វិលត្រឡប់ទៅវិញក៏អាចថាបាន ។ មើលទៅអាកប្បកិរិយារបស់គាត់ គឺជាការលត់ដំបែបប្រជាភិថុតិ ព្រោះគាត់មានចរិតក្អេងក្អាង គ្មានខ្លាចក្រែងនរណាម្នាក់ឡើយ គាត់ទាមទារកាន់គោណាដែលខ្លាំងហើយលឿនជាងគេ ។ ជាងនេះទៅទៀត គាត់យកកន្ទុកនៅក្នុងមន្ទីរស្រេចតែចិត្តដើម្បីយកមកលាយនឹងដើមចេកល្អៗដែលគាត់កាប់ស្រេចនឹងចិត្តយកមកបំប៉នគោគាត់ឲ្យធាត់មូលរលោងខុសគេតែឯង ។ ចំណែកចុងសំណាបខ្ចីៗទាំងអស់ត្រូវបានថ្នាក់ដឹកនាំប្រមូលយកមកឲ្យគោរបស់គាត់ទាំងអស់ ជាហេតុធ្វើឲ្យគាត់តាំងខ្លួនជាមនុស្សសកម្មក្នុងការងារជាងគេ ព្រោះកសិករទូទៅដឹកកណ្តាប់ដឹកស្រូវបានតែមួយជើងទេ រីឯគាត់វិញខំបំបោលគោដ៏ធាត់មានកម្លាំងខ្លាំងរបស់គាត់ឲ្យបានពីរជើង ប៉ុន្តែរឿងភ្ជួររាស់វិញគាត់មិនសូវធ្វើទេ គឺគាត់ទុកឲ្យគោរបស់គាត់សម្រាប់តែបររទេះប៉ុណ្ណោះ ។ គាត់មិនដែលហូបបបរជាមួយប្រជាជនធម្មតាទេ គឺគាត់ចាំហូបក្រោយគេជាមួយថ្នាក់ដឹកនាំ ចំណែកប្រពន្ធគាត់វិញឲ្យធ្វើការតែនៅកន្លែងរោងបាយប៉ុណ្ណោះ ។ ប្រជាជនគ្រប់គ្នាមិនហ៊ាននិយាយអ្វីទាំងអស់ ប៉ុន្តែចាត់ទុកថានេះជាខ្សែថ្នាក់ដឹកនាំ គេធ្វើអ្វីក៏មិនខុសដែរ គ្រាន់តែនាំគ្នាគិតក្នុងចិត្តថា គាត់ប្រើក្បួនខ្ចបដើរខ្សែលើគេ មិនយុត្តិធម៌និងមិនស្មើភាពសម្រាប់កសិករទូទាំងសហករណ៍ ។ មានព្រឹកមួយពេលជិតដល់ម៉ោងបាយថ្ងៃត្រង់ ខ្ញុំបានដើរទៅមើលដើមស្វាយមួយដើមដ៏ធំដែលគេមានគម្រោងកាប់វានៅថ្ងៃស្អែក នៅពេលខ្ញុំដើរកាត់វាលស្រែខាងក្រោយភូមិ កម្មាភិបាលស្រុកម្នាក់បានបក់ដៃហៅខ្ញុំឲ្យដើរទៅជិតគាត់ រួចគាត់បានសម្លុត ព្រមទាំងគំហកដោយប្រើពាក្យអសុរសនិងទ្រគោះបោះបោកថា «ជញ្ជូនកណ្តាប់ស្រូវដាក់រទេះស្រូវឲ្យអញ ព្រោះអ្អែងជាពួកវណ្ណៈជិះជាន់» ។

**(នៅមានត)**

**ហេង ខុន**






ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 115, July 2009 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.